# សៀមរាបឆ្លាតវៃ
# ផែនទីបង្ហាញផ្លូវទីក្រុងឆ្លាតវៃ
# នៃខេត្តសៀមរាប

## SIEM REAP SMART

Siem Reap Smart City Roadmap







"សៀមរាបស្អាតវៃ"

# ផែនទីបង្ហាញផ្លូវទីក្រុងស្អាតវៃ នៃខេត្តសៀមរាប

រដ្ឋបាលខេត្តសៀមរាប

# មាតិកា


**មាតិកា** ........ i

**អក្សរកាត់** ........ iii

**បុព្វកថា** ........ vi

**សេចក្តីផ្តើម** ........ viii

**ជំពូកទី ១: គោលបំណង និងចក្ខុវិស័យ** ........ **១**

១.១ គោលបំណងនៃផែនទីបង្ហាញផ្លូវទីក្រុងឆ្លាតវៃ ........ ១

១.២ ចក្ខុវិស័យទីក្រុងឆ្លាតវៃ ........ ១

១.៣ វិធីសាស្រ្តទីក្រុងឆ្លាតវៃ ........ ៣

**ជំពូកទី ២: ផែនការពាក់ព័ន្ធ និងគម្រោងសាកល្បង** ........ **៥**

២.១ ផែនការមេអភិវឌ្ឍន៍ទេសចរណ៍ខេត្តសៀមរាប ឆ្នាំ ២០២១-២០៣៥ ........ ៥

២.២ គម្រោងស្ថាបនាហេដ្ឋារចនាសម្ព័ន្ធផ្លូវចំនួន ៣៨ខ្សែ នៅក្រុងសៀមរាប ខេត្តសៀមរាប ........ ៦

២.៣ ប្លង់គោលប្រើប្រាស់ដីក្រុងសៀមរាប ចក្ខុវិស័យឆ្នាំ ២០៣៥ ........ ៦

២.៤ ផែនទីបង្ហាញផ្លូវទីក្រុងឆ្លាតវៃថ្នាក់ជាតិ ........ ៧

២.៥ ផែនការពាក់ព័ន្ធសំខាន់ៗផ្សេងទៀត ........ ៧

**ជំពូកទី ៣: បញ្ហាប្រឈម** ........ **៩**

៣.១ បញ្ហាទាក់ទងនឹងប្រតិបត្តិការរដ្ឋបាលទូទៅ ........ ៩

៣.២ បញ្ហាពាក់ព័ន្ធនឹងវិស័យគោលដៅ ........ ១០

៣.៣ សេចក្តីសង្ខេបនៃបញ្ហាប្រឈមនៅខេត្តសៀមរាប ........ ១៣

**ជំពូកទី ៤: យុទ្ធសាស្រ្ត** ........ **១៤**

៤.១ វិធីសាស្រ្តរដ្ឋបាល ........ ១៤

៤.២ វិធីសាស្រ្តតាមវិស័យ ........ ១៤

៤.៣ រចនាសម្ព័ន្ធនៃការអនុវត្ត ........ ១៤

៤.៤ វិធីសាស្រ្ត ........ ១៦

៤.៥ ទិដ្ឋភាពរួមនៃផែនទីបង្ហាញផ្លូវទីក្រុងឆ្លាតវៃ នៃខេត្តសៀមរាប ........ ១៧

**ជំពូកទី ៥: គោលនយោបាយមូលដ្ឋាន និងទិសដៅនៃវិធានការ នៃវិធីសាស្រ្តរដ្ឋបាល** ........ **១៨**

៥.១ គោលនយោបាយមូលដ្ឋាន និងទិសដៅនៃវិធានការ ..... ១៨
៥.២ ស្ថាប័នរដ្ឋបាល ..... ១៨
៥.៣ ប្រព័ន្ធច្បាប់ និងការគាំទ្រអាជីវកម្ម ..... ១៩
៥.៤ ការគ្រប់គ្រងទិន្នន័យ ..... ២១
**ជំពូកទី ៦: គោលនយោបាយមូលដ្ឋាន និងទិសដៅនៃវិធានការនៃវិធីសាស្ត្រតាមវិស័យ ..... ២៣**
៦.១ ទេសចរណ៍ឆ្លាតវៃ ..... ២៣
៦.២ ការចល័តឆ្លាតវៃ ..... ២៤
៦.៣ សន្តិសុខ និងសុវត្ថិភាពឆ្លាតវៃ ..... ២៥
៦.៤ ការគ្រប់គ្រងកាកសំណល់ឆ្លាតវៃ ..... ២៦
**ជំពូកទី ៧: វិធានការអនុវត្ត ..... ៣០**
៧.១ ពង្រឹងការអនុវត្តមុខងាររបស់គណៈកម្មាធិការទីក្រុងឆ្លាតវៃ (SCC) ..... ៣០
៧.២ ការរៀបចំ និងដំណើរការទីចាត់ការសម្រាប់អនុវត្តគម្រោងទីក្រុងឆ្លាតវៃ ..... ៣១
៧.៣ ការបង្កើត និងប្រតិបត្តិការនៃវេទិកាសហប្រតិបត្តិការរវាងវិស័យឯកជន-វិស័យសាធារណៈ-ស្ថាប័នសិក្សាធិការ-សហគមន៍ (Smart City Consortium) ..... ៣២
៧.៤ ប្រព័ន្ធត្រួតពិនិត្យ និងវាយតម្លៃ ..... ៣៤
៧.៥ ទំនាក់ទំនងសាធារណៈ និងវិធានការផ្សព្វផ្សាយកិត្តិនាម "សៀមរាបឆ្លាតវៃ" ..... ៣៥
៧.៦ ការអភិវឌ្ឍប្រព័ន្ធប្រតិបត្តិការ លក្ខណៈឌីជីថល និងការលើកម្ពស់ទិន្នន័យចំហ (Open Data) ..... ៣៧
៧.៧ ការកែលម្អបរិយាកាសវិនិយោគ ..... ៤២
៧.៨ ការកែលម្អមុខងារគាំទ្រ (Incubation Functions) ..... ៤២
៧.៩ ការកំណត់តំបន់អាទិភាព ..... ៤៣
**ជំពូកទី ៨: ទម្រង់នៃគម្រោងអាទិភាព (បង្កើតឡើងនៅក្នុងឆ្នាំ២០២១) ..... ៤៥**
៨.១ ការគ្រប់គ្រងទិន្នន័យ -DATA MANAGEMENT ..... ៤៥
៨.២ ទេសចរណ៍ឆ្លាតវៃ ..... ៤៨
៨.៣. ការចល័តឆ្លាតវៃ ..... ៥៥
៨.៤ សន្តិសុខ និងសុវត្ថិភាពឆ្លាតវៃ ..... ៦៦
៨.៥ ការគ្រប់គ្រងកាកសំណល់ឆ្លាតវៃ ..... ៧១
**ឧបសម្ព័ន្ធ ១៖ វិធីសាស្ត្រក្នុងការធ្វើបច្ចុប្បន្នភាពផែនទីបង្ហាញផ្លូវ ..... ៨២**
**ឧបសម្ព័ន្ធ ២៖ ផែនការថវិកា ..... ៨៦**
**ឧបសម្ព័ន្ធ ៣៖ វឌ្ឍនភាពនៃ ផែនការសកម្មភាព ..... ៨៨**

# អក្សរកាត់

| អក្សរកាត់ | ឈ្មោះជាភាសាអង់គ្លេស | ឈ្មោះជាភាសាខ្មែរ |
|---|---|---|
| ADB | Asian Development Bank | ធនាគារអភិវឌ្ឍន៍អាស៊ី |
| AI | Artificial Intelligence | បញ្ញាសិប្បនិម្មិត |
| APSARA National Authority | The Authority for the Protection of the Site and the Management of the Region of Angkor | អាជ្ញាធរជាតិអប្សរា |
| AR | Augmented Reality | បច្ចេកវិទ្យា AR |
| ASCN | ASEAN Smart Cities Network | បណ្តាញទីក្រុងឆ្លាតវៃអាស៊ាន |
| ASEAN | Association of Southeast Asian Nations | សមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ (អាស៊ាន) |
| BOD | Biochemical Oxygen Demand | តម្រូវការអុកស៊ីសែនជីវៈគីមី |
| CCTV | Closed-Circuit Television | កាមេរ៉ាសុវត្ថិភាព CCTV |
| CDC | The Council for the Development of Cambodia | ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា |
| CDIA | Cities Development Initiative for Asia | គំនិតផ្តួចផ្តើមអភិវឌ្ឍន៍ទីក្រុងសម្រាប់អាស៊ី |
| COD | Chemical Oxygen Demand | តម្រូវការអុកស៊ីសែនគីមី |
| COVID-19 | Coronavirus Disease 2019 | ជំងឺវីរុសកូរ៉ូណាឆ្នាំ ២០១៩ (កូវីដ-១៩) |
| DLMUPC | Siem Reap Provincial Department of Land Management, Urban Planning and Construction | មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី ខេត្តសៀមរាប |
| DoE | Siem Reap Provincial Department of Environment | មន្ទីរបរិស្ថាន ខេត្តសៀមរាប |
| DoT | Siem Reap Provincial Department of Tourism | មន្ទីរទេសចរណ៍ ខេត្តសៀមរាប |
| DoP | Siem Reap Provincial Department of Planning | មន្ទីរផែនការ ខេត្តសៀមរាប |
| DPT | Siem Reap Provincial Department of Post and Telecommunication | មន្ទីរប្រៃសណីយ៍ និងទូរគមនាគមន៍ ខេត្តសៀមរាប |
| DPWT | Siem Reap Provincial Department of Public Works and Transport | មន្ទីរសាធារណការ និងដឹកជញ្ជូន ខេត្តសៀមរាប |
| DRD | Siem Reap Provincial Department of Rural Development | មន្ទីរអភិវឌ្ឍន៍ជនបទ ខេត្តសៀមរាប |
| EDC | Electricite du Cambodge | អគ្គិសនីកម្ពុជា |
| EV | Electric Vehicle | យានយន្តអគ្គិសនី |

| អក្សរកាត់ | ឈ្មោះជាភាសាអង់គ្លេស | ឈ្មោះជាភាសាខ្មែរ |
|---|---|---|
| GAEA | Global Action for Environment Awareness Waste Management Company | ក្រុមហ៊ុន ហ្គាអ៊ីយ៉ា ភីអិលស៊ី |
| GPS | Global Positioning System | ប្រព័ន្ធកំណត់ទីតាំងជាសកល (ប្រព័ន្ធ GPS) |
| ICT | Information and Communications Technology | បច្ចេកវិទ្យាព័ត៌មាន និងទំនាក់ទំនង |
| IoT | Internet of Things | អ៊ីនធឺណិតនៃវត្ថុ |
| IT | Information Technology | បច្ចេកវិទ្យាព័ត៌មាន |
| JICA | Japan International Cooperation Agency | ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិនៃប្រទេសជប៉ុន |
| LED | Light Emitting Diode | អំពូល LED |
| MaaS | Mobility as a Service | ការចល័តជាសេវាកម្ម (សេវាកម្មធ្វើដំណើរទេសចរណ៍ជាកញ្ចប់) |
| MCFA | Ministry of Culture and Fine Arts | ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ នៃព្រះរាជាណាចក្រកម្ពុជា |
| MLMUPC | Ministry of Land Management, Urban Planning and Construction, the Kingdom of Cambodia | ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ នៃព្រះរាជាណាចក្រកម្ពុជា |
| MoE | Ministry of Environment, the Kingdom of Cambodia | ក្រសួងបរិស្ថាន នៃព្រះរាជាណាចក្រកម្ពុជា |
| MEF | Ministry of Economy and Finance, the Kingdom of Cambodia | ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នៃព្រះរាជាណាចក្រកម្ពុជា |
| MoH | Ministry of Health, the Kingdom of Cambodia | ក្រសួងសុខាភិបាល នៃព្រះរាជាណាចក្រកម្ពុជា |
| MoI | Ministry of Interior, the Kingdom of Cambodia | ក្រសួងមហាផ្ទៃ នៃព្រះរាជាណាចក្រកម្ពុជា |
| MoT | Ministry of Tourism, the Kingdom of Cambodia | ក្រសួងទេសចរណ៍ នៃព្រះរាជាណាចក្រកម្ពុជា |
| MPWT | Ministry of Public Works and Transport, the Kingdom of Cambodia | ក្រសួងសាធារណការ និងដឹកជញ្ជូន នៃព្រះរាជាណាចក្រកម្ពុជា |
| NGO | Non-Governmental Organization | អង្គការមិនមែនរដ្ឋាភិបាល |
| NR6 | National Road No. 6 | ផ្លូវជាតិលេខ ៦ |
| PIN | People in Need | ប្រជាពលរដ្ឋដែលកំពុងត្រូវការជំនួយ |
| PIP | Public Investment Program | កម្មវិធីវិនិយោគសាធារណៈ |
| PoC | Proof of Concept | ភស្តុតាងនៃគំនិត (គម្រោងសាកល្បង) |
| SCC | Smart City Committee | គណៈកម្មាធិការទីក្រុងឆ្លាតវៃ |
| SDGs | Sustainable Development Goals | គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព |

| អក្សរកាត់ | ឈ្មោះជាភាសាអង់គ្លេស | ឈ្មោះជាភាសាខ្មែរ |
|---|---|---|
| SPC | Special Purpose Company | ក្រុមហ៊ុនគោលបំណងពិសេស |
| SPV | Special Purpose Vehicle | យានយន្តគោលបំណងពិសេស |
| UNESCO | The United Nations Educational, Scientific and Cultural Organization | អង្គការអប់រំ វិទ្យាសាស្ត្រ និងវប្បធម៌របស់អង្គការសហប្រជាជាតិ |
| USD or US$ | United States Dollars | ដុល្លារសហរដ្ឋអាមេរិក |
| UNDP | United Nations Development Program | កម្មវិធីអភិវឌ្ឍន៍របស់អង្គការសហប្រជាជាតិ |
| VR | Virtual Reality | បច្ចេកវិទ្យា VR |



# បុព្វកថា

សូមគោរពសម្តេច ឯកឧត្តម លោកជំទាវ លោក លោកស្រី ជាទីគោរព និងជាទីរាប់អាន!

ជាបឋមក្នុងនាមក្រុមប្រឹក្សាខេត្ត គណៈអភិបាលខេត្ត និងក្នុងនាមរូបខ្ញុំផ្ទាល់ សូមមេត្តាអនុញ្ញាត និងអនុញ្ញាតឱ្យរូបខ្ញុំធ្វើការបង្ហាញអំពីការរៀបចំអភិវឌ្ឍក្រុងសៀមរាបនៃខេត្តសៀមរាបជាទីក្រុងឆ្លាតវៃ តាមរយៈ**ផែនទីបង្ហាញផ្លូវទីក្រុងឆ្លាតវៃនៃខេត្តសៀមរាប**។

ខេត្តសៀមរាប គឺជាខេត្តមួយនៅក្នុងចំណោមរាជធានី ខេត្ត ទាំង២៥ នៃព្រះរាជាណាចក្រកម្ពុជា ដែលស្ថិតនៅប៉ែកពាយ័ព្យនៃប្រទេស និងមានចម្ងាយ ៣១៤ គ.ម ពីរាជធានីភ្នំពេញ ហើយបច្ចុប្បន្ននេះ ខេត្តសៀមរាបមាន ០១ក្រុង ១១ស្រុក ១២សង្កាត់ ៨៨ឃុំ និង៩១០ភូមិ។ ក្រុងសៀមរាប នៃខេត្តសៀមរាប ត្រូវបានដាក់បញ្ចូលទៅជាសមាជិក នៃបណ្តាញទីក្រុងឆ្លាតវៃអាស៊ាន នៅក្នុងកិច្ចប្រជុំកំពូលអាស៊ានកាលពីឆ្នាំ ២០១៨ នៅក្នុងប្រទេសសឹង្ហបុរី។ នៅក្នុងការរៀបចំអភិវឌ្ឍក្រុងសៀមរាប នៃខេត្តសៀមរាបឱ្យក្លាយជាទីក្រុងឆ្លាតវៃអាស៊ាននេះ រាជរដ្ឋាភិបាលកម្ពុជា ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិត និងដ៏ឈ្លាសវៃបំផុតរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** បានដាក់ចេញនូវគោលនយោបាយអភិវឌ្ឍន៍ខេត្តសៀមរាបឱ្យក្លាយជាប៉ូលសេដ្ឋកិច្ចមួយរបស់ប្រទេសកម្ពុជា នៅក្នុងចំណោមប៉ូលសេដ្ឋកិច្ចផ្សេងៗទៀតរបស់ប្រទេស។ នៅក្នុងនោះ ការអភិវឌ្ឍ និងកែលម្អហេដ្ឋារចនាសម្ព័ន្ធផ្លូវ ៣៨ខ្សែក្នុងក្រុងសៀមរាប នៃខេត្តសៀមរាប គឺជាការអភិវឌ្ឍមួយដ៏ធំ ដែលបានប្រែក្លាយមុខមាត់ក្រុងសៀមរាបឱ្យក្លាយជាទីក្រុងទេសចរណ៍មួយដ៏គួរឱ្យទាក់ទាញ និងប្រកបដោយផាសុកភាព ហើយទន្ទឹមនេះ ការអភិវឌ្ឍ និងកែលម្អផ្លូវ ៣៨ខ្សែនេះ ក៏បានចូលរួមចំណែកយ៉ាងធំ ក្នុងការរៀបចំក្រុងសៀមរាប នៃខេត្តសៀមរាបឱ្យក្លាយជាទីក្រុងឆ្លាតវៃ។

ទន្ទឹមនឹងការរៀបចំអភិវឌ្ឍក្រុងសៀមរាប នៃខេត្តសៀមរាបជាទីក្រុងឆ្លាតវៃ ដោយកម្ពុជាខ្លួនឯងផ្ទាល់ ខេត្តសៀមរាប ក៏ទទួលបាននូវជំនួយ នៃកិច្ចសហប្រតិបត្តិការបច្ចេកទេសពី **ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិនៃប្រទេសជប៉ុន (JICA)** ដើម្បីជួយរៀបចំក្រុងសៀមរាប នៃខេត្តសៀមរាបឱ្យក្លាយជាទីក្រុងឆ្លាតវៃអាស៊ានផងដែរ។ ចាប់តាំងពីឆ្នាំ ២០២០ រហូតមកទល់ពេលនេះ ទោះបីជាស្ថិតនៅក្នុងដំណាក់កាលនៃការរីករាលដាលនៃជំងឺកូវីដ-១៩ យ៉ាងណាក៏ដោយ ក៏ក្រុមការងារនៃទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិនៃប្រទេសជប៉ុន (JICA) បានធ្វើការសហការយ៉ាងជិតស្និទ្ធជាមួយក្រុមការងាររបស់រដ្ឋបាលខេត្ត ក្នុងការរៀបចំក្រុងសៀមរាប នៃខេត្តសៀមរាប ឱ្យក្លាយជាទីក្រុងឆ្លាតវៃនាពេលខាងមុខ។ នៅក្នុងរយៈពេល ០៣ឆ្នាំ នៃកិច្ចសហប្រតិបត្តិការនេះ យើងសម្រេចបាននូវសមិទ្ធផលជាច្រើនគួរជាទីមោទក ហើយដែលក្នុងនោះ សមិទ្ធផលដែលធំជាងគេនោះ គឺការរៀបចំ**ផែនទីបង្ហាញ**

**ផ្លូវទីក្រុងឆ្លាតវៃ នៃខេត្តសៀមរាប**។ ផែនទីបង្ហាញផ្លូវទីក្រុងឆ្លាតវៃ នៃខេត្តសៀមរាបនេះ គឺជាឯកសារចង្អុលផ្លូវ សម្រាប់ការរៀបចំក្រុងសៀមរាប ឱ្យក្លាយជាទីក្រុងឆ្លាតវៃ ហើយដែលមានចក្ខុវិស័យត្រូវសម្រេចឱ្យបានរហូតដល់ឆ្នាំ២០៣៥។ ការរៀបចំផែនទីបង្ហាញផ្លូវទីក្រុងឆ្លាតវៃ នៃខេត្តសៀមរាបនេះ ក៏ត្រូវបានធ្វើឱ្យមានសង្គតិភាពផងដែរជាមួយឯកសារគោលនយោបាយពាក់ព័ន្ធនានារបស់រាជរដ្ឋាភិបាលកម្ពុជា ដែលក្នុងនោះមានដូចជាផែនការមេអភិវឌ្ឍន៍ទេសចរណ៍ខេត្តសៀមរាបឆ្នាំ ២០២១-២០៣៥ គម្រោងស្ថាបនាហេដ្ឋារចនាសម្ព័ន្ធផ្លូវ៣៨ខ្សែនៅក្រុងសៀមរាប ខេត្តសៀមរាប ប្លង់គោលប្រើប្រាស់ដីក្រុងសៀមរាប ចក្ខុវិស័យឆ្នាំ ២០៣៥ ផែនទីបង្ហាញផ្លូវទីក្រុងឆ្លាតវៃរបស់រាជរដ្ឋាភិបាលកម្ពុជា និងផែនការពាក់ព័ន្ធនានាផ្សេងៗទៀត។ ជាមួយគ្នានេះ នៅក្នុងផែនទីបង្ហាញផ្លូវទីក្រុងឆ្លាតវៃនៃខេត្តសៀមរាបនេះ ក៏បានរៀបរាប់អំពីយុទ្ធសាស្ត្រ វិធានការអនុវត្ត និងគម្រោងអាទិភាពសំខាន់ៗ ដើម្បីសម្រេចឱ្យបានការរៀបចំក្រុងសៀមរាបឱ្យក្លាយជាទីក្រុងឆ្លាតវៃអាស៊ានសម្រាប់ចក្ខុវិស័យ ឆ្នាំ២០៣៥។ តាមរយៈផែនទីបង្ហាញផ្លូវទីក្រុងឆ្លាតវៃ នៃខេត្តសៀមរាបនេះ ខ្ញុំសង្ឃឹមយ៉ាងមុតមាំថា ឯកសារនេះនឹងក្លាយទៅជាឯកសារគោលនយោបាយដ៏ល្អមួយរបស់រដ្ឋបាលខេត្តសៀមរាប ក្នុងការរៀបចំក្រុងសៀមរាប ក៏ដូចជាខេត្តសៀមរាបឱ្យក្លាយទៅជាទីក្រុងឆ្លាតវៃអាស៊ាន ស្របតាមចក្ខុវិស័យ ដែលសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ (អាស៊ាន)បានដាក់ចេញសម្រាប់បណ្ដាទីក្រុងទាំង ២៦ របស់បណ្ដារដ្ឋជាសមាជិកនៃសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍(អាស៊ាន)។ ទន្ទឹមនឹងនេះដែរ ខ្ញុំក៏សង្ឃឹមផងដែរថា តាមរយៈ ផែនទីបង្ហាញផ្លូវទីក្រុងឆ្លាតវៃ នៃខេត្តសៀមរាបនេះ នឹងក្លាយជាឯកសារដ៏គួរឱ្យទាក់ទាញសម្រាប់ការវិនិយោគ ទាំងវិស័យសាធារណៈ និងវិស័យឯកជន ដើម្បីចូលរួមចំណែកសម្រេចឱ្យបាន ការរៀបចំអភិវឌ្ឍក្រុងសៀមរាប នៃខេត្តសៀមរាបឱ្យក្លាយជាទីក្រុងឆ្លាតវៃសម្រាប់ចក្ខុវិស័យឆ្នាំ២០៣៥ សំដៅចូលរួមចំណែកលើកកម្ពស់វិស័យទេសចរណ៍របស់ខេត្តសៀមរាបជាមួយរាជរដ្ឋាភិបាលនិងលើកកម្ពស់គុណភាពជីវិតឱ្យបានកាន់តែល្អប្រសើរឡើង។

ក្នុងនាមក្រុមប្រឹក្សាខេត្ត គណៈអភិបាលខេត្ត និងក្នុងនាមខ្លួនខ្ញុំផ្ទាល់ ខ្ញុំសូមស្នើដល់គ្រប់អ្នកពាក់ព័ន្ធទាំងអស់ ត្រូវផ្ដល់អាទិភាពដល់ការអនុវត្តជាក់ស្ដែងនូវផែនទីបង្ហាញផ្លូវទីក្រុងឆ្លាតវៃ នៃខេត្តសៀមរាបនេះ ដើម្បីចូលរួមចំណែកក្នុងការលើកកម្ពស់វិស័យទេសចរណ៍ លើកកម្ពស់ការផ្ដល់សេវាសាធារណៈ និងធ្វើឱ្យគុណភាពនៃជីវិតមានលក្ខណៈកាន់តែល្អប្រសើរឡើង។

ថ្ងៃព្រហស្បតិ៍ ១១កើត ខែផល្គុន ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

ខេត្តសៀមរាប ថ្ងៃទី០២ ខែមីនា ឆ្នាំ២០២៣

**អភិបាលខេត្ត**

ទៀ សីហា

# សេចក្តីផ្តើម

ទីក្រុងសៀមរាប នៃខេត្តសៀមរាប គឺជាទីក្រុងមួយដែលផ្តោតលើវិស័យទេសចរណ៍ ដែលមានតំបន់អង្គរជាបេតិកភណ្ឌវប្បធម៌ពិភពលោក។ ខណៈដែលចំនួនប្រជាពលរដ្ឋក្នុងក្រុងសៀមរាប មានប្រមាណ ២៤៥,៤៩៤នាក់ ដោយយោងតាមជំរឿនទូទៅ ក្នុងឆ្នាំ២០១៩ ចំនួនភ្ញៀវទេសចរមានចំនួនប្រហែល ២.៨៦លាននាក់ គិតត្រឹមឆ្នាំ២០១០ ខណៈចំនួនភ្ញៀវទេសចរជាក់ស្តែងក្នុងឆ្នាំ២០១៩ មានរហូតដល់ ៤.២៦លាននាក់ ដែលក្នុងនោះ៧០% នៃភ្ញៀវទេសចរបរទេសទាំងអស់ដែលមកទស្សនាប្រទេសកម្ពុជា សុទ្ធសឹងតែមកទស្សនាទីក្រុងសៀមរាបផងដែរ។

ម្យ៉ាងវិញទៀត ហេដ្ឋារចនាសម្ព័ន្ធ សេវាសង្គម និងការកែលម្អផ្សេងៗទៀត ពុំទាន់គ្រប់គ្រាន់ដើម្បីសម្រួលដល់ការកើនឡើងនៃចំនួនភ្ញៀវទេសចរនៅឡើយ។ បញ្ហាប្រឈមរបស់ប្រជាពលរដ្ឋ និងភ្ញៀវទេសចរ គឺការធ្លាក់ចុះនៃជីវភាព រស់នៅ និងបរិស្ថានទីក្រុង។ ទាំងនេះរួមបញ្ចូលជាឧទាហរណ៍ដូចជាការកកស្ទះចរាចរណ៍កាន់តែកើនឡើងដោយសារតែកំណើនយ៉ាងរហ័សនៃចំនួនយានយន្ត ការរេចរឹលបរិស្ថានដោយសារការកើនឡើងនៃកាកសំណល់ និងការបញ្ចេញចោលនូវទឹកកខ្វក់ ព្រមទាំងការកើតឡើងនៃបទល្មើសផ្សេងៗផងដែរ។ ចំណូលមកពីវិស័យទេសចរណ៍សរុបរបស់កម្ពុជាក្នុងឆ្នាំ ២០២០ មានចំនួន ១ពាន់លានដុល្លារសហរដ្ឋអាមេរិក (ថយចុះ ៧៩.៤% បើធៀបនឹងឆ្នាំ២០១៩ ដែលកាលនោះកម្ពុជារកចំណូលបាន ៤.៩៣ពាន់លានដុល្លារសហរដ្ឋអាមេរិក) ហើយចំណែកឯចំនួនភ្ញៀវទេសចរមានប្រមាណ ១.៣ លាននាក់ (ធ្លាក់ចុះ ៨០.២% បើធៀបនឹងឆ្នាំ២០១៩ ដែលមានចំនួនរហូតដល់ ៦.៦១លាននាក់) ដោយសារផលប៉ះពាល់នៃជំងឺកូវីដ-១៩។ ការណ៍នេះបានជះឥទ្ធិពលយ៉ាងខ្លាំងដល់សេដ្ឋកិច្ច និងការងារនៃទីក្រុងសៀមរាប ដែលជាទីក្រុងទេសចរណ៍។ ម្យ៉ាងវិញទៀត ខេត្តសៀមរាប ត្រូវបានព្យាករថានឹងទទួលបានភ្ញៀវទេសចរប្រមាណ ១១លាននាក់នៅឆ្នាំ២០៣៥ (ផែនការមេអភិវឌ្ឍន៍ទេសចរណ៍ខេត្តសៀមរាបឆ្នាំ២០២១-២០៣៥)។ វិធីសាស្រ្ត "ទីក្រុងឆ្លាតវៃ" ត្រូវបានវិភាគថាជាមធ្យោបាយដ៏មានប្រសិទ្ធភាពក្នុងការអភិវឌ្ឍបរិស្ថានទីក្រុង ដើម្បីឆ្លើយតបទៅនឹងតម្រូវការផ្សេងៗរបស់ភ្ញៀវទេសចរនាពេលអនាគត ក្រោយជំងឺកូវីដ-១៩ ។

ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ ដោយសារឌីជីថលនីយកម្មឆាប់រហ័សនៃសកម្មភាពពលរដ្ឋ និងសេដ្ឋកិច្ច ទីក្រុងឆ្លាតវៃបានក្លាយជានិន្នាការពេញនិយមថាជាមធ្យោបាយថ្មីក្នុងការអភិវឌ្ឍទីក្រុងនៅជុំវិញពិភពលោក។ ទោះជាយ៉ាងណាក៏ដោយ និយមន័យ និងវិធីសាស្រ្តលម្អិតនៃទីក្រុងឆ្លាតវៃមានភាពខុសគ្នាទៅតាមតំបន់ ប្រទេស និងរដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ។ ចលនាទីក្រុងឆ្លាតវៃក្នុងខេត្តសៀមរាប ត្រូវបានអមដោយការអនុម័តឯកសារក្របខ័ណ្ឌបណ្តាញទីក្រុងឆ្លាតវៃអាស៊ាន (ASCN) ក្នុងកិច្ចប្រជុំកំពូលអាស៊ានក្នុងឆ្នាំ ២០១៨ ដែលបានបើកដំណើរការវេទិកាសម្រាប់ទីក្រុងពីបណ្តាប្រទេសសមាជិកអាស៊ានដើម្បីធ្វើកិច្ចសហប្រតិបត្តិការ ហើយខេត្តសៀមរាបនៅឆ្នាំ២០១៩ គណៈកម្មាធិការទីក្រុងឆ្លាតវៃ ក្រោមការដឹកនាំរបស់រដ្ឋបាលខេត្ត បានបង្កើតឡើងជាអង្គភាពដើម្បីពិភាក្សាអំពីទិសដៅនៃទីក្រុងឆ្លាតវៃរបស់ខេត្តសៀមរាប។

ដើម្បីសម្រេចបានទីក្រុងឆ្លាតវៃក្នុងខេត្តសៀមរាប នៅឆ្នាំ២០២០ រដ្ឋបាលខេត្តសៀមរាប ក្រោមជំនួយកិច្ចសហប្រតិបត្តិការបច្ចេកទេសពីទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិនៃប្រទេសជប៉ុន(JICA) បានចាប់ផ្តើមរៀបចំឯកសារផែនទីបង្ហាញផ្លូវទីក្រុងឆ្លាតវៃនៃខេត្តសៀមរាប។ ដំណាក់កាលនៃការរៀបចំគឺបានធ្វើឡើងដោយមានការពិគ្រោះយោបល់ជាមួយតំណាងប្រជាពលរដ្ឋ វិស័យឯកជន សាកលវិទ្យាល័យ ដៃគូអភិវឌ្ឍន៍ និងអ្នកជំនាញផ្សេងៗទៀត។ ការបោះពុម្ពលើកដំបូងនៃផែនទីបង្ហាញផ្លូវនេះត្រូវបានធ្វើឡើង និងអនុម័តដោយទូលំទូលាយក្នុងឆ្នាំ ២០២១។

ផែនទីបង្ហាញផ្លូវនេះត្រូវបានធ្វើបច្ចុប្បន្នភាពក្នុងខែកុម្ភៈ ឆ្នាំ២០២៣។ ផែនទីបង្ហាញផ្លូវនេះមាន២ផ្នែក ដែលផ្នែកទី១បង្ហាញពីចក្ខុវិស័យ និងទិសដៅនៃខេត្តសៀមរាប និងផ្នែកទី២បង្ហាញពីផែនការសកម្មភាព។ ដោយសារតែផ្នែកទី១ ពណ៌នាអំពីទស្សនវិជ្ជារបស់ទីក្រុងឆ្លាតវៃ នៃខេត្តសៀមរាបនោះ នឹងពុំមានការផ្លាស់ប្តូរអ្វី ធំដុំណាមួយនៅក្នុងជំពូកនេះ នៅពេលខាងមុខឡើយ។ ផ្នែកទី២ ត្រូវការធ្វើបច្ចុប្បន្នភាពទៅតាមភាពចាំបាច់ដែលសមស្រប ព្រោះថាផែនការសកម្មភាពត្រូវការផ្លាស់ប្តូរទៅតាមកាលៈទេសៈដើម្បីឱ្យស្របជាមួយនឹងការអភិវឌ្ឍឥតឈប់ឈរនៃបច្ចេកវិទ្យាឆ្លាតវៃ។ ដូចដែលបានកត់សម្គាល់ខាងលើ ការបោះពុម្ពលើកដំបូងនៃផែនទីបង្ហាញផ្លូវនេះត្រូវបានធ្វើឡើងក្នុងឆ្នាំ ២០២១ ដូច្នេះផែនការសកម្មភាពដែលមាននៅក្នុងនេះ បង្ហាញឱ្យឃើញនូវវឌ្ឍនភាពបច្ចុប្បន្ន ត្រឹមខែកុម្ភៈ ឆ្នាំ២០២៣។

ដោយសារផែនទីបង្ហាញផ្លូវនេះជាឯកសាររស់រវើក វានឹងមានភាពបត់បែនដើម្បីសម្របទៅនឹងការផ្លាស់ប្តូរគម្រោងអាទិភាព និងផែនការសកម្មភាព ហើយនឹងរួមបញ្ចូលនូវគំនិតផ្តួចផ្តើមទីក្រុងឆ្លាតវៃជាច្រើនសម្រាប់ខេត្តសៀមរាបនៅពេលខាងមុខផងដែរ។

"សៀមរាបឆ្លាតវៃ"

# ផែនទីបង្ហាញផ្លូវទីក្រុងឆ្លាតវៃ នៃខេត្តសៀមរាប
# ផ្នែកទី ១: វិធីសាស្ត្រទីក្រុងឆ្លាតវៃ

# ជំពូកទី ១: គោលបំណង និងចក្ខុវិស័យ

## ១.១ គោលបំណងនៃផែនទីបង្ហាញផ្លូវទីក្រុងឆ្លាតវៃ

ផែនទីបង្ហាញផ្លូវទីក្រុងឆ្លាតវៃ នៃខេត្តសៀមរាប ត្រូវបានធ្វើការអភិវឌ្ឍឡើងដើម្បីបង្កើតចក្ខុវិស័យមួយសម្រាប់ទីក្រុងឆ្លាតវៃ នៅក្នុងខេត្តសៀមរាប និងរៀបចំគម្រោងការនៃជំហានដែលត្រូវអនុវត្ត ព្រមទាំងរៀបចំយុទ្ធសាស្ត្រដើម្បីសម្រេចអោយបាននូវចក្ខុវិស័យនេះ។ ផែនទីបង្ហាញផ្លូវនេះ ត្រូវបានរៀបចំឡើងដោយមានការចូលរួមជាតុចូលពីប្រជាពលរដ្ឋខេត្តសៀមរាប វិស័យឯកជន មន្ត្រីរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ផ្សេងៗ។

ផែនទីបង្ហាញផ្លូវនឹងដើរតួនាទីជាឧបករណ៍ភ្ជាប់ទំនាក់ទំនង ដើម្បីជូនដំណឹងដល់ភាគីពាក់ព័ន្ធអំពីផែនការ និងវឌ្ឍនភាពរបស់ខ្លួន។ មួយវិញទៀត ផែនទីបង្ហាញផ្លូវនេះជួយសម្រួលដល់គំនិតផ្តួចផ្តើម របស់មន្ទីរ អង្គភាព និងទីចាត់ការផ្សេងៗនៅក្នុងរដ្ឋបាលខេត្ត វិស័យឯកជន និងភាគីពាក់ព័ន្ធផ្សេងទៀត។ ផែនទីបង្ហាញផ្លូវនឹងមិនត្រឹមតែដើរតួជាឧបករណ៍សម្រាប់ចែករំលែកព័ត៌មាននៅក្នុងទីក្រុងនេះប៉ុណ្ណោះទេ ប៉ុន្តែក៏ជាឧបករណ៍សម្រាប់ផ្សព្វផ្សាយព័ត៌មានទៅកាន់ទីក្រុងផ្សេងៗទៀត ទាំងក្នុង និងក្រៅប្រទេស។ គេរំពឹងថា តាមរយៈការប្រាស្រ័យទាក់ទង និងការផ្សព្វផ្សាយ នោះការច្នៃប្រឌិតបង្កើតថ្មី នឹងត្រូវបានជំរុញសម្រាប់ការអភិវឌ្ឍទីក្រុង។

លើសពីនេះទៀត គោលដៅជាក់លាក់ដែលអាចវាស់វែងបាន និងសូចនាករនានា នឹងត្រូវបានកំណត់ដោយផ្អែកលើផែនទីបង្ហាញផ្លូវនេះ។ តាមរយៈការតាមដានវឌ្ឍនភាពដោយផ្ទៀងផ្ទាត់ជាមួយកត្តាទាំងឡាយនេះ យើងនឹងអាចកំណត់អត្តសញ្ញាណផ្នែកដែលត្រូវការធនធានបន្ថែម ឬការកែតម្រូវបន្ថែមទៀត។ ផែនទីបង្ហាញផ្លូវក៏អាចត្រូវបានប្រើដើម្បីត្រួតពិនិត្យ និងវាយតម្លៃគំនិតផ្តួចផ្តើមទីក្រុងឆ្លាតវៃ ដោយធ្វើបច្ចុប្បន្នភាព និងកែសម្រួលផែនទីបង្ហាញផ្លូវជាប្រចាំតាមតម្រូវការចាំបាច់ជាក់ស្តែង។ ដូច្នេះ ផែនទីបង្ហាញផ្លូវនេះ ត្រូវបានគេរំពឹងទុកថា នឹងជួយបង្កើនប្រសិទ្ធភាពនៃកិច្ចខិតខំប្រឹងប្រែងក្នុងការធ្វើផែនការ ការអនុវត្ត និងការវាយតម្លៃ ប្រកបដោយប្រសិទ្ធភាពខ្ពស់ ស្របតាមចក្ខុវិស័យរបស់ខេត្តសៀមរាប។

## ១.២ ចក្ខុវិស័យទីក្រុងឆ្លាតវៃ

ចក្ខុវិស័យ "សៀមរាបឆ្លាតវៃ" បង្កើតឡើងក្នុងគោលដៅប្រែក្លាយទីក្រុងសៀមរាបឱ្យទៅជាទីក្រុងឆ្លាតវៃក្នុងឆ្នាំ២០៣៥។ រូបភាពខាងក្រោម បង្ហាញពីចក្ខុវិស័យរបស់ "សៀមរាបឆ្លាតវៃ"។

ចក្ខុវិស័យនេះមានសសរស្តម្ភចំនួន ៤ ដែលមានដូចជា "ដើម្បី" "ជាមួយ" "តាមរយៈ" និង "ឆ្ពោះទៅ"។ សសរស្តម្ភទាំង៤ មានទិសដៅស្របទៅនឹងផែនការមេអភិវឌ្ឍន៍ទេសចរណ៍ក្នុងខេត្តសៀមរាបឆ្នាំ២០២១-២០៣៥ ("សម្រេចបាននូវឧស្សាហកម្មទេសចរណ៍ដែលមានគុណភាពខ្ពស់ រួមទាំងទេសចរណ៍វប្បធម៌ និងទេសចរណ៍ប្រកបដោយនិរន្តរភាព") ក៏ដូចជាឯកសារច្បាប់សំខាន់ៗផ្សេង

ទៀតនៅក្នុងប្រទេសកម្ពុជា ដូចដែលបានលើកឡើងនៅក្នុងជំពូកទី២។ ចក្ខុវិស័យនេះក៏ស្របគ្នាផង ដែរជាមួយនឹងក្របខ័ណ្ឌអភិវឌ្ឍន៍ទីក្រុងឆ្លាតវៃថ្នាក់ជាតិ នៃព្រះរាជាណាចក្រកម្ពុជា ដែលចែងថា ទីក្រុងឆ្លាតវៃធានាបាននូវគុណភាពជីវិត កំណើនសេដ្ឋកិច្ច ការអភិវឌ្ឍប្រកបដោយចីរភាព ភាពធន់ បរិស្ថាន និងបរិយាបន្ន។




**ចក្ខុវិស័យរបស់ "សៀមរាបឆ្លាតវៃ"**

**សសរស្តម្ភទីមួយ** គឺ "ដើម្បី" ដែលមានគោលដៅសម្រេចឱ្យបាននូវទីក្រុងឆ្លាតវៃសម្រាប់ប្រជាពលរដ្ឋ និងភ្ញៀវទេសចរ។ បរិយាបន្ន ក៏មានសារៈសំខាន់ផងដែរ ដូច្នេះហើយ ទស្សនៈនៃការពិចារណាលើក្រុមដែលងាយរងគ្រោះក្នុងសង្គម រួមទាំងយេនឌ័រ គួរតែត្រូវបានដាក់បញ្ចូល។

**សសរស្តម្ភទីពីរ** គឺ "ជាមួយ" ដែលជាគុណតម្លៃដ៏សំខាន់ ដែលសង្កត់ធ្ងន់ថាទោះជាមានការប្រើប្រាស់បច្ចេកវិទ្យាខ្ពស់ក្តី ក៏ត្រូវរក្សា និងការពារវប្បធម៌ ធម្មជាតិ និងប្រវត្តិសាស្ត្រដែលតំណាងដោយបេតិកភណ្ឌអង្គរដែលខេត្តសៀមរាបបានកសាងឡើងមកតាំងពីអតីតកាលឱ្យបានល្អ និងទុកជាកេរមត៌កដល់ជំនាន់ក្រោយ។

**សសរស្តម្ភទីបី** គឺ "តាមរយៈ" ដែលសង្កត់ធ្ងន់ថាក្រៅពីការប្រើប្រាស់វិធីសាស្ត្រដែលផ្អែកលើបច្ចេកវិទ្យា វិធីសាស្ត្រដែលផ្តោតលើដំណោះស្រាយជាធំដើម្បីដោះស្រាយបញ្ហានានាក្នុងទីក្រុងក៏ចាំបាច់ផងដែរ។ មានបច្ចេកវិទ្យាជាច្រើនដែលអាចប្រើប្រាស់បាននាពេលបច្ចុប្បន្ន ហើយវាជាការសំខាន់ក្នុងការជ្រើសរើសបច្ចេកវិទ្យាសមស្របសម្រាប់វិស័យនីមួយៗ និងបរិបទក្នុងតំបន់ ហើយត្រូវប្រើបច្ចេកវិទ្យានោះដោយភាពឆ្លាតវៃ។

**សសរស្តម្ភទីបួន** គឺ "ឆ្ពោះទៅ" ដោយមានទិសដៅក្នុងការអភិវឌ្ឍប្រកបដោយចីរភាព មានបរិស្ថានល្អ និងហេដ្ឋារចនាសម្ព័ន្ធទេសចរណ៍ប្រកបដោយផាសុកភាពសម្រាប់ប្រជាពលរដ្ឋ និងភ្ញៀវទេសចរ។

## ១.៣ វិធីសាស្ត្រទីក្រុងឆ្លាតវៃ

នៅក្នុងក្របខ័ណ្ឌគោលនយោបាយសេដ្ឋកិច្ច និងសង្គមឌីជីថលកម្ពុជា ឆ្នាំ២០២១-២០៣៥ ទីក្រុងឆ្លាតវៃក្នុងប្រទេសកម្ពុជាបានកំណត់ថាជា "ទីក្រុងដែលបំពាក់ និងប្រើប្រាស់បច្ចេកវិទ្យាឌីជីថល និងទំនើបបំផុត ដើម្បីបង្កើនប្រសិទ្ធភាពប្រតិបត្តិការទូទាំងទីក្រុង តាមរយៈការចែករំលែកព័ត៌មានជាមួយ សាធារណជន និងលើកកម្ពស់គុណភាពសេវាសាធារណៈ ក៏ដូចជាសុខុមាលភាពសង្គម"។ វិធីសាស្ត្រសម្រាប់ការអនុវត្តទីក្រុងឆ្លាតវៃមានភាពខុសប្លែកគ្នាពីទីក្រុងមួយទៅទីក្រុងមួយ ដោយកត្តាភូមិសាស្ត្រ សេដ្ឋកិច្ច សង្គម និងវប្បធម៌។ វិធីសាស្ត្រទីក្រុងឆ្លាតវៃក្នុងខេត្តសៀមរាប ជាដំបូងត្រូវកំណត់វិស័យសំខាន់ៗជាមុនសិន ដើម្បីធ្វើការវិភាគលើបញ្ហាតាមវិស័យទាំងនោះ។ បន្ទាប់មក ត្រូវកំណត់ចក្ខុវិស័យសម្រាប់អនាគតឱ្យច្បាស់លាស់ ដើម្បីបង្កើតផែនទីបង្ហាញផ្លូវ សម្រាប់អនុវត្ត។




នៅក្នុងដំណាក់កាលនៃការអនុវត្តផែនទីបង្ហាញផ្លូវ ការវិភាគព័ត៌មានដែលមានស្រាប់ និងការបំប្លែងធាតុចូលចាំបាច់នានា (assets) ទៅជាទិន្នន័យ នឹងត្រូវយកជាមូលដ្ឋាន។ ការបង្កើតប្រព័ន្ធ និងការអនុវត្តវិធានការសម្រាប់វិស័យនីមួយៗនឹងចាប់ផ្តើមពីវិស័យដែលអាចធ្វើទៅបាន ហើយនឹងត្រូវបានកែលម្អដោយការឆ្លុះបញ្ចាំងពីមេរៀនដែលបានរៀនពីវិស័យផ្សេងទៀត។ តាមរយៈការអនុវត្តសកម្មភាពទាំងនេះ កិច្ចសហប្រតិបត្តិការជាមួយសហគ្រាស រដ្ឋាភិបាល វិស័យសិក្សា និងសហគមន៍នឹងត្រូវបានពន្លឿន ហើយលទ្ធផលនៃសកម្មភាពនឹងត្រូវចែករំលែកទៅកាន់សង្គម ទាំងជាតិ និងអន្តរជាតិ។ ការចែករំលែកព័ត៌មាននេះ ត្រូវបានគេរំពឹងថានឹងលើកទឹកចិត្តដល់អ្នកចូលរួមថ្មីៗ ដោយរាប់បញ្ចូលទាំងអាជីវកម្មឯកជនដែលនឹងអាចបង្កើតគុណតម្លៃថ្មីក្នុងនាមជាទីក្រុងទេសចរណ៍អន្តរជាតិ។ តាមរយៈកិច្ចខិតខំប្រឹងប្រែងទាំងនេះ គំនិតផ្តួចផ្តើមទីក្រុងឆ្លាតវៃខេត្តសៀមរាប ធានាបាននូវការអភិវឌ្ឍប្រកបដោយនិរន្តរភាព ហើយទីបំផុតសម្រេចបាននូវគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព (SDGs) និងការលើកកម្ពស់សុខុមាលភាពរបស់ប្រជាពលរដ្ឋក្នុងខេត្តសៀមរាប។


ការបង្កើតគុណតម្លៃជាទីក្រុងទេសចរណ៍អន្តរជាតិ
ការអនុវត្តគម្រោងសាកល្ប
និងការត្រួតពិនិត្យជាមួយនឹងវិធីសាស្រ្តចាប់ផ្តើមពីខ្នាតតូច ( small-start-approach )
កិច្ចសហប្រតិបត្តិការ និងការអភិវឌ្ឍន៍សមត្ថភាព
ការចែករំលែកចំណេះដឹង និងការទាក់ទាញវិស័យឯកជន

# ជំពូកទី ២: ផែនការពាក់ព័ន្ធ និងគម្រោងសាកល្បង

## ២.១ ផែនការមេអភិវឌ្ឍន៍ទេសចរណ៍ខេត្តសៀមរាប ឆ្នាំ ២០២១-២០៣៥

### *២.១.១ ចក្ខុវិស័យទេសចរណ៍រយៈពេលវែងសម្រាប់ឆ្នាំ ២០២១-២០៣៥*

ផែនការមេអភិវឌ្ឍន៍ទេសចរណ៍ខេត្តសៀមរាប ឆ្នាំ២០២១-២០៣៥ ត្រូវបានបង្កើតឡើងដោយក្រសួងទេសចរណ៍ ក្នុងឆ្នាំ២០២១។ ចក្ខុវិស័យរយៈពេលវែង នៃផែនការមេនេះ ត្រូវបានកំណត់ថា "ខេត្តសៀមរាបនឹងក្លាយជាគោលដៅទេសចរណ៍អន្តរជាតិដ៏ទាក់ទាញប្រកបដោយគុណភាព ផ្តល់នូវធនធានទេសចរណ៍ជាច្រើន ជាមួយនឹងការទទួលស្គាល់ជាសកលអំពីបេតិកភណ្ឌវប្បធម៌ និងការអភិរក្សការពារសម្បត្តិធម្មជាតិ ព្រមទាំងទាក់ទាញភ្ញៀវទេសចរ ឱ្យមកទស្សនាម្តងហើយម្តងទៀត ដោយភ្ជាប់ជាមួយនឹងការអភិវឌ្ឍសេដ្ឋកិច្ចតាមមូលដ្ឋាន ការកាត់បន្ថយភាពក្រីក្រ និងការឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុ"។ ចក្ខុវិស័យនៃផែនទីបង្ហាញផ្លូវទីក្រុងឆ្លាតវៃសៀមរាប ត្រូវបានបង្កើតឡើងដោយផ្អែកលើផែនការមេ។

### *២.១.២ ក្របខ័ណ្ឌគម្រោងការទេសចរណ៍*

យោងតាមផែនការមេអភិវឌ្ឍន៍ទេសចរណ៍ខេត្តសៀមរាប សម្រាប់ឆ្នាំ ២០២១-២០៣៥ ចំនួនភ្ញៀវទេសចរប្រចាំឆ្នាំនៅខេត្តសៀមរាប ត្រូវបានគេរំពឹងថានឹងកើនឡើងពី ៤.២ លាននាក់ក្នុងឆ្នាំ ២០១៩ ដល់ ១៨.៤១ លាននាក់ក្នុងឆ្នាំ ២០៣៥។ ក្នុងឆ្នាំ ២០២០ ចំនួនភ្ញៀវទេសចរ បានធ្លាក់ចុះមកត្រឹម ១.១ លាននាក់ ដោយសារតែឥទ្ធិពលនៃជំងឺកូវីដ-១៩ ប៉ុន្តែគេរំពឹងថានឹងកើនឡើងបន្ទាប់ពីឆ្នាំ ២០២១។

**ការព្យាករចំនួនភ្ញៀវទេសចរ (គិតដល់ឆ្នាំ ២០៣៥)**

| ប្រការ | | ២០១៩ | ២០២៣ | ២០២៨ | ២០៣០ | ២០៣៥ |
|---|---|---|---|---|---|---|
| ចំនួនភ្ញៀវទេសចរ | សរុប | ៤,២៦២,៣០៦ | ៣,៣៥៩,៥៨៥ | ៧,៧៧២,៤៤៦ | ១០,៥៣៦,៤៨៩ | ១៨,៤១៣,១៤០ |
| | បរទេស | ២,២០៥,៦៩៧ | ១,៣២៦,៣១៩ | ៣,៦៨២,៨២១ | ៥,១២៧,៩៦០ | ៧,៥៣៤,៦៥៦ |
| | ក្នុងស្រុក | ២,០៥៦,៦០៩ | ២,០៣៣,២៦៦ | ៤,០៨៩,៦២៥ | ៥,៤០៨,៥២៩ | ១០,៨៧៨,៤៨៤ |
| រយៈពេលស្នាក់នៅជាមធ្យម | បរទេស | ២.៨ | ២.៨ | ៤.៥ | ៤.៥ | ៤.៥ |
| | ក្នុងស្រុក | ១.០ | ២.៥ | ២.៥ | ២.៥ | ២.៥ |

ប្រភព៖ ផែនការមេអភិវឌ្ឍន៍ទេសចរណ៍ខេត្តសៀមរាប (២០២១-២០៣៥)1

1 យោងតាមសេណារីយូទី១ ក្នុងផែនការមេ អភិវឌ្ឍន៍ទេសចរណ៍ខេត្តសៀមរាប សម្រាប់ឆ្នាំ ២០២១-២០៣៥ ចំនួនភ្ញៀវទេសចរ នឹងកើនឡើងដូចខាងក្រោម៖
ភ្ញៀវបរទេស ៖
ឆ្នាំ២០២០ ៖ថយចុះ ៧៨% បើប្រៀបធៀបនឹងឆ្នាំមុន ដោយសារកូវីដ-១៩
ឆ្នាំ២០២១～ឆ្នាំ២០២២ ៖ កើនឡើង ៤៥% ក្នុង ១ ឆ្នាំ

## ២.២ គម្រោងស្ថាបនាហេដ្ឋារចនាសម្ព័ន្ធផ្លូវចំនួន ៣៨ខ្សែ នៅក្រុងសៀមរាប ខេត្តសៀមរាប

នៅក្នុងឆ្នាំ២០២១ រាជរាជរដ្ឋាភិបាលកម្ពុជា បានអនុវត្តគម្រោងសាងសង់ផ្លូវចំនួន ៣៨ខ្សែ នៅក្រុងសៀមរាប ខេត្តសៀមរាប ដោយប្រើប្រាស់កញ្ចប់ថវិកាជាតិចំនួន ១៤៩.២១ លានដុល្លារសហរដ្ឋអាមេរិក ស្របតាមផែនការមេអភិវឌ្ឍន៍ទេសចរណ៍ខេត្តសៀមរាប។ គម្រោងនេះ រួមមាន ការសាងសង់ផ្លូវចំនួន ៣៨ ខ្សែ ដែលមានប្រវែងសរុបជាង ១០៦ គីឡូម៉ែត្រ និងប្រព័ន្ធលូ និងលូប្រវែង ២៥០ គីឡូម៉ែត្រ។ លើសពីនេះទៅទៀត ក៏មានការដំឡើងកាមេរ៉ាសុវត្ថិភាព (CCTV) ចំនួន ២០០ គ្រឿង ភ្លើងសញ្ញាចរាចរណ៍ចំនួន ២០ គ្រឿង ភ្លើងបំភ្លឺផ្លូវសាធារណៈចំនួន ៥,៣០០ ដើម និងដាំដើមឈើចំនួន ៣,១២៥ ដើម។

## ២.៣ ប្លង់គោលប្រើប្រាស់ដីក្រុងសៀមរាប ចក្ខុវិស័យឆ្នាំ ២០៣៥

ប្លង់គោលប្រើប្រាស់ដីក្រុងសៀមរាប ចក្ខុវិស័យឆ្នាំ២០៣៥ ត្រូវបានបង្កើតឡើងនៅក្នុងឆ្នាំ ២០១៨។ ក្នុងនោះដែរ ចំនួនប្រជាពលរដ្ឋក្នុងក្រុងសៀមរាបក្នុងឆ្នាំ ២០៣៥ ត្រូវបានប៉ាន់ប្រមាណថាមានចំនួន ៤៤០,០៩៩ នាក់ ដោយផ្អែកលើលទ្ធផលជំរឿនប្រជាសាស្ត្រទូទាំងប្រទេស។ ម្យ៉ាងវិញទៀត យោងតាមប្លង់គោលប្រើប្រាស់ដីក្រុងសៀមរាប ចក្ខុវិស័យឆ្នាំ២០៣៥ ចំនួនប្រជាពលរដ្ឋដែលធ្វើការតាមកម្រិតប្រភេទឧស្សាហកម្មនៅក្នុងក្រុងសៀមរាបនៅឆ្នាំ ២០០៨ និង ២០៣៥ ត្រូវបានបង្ហាញក្នុងតារាង។

**តារាង ២.១៖កំលាំងពលកម្មតាមកម្រិតឧស្សាហកម្មនៅក្នុងក្រុងសៀមរាបនៅឆ្នាំ២០០៨ និងឆ្នាំ២០៣៥**

| ចំណាត់ថ្នាក់ឧស្សាហកម្ម | ចំនួនកម្មករនៅឆ្នាំ២០០៨ | ចំនួនកម្មករនៅឆ្នាំ២០៣៥ | អាត្រាកំណើន |
|---|---|---|---|
| ឧស្សាហកម្មកម្រិតទី១ | ២១,១៥៣ | ៣៤,៣២៨ | +៦២% |
| ឧស្សាហកម្មកម្រិតទី២ | ១៦,៥៩៩ | ៧៦,៨៩៤ | +៣៦៣% |
| ឧស្សាហកម្មកម្រិតទី៣ | ៦៣,៤៥៩ | ១១៧,៦៣០ | +៨៥% |

ប្រភព៖ ប្លង់គោលប្រើប្រាស់ដីក្រុងសៀមរាប ចក្ខុវិស័យ ឆ្នាំ២០៣៥ 2

ឆ្នាំ២០២៣~ឆ្នាំ២០២៥ ៖ កើនឡើង ៣០% ក្នុង ១ ឆ្នាំ
ឆ្នាំ២០២៦~ឆ្នាំ២០៣០ ៖ កើនឡើង ៨% ក្នុង ១ ឆ្នាំ
ឆ្នាំ២០៣១~ឆ្នាំ២០៣៥ ៖ កើនឡើង ៥% ក្នុង ១ ឆ្នាំ
ភ្ញៀវក្នុងស្រុក ៖
ឆ្នាំ២០២០ ៖ ថយចុះ ៥៥% បើប្រៀបធៀបនឹងឆ្នាំមុន ដោយសារកូវីដ-១៩
ឆ្នាំ២០២១~ឆ្នាំ២០២៣ ៖ កើនឡើង ៣០% ក្នុង ១ ឆ្នាំ
ឆ្នាំ២០២៤~ឆ្នាំ២០៣០ ៖ កើនឡើង ១២% ក្នុង ១ ឆ្នាំ
ឆ្នាំ២០២៤~ឆ្នាំ២០៣៥ ៖ កើនឡើង ៨% ក្នុង ១ ឆ្នាំ

2ការព្យាករណ៍នេះត្រូវបានគណនាដោយផ្អែកលើតួលេខនៃជំរឿនជាតិឆ្នាំ ១៩៩៨ និងជំរឿនជាតិឆ្នាំ ២០០៨ ហើយចាប់តាំងពីការរីកចម្រើននៃឧស្សាហកម្មកម្រិតទី២ មានភាពគួរឱ្យកត់សម្គាល់ក្នុងរយៈពេល ១០ ឆ្នាំចុងក្រោយនេះ វាត្រូវបានគណនាជាអត្រាកំណើនគួរឱ្យកត់សម្គាល់សូម្បីតែនៅក្នុងព្យាករណ៍ឆ្នាំ ២០៣៥ ដែរ។ ទោះជាយ៉ាងណាក៏ដោយ តាមការពិត ផែនការមេការប្រើប្រាស់ដីមិនបានកំណត់ការប្រើប្រាស់ដីឧស្សាហកម្ម ដើម្បីសម្រួលដល់កំណើននៃចំនួនប្រជាជនដែលចូលរួមនៅក្នុងឧស្សាហកម្មកម្រិតទី ២ ដូចគ្នាទៅនឹងតួលេខនេះទេ ហើយវាហាក់ដូចជាពិបាកក្នុងការសម្រេចនូវតួលេខនេះ។ នៅក្នុងការសិក្សានេះ លេខនេះមិនត្រូវបានប្រើជាលក្ខខណ្ឌដែលបានផ្តល់ឱ្យទេ ហើយត្រូវបានចាត់ទុកជាតម្លៃយោងតែប៉ុណ្ណោះ។

## ២.៤ ផែនទីបង្ហាញផ្លូវទីក្រុងឆ្លាតវៃថ្នាក់ជាតិ

ផែនទីបង្ហាញផ្លូវទីក្រុងឆ្លាតវៃថ្នាក់ជាតិ គ្រោងនឹងត្រូវអនុម័តឱ្យប្រើប្រាស់នៅឆ្នាំ២០២៣ ដើម្បីកំណត់ក្របខ័ណ្ឌគោលនយោបាយទីក្រុងឆ្លាតវៃ ដែលផ្តួចផ្តើមដោយក្រសួងមហាផ្ទៃ។ ផែនទីបង្ហាញផ្លូវទីក្រុងឆ្លាតវៃនេះ បង្ហាញអំពីទស្សនទាននៃការអភិវឌ្ឍទីក្រុងឆ្លាតវៃសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ។ ផែនទីបង្ហាញផ្លូវទីក្រុងឆ្លាតវៃ នៃខេត្តសៀមរាបក៏នឹងត្រូវរៀបចំកែសម្រួលអោយមានសង្គតិភាព ជាមួយនឹងក្របខ័ណ្ឌគោលនយោបាយទីក្រុងឆ្លាតវៃថ្នាក់ជាតិ។ គេរំពឹងថា នៅក្នុងផែនទីបង្ហាញផ្លូវទីក្រុងឆ្លាតវៃថ្នាក់ជាតិ នឹងគ្របដណ្តប់កត្តាជំរុញទាំងអស់នេះដូចជា "ស្ថាប័ន និងគោលនយោបាយ បច្ចេកវិទ្យា និងនវានុវត្ត ធុរកិច្ច និងហិរញ្ញវត្ថុ សមត្ថភាព និងជំនាញឌីជីថល ការធ្វើផែនការ និងការសម្របសម្រួល"។ លើសពីនោះ គោលបំណងនៃការអភិវឌ្ឍទីក្រុងឆ្លាតវៃ គឺធ្វើផែនការដើម្បីធានាបាននូវគុណភាពជីវិតកាន់តែប្រសើរឡើង កំណើនសេដ្ឋកិច្ច ការអភិវឌ្ឍប្រកបដោយនិរន្តរភាព ភាពធន់ និងបរិស្ថាន និងបរិយាបន្ន ហើយទស្សនវិជ្ជានេះ ក៏នឹងត្រូវបានយកមកអនុវត្តចំពោះផែនទីបង្ហាញផ្លូវទីក្រុងឆ្លាតវៃ នៃខេត្តសៀមរាបផងដែរ។

## ២.៥ ផែនការពាក់ព័ន្ធសំខាន់ៗផ្សេងទៀត

តារាងខាងក្រោមសង្ខេបអំពីផែនការ ច្បាប់ អនុក្រឹត្យដែលពាក់ព័ន្ធសំខាន់ៗ និងខ្លឹមសារដែលត្រូវដាក់បញ្ចូល។

**តារាង ២.២ ផែនការពាក់ព័ន្ធសំខាន់ៗផ្សេងទៀត**

| ច្បាប់/អនុក្រឹត្យ (ស្ថាប័នសំខាន់ៗ) | ឆ្នាំ | ខ្លឹមសារដែលត្រូវដាក់បញ្ចូល |
|---|---|---|
| ច្បាប់ និងបទបញ្ញត្តិស្តីពីការកំណត់តំបន់ និងការការពារបរិស្ថានក្នុងតំបន់បុរាណដ្ឋានអង្គរខេត្តសៀមរាប (ព្រះរាជាណាចក្រកម្ពុជា) | ១៩៩៤ | តំបន់បុរាណវិទ្យាអង្គរ និងតំបន់អភិរក្សបរិស្ថានផ្សេងៗទៀតត្រូវបានកំណត់ជាតំបន់ដែលត្រូវអភិរក្ស ហើយត្រូវបានបែងចែកជា ៥ តំបន់ ដែលតំបន់នីមួយៗមានបទបញ្ញត្តិរៀងៗខ្លួន។ |
| ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់<br>ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ (ព្រះរាជាណាចក្រកម្ពុជា) | ២០០១<br>២០០៨ | កំណត់វិសាលភាពការងារសម្រាប់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់នីមួយៗ។ |
| គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព (អង្គការសហប្រជាជាតិ) | ២០១៥ | គោលដៅទី ១១ (ការធ្វើឱ្យទីក្រុង និងការតាំងទីលំនៅកាន់តែមានសុវត្ថិភាព បរិស្ថាន ធន់នឹងការប្រែប្រួលអាកាសធាតុ និងមាននិរន្តរភាព) មួយវិញទៀតប្រទេសកម្ពុជាក៏ផ្តោតផងដែរទៅលើការកាត់បន្ថយការបំពុលនៅក្នុងទីក្រុងរបស់ប្រជាពលរដ្ឋម្នាក់ៗ ដោយផ្តោតលើគុណភាពខ្យល់ និងការគ្រប់គ្រងកាកសំណល់នៅក្នុងទីក្រុង និងតំបន់ផ្សេងៗទៀត |
| ការចូលរួមចំណែករបស់កម្ពុជា ដើម្បីអនុវត្តអនុសញ្ញាក្របខ័ណ្ឌសហប្រជា | ២០១៥ | កម្ពុជាមានគោលដៅកាត់បន្ថយការបំភាយឧស្ម័ន ៤១.៧% នៅឆ្នាំ ២០៣០ បើប្រៀបធៀបទៅនឹងពេលបច្ចុប្បន្ន។ |

| | | |
|---|---|---|
| ជាតិស្តីពីការប្រែប្រួលអាកាសធាតុ (NDCs)(កំណត់នៅក្នុងកិច្ចព្រមព្រៀងទីក្រុងប៉ារីស) | | |
| យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ របស់រាជរដ្ឋាភិបាល នីតិកាលទី៦ នៃរដ្ឋសភា (ព្រះរាជាណាចក្រកម្ពុជា) | ២០១៨ | ចក្ខុវិស័យសម្រាប់ឆ្នាំ២០៣០ កម្ពុជានឹងចាកចេញពីប្រទេសមានចំណូលមធ្យមកម្រិតទាបទៅជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់ ហើយចក្ខុវិស័យសម្រាប់ឆ្នាំ២០៥០ កម្ពុជានឹងក្លាយជាប្រទេសមានចំណូលខ្ពស់។ |
| អនុក្រឹត្យលេខ ២២៤អនក្រ.បក ស្តីពីលិខិតអនុញ្ញាតសាងសង់ (ព្រះរាជាណាចក្រកម្ពុជា) | ២០២០ | កំណត់នីតិវិធី និងអង្គភាពអនុម័តសម្រាប់លិខិតអនុញ្ញាតសាងសង់ និងការអនុម័តទៅតាមទំហំសំណង់។ |
| ក្របខ័ណ្ឌគោលនយោបាយសេដ្ឋកិច្ច និង សង្គមឌីជីថលកម្ពុជា ២០២១-២០៣៥ (ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍) | ២០២១ | គោលនយោបាយនេះមានពិពណ៌នាអំពីនិយមន័យនៃ "ទីក្រុងឆ្លាតវៃ"។ គោលនយោបាយនេះបានសង្កត់ធ្ងន់លើការប្រើប្រាស់បច្ចេកវិទ្យាដើម្បីកែលម្អកំណើន ផលិតភាព និងប្រសិទ្ធភាពក្នុងវិស័យផ្សេងៗនៃសេដ្ឋកិច្ច និងសង្គម តាមរយៈការផ្លាស់ប្តូរទៅកាន់ឌីជីថល(បរិវត្តកម្មឌីជីថល)។ គោលនយោបាយនេះក៏លើកឡើងផងដែរអំពីសារៈសំខាន់នៃការកសាងសង្គមឌីជីថលជាមួយនឹងការទទួលបានសេវាឌីជីថលប្រកបដោយសុវត្ថិភាព ការរក្សាអត្តសញ្ញាណជាតិ និងវប្បធម៌។ |
| យុទ្ធសាស្ត្រអភិវឌ្ឍន៍រយៈពេលវែងប្រកបដោយអព្យាក្រឹតកាបូន (ក្រសួងបរិស្ថាន) | ២០២១ | វិធានការកាត់បន្ថយការប្រែប្រួលអាកាសធាតុក្នុងវិស័យកសិកម្ម ព្រៃឈើ ថាមពល ការដឹកជញ្ជូន ឧស្សាហកម្ម និងវិស័យទាក់ទងនឹងកាកសំណល់។ |
| ច្បាប់ស្តីពីការវិនិយោគ នៃព្រះរាជាណាចក្រកម្ពុជា (ព្រះរាជាណាចក្រកម្ពុជា) | ២០២១ | ច្បាប់ស្តីពីការវិនិយោគបង្ហាញពីអង្គភាពផ្តល់អាជ្ញាប័ណ្ណយោងទៅតាមចំនួនទឹកប្រាក់វិនិយោគ និងកំណត់ការលើកទឹកចិត្តសម្រាប់ការវិនិយោគក្នុងវិស័យអាទិភាពចំនួន ១៨។ |
| គោលនយោបាយរដ្ឋាភិបាលឌីជីថលកម្ពុជា ២០២២-២០៣៥ (ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍) | ២០២២ | គោលនយោបាយនេះផ្តោតលើការធ្វើទំនើបកម្ម និងការរួមបញ្ចូលប្រព័ន្ធគ្រប់គ្រងរដ្ឋាភិបាល និងសេវាសាធារណៈ ដើម្បីលើកកម្ពស់អភិបាលកិច្ចល្អ និងសេវាសាធារណៈ ដើម្បីបំពេញតម្រូវការរបស់ប្រជាពលរដ្ឋប្រកប ដោយយុត្តិធម៌ សមធម៌ តម្លាភាព គណនេយ្យភាព និងបរិស្ថានល្អ។ |

# ជំពូកទី ៣: បញ្ហាប្រឈម

ផែនទីបង្ហាញផ្លូវគ្របដណ្តប់លើវិស័យដូចជា ប្រតិបត្តិការរដ្ឋបាល ទេសចរណ៍ ការធ្វើដំណើរ សន្តិសុខសុវត្ថិភាព និងការគ្រប់គ្រងបរិស្ថាន។ វិស័យទាំងនេះត្រូវបានកំណត់ និងឯកភាពតាមរយៈការពិភាក្សាជាមួយរដ្ឋបាលខេត្តសៀមរាប និងមន្ត្រីពាក់ព័ន្ធ។

## ៣.១ បញ្ហាទាក់ទងនឹងប្រតិបត្តិការរដ្ឋបាលទូទៅ

យោងទៅតាមស្ថានភាពបច្ចុប្បន្ននៃប្រតិបត្តិការរដ្ឋបាលទូទៅក្នុងខេត្តសៀមរាប បញ្ហាទាក់ទងនឹងប្រធានបទនេះមានដូចខាងក្រោម៖

ទម្រង់នៃគម្រោងអាទិភាពនៅក្នុងជំពូកទី៨ ត្រូវបានបង្កើតឡើងដោយផ្អែកលើបញ្ហាប្រឈមដែលបានបង្ហាញនៅទីនេះ។ បញ្ហាទូទៅចាប់ពីលេខ១ ដល់ លេខ១៩ មានរៀបរាប់នៅក្នុងទម្រង់នៃគម្រោងនោះ។

**តារាង ៣.១៖ បញ្ហាប្រតិបត្តិការរដ្ឋបាលទូទៅនៅក្នុងខេត្តសៀមរាប (ត្រឹមឆ្នាំ ២០២១)**

| វិស័យ | បញ្ហាជាក់លាក់ | បញ្ហាទូទៅ |
|---|---|---|
| ស្ថាប័នរដ្ឋបាល | • ដោយសារគណៈកម្មាធិការទីក្រុងឆ្លាតវៃបច្ចុប្បន្នមិនរាប់បញ្ចូលអាជ្ញាធរជាតិអប្សរា មន្ទីរទេសចរណ៍ និងស្នងការនគរបាលខេត្ត នាំឱ្យមានការលំបាកសម្រាប់គណៈកម្មាធិការក្នុងការដោះស្រាយបញ្ហាពហុវិស័យ ជាពិសេសពាក់ព័ន្ធនឹងវិស័យទេសចរណ៍។<br>• មិនទាន់មានការពិភាក្សាលម្អិតអំពីគម្រោងជាក់លាក់ដែលពាក់ព័ន្ធនឹងទីក្រុងឆ្លាតវៃនៅឡើយទេនៅក្នុងគណៈកម្មាធិការទីក្រុងឆ្លាតវៃ។ គណៈកម្មាធិការនេះមិនទាន់ដើរតួនាទីរបស់ខ្លួនក្នុងការជំរុញគម្រោង ទៅមុខនៅឡើយ។<br>• ចំណេះដឹងបច្ចេកទេសនៃមន្ត្រីរដ្ឋបាលខេត្តសៀមរាបនៅមានកម្រិត ដែលបណ្តាលឱ្យពិបាកដោះស្រាយបញ្ហាដែលទាមទារចំណេះដឹងទាំងនោះ។ | ១. មានតម្រូវការសម្រាប់របនាសម្ព័ន្ធស្ថាប័នរដ្ឋបាលសម្រាប់កិច្ចសហប្រតិបត្តិការឆ្លងវិស័យ |
| | • រដ្ឋបាលខេត្តសៀមរាប ពុំទាន់មានក្រុមការងាររៀបចំ ដើម្បីជំរុញវិធានការពាក់ព័ន្ធនឹងទីក្រុងឆ្លាតវៃនៅឡើយទេ។ | ២. មានតម្រូវការឱ្យមានទីចាត់ការ ផ្សព្វផ្សាយទីក្រុងឆ្លាតវៃ |
| | • ពុំទាន់មានការពិភាក្សារវាងក្រុមហ៊ុនឯកជននិងគណៈកម្មាធិការទីក្រុងឆ្លាតវៃនៅឡើយទេ។ ពុំទាន់មានអ្វីជាមូលដ្ឋានសម្រាប់វិស័យសាធារណៈ និងវិស័យឯកជនក្នុងការសហការលើគម្រោងពហុវិស័យ ឬគម្រោងក្នុងវិស័យថ្មីៗនៅឡើយ។<br>• នៅក្នុងខេត្តសៀមរាប គេកម្រឃើញមានការសិក្សាស្រាវជ្រាវ ឬគម្រោងសិក្សាដែលមានការចូលរួមយ៉ាងសកម្មពីវិស័យសាធារណៈនៅឡើយ។ | ៣. មានតម្រូវការឱ្យមានមូលដ្ឋាននៃស្ថាប័នសម្រាប់កិច្ចសហប្រតិបត្តិការពហុភាគី |
| ប្រព័ន្ធច្បាប់ និងការគាំទ្រអាជីវកម្ម | • ទោះបីជាមានច្បាប់ផ្សេងៗសម្រាប់យោង និងនីតិវិធីច្បាប់ដែលត្រូវអនុវត្តតាមក្នុងលក្ខខណ្ឌនៃប្រតិបត្តិការអាជីវកម្មក៏ដោយ ក៏ព័ត៌មានដែលទាក់ទងនឹងបញ្ហាទាំងនេះមិនត្រូវបានប្រមូលឡើយ។ នេះធ្វើឱ្យអាជីវកម្មឯកជនមានភាពស្ទាក់ស្ទើរក្នុងការបើកអាជីវកម្មរបស់ខ្លួននៅខេត្តសៀមរាប។ | ៤. ត្រូវការការបំភ្លឺឱ្យច្បាស់លាស់ និងសម្រួលនីតិវិធីច្បាប់ដ៏ស្មុគស្មាញ |

| | | |
|---|---|---|
| | • នីតិវិធីនៃការបើកដំណើរការអាជីវកម្មពហុវិស័យ ឬអាជីវកម្មក្នុងវិស័យថ្មី ពុំទាន់មានភាពច្បាស់លាស់ ដែលធ្វើឱ្យអាជីវកម្មឯកជនស្ទាក់ស្ទើរក្នុងការបើកអាជីវកម្មរបស់ពួកគេនៅក្នុងខេត្តសៀមរាប។ | |
| | • ពុំទាន់មានការពិភាក្សារវាងក្រុមហ៊ុនឯកជន និងគណៈកម្មាធិការទីក្រុងឆ្លាតវៃនៅឡើយទេ។ វិស័យសាធារណៈមិនទាន់ទទួលបានជោគជ័យក្នុងការទាក់ទាញគំនិតផ្តួចផ្តើមសាធារណៈដើម្បីឱ្យក្រុមហ៊ុនឯកជនផ្តល់សេវាសាធារណៈក្នុងលក្ខណៈជាផ្នែកមួយនៃអាជីវកម្មរបស់ខ្លួននៅឡើយ។ | ៥. ត្រូវការការជម្រុញយ៉ាងសកម្មដល់អាជីវកម្មឯកជនដែលទាក់ទងនឹងទីក្រុងឆ្លាតវៃ |
| ការគ្រប់គ្រងទិន្នន័យ | • កង្វះកម្មវិធី (Software)<br>• ហេដ្ឋារចនាសម្ព័ន្ធពុំគ្រប់គ្រាន់សម្រាប់ការរក្សាទុក និងចែករំលែកទិន្នន័យ | ៦.ត្រូវការការធ្វើឱ្យប្រសើរឡើងនូវស្ថានភាពផ្នែករឹង (Hardware) និង ICT |
| | • ទិន្នន័យនៅតាមបណ្តាមន្ទីរនានាគឺស្ថិតក្នុងទម្រង់នៃទិន្នន័យដែលមិនងាយស្រួលក្នុងការប្រើប្រាស់។<br>• មន្ត្រីរាជរដ្ឋាភិបាលនៅមានការខ្វះខាតបទពិសោធន៍ និងសមត្ថភាពក្នុងការចាត់ចែងទិន្នន័យឱ្យបានត្រឹមត្រូវនៅឡើយ។ | ៧. ត្រូវការការចែករំលែកទិន្នន័យ និងការប្រើប្រាស់ទិន្នន័យពហុវិស័យ |
| | • ពុំសូវមានការយកទុកដាក់លើដំណើរការនៃការសម្រេចចិត្តបង្ហាញទិន្នន័យ ដែលនាំឱ្យការបង្ហាញទិន្នន័យមានលក្ខណៈយឺតយ៉ាវ។ | ៨. ត្រូវការប្រព័ន្ធទិន្នន័យបើកចំហ សុវត្ថិភាពទិន្នន័យ និងបទប្បញ្ញត្តិ |

ប្រភព៖ ក្រុមការងារគម្រោងទីក្រុងឆ្លាតវៃ

កំណត់សម្គាល់៖ ការកំណត់អត្តសញ្ញាណបញ្ហាគឺផ្អែកលើការស្ទង់មតិដែលបានធ្វើឡើងក្នុងឆ្នាំ ២០២០។

## ៣.២ បញ្ហាពាក់ព័ន្ធនឹងវិស័យគោលដៅ

យោងទៅតាមស្ថានភាពបច្ចុប្បន្ននៃវិស័យគោលដៅក្នុងខេត្តសៀមរាប បញ្ហាពាក់ព័ន្ធនឹងប្រធានបទនេះមានដូចខាងក្រោម៖

**តារាង ៣.២៖ បញ្ហានៃវិស័យគោលដៅក្នុងខេត្តសៀមរាប (ត្រឹមឆ្នាំ ២០២១)**

| វិស័យ | បញ្ហាជាក់លាក់ | បញ្ហាទូទៅ |
|---|---|---|
| ទេសចរណ៍ | • ថ្វីត្បិតតែមានភ្ញៀវទេសចរណ៍ជាតិ និងអន្តរជាតិមកទស្សនាតំបន់ឧទ្យានបុរាណដ្ឋានអង្គរយ៉ាងច្រើនក៏ដោយ ក៏នៅមានធនធានទេសចរណ៍ជាច្រើនទៀតនៅពុំទាន់ល្បីឈ្មោះ ឬនៅមិនទាន់មានគេរុករកឃើញនៅឡើយ។កិត្តិនាមដែលល្បីតែនៅមានកម្រិតបែបនេះ បណ្តាលឱ្យភ្ញៀវមកទស្សនាត្រឹមតែម្តងប៉ុណ្ណោះ។<br>• ព័ត៌មានទេសចរណ៍មិនស្ថិតនៅផ្តុំគ្នាទេ ដែលធ្វើឱ្យលំបាកដល់ភ្ញៀវក្នុងការប្រមូលព័ត៌មាននៃសេវាកម្មទេសចរណ៍ដែលស្របតាមចំណង់ចំណូលចិត្តរបស់ខ្លួន។ ជាលទ្ធផល ទីក្រុងនេះមិនបានក្លាយជាតំបន់ទេសចរណ៍ដ៏ទាក់ទាញសម្រាប់ភ្ញៀវទេសចរដែលមកតែម្នាក់ឯងដោយឡែកៗឡើយ។<br>• ឧកខានក្នុងការចាប់យកតម្រូវការពីភ្ញៀវដែលមិនមែនជាអ្នកទេសចរណ៍ដូចជា MICE ជាដើម។ | ៩. ត្រូវពង្រឹងការផ្សព្វផ្សាយជាទីក្រុងទេសចរណ៍ |

| | | |
|---|---|---|
| | • មធ្យោបាយធ្វើដំណើរដែលអាចរកបានសម្រាប់ភ្ញៀវទេសចរដូចជារថយន្តក្រុងទេសចរណ៍ រ៉ឺម៉កកង់បី និងរថយន្តឈ្នួលគឺមានចំនួនកំណត់នៅឡើយ។ ជាពិសេសគឺខ្វះមធ្យោបាយធ្វើដំណើរចម្ងាយផ្លូវខ្លី ដែលធ្វើឱ្យប៉ះពាល់ដល់ភាពងាយស្រួលនៃឥរិយាបថទេសចរណ៍។<br>• ដោយសារព័ត៌មានអំពីមធ្យោបាយធ្វើដំណើរផ្សេងៗមិនស្ថិតនៅប្រមូលផ្តុំ អ្នកទេសចរណ៍មិនអាចប្រៀបធៀប និងមិនមានជម្រើសមធ្យោបាយដឹកជញ្ជូនច្រើននៅនឹងកន្លែងនោះទេ។ ហេតុនេះធ្វើឱ្យមិនអាចបង្កើនប្រសិទ្ធិភាពក្នុងការផ្តល់ជម្រើសមធ្យោបាយធ្វើដំណើរដែលស្របតាមស្ថានភាពរបស់ភ្ញៀវទេសចរ។<br>• ក្នុងករណីជាច្រើន មានទទួលយកតែការទូទាត់ជាសាច់ប្រាក់សុទ្ធតែប៉ុណ្ណោះ។ នេះមិនបានផ្តល់ភាពងាយស្រួលក្នុងការចាយវាយរបស់ភ្ញៀវឡើយ។ | ១០. ត្រូវបង្កើនភាពងាយស្រួលដល់ឥរិយាបថនៃភ្ញៀវទេសចរ |
| | • នៅក្នុងតំបន់បេតិកភណ្ឌ ព័ត៌មានបន្ថែមដើម្បីបង្កើនភាពទាក់ទាញ (ដូចជាប្រវត្តិសាស្ត្រជាដើម) គឺពុំមានលក្ខណៈជាចក្ខុនិម្មិតដែលជារូបភាព ឬវីដេអូដែលអាចមើលឃើញសម្រាប់ភ្ញៀវឡើយ។<br>• សេវាកម្មទេសចរណ៍ដែលមានតម្លៃបន្ថែម (ដូចជាទិដ្ឋភាពអប់រំនៃសេវាកម្មទេសចរណ៍ ទេសចរណ៍សហគមន៍ ។ល។) មិនទាន់ត្រូវបានអភិវឌ្ឍឱ្យបានគ្រប់គ្រាន់នៅឡើយ។<br>• ទោះបីជាផ្នែកខ្លះនៃទីក្រុង ដូចជាទេសភាពផ្លូវផាប់ស្ទ្រីត មានសក្តានុពលជាកន្លែងទេសចរណ៍ក៏ដោយ ក៏កន្លែងផ្សេងៗទៀតនៃទីក្រុងមិនទាន់ត្រូវបានប្រើប្រាស់ពេញលេញដើម្បីទាក់ទាញទេសចរណ៍នៅឡើយ។ | ១១. ត្រូវបង្កើនភាពទាក់ទាញនៃបទពិសោធន៍ក្នុងស្រុកនៅតាមកន្លែងទាក់ទាញទេសចរណ៍នានា |
| ការចល័ត | • មានការកកស្ទះចរាចរណ៍ ហើយហានិភ័យនៃគ្រោះថ្នាក់ចរាចរណ៍មានការកើនឡើងដោយសារសញ្ញាចរាចរណ៍ និងការកំណត់ទិសនាសម្ព័ន្ធផ្លូវបំបែកមិនទាន់បានសមរម្យ។<br>• អ្នកថ្មើរជើងពុំសូវមានភាពងាយស្រួល និងសុវត្ថិភាពដោយសារមានការចតនៅលើចិញ្ចើមផ្លូវ និងផ្លូវថ្មើរជើង។ | ១២. ត្រូវការភាពងាយស្រួលដោយគ្មានការកកស្ទះចរាចរណ៍ និងការចតនៅតាមដងផ្លូវ |
| | • ផែនការជួសជុលថែទាំផ្លូវមានស្រាប់រួចហើយ ប៉ុន្តែថវិកាសម្រាប់ថែទាំពុំទាន់គ្រប់គ្រាន់នោះទេ។<br>• ប្រព័ន្ធថែទាំផ្លូវដែលគិតពីថ្លៃចំណាយក្នុងមួយវដ្តជីវិតនៃផ្លូវមិនត្រូវបានអនុវត្តទេ ដោយសារមិនទាន់មានដាក់ឱ្យប្រើនូវប្រព័ន្ធគ្រប់គ្រងផ្លូវគ្រប់គ្រាន់នៅឡើយ។ | ១៣. ត្រូវការការជួសជុលថែទាំផ្លូវដែលប្រសើរឡើង |
| | • ការបញ្ចេញឧស្ម័នច្រើនពីយានជំនិះចាស់ៗបានបង្កឱ្យមានការបំពុលបរិយាកាស និងការធ្លាក់ចុះនូវផាសុកភាពរបស់ភ្ញៀវទេសចរ និងគុណភាពជីវិតរបស់ប្រជាពលរដ្ឋ។ | ១៤. ត្រូវការខ្យល់អាកាសបរិសុទ្ធ និងការចល័តដែលមិនប៉ះពាល់ដល់បរិស្ថាន |
| សន្តិសុខ | • អត្រាបទល្មើស មានកម្រិតទាប (បើធៀបនឹងទីក្រុងភ្នំពេញ) ប៉ុន្តែភ្ញៀវទេសចរអន្តរជាតិត្រូវបានគេណែនាំឱ្យចាត់វិធានការប្រុងប្រយ័ត្នចំពោះបទល្មើស។<br>• ត្រូវបង្កើនប្រសិទ្ធភាពក្នុងការទប់ស្កាត់បទល្មើស និងការកំណត់មុខសញ្ញាបទល្មើស។<br>• ចាំបាច់ត្រូវធ្វើឱ្យប្រសើរឡើងនូវការបង្ការ និងការកំណត់មុខសញ្ញានៃការបើកបរដែលប្រកបដោយគ្រោះថ្នាក់។ | ១៥. ត្រូវការសុវត្ថិភាពបន្ថែមដោយជៀសផុតហានិភ័យនៃគ្រោះថ្នាក់ចរាចរណ៍ និងបទល្មើស |

| | | |
|---|---|---|
| | • ចាំបាច់ត្រូវមានបរិក្ខារ និងប្រព័ន្ធកំណត់មុខសញ្ញាអគ្គិភ័យទាន់ពេល និងការពន្លត់អគ្គិភ័យដោយប្រជាពលរដ្ឋ និងបុគ្គលិកមុនពេលភ្នាក់ងារពន្លត់អគ្គិភ័យដ្មេមកដល់។<br>• ចាំបាច់ត្រូវធ្វើឱ្យប្រសើរឡើងនូវប្រព័ន្ធប្រកាសអាសន្នជូនប្រជាពលរដ្ឋ និងភ្ញៀវទេសចរ។ | ១៦. ត្រូវការសុវត្ថិភាពបន្ថែមទៀតទល់នឹងគ្រោះមហន្តរាយនានា (ដូចជាអគ្គិភ័យ ទឹកជំនន់។ល។) |
| កាកសំណល់ | • អាកប្បកិរិយារបស់ប្រជាពលរដ្ឋ និងភ្ញៀវទេសចរចំពោះការចោលសំរាម និងទឹកកខ្វក់កំពុងប៉ះពាល់បរិស្ថាន។ [សំណល់រឹង ទឹកស្អុយ] | ១៧. ត្រូវការការអប់រំដែលឈានទៅរកសកម្មភាពដែលប្រកបដោយភាតរបរិស្ថាន |
| | • ការបែងចែកការទទួលខុសត្រូវក្នុងចំណោមស្ថាប័នពាក់ព័ន្ធ គឺពុំទាន់ច្បាស់លាស់។ ជាលទ្ធផល ប្រតិបត្តិការគ្រប់គ្រងកាកសំណល់របស់ក្រុមហ៊ុនឯកជន (រួមទាំងទិន្នន័យមូលដ្ឋាន ដូចជាចំនួនសំរាមដែលប្រមូលបាន និងចំនួនគ្រួសារដែលបានចុះកិច្ចសន្យា) មិនត្រូវបានត្រួតពិនិត្យពេញលេញដោយវិស័យសាធារណៈនោះទេ។ [កាកសំណល់រឹង]<br>• សមត្ថភាពរបស់វិស័យសាធារណៈក្នុងការគ្រប់គ្រង និងត្រួតពិនិត្យប្រតិបត្តិការគ្រប់គ្រងសំរាមនៅខ្វះខាតនៅឡើយ។ [កាកសំណល់រឹង]<br>• ប្រព័ន្ធប្រមូលប្រាក់មិនទាន់ត្រូវបានបង្កើតឡើងប្រកបដោយប្រសិទ្ធភាពនៅឡើយ ហើយប្រតិបត្តិការក៏មិនទាន់មាននិរន្តរភាពដែរ។ [សំណល់រឹង ទឹកស្អុយ] | ១៨. តម្រូវការសម្រាប់ការអនុវត្តគំនិតផ្តួចផ្តើមសាធារណៈ |
| | • បរិស្ថាននៃកន្លែងចាក់សំរាមគឺគ្មានអនាម័យ។ [កាកសំណល់រឹង]<br>• សមត្ថភាពរបស់រោងចក្រប្រព្រឹត្តិកម្មទឹកកខ្វក់នៅមិនទាន់គ្រប់គ្រាន់សម្រាប់ទឹកកខ្វក់នាពេលអនាគត។ [ទឹកស្អុយ] | ១៩. មានតម្រូវការបន្ថែមលើការកសាងហេដ្ឋារចនាសម្ព័ន្ធ |

## ៣.៣ សេចក្តីសង្ខេបនៃបញ្ហាប្រឈមនៅខេត្តសៀមរាប

ផ្អែកលើបញ្ហាទាំងឡាយខាងលើ បញ្ហានៃការគ្រប់គ្រងរដ្ឋបាល និងបញ្ហាប្រតិបត្តិការរដ្ឋបាលខេត្តសៀមរាប ត្រូវបានសង្ខេប ហើយសរុបចំនួន ១៩ បញ្ហាសំខាន់ៗ ដូចខាងក្រោម។




រូបភាព ៣.១៖ បញ្ហាសំខាន់ៗចំនួន ១៩ នៅខេត្តសៀមរាប

# ជំពូកទី ៤: យុទ្ធសាស្ត្រ

ដើម្បីសម្រេចឱ្យបាននូវចក្ខុវិស័យ និងទស្សនទានទាំងឡាយខាងលើ មានវិធីសាស្ត្រជាយុទ្ធសាស្ត្រចំនួនពីរដែលត្រូវបានរៀបចំឡើងគឺ វិធីសាស្ត្ររដ្ឋបាល និងវិធីសាស្ត្រតាមវិស័យ។

## ៤.១ វិធីសាស្ត្ររដ្ឋបាល

"វិធីសាស្ត្ររដ្ឋបាល" មានគោលនយោបាយដែលតម្រូវឱ្យស្ថាប័នរដ្ឋជាអ្នកអនុវត្ត ដើម្បីសម្រេចបានទីក្រុងឆ្លាតវៃស្របតាមផែនទីបង្ហាញផ្លូវ។ វិធីសាស្ត្រនេះ ត្រូវបានរៀបចំដោយមានសសរស្តម្ភចំនួន ៣។ សសរស្តម្ភ "ស្ថាប័នរដ្ឋបាល" មានគោលបំណងពង្រឹងស្ថាប័នរដ្ឋបាល ដែលដើរតួនាទីសំខាន់ក្នុងការអភិវឌ្ឍទីក្រុងឆ្លាតវៃ ហើយក៏មានគោលបំណងពង្រឹងទំនាក់ទំនងរវាងភាគីពាក់ព័ន្ធដើម្បីនវានុវត្តន៍ផងដែរ។ សសរស្តម្ភ "ប្រព័ន្ធគាំទ្រអាជីវកម្ម" មានគោលបំណងធ្វើឱ្យប្រសើរឡើង នូវបរិយាកាសធុរកិច្ចក្នុងខេត្តសៀមរាប និងបញ្ជាក់ពីតួនាទីរបស់ស្ថាប័នរដ្ឋ ដើម្បីគាំទ្រអាជីវកម្មនានាដែលទាក់ទងនឹងទីក្រុងឆ្លាតវៃ។ សសរស្តម្ភ "ការគ្រប់គ្រងទិន្នន័យ" មានវិធានការ ដើម្បីលើកកម្ពស់ការប្រមូលទិន្នន័យ និងការប្រើប្រាស់ ដែលជាទិដ្ឋភាពជាមូលដ្ឋាននៃទីក្រុងឆ្លាតវៃ។

## ៤.២ វិធីសាស្ត្រតាមវិស័យ

វិធីសាស្ត្រតាមវិស័យ គឺជាវិធីសាស្ត្រដែលកំណត់ឱ្យមានវិស័យគោលដៅចំនួនបួន ដូចជា វិស័យទេសចរណ៍ឆ្លាតវៃ (SMART TOURISM) វិស័យធ្វើដំណើរ និងដឹកជញ្ជូនឆ្លាតវៃ (SMART MOBILITY) វិស័យសន្តិសុខ និងសុវត្ថិភាពឆ្លាតវៃ (SMART SECURITY AND SAFETY) និង ការគ្រប់គ្រងកាកសំណល់ឆ្លាតវៃ (SMART WASTE MANAGEMENT)។ វិស័យនីមួយៗ បានកំណត់នូវគោលនយោបាយមូលដ្ឋាន និងវិធាន ដើម្បីសម្រេចឱ្យបានគោលនយោបាយមូលដ្ឋាននោះគឺ ទិសដៅនៃវិធានការ និងសកម្មភាពរយៈពេលខ្លី។ ផែនទីបង្ហាញផ្លូវនេះ គឺផ្អែកលើវិស័យសំខាន់ៗទាំងបួនដែលជាលទ្ធផលទទួលបានពីការវិភាគអំពីបញ្ហាទីក្រុង។ ដោយឡែកវិស័យអប់រំ វិស័យសុខាភិបាល និងវិស័យផ្សេងៗទៀតនឹងត្រូវបានបញ្ចូលទៅក្នុងផែនទីបង្ហាញផ្លូវនេះនាពេលអនាគតទៅតាមតម្រូវការជាក់ស្តែង។

## ៤.៣ រចនាសម្ព័ន្ធនៃការអនុវត្ត

ដើម្បីលើកកម្ពស់ផែនទីបង្ហាញផ្លូវទីក្រុងឆ្លាតវៃ តួនាទី និងយន្តការសហការរបស់ភាគីពាក់ព័ន្ធ (តួអង្គ)ចំនួនបួន រួមមាន វិស័យឯកជន (សហគ្រាសអាជីវកម្ម) វិស័យសាធារណៈ (រាជរដ្ឋាភិបាល)

ស្ថាប័នសិក្សាធិការ (សាកលវិទ្យាល័យ និងវិទ្យាស្ថាន) និងសហគមន៍ (ប្រជាពលរដ្ឋ និងភ្ញៀវទេសចរ) ត្រូវបានពិពណ៌នាដូចខាងក្រោម៖

- វិស័យឯកជន៖ ជាតួអង្គសំខាន់ក្នុងការអនុវត្តសកម្មភាព និងគម្រោងនៃទីក្រុងឆ្លាតវៃ គឺមានន័យថាជាអ្នកផ្តល់សេវាកម្ម។ តួអង្គនេះរួមចំណែកដល់ការកែលម្អសេវាកម្មទីក្រុង និងការអភិវឌ្ឍប្រកបដោយចីរភាពតាមរយៈប្រតិបត្តិការអាជីវកម្មដើម្បីទទួលបានប្រាក់ចំណេញ។
- រាជរដ្ឋាភិបាល៖ ជាអ្នកសម្របសម្រួលដំណើរការទាំងមូល រួមទាំងការបង្កើតគោលនយោបាយ និងច្បាប់ ការធ្វើផែនការ និងការអនុវត្តគម្រោង។ ស្ថាប័ននេះ បង្កើត និងដំណើរការវេទិកាទីក្រុងឆ្លាតវៃសម្រាប់កិច្ចសហការរវាងភាគីពាក់ព័ន្ធ។
- សាកលវិទ្យាល័យ និងវិទ្យាស្ថាន៖ ជាអ្នកលើកកម្ពស់ការស្រាវជ្រាវ និងការអភិវឌ្ឍបច្ចេកវិទ្យាឆ្លាតវៃ ការអនុវត្តគម្រោង និងការត្រួតពិនិត្យដោយសហការជាមួយវិស័យឯកជន និងសហការជាមួយស្ថាប័នសិក្សាក្នុងស្រុក និងអន្តរជាតិ។
- ប្រជាពលរដ្ឋ និងភ្ញៀវទេសចរ៖ គឺជាអ្នកទទួលផលពីការកែលម្អបរិស្ថានទីក្រុង ក៏ដូចជាអ្នកផ្តល់សេវាដ៏មានសក្តានុពលសម្រាប់ការគ្រប់គ្រងបរិស្ថានទីក្រុង និងការគ្រប់គ្រងតំបន់។




**រូបភាព ៤.១៖ យន្តការសហការក្នុងចំណោមភាគីពាក់ព័ន្ធ**

## ៤.៤ វិធីសាស្ត្រ

នៅក្នុងប្រភេទវិធីសាស្ត្រនីមួយៗខាងលើនេះ មានបង្ហាញពីគោលនយោបាយមូលដ្ឋាន ទិសដៅនៃវិធានការ និងសកម្មភាពរយៈពេលខ្លី។ ទិសដៅរួមគឺដើម្បីទាញយកប្រភេទព័ត៌មានផ្សេងៗ និងបញ្ចូលព័ត៌មានទាំងនោះទៅក្នុងសំណុំទិន្នន័យចាំបាច់ បង្កើតប្រព័ន្ធមួយដើម្បីដំណើរការទីក្រុងឆ្លាតវៃក្នុងវិធីសាស្ត្ររដ្ឋបាល( យុទ្ធសាស្ត្រប្រតិបត្តិការ) និងអនុវត្តគំនិតផ្តួចផ្តើមក្នុងវិស័យជាក់លាក់។ គំនិតផ្តួចផ្តើមក្នុងវិស័យនេះ នឹងក្លាយជាជំហានដើម្បីសម្រេចបាននូវគោលដៅ "សៀមរាបឆ្លាតវៃ" នៃសុខុមាលភាព ការពេញចិត្តរបស់ភ្ញៀវទេសចរ និងការលើកកម្ពស់អាជីវកម្ម។

ម៉្យាងវិញទៀត ដោយសារវិធីសាស្ត្ររដ្ឋបាល និងវិធីសាស្ត្រតាមវិស័យនឹងត្រូវបានរៀបចំ និងផ្សារភ្ជាប់គ្នាក្នុងអំឡុងពេលនៃការអនុវត្ត វិធីសាស្ត្រទាំងនេះនឹងមានភាពចាំបាច់ដើម្បីឆ្លុះបញ្ចាំងពីបទពិសោធន៍នៃវិធីសាស្ត្រនីមួយៗរវាងគ្នាទៅវិញទៅមក ដើម្បីអោយកាន់តែប្រសើរឡើង។




**រូបភាពទី ៤.២៖ ទំនាក់ទំនងរវាងទិន្នន័យ ចក្ខុវិស័យ និងវិធីសាស្ត្រ**

## ៤.៥ ទិដ្ឋភាពរួមនៃផែនទីបង្ហាញផ្លូវទីក្រុងឆ្លាតវៃ នៃខេត្តសៀមរាប

រូបភាពរួមនៃផែនទីបង្ហាញផ្លូវទីក្រុងឆ្លាតវៃ នៃខេត្តសៀមរាប មានបង្ហាញក្នុងរូបភាពខាងក្រោម៖




**រូបភាព ៤.៣៖ រូបភាពរួមនៃផែនទីបង្ហាញផ្លូវសៀមរាបឆ្លាតវៃ[3]**

3 ផែនទីបង្ហាញផ្លូវនេះគឺផ្តោតលើវិស័យទាំងបួនដែលត្រូវបានចាត់ទុកថាមានសារៈសំខាន់ជាលទ្ធផលនៃការវិភាគអំពីបញ្ហាទីក្រុង ក៏ប៉ុន្តែវិស័យអប់រំ វិស័យសុខាភិបាល និងវិស័យផ្សេងៗទៀតនឹងត្រូវបានបញ្ចូលទៅក្នុងផែនទីបង្ហាញផ្លូវនេះនាពេលអនាគត ទៅតាមតម្រូវការជាក់ស្តែង។

# ជំពូកទី ៥: គោលនយោបាយមូលដ្ឋាន និងទិសដៅនៃវិធានការ នៃវិធីសាស្ត្ររដ្ឋបាល

## ៥.១ គោលនយោបាយមូលដ្ឋាន និងទិសដៅនៃវិធានការ

វិធីសាស្ត្ររដ្ឋបាលមានសសរស្តម្ភចំនួនបីគឺៈ "ស្ថាប័នរដ្ឋបាល" "ប្រព័ន្ធច្បាប់ និងការគាំទ្រអាជីវកម្ម" និង "ការគ្រប់គ្រងទិន្នន័យ"។ សសរស្តម្ភទាំងបីនេះនឹងក្លាយជាមូលដ្ឋានគ្រឹះសម្រាប់ការអនុវត្តវិធីសាស្ត្រតាមវិស័យ និងការសម្រេចបាននូវទីក្រុងឆ្លាតវៃ។ កិច្ចការទាំងនេះ នឹងត្រូវបានជំរុញដោយស្ថាប័នរាជរដ្ឋាភិបាល ខណៈពេលដែលមានការចូលរួមយ៉ាងសកម្មពីគ្រឹះស្ថានសិក្សា និងស្ថាប័នឯកជន។

## ៥.២ ស្ថាប័នរដ្ឋបាល

វិធីសាស្ត្រជាមូលដ្ឋានសម្រាប់ស្ថាប័នរដ្ឋបាលគឺ "កិច្ចសហប្រតិបត្តិការបើកចំហ"បន្ថែមទៀត។ ឈរលើមូលដ្ឋាននោះ យើងបានកំណត់ទិសដៅវិធានការពីរគឺ "ការកសាងប្រព័ន្ធកិច្ចសហប្រតិបត្តិការរវាងវិស័យឯកជន-វិស័យសាធារណៈ-ស្ថាប័នសិក្សាធិការ" និង "ការចូលរួមពីភាគីពាក់ព័ន្ធផ្សេងៗទៀត"។




នៅក្នុងស្ថាប័នរដ្ឋបាល មានគោលដៅសម្រាប់ការធ្វើកិច្ចសហការរវាងវិស័យឯកជន-វិស័យសាធារណៈ-ស្ថាប័នសិក្សាធិការ-សហគមន៍ ការចែករំលែកព័ត៌មាន និងកិច្ចសហប្រតិបត្តិការរវាងពហុស្ថាប័នរដ្ឋបាល។ ដើម្បីលើកកម្ពស់កិច្ចសហប្រតិបត្តិការរវាងវិស័យឯកជន-វិស័យសាធារណៈ-ស្ថាប័នសិក្សាធិការ-សហគមន៍ ទាមទារឱ្យមានការរៀបចំវេទិកាមួយ ដើម្បីបង្កើតឱកាសឱ្យមានការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធក្នុងការចែករំលែកព័ត៌មាន និងផ្លាស់ប្តូរយោបល់ អំពីផែនទីបង្ហាញផ្លូវ និងការអភិវឌ្ឍអាជីវកម្ម ដើម្បីសម្រេចបាននូវចក្ខុវិស័យ តាមរយៈការប្រមូលផ្តុំនៅវេទិកាសហការរវាងវិស័យឯកជន-វិស័យសាធារណៈ-ស្ថាប័នសិក្សាធិការ-សហគមន៍។ គេរំពឹងថានវានុវត្តន៍បើកចំហ នឹងត្រូវទទួលបានតាមរយៈការរៀបចំវេទិកាបែបនេះ។ នៅក្នុងស្ថាប័នរដ្ឋបាល ដើម្បីពង្រឹងរចនាសម្ព័ន្ធអង្គភាពនៃរដ្ឋបាលដែលសម្របសម្រួលការចែករំលែកព័ត៌មាន និងកិច្ចសហប្រតិបត្តិការរវាងពហុស្ថាប័នរដ្ឋបាល ត្រូវធ្វើការរៀបចំគណៈកម្មាធិការទីក្រុងឆ្លាតវៃពហុស្ថាប័ន និងការបង្កើតអង្គភាពអនុវត្ត (ទីចាត់ការទីក្រុងឆ្លាតវៃ)ដែលដើរតួនាទីស្នូលក្នុងការគ្រប់គ្រង។

ដើម្បីឆ្លើយតបទៅនឹងបញ្ហាប្រឈម ទិសដៅនៃវិធានការ និងសកម្មភាពរយៈពេលខ្លីត្រូវបានបង្ហាញក្នុងតារាងខាងក្រោម៖

**តារាង៥.១៖ បញ្ហាប្រឈម ទិសដៅនៃវិធានការ សកម្មភាពរយៈពេលខ្លី នៅក្នុងស្ថាប័នរដ្ឋបាល**

| បញ្ហាប្រឈម | ទិសដៅនៃវិធានការ | សកម្មភាពរយៈពេលខ្លី |
|---|---|---|
| ១. មានតម្រូវការរចនាសម្ព័ន្ធអង្គភាពរដ្ឋបាលសម្រាប់ការសហការឆ្លងវិស័យ<br>→គណៈកម្មាធិការទីក្រុងឆ្លាតវៃនេះមិនទាន់ដាក់បញ្ចូលអង្គភាពសំខាន់ៗដូចជាអាជ្ញាធរជាតិអប្សរា មន្ទីរទេសចរណ៍ និងស្នងការនគរបាលខេត្តនៅឡើយទេ<br>→គណៈកម្មាធិការទីក្រុងឆ្លាតវៃមិនទាន់ពិភាក្សាអំពីគម្រោងជាក់លាក់នៅឡើយ | ~"រចនាសម្ព័ន្ធពហុស្ថាប័នរដ្ឋបាល" ធ្វើការរួមគ្នាជាមួយរាជរដ្ឋាភិបាល ដើម្បីដោះស្រាយបញ្ហាទីក្រុងឆ្លាតវៃដែលស្ថាប័នតែមួយមិនអាចសម្រេចបាន~ | • ការពង្រីកមុខងារ និងប្រតិបត្តិការនៃគណៈកម្មាធិការទីក្រុងឆ្លាតវៃ<br>• ការបង្កើតថ្មីនៃទីចាត់ការទីក្រុងឆ្លាតវៃ |
| ២. មានតម្រូវការទីចាត់ការទីក្រុងឆ្លាតវៃ។<br>→រដ្ឋបាលខេត្តមិនមានមុខងារផ្សព្វផ្សាយគម្រោងទាក់ទងនឹងទីក្រុងឆ្លាតវៃទេ។ | | |
| ៣. មានតម្រូវការស្ថាប័នជាមូលដ្ឋាននៃសហប្រតិបត្តិការពហុភាគី<br>→ការពិភាក្សា និងការសម្របសម្រួលរវាងគណៈកម្មាធិការទីក្រុងឆ្លាតវៃ និងវិស័យឯកជនមិនទាន់បានធ្វើឡើងនៅឡើយ<br>→គ្មានគម្រោង ឬសកម្មភាពស្រាវជ្រាវណាមួយត្រូវបានគេមើលឃើញតាមរយៈកិច្ចសហការយ៉ាងសកម្មរវាងវិស័យសាធារណៈ និងវិស័យសិក្សានៅឡើយ | "ការកសាងប្រព័ន្ធសហការរវាងវិស័យឯកជន -វិស័យសាធារណៈ -ស្ថាប័នសិក្សាធិការ -សហគមន៍"<br>~ជំរុញនវានុវត្តន៍ការច្នៃប្រឌិតរួមគ្នា ដើម្បីធ្វើបច្ចុប្បន្នភាពបច្ចេកវិទ្យានវានុវត្តន៍ជាប្រចាំ~ | • ការរៀបចំ និងប្រតិបត្តិការនៃវេទិកាសហការរវាងវិស័យឯកជន -វិស័យសាធារណៈ -ស្ថាប័នសិក្សាធិការ -សហគមន៍ |

ប្រភព៖ ក្រុមសិក្សា JICA

## ៥.៣ ប្រព័ន្ធច្បាប់ និងការគាំទ្រអាជីវកម្ម

គោលនយោបាយមូលដ្ឋានសម្រាប់ប្រព័ន្ធច្បាប់ និងការគាំទ្រអាជីវកម្មគឺ "ការជំរុញអាជីវកម្មឆ្លាតវៃ"។ ដើម្បីសម្រេចបានគោលនយោបាយមូលដ្ឋាននេះ ទាមទារអោយមានការកំណត់ទិសដៅនៃវិធានការចំនួនពីរគឺ "ការកែលម្អបរិយាកាសអាជីវកម្ម" និង "ការពង្រឹងមុខងារគាំទ្រអាជីវកម្ម"។




អាជីវកម្មឆ្លាតវៃ ឬអាជីវកម្មទីក្រុងឆ្លាតវៃ ត្រូវបានកំណត់យ៉ាងទូលំទូលាយថាជាអាជីវកម្មពហុវិស័យជាវិស័យថ្មី ឬអាជីវកម្មដែលប្រើប្រាស់ទិន្នន័យជាទំនិញ។ ចំពោះប្រព័ន្ធច្បាប់ និងការគាំទ្រអាជីវកម្ម

វិស័យសាធារណៈត្រូវគាំទ្រធុរកិច្ចសម្រាប់អាជីវកម្មឯកជន ដើម្បីលើកកម្ពស់ការបង្កើតអាជីវកម្មថ្មីៗទាក់ទងនឹងបច្ចេកវិទ្យាឆ្លាតវៃ។ ការបង្កើតប្រព័ន្ធអេកូឡូស៊ីសម្រាប់អាជីវកម្មឯកជនដែលបង្កើតថ្មីគឺជាចំណុចស្នូលនៃប្រព័ន្ធច្បាប់ និងការគាំទ្រអាជីវកម្ម។ វាក៏ចាំបាច់ផងដែរក្នុងការបង្កើតសេវាកម្មច្រកចេញចូលតែមួយនៅក្នុងរាជរដ្ឋាភិបាល និងធ្វើនិយ័តកម្មនានា ដើម្បីជួយសម្រួលដល់អាជីវកម្មឯកជន។ លើសពីនេះ ការជំរុញនូវការអនុវត្តគម្រោងសាកល្បង (Proof of Concept) ក៏ជាវិធីសាស្ត្រដ៏សំខាន់មួយ ហើយវាមានប្រសិទ្ធភាពក្នុងការបង្កើតឱកាស និងទីកន្លែងដែលងាយស្រួលសម្រាប់ការអនុវត្ត POC។ ដើម្បីទាក់ទាញដល់ប្រជាពលរដ្ឋ និងលើកកម្ពស់ការយល់ដឹងរបស់ពួកគាត់ គេអាចកំណត់យកតំបន់អាទិភាពដែលនឹងធ្វើជាឧទាហរណ៍គំរូក្នុងការបង្កើតទៅជាកន្លែងលក់ទំនិញផ្សេងៗ ដូចជាតំបន់ផាប់ស្ទ្រីត និងកន្លែងផ្សេងៗទៀតនៅកណ្ដាលក្រុងជាដើម។

ដើម្បីឆ្លើយតបទៅនឹងបញ្ហាប្រឈម ទិសដៅនៃវិធានការ និងសកម្មភាពរយៈពេលខ្លីត្រូវបានបង្ហាញក្នុងតារាងខាងក្រោម៖

**តារាង ៥.២៖ បញ្ហាប្រឈម ទិសដៅនៃវិធានការ សកម្មភាពរយៈពេលខ្លី ក្នុងប្រព័ន្ធច្បាប់ និងការគាំទ្រអាជីវកម្ម**

| បញ្ហាប្រឈម | ទិសដៅនៃវិធានការ | សកម្មភាពរយៈពេលខ្លី |
|---|---|---|
| ៤. នីតិវិធីស្មុគស្មាញទាក់ទងនឹងការអនុវត្តគម្រោងព័ត៌មានស្ដីពីច្បាប់ និងប្រព័ន្ធដែលពាក់ព័ន្ធមិនត្រូវបានប្រមូលផ្តុំ។នីតិវិធីរបស់ប្រព័ន្ធមិនច្បាស់លាស់សម្រាប់អាជីវកម្មអន្តរវិស័យ និងអាជីវកម្មក្នុងវិស័យថ្មី | "ការបង្កើនប្រសិទ្ធភាពក្នុងការធ្វើអាជីវកម្ម" ~រាជរដ្ឋាភិបាលគាំទ្រយ៉ាងសកម្មនូវអាជីវកម្មឆ្លាតវៃរបស់ឯកជន~ | • ការកែលម្អបរិយាកាសអាជីវកម្មសម្រាប់អាជីវកម្មឯកជន |
| ៥. សកម្មភាពចូលរួមពីវិស័យឯកជនមិនទាន់គ្រប់គ្រាន់ដើម្បីលើកកម្ពស់អាជីវកម្មទីក្រុងឆ្លាតវៃ: ខ្វះការទាក់ទាញវិស័យឯកជនក្នុងការចូលរួមចំណែកផ្តល់សេវាសាធារណៈដែលរដ្ឋពុំទាន់មានលទ្ធភាពក្នុងការផ្តល់ជូនប្រជាពលរដ្ឋ | "ការពង្រឹងមុខងារគាំទ្រ" ~រដ្ឋបាលនឹងទាក់ទាញ និងជំរុញអាជីវកម្មថ្មីៗយ៉ាងសកម្ម~ | • ការគាំទ្រអាជីវកម្មឯកជនដើម្បីចូលរួមចំណែកផ្តល់សេវាសាធារណៈ |

ប្រភព៖ ក្រុមសិក្សា JICA

ដើម្បីដោះស្រាយបញ្ហាខាងលើនេះ ចាំបាច់ត្រូវចាត់វិធានការពង្រឹងសមត្ថភាពជាដំណាក់កាល ដូចជារៀបចំរចនាសម្ព័ន្ធអង្គភាព ការកែលម្អប្រព័ន្ធ និងការត្រួតពិនិត្យផ្ទៀងផ្ទាត់តាមរយៈការបង្ហាញជាបទពិសោធន៍ និងការជំរុញផ្សព្វផ្សាយគម្រោងផ្សេងៗទៀត។

## តារាង ៥.៣៖ ផែនការសកម្មភាពក្នុងការអភិវឌ្ឍសមត្ថភាព

| ដំណាក់កាល | គោលនយោបាយមូលដ្ឋាន | វិធានការដែលត្រូវអនុវត្ត |
|---|---|---|
| ជំហានទី១ | ជំរុញការអនុវត្តគម្រោងក្នុងយន្តការដែលមានស្រាប់ | • រៀបចំយន្តការច្រកចេញចូលតែមួយសម្រាប់អនុវត្តទីក្រុងឆ្លាតវៃ (ចាត់តាំងទីចាត់ការដែលមានស្រាប់នៅក្នុងរដ្ឋបាលខេត្ត ) និងនីតិវិធីផ្តល់អាជ្ញាប័ណ្ណ<br>• ការចែករំលែកព័ត៌មានគម្រោង និងការគាំទ្រការអនុម័តសម្រាប់គម្រោងខ្នាតធំនៅក្នុងគណៈកម្មាធិការទីក្រុងឆ្លាតវៃដែលមានស្រាប់ |
| ជំហានទី២ | ការបង្កើត និងដំណើរការវេទិកាដោយគណៈកម្មាធិការទីក្រុងឆ្លាតវៃ និងការបង្កើនប្រាក់ចំណូលសាធារណៈតាមរយៈបច្ចេកវិទ្យាឆ្លាតវៃ ដោយវិស័យឯកជន និងថ្នាលទិន្នន័យ | • ការជំរុញការវិនិយោគឯកជនតាមរយៈសកម្មភាពវេទិកា<br>• ការបង្កើតការឧបត្ថម្ភធនទីក្រុងឆ្លាតវៃ របស់រាជរដ្ឋាភិបាលនិងរដ្ឋបាលខេត្ត<br>• ការបង្កើតមូលនិធិអភិវឌ្ឍន៍ទេសចរណ៍ (មូលនិធិឯកជន មូលនិធិសប្បុរសធម៌ ការរៃអង្គាសប្រាក់ពីភ្ញៀវទេសចរ។ល។)<br>• ការអភិវឌ្ឍប្រព័ន្ធច្បាប់ចាំបាច់សម្រាប់ការអនុវត្តទីក្រុងឆ្លាតវៃ |
| ជំហានទី៣ | បង្កើត "អង្គភាពគ្រប់គ្រងទីក្រុងឆ្លាតវៃ និងគ្រប់គ្រងតំបន់" ដើម្បីរកប្រាក់ចំណូលតាមរយៈថ្នាលទិន្នន័យ | • ការបង្កើត SPC និង/ឬSPV ដោយវិស័យឯកជន និងសហគមន៍<br>• កិច្ចសហប្រតិបត្តិការរវាងវិស័យសាធារណៈ និង SPC/SPV សម្រាប់ថ្នាលទិន្នន័យ |

ប្រភព៖ ក្រុមសិក្សា JICA

## ៥.៤ ការគ្រប់គ្រងទិន្នន័យ

គោលនយោបាយមូលដ្ឋានសម្រាប់ការគ្រប់គ្រងទិន្នន័យ គឺ "**ការប្រើប្រាស់ទិន្នន័យដ៏មានតម្លៃប្រកបដោយប្រយោជន៍**"។ ដើម្បីសម្រេចបានគោលនយោបាយមូលដ្ឋាននេះ ទាមទារអោយមានការកំណត់ទិសដៅនៃវិធានការចំនួនពីរគឺ "**ការអភិវឌ្ឍថ្នាលទិន្នន័យ**" និង "**ការលើកកម្ពស់ទិន្នន័យចំហ (OPEN DATA)**"។




ក្នុងការគ្រប់គ្រងទិន្នន័យ មានសារៈសំខាន់ណាស់ក្នុងការកសាងយន្តការមួយដើម្បីប្រមូល និងចែករំលែកទិន្នន័យជាមួយអ្នកពាក់ព័ន្ធគ្រប់វិស័យ ដើម្បីទាក់ទាញនូវនវានុវត្តន៍ និងបង្កើត និងកែលម្អសេវាកម្មទីក្រុងថ្មីៗ។ ដូច្នេះមានការទាមទារនូវកិច្ចខិតខំប្រឹងប្រែងក្នុងការបង្កើតវេទិកាមួយដែលគ្រប់គ្រងនូវទិន្នន័យដែលបានស្រង់ចេញពីគម្រោងផ្សេងៗ ប្រព័ន្ធដែលបង្ហាញទិន្នន័យដែលគិតគូរអំពីឯកជនភាព។

ដើម្បីឆ្លើយតបទៅនឹងបញ្ហាប្រឈម ទិសដៅនៃវិធានការ និងសកម្មភាពរយៈពេលខ្លី ត្រូវបានបង្ហាញក្នុងតារាងខាងក្រោម។

**តារាង ៥.៤៖ បញ្ហាប្រឈម ទិសដៅនៃវិធានការ សកម្មភាពរយៈពេលខ្លី ក្នុងការគ្រប់គ្រងទិន្នន័យ**

| បញ្ហាប្រឈម | ទិសដៅនៃវិធានការ | សកម្មភាពរយៈពេលខ្លី |
|---|---|---|
| ៦. មិនទាន់បានអភិវឌ្ឍនូវផ្នែករឹងសម្រាប់គ្រប់គ្រងទិន្នន័យ និងហេដ្ឋារចនាសម្ព័ន្ធទំនាក់ទំនង<br>→ហេដ្ឋារចនាសម្ព័ន្ធរឹងមិនគ្រប់គ្រាន់សម្រាប់ការគ្រប់គ្រងទិន្នន័យ ដូចជាម៉ាស៊ីនមេជាដើម | "ការអភិវឌ្ឍថ្នាលទិន្នន័យ"<br>~បង្កើតមុខងារប្រតិបត្តិការមួយនៅពេលអនាគត ដើម្បីសម្រេចនូវការបង្កើនប្រសិទ្ធភាពរួម~ | • ការប្រមូល និងការផ្ទុកទិន្នន័យរួមបញ្ចូលគ្នា (D-០១) |
| ៧. មិនទាន់មានការចែករំលែក និងប្រើប្រាស់ទិន្នន័យពហុវិស័យ<br>→ការរក្សាទុកទិន្នន័យមិនទាន់មានប្រសិទ្ធភាព<br>→បទពិសោធន៍របស់បុគ្គលិករដ្ឋបាលក្នុងការគ្រប់គ្រងទិន្នន័យនៅមានកម្រិត | | • ការប្រមូល និងការផ្ទុកទិន្នន័យរួមបញ្ចូលគ្នា (D-០១) |
| ៨. មិនទាន់មាន ប្រព័ន្ធទិន្នន័យបើកចំហ សុវត្ថិភាពទិន្នន័យ និងបទបញ្ញត្តិ<br>→ដំណើរការធ្វើសេចក្តីសម្រេចចិត្ត ទាក់ទងនឹងការចាត់ចែងព័ត៌មាន មានភាពច្របូកច្របល់ | "ការលើកកម្ពស់ទិន្នន័យចំហ (OPEN DATA)"<br>~ការលើកទឹកចិត្តដល់ការប្រើប្រាស់ទិន្នន័យដោយឥតគិតថ្លៃដោយការបង្ហាញព័ត៌មាន~ | • ការបង្ហាញទិន្នន័យដល់ភាគីពាក់ព័ន្ធ (D-០២) |

ប្រភព៖ ក្រុមសិក្សា JICA

# ជំពូកទី ៦: គោលនយោបាយមូលដ្ឋាន និងទិសដៅនៃវិធានការនៃវិធីសាស្ត្រតាមវិស័យ

## ៦.១ ទេសចរណ៍ឆ្លាតវៃ

គោលនយោបាយមូលដ្ឋានសម្រាប់ទេសចរណ៍ឆ្លាតវៃ គឺ "**ទេសចរណ៍កាន់តែមានភាពងាយស្រួល និងជាទីពេញចិត្ត**"។ ដើម្បីសម្រេចបានគោលនយោបាយមូលដ្ឋាននេះ ទាមទារអោយមានការកំណត់ទិសដៅនៃវិធានការចំនួនពីរគឺ "**ការធ្វើបច្ចុប្បន្នភាពសេវាកម្មទេសចរណ៍**" និង "**ការបំពេញតម្រូវការទេសចរណ៍**"។




ខេត្តសៀមរាប ត្រូវបានគេស្គាល់ថាជាច្រកចូលទៅកាន់តំបន់បេតិកភណ្ឌពិភពលោកនៃប្រាសាទអង្គរវត្ត ទោះបីជាខេត្តនេះត្រូវបានភ្ញៀវទេសចរជាតិ និងអន្តរជាតិ មកទស្សនាជាច្រើនក៏ដោយ ក៏ប៉ុន្តែតំបន់ផ្សេងៗក្រៅពីប្រាសាទបុរាណដូចជាតំបន់ធម្មជាតិ វប្បធម៌ ទំនាក់ទំនងរវាងប្រជាពលរដ្ឋ និងទីផ្សារជាដើម នៅមិនទាន់មានភ្ញៀវទេសចរច្រើនបានស្គាល់ ឬមានអ្នកទៅទស្សនាច្រើននៅឡើយ ដោយហេតុនេះហើយធ្វើអោយភ្ញៀវដែលមកទស្សនា ម្តងហើយ មិនត្រឡប់មកសារជាថ្មីទៀត។

ក្នុងវិស័យទេសចរណ៍ឆ្លាតវៃ ចាំបាច់ត្រូវផ្សព្វផ្សាយធនធានទេសចរណ៍ដែលមាននៅក្នុងខេត្តសៀមរាបឱ្យបានទូលំទូលាយជាពិសេសតំបន់ទេសចរណ៍ថ្មីៗដែលមានភាពទាក់ទាញ និងសម្បូរបែប។ ដូចនេះ ដើម្បីទទួលបានភ្ញៀវទេសចរយ៉ាងច្រើនសន្ធឹកសន្ធាប់នៅថ្ងៃអនាគត ខេត្តសៀមរាបចាំបាច់ត្រូវរៀបចំប្រែក្លាយតំបន់ទាំងនោះជាតំបន់ទេសចរណ៍ដ៏ទាក់ទាញបំផុត សម្បូរបែប និងប្រកបដោយផាសុកភាព សម្រាប់ដំណើរកម្សាន្តជាក្រុម ជាលក្ខណៈបុគ្គល និងប្រជាពលរដ្ឋក្នុងតំបន់។

ភ្ញៀវទេសចរ ត្រូវការនូវព័ត៌មានអំពីតំបន់ទេសចរណ៍ និងមធ្យោបាយធ្វើដំណើរដែលល្អបំផុតសម្រាប់ពួកគេដើម្បីទៅកាន់ទីនោះ។ ដូចនេះ ដើម្បីបង្កភាពងាយស្រួលដល់ភ្ញៀវទេសចរ វេទិកាដែលត្រូវបានធ្វើសមាហរណកម្ម ( E-tourism platform ) នឹងត្រូវបានប្រើប្រាស់ ដើម្បីទទួលបាននូវព័ត៌មានដែលច្បាស់លាស់ និងមានភាពងាយស្រួលសម្រាប់ភ្ញៀវទេសចរក្នុងការសម្រេចចិត្តជ្រើសរើសសកម្មភាពទាំងឡាយពាក់ព័ន្ធនឹងទេសចរណ៍ ដូចជា ការជ្រើសរើសមធ្យោបាយធ្វើដំណើរ ការប្រើប្រាស់សេវាកម្ម និងផលិតផលផ្សេងៗនៅតាមតំបន់ទេសចរណ៍នីមួយៗ ជាដើម។ ការរៀបចំយន្តការអភិវឌ្ឍ

វិស័យទេសចរណ៍បែបនេះ រំពឹងថានឹងផ្តល់ផលប្រយោជន៍ដល់អ្នកដែលធ្វើការក្នុងវិស័យទេសចរណ៍ និងវិស័យផ្សេងៗផងដែរ។

ដើម្បីឆ្លើយតបទៅនឹងបញ្ហាប្រឈម ទិសដៅនៃវិធានការ និងសកម្មភាពរយៈពេលខ្លី ត្រូវបានបង្ហាញក្នុងតារាងខាងក្រោម។

**តារាង ៦.១៖ បញ្ហាប្រឈមក្នុងវិស័យទេសចរណ៍ឆ្លាតវៃ ទិសដៅនៃវិធានការ សកម្មភាពយៈពេលខ្លី**

| បញ្ហាប្រឈម | ទិសដៅនៃវិធានការ | សកម្មភាពរយៈពេលខ្លី |
|---|---|---|
| ១០. កង្វះភាពងាយស្រួលសម្រាប់សកម្មភាពទេសចរណ៍<br>→សេវាចល័តមិនត្រូវបានផ្តល់តាមតម្រូវការរបស់ភ្ញៀវទេសចរ<br>→ក្នុងករណីខ្លះ មានតែការទូទាត់ជាសាច់ប្រាក់ប៉ុណ្ណោះ ដោយពុំមានការទូទាត់តាមប្រព័ន្ធអេឡិចត្រូនិច | "បង្កើនភាពឆ្លាតវៃក្នុងសេវាកម្មទេសចរណ៍"<br>~ផ្តល់សេវាទេសចរណ៍កាន់តែមានភាពងាយស្រួលដោយសេរី និងឆ្លាតវៃ~ | • ការផ្តោតទៅលើប្រព័ន្ធនៃការកក់និងការទូទាត់ (T-០២)<br>• ការអភិវឌ្ឍការចែករំលែកនូវសេវាចល័តរួម (T-០៣)<br>• សេវាកម្មធ្វើដំណើរទេសចរណ៍ MaaS (T-០៤)<br>• ការដាក់ឱ្យប្រើប្រាស់ប្រព័ន្ធទូទាត់អេឡិចត្រូនិកក្នុងស្រុក ដោយប្រើលេខកូដ QR (T-០៥) |
| ១១. កង្វះការផ្សព្វផ្សាយជាទីក្រុងទេសចរណ៍<br>→ព័ត៌មានទេសចរណ៍មិនបានកំណត់នូវគោលដៅជាក់លាក់ ដែលវាពិបាកក្នុងការផ្តល់សេវាកម្មទេសចរណ៍ដែលតម្រូវតាមចំណង់ចំណូលចិត្តរបស់អ្នកដំណើរជាបុគ្គល។<br>→ព័ត៌មានបន្ថែមដើម្បីធ្វើឱ្យតំបន់ទេសចរណ៍កាន់តែទាក់ទាញមិនត្រូវបានផ្តល់ឱ្យក្នុងលក្ខណៈងាយយល់ឡើយ។ | "ការបំពេញតាមតម្រូវការរបស់ភ្ញៀវទេសចរ"<br>~ជំរុញការយល់ដឹងរបស់ភ្ញៀវទេសចរអំពីធនធានទេសចរណ៍ចម្រុះដើម្បីផ្តល់នូវការពេញចិត្តដល់ភ្ញៀវទេសចរ~ | • ការអភិវឌ្ឍវេទិកាផ្សព្វផ្សាយទេសចរណ៍(T-០១)<br>• លើកកម្ពស់បទពិសោធន៍ទេសចរណ៍ក្នុងស្រុក ដោយប្រើប្រាស់បច្ចេកវិទ្យា AR (T-០៦) |

ប្រភព៖ ក្រុមសិក្សា JICA

## ៦.២ ការចល័តឆ្លាតវៃ

គោលនយោបាយមូលដ្ឋានសម្រាប់ការចល័តឆ្លាតវៃ គឺ **"ឆ្ពោះទៅរកប្រព័ន្ធចល័តប្រកបដោយនិរន្តរភាព សុវត្ថិភាព និងភាពងាយស្រួលខ្ពស់"**។ ដើម្បីសម្រេចបានគោលនយោបាយមូលដ្ឋាននេះ ទាមទារអោយមានការកំណត់ទិសដៅនៃវិធានការចំនួនពីរ គឺ **"សម្រួលចរាចរណ៍ និងលើកកម្ពស់សុវត្ថិភាព"** និង **"ការបង្កើនប្រសិទ្ធភាព និងការគិតគូរដល់បរិស្ថាន"**។



នៅក្នុងវិស័យចល័តឆ្លាតវៃ មានសារៈសំខាន់ណាស់ក្នុងការកែលម្អទិដ្ឋភាពបីគឺ ភាពងាយស្រួល សុវត្ថិភាព និងនិរន្តរភាព ដើម្បីផ្តល់នូវប្រព័ន្ធចល័តកម្រិតខ្ពស់សម្រាប់ប្រជាពលរដ្ឋ និងភ្ញៀវទេសចរ។ ដូច្នេះ តម្រូវឱ្យមានការកែលម្អ វិស័យចល័ត ដូចជា ប្រព័ន្ធដឹកជញ្ជូន ការថែទាំផ្លូវ និងយានយន្ត រួមទាំងប្រព័ន្ធគ្រប់គ្រងចំណតរថយន្ត និងការដាក់ឱ្យប្រើប្រាស់យានយន្តអគ្គិសនី។

ដើម្បីឆ្លើយតបទៅនឹងបញ្ហាប្រឈម ទិសដៅនៃវិធានការ និងសកម្មភាពរយៈពេលខ្លី ត្រូវបានបង្ហាញក្នុងតារាងខាងក្រោម។

**តារាង ៦.២៖ បញ្ហាប្រឈមក្នុងចល័តភាពឆ្លាតវៃ ទិសដៅនៃវិធានការ សកម្មភាពរយៈពេលខ្លី**

| បញ្ហាប្រឈម | ទិសដៅនៃវិធានការ | សកម្មភាពរយៈពេលខ្លី |
|---|---|---|
| ១២. បញ្ហាចរាចរណ៍ដូចជាការកកស្ទះ គ្រោះថ្នាក់ចរាចរណ៍ និងការចតរថយន្តនៅតាមដងផ្លូវ<br>→ការកកស្ទះចរាចរណ៍ និងគ្រោះថ្នាក់ចរាចរណ៍បានកើតឡើងដោយសារតែរូបរាងផ្លូវបំបែក និងភ្លើងសញ្ញាចរាចរណ៍មិនត្រឹមត្រូវ។<br>→ការចតនៅតាមផ្លូវធ្វើឱ្យប៉ះពាល់ដល់អ្នកថ្មើរជើង។ | "សម្រួលចរាចរណ៍ និងលើកកម្ពស់សុវត្ថិភាព"<br>~បង្កើតមធ្យោបាយធ្វើដំណើរប្រកបដោយសុវត្ថិភាព និងងាយស្រួលសម្រាប់ប្រជាពលរដ្ឋ~ | • ការណែនាំប្រព័ន្ធចំណតយានយន្តជាផ្លូវការ (M-០១)<br>• ការកែលម្អភ្លើងបំភ្លឺផ្លូវ (M-០៣)<br>• ការកែលម្អប្រព័ន្ធសញ្ញាចរាចរណ៍ (M-០៤)<br>• ការកែលម្អការគ្រប់គ្រងសុវត្ថិភាពចរាចរណ៍ (M-០៥) |
| ១៣. ការថែទាំផ្លូវមិនមានប្រសិទ្ធភាព<br>→ការគ្រប់គ្រងដោយផ្អែកលើការត្រួតពិនិត្យបរិមាណនៃស្ថានភាពផ្លូវមិនអាចធ្វើទៅបានឡើយ។ | "ការបង្កើនប្រសិទ្ធភាព និងការគិតគូរដល់បរិស្ថាន"<br>~ពិចារណាលើការងារការពារថែទាំផ្លូវថ្នល់ និងបរិស្ថាន~ | • ការត្រួតពិនិត្យស្ថានភាពផ្ទៃផ្លូវ (M-០២)<br>• ការណែនាំអំពីយានយន្តអគ្គិសនី (M-០៦) |
| ១៤. ការបំពុលបរិស្ថានដែលបណ្តាលមកពីចល័តភាព<br>→ការបំភាយឧស្ម័នចេញពីរថយន្តចាស់ៗគឺប៉ះពាល់ដល់គុណភាពខ្យល់។ | | |

ប្រភព៖ ក្រុមសិក្សា JICA

## ៦.៣ សន្តិសុខ និងសុវត្ថិភាពឆ្លាតវៃ

គោលនយោបាយមូលដ្ឋានសម្រាប់វិស័យសន្តិសុខ និងសុវត្ថិភាពឆ្លាតវៃ គឺ **"ឆ្ពោះទៅកាន់ទិសដៅទេសចរណ៍ដែលមានសុវត្ថិភាពខ្ពស់"**។ ដើម្បីសម្រេចបានគោលនយោបាយមូលដ្ឋាននេះ ទាមទារឱ្យមានការកំណត់ទិសដៅនៃវិធានការចំនួនពីរគឺ **"ការកាត់បន្ថយបទល្មើស និងគ្រោះថ្នាក់ចរាចរណ៍"** និង **"ការឆ្លើយតបទៅនឹងគ្រោះធម្មជាតិ"**។



ពាក់ព័ន្ធទៅនឹងវិស័យសន្តិសុខ សុវត្ថិភាពសម្រាប់ភ្ញៀវទេសចរ ខេត្តសៀមរាបមានការទទួលស្គាល់ក្នុងកម្រិតដែលភ្ញៀវទេសចរអាចទទួលយកបានហើយ ទៅលើតម្រូវការសន្តិសុខ សុវត្ថិភាពជាមូលដ្ឋាន ប៉ុន្តែក្នុងនាមជាទីក្រុងទេសចរណ៍លំដាប់អន្តរជាតិ ស្តង់ដារសន្តិសុខសុវត្ថិភាពគឺនៅមិនទាន់គ្រប់គ្រាន់នៅឡើយ ដែលធ្វើឱ្យភ្ញៀវទេសចរត្រូវធ្វើមានការប្រុងប្រយ័ត្នការពារសន្តិសុខ និងសុវត្ថិភាពដោយខ្លួនឯង។ ដូច្នេះ ខេត្តសៀមរាប ត្រូវពង្រឹងសន្តិសុខមូលដ្ឋានអោយក្លាយជាទីក្រុងទេសចរណ៍អន្តរជាតិប្រកបដោយសន្តិសុខ សុវត្ថិភាពខ្ពស់ ដែលធ្វើឱ្យភ្ញៀវទេសចរកាន់តែមានអារម្មណ៍កក់ក្តៅខ្លាំងឡើង នៅពេលដែលពួកគាត់មកទស្សនាខេត្តសៀមរាប។

ដើម្បីឆ្លើយតបទៅនឹងបញ្ហាប្រឈម ទិសដៅនៃវិធានការ និងសកម្មភាពរយៈពេលខ្លី ត្រូវបានបង្ហាញក្នុងតារាងខាងក្រោម។

គម្រោងទាំងនេះអាចបែងចែកយ៉ាងទូលំទូលាយជាបីប្រភេទគឺ៖ ការទប់ស្កាត់បទល្មើស ការទប់ស្កាត់គ្រោះមហន្តរាយ និងព័ត៌មាន ហើយនឹងរួមចំណែកធ្វើឱ្យប្រសើរឡើងនូវភាពពេញចិត្តរបស់ប្រជាពលរដ្ឋ និងភ្ញៀវទេសចរ។

**តារាង ៦.៣៖ បញ្ហាប្រឈមនៃវិស័យសន្តិសុខ និងសុវត្ថិភាពឆ្លាតវៃ ទិសដៅនៃវិធានការ សកម្មភាពរយៈពេលខ្លី**

| បញ្ហាប្រឈម | ទិសដៅនៃវិធានការ | សកម្មភាពរយៈពេលខ្លី |
|---|---|---|
| ១៥. ត្រូវការសុវត្ថិភាពបន្ថែមដោយជៀសផុតហានិភ័យនៃគ្រោះថ្នាក់ចរាចរណ៍ និងបទល្មើស<br>→ការរកឃើញបទល្មើស និងគ្រោះថ្នាក់ចរាចរណ៍ឱ្យបានឆាប់រហ័សគឺជាការចាំបាច់។ | "ការកាត់បន្ថយបទល្មើស និងគ្រោះថ្នាក់ចរាចរណ៍"<br>~កាត់បន្ថយហានិភ័យបទល្មើស និងគ្រោះថ្នាក់ចរាចរណ៍ ដើម្បីធានាសុវត្ថិភាព~ | • ការណែនាំប្រព័ន្ធ CCTV (S-០១)<br>• ការកែលម្អទំនាក់ទំនងសាធារណៈ ដើម្បីសុវត្ថិភាព (S-០៤) |
| ១៦. វិធានការនៃការឆ្លើយតបទៅនឹងហានិភ័យគ្រោះមហន្តរាយ (អគ្គិភ័យ/ ទឹកជំនន់)នៅមានការយឺតយ៉ាវនៅឡើយ<br>→ ការរកឃើញសញ្ញានៃអគ្គិភ័យបានឆាប់រហ័សដើម្បីជួយពន្លត់អគ្គិភ័យក្នុងគ្រាបឋម នៅមានកំរិត។<br>→ព័ត៌មានជូនដំណឹងអំពីទឹកជំនន់មិនត្រូវបានផ្តល់ឱ្យគ្រប់គ្រាន់និងទាន់ពេលវេលាដល់ប្រជាពលរដ្ឋ និងភ្ញៀវទេសចរឡើយ។ | "ការឆ្លើយតបទៅនឹងគ្រោះមហន្តរាយ"<br>~ធានាសុវត្ថិភាពទប់ទល់នឹងគ្រោះទឹកជំនន់ និងអគ្គិភ័យជាដើមដោយពន្លឿនសកម្មភាពទប់ស្កាត់ឆាប់រហ័ស~ | • ការអភិវឌ្ឍប្រព័ន្ធប្រកាសអាសន្នទឹកជំនន់ (S-០២)<br>• ការដំឡើងប្រព័ន្ធប្រកាសអាសន្នអគ្គិភ័យ (S-០៣) |

ប្រភព៖ ក្រុមសិក្សា JICA

## ៦.៤ ការគ្រប់គ្រងកាកសំណល់ឆ្លាតវៃ

គោលនយោបាយមូលដ្ឋានសម្រាប់វិស័យគ្រប់គ្រងកាកសំណល់ឆ្លាតវៃគឺ **"ឆ្ពោះទៅរកការបង្កើតបរិស្ថានទីក្រុងប្រកបដោយអនាម័យ និងសុខភាពល្អ"**។ ដើម្បីសម្រេចបានគោលនយោបាយមូលដ្ឋាននេះ ទាមទារអោយមានការកំណត់នូវទិសដៅនៃវិធានការចំនួន ៣ចំនុចសំខាន់ៗគឺ **"ការអប់រំ**

លើវិស័យបរិស្ថាន” “ពង្រឹងការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន” “សាងសង់ហេដ្ឋារចនាសម្ព័ន្ធគាំទ្រការគ្រប់គ្រងសំណល់”។




ក្នុងវិស័យការគ្រប់គ្រងសំណល់ឆ្លាតវៃ រដ្ឋបាលសាធាណៈ ត្រូវមានគំនិតផ្តួចផ្តើមក្នុងការអនុវត្តគម្រោងនានា និងកសាងកែលម្អហេដ្ឋារចនាសម្ព័ន្ធពាក់ព័ន្ធនឹងការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនជាមួយគ្នានេះដែរ ប្រជាពលរដ្ឋ និងភ្ញៀវទេសចរ ត្រូវចូលរួមយ៉ាងសកម្មក្នុងការអនុវត្តការគ្រប់គ្រងសំរាមសំណល់រឹងទីប្រជុំជន ក្នុងគោលបំណងធានាឱ្យបាននូវនិរន្តភាពបរិស្ថាន។ ជាពិសេស ការលើកកម្ពស់ការយល់ដឹងអំពីបរិស្ថានគឺជាដំណោះស្រាយដ៏សំខាន់ដើម្បីផ្សព្វផ្សាយដល់ប្រជាពលរដ្ឋ។ ក្រោយពីទទួលបាននូវចំណេះដឹងពីវិស័យបរិស្ថាន តាមរយៈប្រព័ន្ធផ្សព្វផ្សាយ និងយុទ្ធនាការផ្សេងៗដោយផ្តោតទៅលើការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន និងធ្វើឱ្យសាធារណជនធ្វើការផ្លាស់ប្តូរឥរិយាបថ និងដើរតួនាទីយ៉ាងសំខាន់ក្នុងការចូលរួមអនុវត្តការគ្រង់គ្រងសំរាម សំណល់រឹងទីប្រជុំជន ក្នុងខេត្តសៀមរាប។

ឆ្លើយតបទៅនឹងបញ្ហាប្រឈម ទិសដៅនៃវិធានការ និងសកម្មភាពរយៈពេលខ្លីត្រូវបានបង្ហាញដូចតារាងខាងក្រោម។

**តារាង ៦.៤៖ បញ្ហាប្រឈម ទិសដៅនៃវិធានការ សកម្មភាពរយៈពេលខ្លី ក្នុងការគ្រប់គ្រងកាកសំណល់ឆ្លាតវៃ**

| បញ្ហាប្រឈម | ទិសដៅនៃវិធានការ | សកម្មភាពរយៈពេលខ្លី |
|---|---|---|
| ១៧. ត្រូវការការអប់រំដែលឈានទៅរកសកម្មភាពដែលប្រកបដោយភាគបរិស្ថាន<br>→ចាំបាច់ត្រូវផ្លាស់ប្តូរឥរិយាបថរបស់ប្រជាពលរដ្ឋទាក់ទងនឹងការបោះចោលសំរាម និងទឹកកខ្វក់ | ពង្រឹងការយល់ដឹងពីបរិស្ថាន<br>~លើកកម្ពស់ការយល់ដឹងអំពីបរិស្ថាននិងសកម្មភាពបរិស្ថានដោយស្ម័គ្រចិត្ត និងសកម្មរបស់ប្រជាពលរដ្ឋម្នាក់ៗ~ | • ពង្រឹងប្រព័ន្ធគ្រប់គ្រងសំរាមសំណល់រឹងទីប្រជុំជន (W-០១) |
| ១៨. តម្រូវការសម្រាប់ការជំរុញគំនិតផ្តួចផ្តើមសាធារណៈ<br>→សមត្ថភាពមន្រ្តីជំនាញលើការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន នៅមានកម្រិត<br>→ប្រព័ន្ធប្រមូលថ្លៃសេវាមិនត្រូវបានបង្កើតឡើង និងអនុវត្តឱ្យមានប្រសិទ្ធភាព | ពង្រឹងការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន<br>~រដ្ឋបាលសាធាណៈត្រូវផ្តួចផ្តើមគំនិតអនុវត្តការគ្រប់គ្រងសំណល់ដើម្បីឆ្ពោះទៅកាន់ការគ្រប់គ្រងបរិស្ថានប្រកបដោយនិរន្តរភាព~ | • ការជំរឿងប្រព័ន្ធ IoT សម្រាប់គ្រប់គ្រងការប្រមូលសំរាម (W-០២)<br>• ការកែលម្អប្រព័ន្ធគ្រប់គ្រងឧបករណ៍បរិក្ខារទឹកកខ្វក់ (W-០៥)<br>• យន្តការបង់ថ្លៃសេវាសាធារណៈរួមគ្នា (W-០៦) |

| | | |
|---|---|---|
| ១៩. មានតម្រូវការបន្ថែមលើការកសាងហេដ្ឋារចនាសម្ព័ន្ធ<br>→ពុំមានទីលានទុកដាក់សំរាមប្រកបដោយអនាម័យ<br>→សមត្ថភាពស្ថានីយ៍ប្រព្រឹត្តិកម្មទឹកកខ្វក់មិនទាន់ឆ្លើយតបនឹងតម្រូវការជាក់ស្តែង | សាងសង់ហេដ្ឋារចនាសម្ព័ន្ធគាំទ្រការគ្រប់គ្រងសំណល់<br>~កសាងហេដ្ឋារចនាសម្ព័ន្ធចំបាច់សម្រាប់ការគ្រប់គ្រងសំណល់~ | • ការគ្រប់គ្រងទីលានទុកដាក់សំរាមប្រកបដោយអនាម័យ (W-0៣ )<br>• ការកែលម្អគុណភាពស្ទឹង និងការប្រើប្រាស់ស្ទឹង (W-0៤ ) |

ប្រភព៖ ក្រុមសិក្សា JICA

"សៀមរាបឆ្លាតវៃ"

# ផែនទីបង្ហាញផ្លូវទីក្រុងឆ្លាតវៃ នៃខេត្តសៀមរាប
# ផ្នែកទី ២: ផែនការសកម្មភាព

# ជំពូកទី ៧: វិធានការអនុវត្ត

## ៧.១ ពង្រឹងការអនុវត្តមុខងាររបស់គណៈកម្មាធិការទីក្រុងឆ្លាតវៃ (SCC)

ដើម្បីអនុវត្តផែនទីបង្ហាញផ្លូវទីក្រុងឆ្លាតវៃ សមត្ថភាពរបស់គណៈកម្មាធិការទីក្រុងឆ្លាតវៃ នឹងត្រូវបានពង្រឹង តាមរយៈសកម្មភាពមួយចំនួន ដូចខាងក្រោម៖

- គណៈកម្មាធិការទីក្រុងឆ្លាតវៃ ត្រូវពង្រឹងតួនាទី ភារកិច្ចដើម្បីអនុវត្តផែនទីបង្ហាញផ្លូវទីក្រុងឆ្លាតវៃ
- មន្ទីរទេសចរណ៍ និងស្នងការដ្ឋាននគរបាលខេត្ត ត្រូវចូលរួមក្នុងគណៈកម្មាធិការទីក្រុងឆ្លាតវៃ ដើម្បីសម្រេចបាននូវគោលដៅនៃការលើកកម្ពស់វិស័យទេសចរណ៍ និងការកែលម្អសុវត្ថិភាព
- ដើម្បីគ្រប់គ្រង និងអនុវត្តគម្រោងតំបន់បេតិកភណ្ឌអង្គរ អាជ្ញាធរជាតិអប្សរា និងគ្រឹះស្ថានអង្គរ ក៏ត្រូវចូលរួមនៅក្នុងគណៈកម្មាធិការទីក្រុងឆ្លាតវៃផងដែរ។ វាអាចនឹងត្រូវបានពិចារណាបន្ថែមទៀត ក្នុងការបង្កើតក្រុមការងារផ្តោតសំខាន់លើតំបន់បេតិកភណ្ឌ ក៏ដូចជាការអភិវឌ្ឍទីក្រុងឆ្លាតវៃផងដែរ
- រដ្ឋបាលខេត្តសៀមរាបនឹងបង្កើត "ទីចាត់ការទីក្រុងឆ្លាតវៃ"។ ប៉ុន្តែដោយសារទីចាត់ការទីក្រុងឆ្លាតវៃនេះ នៅពុំទាន់ចេញជារូបរាង បច្ចុប្បន្ននេះ លេខាធិការដ្ឋានមួយត្រូវបានបង្កើត និងដើរតួនាទីជាសេនាធិការរបស់គណៈកម្មាធិការទីក្រុងឆ្លាតវៃ ដើម្បីសម្របសម្រួលការងារ និងការអនុវត្តគម្រោងពាក់ព័ន្ធនឹងទីក្រុងឆ្លាតវៃ។




**រូបភាព ៧.១៖ សំណើស្តីពីការលើកកម្ពស់គណៈកម្មាធិការទីក្រុងឆ្លាតវៃ**

គណៈកម្មាធិការទីក្រុងឆ្លាតវៃ នឹងដើរតួនាទីយ៉ាងសំខាន់ ក្នុងការដឹកនាំសម្របសម្រួលជាមួយវិស័យឯកជន គ្រឹះស្ថានសិក្សា ស្ថាប័នស្រាវជ្រាវ និងប្រជាពលរដ្ឋ ដើម្បីសម្រេចឱ្យបានទីក្រុងឆ្លាតវៃ។ ដើម្បីអនុវត្តគម្រោងសាកល្បង (The pilot projects) ចាំបាច់ត្រូវរៀបចំឱ្យមានក្រុមការងារមួយ ដោយមានការគាំទ្របច្ចេកទេស និងហិរញ្ញវត្ថុ ពីក្រសួងស្ថាប័នពាក់ព័ន្ធ។ ដូចនេះយន្តការនៃការអនុវត្តទីក្រុងឆ្លាតវៃ ជាយន្តការដែលរួមបញ្ចូលការងារសម្របសម្រួលពីគ្រប់អ្នកពាក់ព័ន្ធ និងការពង្រឹងការអភិវឌ្ឍសមត្ថភាព។

## ៧.២ ការរៀបចំ និងដំណើរការទីចាត់ការសម្រាប់អនុវត្តគម្រោងទីក្រុងឆ្លាតវៃ

ក្នុងប្រតិបត្តិការសម្រាប់ការសម្រេចបានទីក្រុងឆ្លាតវៃ ត្រូវបានរំពឹងថានឹងបង្កើត "ទីចាត់ការសម្រាប់អនុវត្តទីក្រុងឆ្លាតវៃ" នាពេលអនាគត។ តួនាទីសំខាន់ៗរបស់ទីចាត់ការនោះមានដូចខាងក្រោមៈ

### *៧.២.១ តួនាទី និងភារកិច្ចដែលរំពឹងទុកនាពេលខាងមុខ*

- ការវាយតម្លៃគម្រោងដោយផ្អែកលើលក្ខណៈវិនិច្ឆ័យ (អនុលោមភាពជាមួយផែនទីបង្ហាញផ្លូវគោលដៅអភិវឌ្ឍប្រកបដោយចីរភាព ភាពជាដៃគូរវាងរដ្ឋ វិស័យឯកជន និងគ្រឹះស្ថានឧត្តមសិក្សា ការគាំទ្របច្ចេកទេស និងហិរញ្ញវត្ថុ ភាពចាំបាច់នៃការអនុវត្តគម្រោងសាកល្បង (PoC))
- ប្រឹក្សាយោបល់ជាមួយវិស័យឯកជន
- ការបង្រួមនីតិវិធីរដ្ឋបាលចាំបាច់
- ការជ្រើសរើសគម្រោងសាកល្បង (PoC) និងគាំទ្រការអនុវត្ត
- ការចែករំលែកទិន្នន័យជាមួយក្រុមហ៊ុនឯកជន (មិនរាប់បញ្ចូលព័ត៌មានឯកជន)
- សម្របសម្រួលជាមួយក្រុមហ៊ុនឯកជនដើម្បីប្រើប្រាស់ទិន្នន័យដែលទទួលបានដោយក្រុមហ៊ុនឯកជនសម្រាប់គោលបំណងសាធារណៈ
- ផ្គូផ្គងអាជីវកម្មនៃវិស័យឯកជន (ក្នុងស្រុក និងអន្តរជាតិ)
- ការសម្របសម្រួល និងការស្នើសុំថវិកាសម្រាប់សកម្មភាពទាក់ទងនឹងទីក្រុងឆ្លាតវៃ។

### *៧.២.២ ការប្រតិបត្តិការ*

ទីចាត់ការសម្រាប់អនុវត្តទីក្រុងឆ្លាតវៃ ជាទីចាត់ការថ្មីស្ថិតក្នុងរចនាសម្ព័ន្ធរបស់រដ្ឋបាលខេត្តសៀមរាប។ ប៉ុន្តែប្រសិនបើរចនាសម្ព័ន្ធអង្គភាពនេះ ត្រូវការពេលវេលាយូរក្នុងការត្រួតពិនិត្យ និងការឯកភាពពីក្រសួងមហាផ្ទៃ ក្នុងអន្តរកាលនេះ ទីចាត់ការផ្សេងៗដូចជា ទីចាត់ការផែនការ និងវិនិយោគជាដើម អាចនឹងត្រូវដើរតួនាទីក្នុងការអនុវត្តផែនទីបង្ហាញផ្លូវទីក្រុងឆ្លាតវៃនេះ នៅក្នុងដំណាក់កាលចាប់ផ្តើមដំបូង។




រូបភាព ៧.២៖ ទំនាក់ទំនងរវាងទីចាត់ការទីក្រុងឆ្លាតវៃ និងស្ថាប័នពាក់ព័ន្ធ

## ៧.៣ ការបង្កើត និងប្រតិបត្តិការនៃវេទិកាសហប្រតិបត្តិការរវាងវិស័យឯកជន-វិស័យសាធារណៈ-ស្ថាប័នសិក្សាធិការ-សហគមន៍ (Smart City Consortium)

វេទិកាសហការរវាងវិស័យឯកជន-វិស័យសាធារណៈ-ស្ថាប័នសិក្សាធិការ-សហគមន៍ (Smart City Consortium) នឹងត្រូវរៀបចំឡើង ដើម្បីអនុវត្តផែនទីបង្ហាញផ្លូវទីក្រុងឆ្លាតវៃ នៅក្នុងខេត្តសៀមរាប ដោយមានការចូលរួមពីរដ្ឋ វិស័យឯកជន ស្ថាប័នសិក្សាធិការ និងសហគមន៍។ វេទិកានេះមានតួនាទីភារកិច្ចដូចខាងក្រោម៖

### *៧.៣.១ តួនាទី និងភារកិច្ចដែលរំពឹងទុកនាពេលខាងមុខ*

- លើកកម្ពស់ និងគាំទ្រជាអាទិភាពសម្រាប់អាជីវកម្មដែលពាក់ព័ន្ធនឹងទីក្រុងឆ្លាតវៃដូចជា ការគាំទ្រ និងកិច្ចប្រតិបត្តិការក្នុងការផ្តល់ផ្នែកហិរញ្ញវត្ថុ និងបច្ចេកទេសដោយផ្អែកតាមតួនាទីភារកិច្ចបានកំណត់។ ការគាំទ្រ និងកិច្ចប្រតិបត្តិការក្នុងការផ្តល់ផ្នែកហិរញ្ញវត្ថុ និងបច្ចេកទេស មានដូចជាការប្រើប្រាស់ប្រាក់ឧបត្ថម្ភធន និងមូលនិធិសកម្មភាពរបស់រាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ ការធ្វើឱ្យមានប្រសិទ្ធភាព និងភាពសាមញ្ញចំពោះនីតិវិធីអនុម័តអាជីវកម្មរបស់រាជរដ្ឋាភិបាល ការផ្តល់បច្ចេកវិទ្យា និងមូលនិធិដោយអាជីវករ ការផ្តល់បច្ចេកវិទ្យា និងចំណេះដឹងដោយគ្រឹះស្ថានសិក្សា និងវិទ្យាស្ថានស្រាវជ្រាវ។

- ការចែករំលែកនូវព័ត៌មាន និងការគាំទ្រការផ្គូផ្គង ដែលមានដូចជា ការគាំទ្រក្រុមហ៊ុន គ្រឹះស្ថានសិក្សា វិទ្យាស្ថានស្រាវជ្រាវ និងភ្នាក់ងាររាជរដ្ឋាភិបាល ដើម្បីណែនាំអង្គភាពទាំងនេះ អាចផ្តល់ដំណោះស្រាយ និងពង្រីកគម្រោងជាគំរូដែលជោគជ័យទៅតំបន់ផ្សេងៗទៀត
- ការផ្សព្វផ្សាយលើកកម្ពស់សកម្មភាពនានានៅក្នុង និងក្រៅប្រទេស ដោយការបង្ហាញការខិតខំប្រឹងប្រែងអនុវត្តគម្រោងសាកល្បង (PoC) ការផ្សព្វផ្សាយព័ត៌មានដូចជាបាឋកថាសំខាន់ៗដោយអ្នកជំនាញ និងចែករំលែកព័ត៌មានតាមអ៊ីមែល និងសិក្ខាសាលាតាមប្រព័ន្ធអនឡាញសម្រាប់សមាជិកវេទិកា។
- វេទិកាទីក្រុងឆ្លាតវៃខាងលើ នឹងត្រូវរាយការណ៍ជូនដល់គណៈកម្មាធិការទីក្រុងឆ្លាតវៃសៀមរាប អំពីសកម្មភាពនានារបស់ខ្លួនជាប្រចាំ។

### ៧.៣.២ ការប្រតិបត្តិការ

វេទិកាទីក្រុងឆ្លាតវៃនេះ នឹងត្រូវបានបង្កើតឡើងក្នុងក្របខ័ណ្ឌនៃរចនាសម្ព័ន្ធអង្គភាពដែលមានស្រាប់ក្នុងរយៈពេលខ្លី។ ក្រុមការងារបច្ចេកទេស (TWG) ដែលមានសមាសភាពពីភ្នាក់ងាររាជរដ្ឋាភិបាល មានតួនាទីជាអ្នកដឹកនាំ ហើយទីចាត់ការសម្រាប់អនុវត្តគម្រោងទីក្រុងឆ្លាតវៃ ឬទីចាត់ការផ្សេងទៀត មានតួនាទីជាសេនាធិការ ក្នុងការរៀបចំកិច្ចប្រជុំផ្សេងៗ ដោយមានការជ្រើសរើសសមាជិកពីអាជីវកម្ម គ្រឹះស្ថានសិក្សា វិទ្យាស្ថានស្រាវជ្រាវ។ លើសពីនេះ វេទិកាទីក្រុងឆ្លាតវៃ នឹងត្រូវរៀបចំបណ្តាញក្រុមការងារ និងលើកកម្ពស់ការចូលរួមក្នុងសន្និសីទអន្តរជាតិដែលមានស្រាប់ដូចជាកិច្ចប្រជុំបណ្តាញទីក្រុងឆ្លាតវៃអាស៊ាន វេទិកាសន្និសីទអភិវឌ្ឍន៍ទីក្រុងជប៉ុន-កម្ពុជា ជាដើម។

- **ការប្រជុំដោយឡែកៗ៖** មុននឹងចាប់ផ្តើមសកម្មភាពនៃវេទិកាទីក្រុងឆ្លាតវៃ នឹងមានការបង្កើតឡើងនូវវេទិកាមួយ សម្រាប់ការពិភាក្សាក្នុងចំណោមភាគីពាក់ព័ន្ធលើខ្លឹមសារនៃសកម្មភាព។ (កិច្ចប្រជុំពេញអង្គបន្តបន្ទាប់ និងការបង្កើតបណ្តាញក្រុមការងារក៏នឹងត្រូវបានអនុម័តផងដែរនៅក្នុងកិច្ចប្រជុំដោយឡែកៗទាំងនោះ)។
- **ការរៀបចំកិច្ចប្រជុំពេញអង្គ៖**វានឹងក្លាយជាទីកន្លែងសម្រាប់ស្វែងយល់ពីគ្នា និងការឯកភាពគ្នាសម្រាប់អ្នកតំណាងនៃវិស័យឯកជន វិស័យសិក្សាស្រាវជ្រាវ រាជរដ្ឋាភិបាល និងសហគមន៍។ ទោះជាយ៉ាងណាក៏ដោយ ការសម្រេចចិត្តត្រូវធ្វើឡើងដោយស្ថាប័ននីមួយៗ ដោយយកប្រធានបទនោះទៅស្ថាប័នរបស់ខ្លួនទៅតាមនីតិវិធីរៀងៗខ្លួន។ កិច្ចប្រជុំពេញអង្គនេះត្រូវបានធ្វើឡើងប្រហែលម្តងក្នុងមួយឆ្នាំ។
- **ការរៀបចំកិច្ចប្រជុំបណ្តាញក្រុមការងារ៖** ដើម្បីដោះស្រាយបញ្ហារួម ពិភាក្សាអំពីដំណោះស្រាយតាមប្រធានបទ ឬវិស័យ ដូចជា ការចល័ត ទេសចរណ៍ បរិស្ថាន សន្តិសុខ និងការគ្រប់គ្រងទិន្នន័យ ហើយធ្វើការលើកកម្ពស់ការចែករំលែកព័ត៌មាន និងគម្រោងរួមគ្នា។ កិច្ចប្រជុំបណ្តាញក្រុមការងារនេះត្រូវបានប្រារព្ធឡើងប្រហែលរៀងរាល់បីខែម្តង ដោយមានការចូលរួមពីភ្នាក់ងាររាជរដ្ឋាភិបាលដែលមាន

យុត្តាធិការលើវិស័យទាំងនេះ អាជីវករឯកជនដែលចូលរួមក្នុងគម្រោង និងសាកលវិទ្យាល័យ ឬស្ថាប័នស្រាវជ្រាវជាដើម ហើយធ្វើកិច្ចពិភាក្សាលក្ខណៈបច្ចេកទេសសម្រាប់ការអនុម័តអាជីវកម្មថ្មីៗ។

នៅក្នុងអំឡុងពេលពីមធ្យមទៅវែង ក្រុមហ៊ុនគោលបំណងពិសេស (SPCs) និងយានយន្តគោលបំណងពិសេស (SPV) នឹងត្រូវបានបង្កើតឡើងដោយមានការចូលរួមពីគ្រប់អាជីវករ និងប្រជាពលរដ្ឋ (គ្រប់អ្នកពាក់ព័ន្ធ) ហើយនឹងត្រូវទទួលខុសត្រូវសម្រាប់ប្រតិបត្តិការគ្រប់គ្រងថ្នាលទិន្នន័យ និងតំបន់ដើម្បីកែលម្អបរិស្ថានទីក្រុង។ ផ្នែកមួយនៃប្រាក់ចំណេញរបស់អាជីវកម្មផ្សេងៗ និងមូលនិធិបានមកពីក្រុមហ៊ុន ត្រូវបានប្រើប្រាស់ក្នុងការចំណាយលើប្រតិបត្តិការ និងការគ្រប់គ្រង។

## ៧.៤ ប្រព័ន្ធត្រួតពិនិត្យ និងវាយតម្លៃ

ISO 37151, 37153 របស់អង្គការអន្តរជាតិសម្រាប់ស្តង់ដារនីយកម្ម និងក្របខ័ណ្ឌផ្សេងៗ ត្រូវបានបង្កើតឡើងជាសូចនាករសម្រាប់វាយតម្លៃទីក្រុងតាមទស្សនៈទីក្រុងឆ្លាតវៃ។ ទាំងនេះត្រូវបានចាត់ទុកថាជាសូចនាករសកលដែលអាចអនុវត្តបានចំពោះទីក្រុងណាមួយ។ ទោះជាយ៉ាងណាក៏ដោយ ផែនទីបង្ហាញផ្លូវទីក្រុងឆ្លាតវៃសម្រាប់ខេត្តសៀមរាប បច្ចុប្បន្នមានភាពជាក់លាក់ចំពោះវិស័យមួយចំនួន រួមទាំងវិស័យទេសចរណ៍ផងដែរ។ ដូច្នេះ វាជាការប្រសើរក្នុងការត្រួតពិនិត្យ និងវាយតម្លៃវឌ្ឍនភាពនៃផែនទីបង្ហាញផ្លូវនេះដោយឯករាជ្យ ដោយផ្អែកទៅលើសូចនាករគោលដៅគន្លឹះ (KGI)ដែលមានស្រាប់ទាំងនេះ។

**តារាង ៧.១៖ សេចក្តីព្រាងសូចនាករគោលដៅសំខាន់ៗ**

| វិស័យ | គោលនយោបាយមូលដ្ឋាន | សូចនាករគោល |
|---|---|---|
| ស្ថាប័នរដ្ឋបាល | កិច្ចសហប្រតិបត្តិការបើកចំហ | មានការពិភាក្សាជាច្រើនដែលពាក់ព័ន្ធនឹងគណៈកម្មាធិការទីក្រុងឆ្លាតវៃ |
| ប្រព័ន្ធច្បាប់ និងគាំទ្រអាជីវកម្ម | លើកកម្ពស់អាជីវកម្មបែបឆ្លាតវៃ | ការអនុញ្ញាតអាជីវកម្មថ្មីពាក់ព័ន្ធនឹងគម្រោងថ្មីៗនៃទីក្រុងឆ្លាតវៃ |
| ការគ្រប់គ្រងទិន្នន័យ | ការប្រើប្រាស់ទិន្នន័យ | បរិមាណនៃទិន្នន័យដែលបានប្រើប្រាស់ និងបង្ហាញ |
| ទេសចរណ៍ឆ្លាតវៃ | វិស័យទេសចរណ៍ កាន់តែមានផាសុកភាព និងភាពពេញចិត្តជាងមុន | ចំនួនភ្ញៀវទេសចរ ចំនួនភ្ញៀវទេសចរត្រលប់មកម្តងទៀត និងអត្រានៃភាពពេញចិត្តរបស់ភ្ញៀវ |
| ការចល័តឆ្លាតវៃ | ប្រព័ន្ធចល័តនឹងមាននិរន្តរភាព សុវត្ថិភាព និងផាសុកភាពកាន់តែប្រសើរឡើង | ចំនួនគ្រោះថ្នាក់ចរាចរណ៍ ចំនួនកកស្ទះចរាចរណ៍ អត្រាយានយន្ត (EV) |
| សន្តិសុខសុវត្ថិភាពឆ្លាតវៃ | ឆ្ពោះទៅកាន់ទិសដៅទេសចរណ៍ដែលមានសុវត្ថិភាពខ្ពស់ | ចំនួនបទល្មើស ចំនួនអ្នកស្លាប់ដោយសារអគ្គិភ័យ ចំនួនអ្នកស្លាប់ដោយសារគ្រោះធម្មជាតិ |
| ការគ្រប់គ្រងកាកសំណល់ឆ្លាតវៃ | ឆ្ពោះទៅរកបរិស្ថានទីក្រុងស្អាត និងមានអនាម័យ | បរិស្ថាននៃស្ទឹងសៀមរាបមិនទាន់ល្អ បរិមាណសំណល់រឹង |

សូចនាករគោលដៅគន្លឹះ (KGI) នឹងត្រូវបានត្រួតពិនិត្យ និងវាយតម្លៃប្រហែលរៀងរាល់ប្រាំឆ្នាំម្តង ហើយត្រូវប្រើជាឯកសារយោងនៅពេលពិនិត្យមើលផែនទីបង្ហាញផ្លូវ។ សូចនាករគោលដៅគន្លឹះ (KGI) ក៏នឹងក្លាយជាព័ត៌មានយោងសម្រាប់ការបង្កើតសកម្មភាពរយៈពេលខ្លីបន្ទាប់ផងដែរ។ ខណៈពេលដែល (KGI)គឺជាសូចនាករសម្រាប់វាស់វែងកម្រិតនៃសមិទ្ធផលនៃគោលនយោបាយមូលដ្ឋាន សូចនាករការអនុវត្តសំខាន់ៗ (KPI) គឺដើម្បីវាស់វែងអំពីកម្រិតសមិទ្ធផលដែលសម្រេចបានលើសកម្មភាពសំខាន់ៗរបស់គម្រោងអាទិភាពដែលបានរៀបរាប់ក្នុងជំពូកទី៨។ វឌ្ឍនភាពនៃគម្រោងអាទិភាពនឹងត្រូវបានត្រួតពិនិត្យជាប្រចាំ។

## ៧.៥ ទំនាក់ទំនងសាធារណៈ និងវិធានការផ្សព្វផ្សាយកិត្តិនាម "សៀមរាបឆ្លាតវៃ"

### *៧.៥.១ គម្មវត្ថុ*

សម្រាប់ការលើកកម្ពស់ទីក្រុងឆ្លាតវៃ ការយល់ដឹងអំពីគំនិតផ្តួចផ្តើមទីក្រុងឆ្លាតវៃរបស់ភាគីពាក់ព័ន្ធ និងការរួមបញ្ចូលមតិចម្រុះពិតជាមានសារៈសំខាន់។ វាមានភាពចាំបាច់ណាស់ក្នុងការបន្សីគ្នារវាងផែនទីបង្ហាញផ្លូវទីក្រុងឆ្លាតវៃជាមួយនឹងសកម្មភាពរបស់រាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ផ្សេងៗដើម្បីអនុវត្តគម្រោងទីក្រុងឆ្លាតវៃកាន់តែល្អប្រសើរ។ លើសពីនេះ វិធីសាស្ត្រនៃទំនាក់ទំនងសាធារណៈអំពីគំនិតផ្តួចផ្តើមទីក្រុងឆ្លាតវៃ គួរតែរួមបញ្ចូលនូវការផ្សព្វផ្សាយកិត្តិនាមដែលអាចកែលម្អមុខមាត់នៃខេត្តសៀមរាប តាមរយៈការប្រើប្រាស់ទីក្រុងឆ្លាតវៃ ហើយមិនគួរកំណត់ត្រឹមតែការផ្តល់ព័ត៌មាននោះទេ។

វិធីសាស្ត្រយុទ្ធសាស្ត្រចំពោះទំនាក់ទំនងខាងក្រៅ និងវិធីសាស្ត្រអន្តរកម្មនឹងពិតជាមានសារៈសំខាន់។ និយមន័យនៃ "ទំនាក់ទំនងសាធារណៈ" នៅទីនេះ គឺសំដៅលើការលើកកម្ពស់ការយល់ដឹង និងការយល់អំពីគ្នាទៅវិញទៅមក និងកសាងទំនាក់ទំនងជាមួយប្រជាពលរដ្ឋ ក្រុមហ៊ុនឯកជន និងភ្នាក់ងាររាជរដ្ឋាភិបាលតាមរយៈទីក្រុងឆ្លាតវៃ ចំណែកឯនិយមន័យនៃ "ការផ្សព្វផ្សាយកិត្តិនាម" គឺសំដៅលើការកែលម្អមុខមាត់តំបន់របស់ខេត្តសៀមរាប និងលើកកម្ពស់គុណតម្លៃទីក្រុងតាមរយៈគំនិតផ្តួចផ្តើមទីក្រុងឆ្លាតវៃ។ គោលបំណងនៃ ទំនាក់ទំនងសាធារណៈ និងយុទ្ធសាស្ត្រកិត្តិនាមត្រូវកំណត់ដូចខាងក្រោម។

- **ការផ្សព្វផ្សាយផែនទីបង្ហាញផ្លូវ៖**
  - ផ្សព្វផ្សាយពីសារៈសំខាន់នៃផែនទីបង្ហាញផ្លូវទីក្រុងឆ្លាតវៃ និងបង្កើនលទ្ធភាពនៃការអនុវត្តទីក្រុងឆ្លាតវៃ (កសាងសន្ទុះ)។
- **ការចែករំលែកចំណេះដឹង៖**
  - ដើម្បីបង្កើនអត្តិភាពនៃខេត្តសៀមរាបក្នុងនាមជាទីក្រុងឆ្លាតវៃ និងទាក់ទាញចំណេះដឹងដែលរួមចំណែកដល់គំនិតផ្តួចផ្តើមទីក្រុងឆ្លាតវៃខេត្តសៀមរាប។
- **ភាពទាក់ទាញរបស់ក្រុមហ៊ុន៖**
  - ទាក់ទាញក្រុមហ៊ុនឯកជនមកខេត្តសៀមរាប ដើម្បីបង្កើនគុណភាពផលិតផល និងសេវាកម្ម។
- **ការលើកកម្ពស់កិត្តិនាមក្នុងតំបន់៖**
  - លើកកម្ពស់កិត្តិនាមនៅក្នុងតំបន់នៃខេត្តសៀមរាបសម្រាប់ប្រជាពលរដ្ឋ និងភ្ញៀវទេសចរដោយប្រើប្រាស់ទីក្រុងឆ្លាតវៃ។

### *៧.៥.២ រចនាសម្ព័ន្ធនៃការអនុវត្ត*

ទីចាត់ការទីក្រុងឆ្លាតវៃ និងទីចាត់ការទំនាក់ទំនងសាធារណៈ និងសហប្រតិបត្តិការអន្តរជាតិត្រូវបានគេរំពឹងថានឹងដើរតួនាទីយ៉ាងសំខាន់ក្នុងសកម្មភាពទំនាក់ទំនងសាធារណៈទាក់ទងនឹងទីក្រុងឆ្លាតវៃ។ម៉្យាងវិញទៀត ដោយសារតែត្រូវការចំណាយពេលវេលាដើម្បីបង្កើតទីចាត់ការទីក្រុងឆ្លាតវៃ ដូចនេះទីចាត់ការទំនាក់ទំនងសាធារណៈ និងសហប្រតិបត្តិការអន្តរជាតិ ទីចាត់ការអន្តរវិស័យ និងទីចាត់ការផែនការ និងវិនិយោគ ត្រូវសហការគ្នាក្នុងការអនុវត្តវិធានការរហូតដល់ពេលដែលទីចាត់ការទីក្រុងឆ្លាតវៃត្រូវបានបង្កើតឡើង។

### *៧.៥.៣ សេចក្តីព្រាងសកម្មភាព*

- ផ្សព្វផ្សាយតាមរយៈបណ្តាញទំនាក់ទំនងសង្គម និងទទួលយកមតិយោបល់
- រៀបចំការជួបជុំខ្លីៗ និងសិក្ខាសាលា

- ការពិភាក្សាបន្តបន្ទាប់ដើម្បីភាពស៊ីសង្វាក់គ្នា ទាក់ទងនឹងការអភិវឌ្ឍទីក្រុងឆ្លាតវៃថ្នាក់ជាតិនៃប្រទេសកម្ពុជា
- ចូលរួមក្នុងសន្និសីទអន្តរជាតិទាក់ទងនឹងទីក្រុងឆ្លាតវៃ
- បង្កើតគេហទំព័រផ្ទាល់ខ្លួន
- បង្កើតវីដេអូទំនាក់ទំនងសាធារណៈ និងផ្សព្វផ្សាយ (តាមរយៈ YouTube ជាដើម)
- បង្កើត និងចែកចាយផ្ទាំងរូបភាព
- បង្កើត និងចែកចាយខិតប័ណ្ណ
- ប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយសាធារណៈ (តាមរយៈទូរទស្សន៍ និងវិទ្យុជាដើម)
- រៀបចំពិព័រណ៍បទពិសោធបច្ចេកវិទ្យាឆ្លាតវៃសម្រាប់ប្រជាពលរដ្ឋក្នុងខេត្តសៀមរាប
- កិច្ចសហប្រតិបត្តិការ និងការផ្លាស់ប្តូរកម្មសិក្សាជាមួយទីក្រុងផ្សេងៗ (ក្នុងស្រុក៖ ភ្នំពេញ បាត់ដំបង ក្រៅប្រទេស៖ ទីក្រុងឆ្លាតវៃក្នុងប្រទេសជប៉ុន)

## ៧.៦ ការអភិវឌ្ឍប្រព័ន្ធប្រតិបត្តិការ លក្ខណៈឌីជីថល និងការលើកម្ពស់ទិន្នន័យចំហ (Open Data)

### *៧.៦.១ ទិដ្ឋភាពទូទៅ*

ដើម្បីសម្រេចបាននូវការគ្រប់គ្រងទីក្រុងដែលជំរុញដោយទិន្នន័យ មជ្ឈមណ្ឌលគ្រប់គ្រងទិន្នន័យ (នៅនឹងកន្លែង ឬប្រើសេវាកម្មក្លោដ) នឹងត្រូវសាងសង់ជាដំណាក់កាល។ ក្រៅពីនេះ ការរួមបញ្ចូលទិន្នន័យ ការភ្ជាប់ប្រព័ន្ធខាងក្រៅជាមួយប្រព័ន្ធទាក់ទងនឹងចល័តភាព សំរាមសំណល់រឹងទីប្រជុំជន ថាមពល និងសុវត្ថិភាពជាដើម និងការបង្ហាញទិន្នន័យ ក៏នឹងត្រូវបានលើកកម្ពស់។ ជាលទ្ធផល អត្ថប្រយោជន៍ខាងក្រោមអាចត្រូវបានគេរំពឹងទុក៖

- ការកែលម្អប្រសិទ្ធភាពរដ្ឋបាល (ភាពងាយស្រួលនៃតំណភ្ជាប់ព័ត៌មាន)
- ការគិតគូរដល់បរិស្ថាន
- ការប្រាស្រ័យទាក់ទងទៅកាន់ប្រជាពលរដ្ឋ និងការកែលម្អសេវាកម្ម
- ការរស់ឡើងវិញនៃសកម្មភាពសាជីវកម្ម
- ការកែលម្អសេវាកម្មសម្រាប់ភ្ញៀវទេសចរ និងធ្វើឱ្យឧស្សាហកម្មទេសចរណ៍រស់ឡើងវិញ




រូបភាព ៧.៤៖ឧទាហរណ៍នៃផ្ទាំងគ្រប់គ្រង

ភាពលែងដំណើរការនៃប្រព័ន្ធ និងកម្មវិធី គឺជាបញ្ហាមិនត្រឹមតែនៅក្នុងការគ្រប់គ្រងទិន្នន័យប៉ុណ្ណោះទេ ប៉ុន្តែជាបញ្ហាទូទៅ។ ជាការចាំបាច់ក្នុងការបន្តសិក្សាពីនិរន្តរភាពនៃប្រព័ន្ធទាំងមូល ដោយពិចារណាលើកម្មវិធី ដើម្បីលើកកម្ពស់នវានុវត្តន៍ជាចំហ និងកិច្ចសហប្រតិបត្តិការ និងការប្រើប្រាស់នៃវិស័យឯកជនសម្រាប់មុខងារមួយចំនួន។

### ៧.៦.២ គោលនយោបាយមូលដ្ឋានសម្រាប់ការបង្កើតថ្នាលទិន្នន័យ (Data Platform)

ខាងក្រោមនេះ បង្ហាញពីគោលនយោបាយមូលដ្ឋានសម្រាប់ការបង្កើតថ្នាលទិន្នន័យ។

#### (១) គោលការណ៍រៀបចំ (Design Policy)

ប្រការទាំងបួនខាងក្រោមនេះ នឹងត្រូវបានស្នើក្នុងការពិចារណាលើការរៀបចំគោលការណ៍សម្រាប់ការបង្កើតថ្នាលទិន្នន័យ៖

- ពហុស្ថាប័ន (រដ្ឋ និងឯកជន)៖ ប្រមូលទិន្នន័យដ៏សម្បូរបែប តាមរយៈការចូលរួមពីអង្គភាព និងក្រុមហ៊ុនផ្សេងៗ។
- ការប្រើប្រាស់ទិន្នន័យលក្ខណៈអន្តរផ្នែក៖ អាចអភិវឌ្ឍសេវាកម្ម និងអាជីវកម្មថ្មីៗដោយប្រើប្រាស់ទិន្នន័យផ្សេងៗ។

- ធ្វើឱ្យមានទាំងសុវត្ថិភាព និងភាពបើកចំហ៖ សម្រេចបាននូវវេទិកាបច្ចេកវិទ្យាព័ត៌មាន និងទំនាក់ទំនង ( ICT Platform ) ដែលមានសុវត្ថិភាព និងរឹងមាំ។ ទិន្នន័យដែលត្រូវការការសម្ងាត់ គួរប្រើតែស្ថាប័នពាក់ព័ន្ធមួយចំនួនប៉ុណ្ណោះ រីឯទិន្នន័យដែលមានជាសាធារណៈវិញ អាចត្រូវបានប្រើប្រាស់យ៉ាងទូលំទូលាយ។
- បរិយាបន្ន៖ ភាគីពាក់ព័ន្ធទូទៅអាចមានសិទ្ធិទទួលបានទិន្នន័យសាធារណៈ។

*(២) លក្ខខណ្ឌបច្ចេកទេស*

តម្រូវការបរិក្ខាររូបវន្តទាំងប្រាំស្រទាប់ ដែលចាំបាច់ក្នុងការបង្កើត និងអភិវឌ្ឍថ្នាលទិន្នន័យ (ដែលហៅម្យ៉ាងទៀតថា វេទិកាទីក្រុងឆ្លាតវៃសៀមរាប ) មានគោលការណ៍រចនាដូចខាងក្រោម៖




**រូបភាព ៧.៥៖ លក្ខខណ្ឌបច្ចេកទេសនៃថ្នាលទិន្នន័យ (វេទិកាទីក្រុងឆ្លាតវៃសៀមរាប) (Siem Reap Smart City Platform)**

## *៧.៦.៣ដ្យាក្រាមគោលគំនិត*

ជាមួយនឹងគោលការណ៍រៀបចំ (Design Policy) តម្រូវការបច្ចេកទេស និងការពិចារណាលើសុវត្ថិភាពដែលបានពិពណ៌នាខាងលើនេះ ជាតុផ្សំនៃថ្នាលទិន្នន័យ និងរបៀបបែងចែកធនធាន នឹងត្រូវបានពិពណ៌នាដូចខាងក្រោម។ ដោយសារប្រព័ន្ធនេះនឹងដំណើរការដោយប្រើសេវាកម្មក្លោដ (Cloud System) ដូច្នេះគេអាចធានាបាននូវចល័តភាពរបស់វា។




រូបភាព ៧.៦៖ ដ្យាក្រាមគោលគំនិតនៃថ្នាលទិន្នន័យ (វេទិកាទីក្រុងឆ្លាតវៃសៀមរាប) ( Siem Reap Smart City Platform )

### *៧.៦.៤ ការការពារទិន្នន័យ (Data Security)*

ដើម្បីធ្វើការលើកកម្ពស់ក្នុងការប្រើប្រាស់ទិន្នន័យចំហ ការការពារទិន្នន័យ ត្រូវតែធានាឱ្យបានដើម្បីឱ្យភាគីពាក់ព័ន្ធនានាមានទំនុកចិត្តក្នុងការផ្តល់ និងប្រើប្រាស់ទិន្នន័យទាំងនោះ។ វិធានការនៃសុវត្ថិភាពទិន្នន័យ គួរតែអនុវត្តតាមវិធានការខាងក្រោម៖

- ទិដ្ឋភាពរាជរដ្ឋាភិបាល៖ ការកំណត់ទិសដៅនៃគំនិតផ្តួចផ្តើម និងវិធានការទីក្រុងឆ្លាតវៃទាំងមូល ការបង្កើតច្បាប់ និងគោលនយោបាយមូលដ្ឋាន និងរចនាសម្ព័ន្ធស្ថាប័ន។
    - ➢ ការបង្កើតគោលនយោបាយសុវត្ថិភាព៖ បង្កើតគោលនយោបាយសុវត្ថិភាពទិន្នន័យមូលដ្ឋាន ស្តង់ដារវិធានការសុវត្ថិភាព និងស្តង់ដារក្នុងការគ្រប់គ្រងទិន្នន័យ (រួមបញ្ចូលទាំងការការពារទិន្នន័យឯកជនផងដែរ)
    - ➢ គោលនយោបាយចែកចាយទិន្នន័យរវាងភាគីពាក់ព័ន្ធ៖ ដើម្បីធានាបានតម្លាភាពពីភាគីពាក់ព័ន្ធ គោលនយោបាយនេះ គួរតែបញ្ចូលក្នុងលក្ខខណ្ឌនៃលទ្ធកម្ម និងកិច្ចសន្យា។
    - ➢ កិច្ចខិតខំប្រឹងប្រែងបន្តដើម្បីរក្សាអភិបាលកិច្ច៖ ដើម្បីរក្សា និងកែលម្អសន្តិសុខទីក្រុងឆ្លាតវៃ លក្ខខណ្ឌវដ្តនៃការរៀបចំផែនការ-អនុវត្ត-ត្រួតពិនិត្យ-សកម្មភាព (PDCA) គួរតែត្រូវបានអនុវត្ត គោលនយោបាយ និងវិធានការការពារទិន្នន័យ គួរតែត្រូវបានពិនិត្យជារឿយៗ។

- ទិដ្ឋភាពថ្នាលទិន្នន័យ៖ ច្បាប់នៃការគ្រប់គ្រងទិន្នន័យ និងការការពារពីការយកទិន្នន័យទៅប្រើប្រាស់ពីជនអនាមិក
  - ➢ វិធានការការពារពីការទាញយកទិន្នន័យពីជនអនាមិក៖ ការកំណត់ការចូលប្រើប្រាស់ អ្នកបញ្ជាគ្រប់គ្រងការប្រើប្រាស់ មុខងារផ្ទៀងផ្ទាត់ និងការត្រួតពិនិត្យសុវត្ថិភាព ។ល។
  - ➢ វិធានការទប់ស្កាត់ឧបទ្ទវហេតុ៖ វិធានការការពារការវាយប្រហារពីការចូលទៅក្នុងវេទិកាក្នុងអំឡុងពេលនៃដំណើរការរៀបចំផែនការ ការរចនា ការអភិវឌ្ឍ និងដំណើរការប្រតិបត្តិការ
  - ➢ វិធានការដែលត្រូវអនុវត្តក្នុងករណីមានឧបទ្ទវហេតុ៖ ដើម្បីកាត់បន្ថយការខូចខាតក្នុងករណីមានឧបទ្ទវហេតុ វិធានការដូចជាការអ៊ិនគ្រីប (Encryption) ទំនាក់ទំនងខាងក្រៅ និងទិន្នន័យ ការBackups និងកំណត់ហេតុ (Logs) គួរតែត្រូវបានអនុវត្តផងដែរ។
- ទិដ្ឋភាពហេដ្ឋារចនាសម្ព័ន្ធ៖ ត្រួតពិនិត្យ និងគ្រប់គ្រងសុវត្ថិភាពនៃប្រព័ន្ធ IoT បណ្តាញចែកចាយទិន្នន័យទៅកាន់ថ្នាលទិន្នន័យ និងឧបករណ៍បញ្ជូនបន្ត ដូច្នេះវិធានការសុវត្ថិភាពសមស្រប អាចត្រូវបានអនុវត្ត។
  - ➢ ការត្រួតពិនិត្យ និងការគ្រប់គ្រងទិន្នន័យ៖ ខណៈពេលធ្វើការត្រួតពិនិត្យ និងគ្រប់គ្រងទិន្នន័យ ភាពងាយរងគ្រោះថ្មីៗ(new vulnerabilities) គួរតែត្រូវបានសិក្សាជាបន្តបន្ទាប់។
  - ➢ វិធានការគ្រប់គ្រងទិន្នន័យដោយខ្លួនឯង៖ អនុវត្តការទំនាក់ទំនង និងទិន្នន័យបែបអ៊ិនគ្រីប (Encryption) មុខងារផ្ទៀងផ្ទាត់ និងវិធានការសុវត្ថិភាព ជាពិសេសឧបករណ៍ IoT។
- ទិដ្ឋភាពសេវាកម្មជាលក្ខណៈបុគ្គល៖ អនុវត្តវិធានការសុវត្ថិភាពសម្រាប់សេវាកម្មជាលក្ខណៈបុគ្គល ដូចជាគម្រោងអាទិភាពនៃផែនទីបង្ហាញផ្លូវ
  - ➢ ការវាយតម្លៃហានិភ័យសម្រាប់សេវាកម្មជាលក្ខណៈបុគ្គល៖ កំណត់ហានិភ័យដោយផ្អែកលើគោលការណ៍សុវត្ថិភាពដែលបានបង្កើតជាមុន និងបង្កើតគោលនយោបាយដើម្បីដោះស្រាយបញ្ហា
  - ➢ វិធានការការពារការវាយប្រហារពីខាងក្រៅ ។ល។៖ អនុវត្ត និងដំណើរការការគ្រប់គ្រងការចូលប្រើសេវាកម្ម ការកំណត់សិទ្ធិអំណាចសមស្រប មុខងារផ្ទៀងផ្ទាត់ ការត្រួតពិនិត្យសុវត្ថិភាព ។ល។
  - ➢ វិធានការទប់ស្កាត់ឧបទ្ទវហេតុមិនឱ្យកើតមានឡើង៖ វិធានការការពារការវាយប្រហារពីការដាក់បញ្ចូលក្នុងដំណើរការរៀបចំផែនការ ការរចនា ការអភិវឌ្ឍ និងដំណើរការប្រតិបត្តិការនៃសេវាកម្ម។

- វិធានការដែលត្រូវអនុវត្តក្នុងករណីមានឧបទ្ទវហេតុ៖ ដើម្បីកាត់បន្ថយការខូចខាតក្នុងករណីមានឧបទ្ទវហេតុ វិធានការដូចជាការអ៊ិនគ្រីប (Encryption) ទំនាក់ទំនងខាងក្រៅ និងទិន្នន័យ ការបម្រុងទុក និងកំណត់ហេតុក៏គួរតែត្រូវបានអនុវត្តផងដែរ។

## ៧.៧ ការកែលម្អបរិយាកាសវិនិយោគ

ជានីតិវិធីរបស់ស្ថាប័នដើម្បីលើកកម្ពស់ផែនទីបង្ហាញផ្លូវនេះ ចាំបាច់ត្រូវអនុវត្តនីតិវិធីសេវាច្រកចេញចូលតែមួយនៅក្នុងរដ្ឋបាលខេត្ត នីតិវិធីសម្រាប់ការអនុវត្តគម្រោងផ្សេងទៀត (គម្រោងសាកល្បង គម្រោងពេញលេញ) និងវិធានការនិយ័ត។

ជាពិសេសក្នុងករណីបច្ចេកវិទ្យាឆ្លាតវៃ មានអាជីវកម្មពហុវិស័យ (ទេសចរណ៍ និងដឹកជញ្ជូន ។ល។) អាជីវកម្មថ្មីដែលមិនធ្លាប់មានពីមុនមកដូចជា MaaS និងអាជីវកម្មដែលប្រើប្រាស់ហេដ្ឋារចនាសម្ព័ន្ធទន់ (ទិន្នន័យ) ជាផលិតផល នៅទូទាំងប្រទេសកម្ពុជាទាំងមូល។ បន្ថែមពីលើការកែលម្អប្រព័ន្ធ វាមានសារៈសំខាន់ណាស់ក្នុងការពន្លឿននីតិវិធីនៃការអនុវត្តគម្រោងនៅថ្នាក់ខេត្ត ក៏ដូចជាការកែលម្អប្រព័ន្ធទាំងមូលនៅក្នុងប្រទេសកម្ពុជាផងដែរ។ ជាពិសេសការកែលម្អប្រព័ន្ធ និងភាពសាមញ្ញនៃនីតិវិធី គឺត្រូវបានទាមទារនៅក្នុងចំណុចខាងក្រោម៖

- ការគ្រប់គ្រងទិន្នន័យ៖ ប្រព័ន្ធច្បាប់សម្រាប់ការការពារព័ត៌មានផ្ទាល់ខ្លួន ការផ្តល់អាជ្ញាបណ្ណសម្រាប់ការប្រើប្រាស់ទិន្នន័យសាធារណៈក្នុងពាណិជ្ជកម្ម ការធានាសុវត្ថិភាពនៃការគ្រប់គ្រងទិន្នន័យ។ល។ វាស្ថិតនៅក្រោមយុត្តាធិការរបស់មន្ទីរប្រៃសណីយ៍ និងទូរគមនាគមន៍ ស្នងការនគរបាលខេត្ត និងរដ្ឋបាលខេត្ត។
- ការអនុញ្ញាតឱ្យប្រើប្រាស់ទីធ្លាសាធារណៈ៖ នីតិវិធីសម្រាប់ការអនុញ្ញាតឱ្យប្រើប្រាស់ការបង្ហាញជាបទពិសោធលើដងផ្លូវ ការគ្រប់គ្រងសេវាចល័តថ្មីៗ ច្បាប់ចរាចរណ៍ផ្លូវគោក។ល។ វាស្ថិតនៅក្រោមយុត្តាធិការរបស់ក្រសួងសាធារណការ និងដឹកជញ្ជូន (ចំពោះផ្លូវជាតិ) មន្ទីរសាធារណការ និងដឹកជញ្ជូន ស្នងការនគរបាលខេត្ត (នគរបាលចរាចរណ៍) និងរដ្ឋបាលខេត្ត។

## ៧.៨ ការកែលម្អមុខងារគាំទ្រ (Incubation Functions)

ដោយសារផ្នែកហិរញ្ញវត្ថុ និងបច្ចេកទេសក្នុងស្ថានប័នរដ្ឋ នៅមានកម្រិតនៅឡើយ ដូច្នេះសកម្មភាពនានាដែលអាចទាក់ទាញវិស័យឯកជនក្នុងការអនុវត្តផែនទីបង្ហាញផ្លូវទីក្រុងឆ្លាតវៃ គឺមានសារៈសំខាន់ ក្នុងទីក្រុងសៀមរាប។ ដូចគ្នាផងដែរ រដ្ឋបាលខេត្តសៀមរាប ជាពិសេសទីចាត់ការទីក្រុងឆ្លាតវៃសៀមរាប ត្រូវធ្វើការអនុវត្តផ្សព្វផ្សាយផែនទីបង្ហាញផ្លូវមួយនេះ ដើម្បីទាក់ទាញគម្រោងនានាពីក្រុមហ៊ុនឯកជន មកធ្វើការដោះស្រាយបញ្ហាក្នុងទីក្រុង។

ព្រឹត្តិការណ៍ដែលសហការគ្នាជាមួយវិស័យឯកជន និង/ឬវិស័យសិក្សា ដូចជាការប្រកួតប្រជែងអាជីវកម្មជាដើម អាចបំផុសឱ្យមានគំនិតអាជីវកម្មថ្មីៗពីវិស័យឯកជន ហើយគំនិតអាជីវកម្មទាំងនោះអាចនាំមកនូវផលចំណេញ និងមាននិរន្តរភាព ព្រមទាំងឆ្លុះបញ្ចាំងពីទស្សនៈនៃវិស័យឯកជនផងដែរ។

ដូច្នេះ តម្រូវឱ្យមានយុទ្ធសាស្រ្តគ្រប់គ្រងការបើកចំហនៃគំនិតច្នៃប្រឌិតពីស្ថាប័នឯកជន ដោយមានការជំរុញពីស្ថាប័នរដ្ឋ ហើយគំនិតនៃគម្រោងពីស្ថាប័នឯកជនទាំងនោះ មិនអាស្រ័យលើថវិការដ្ឋ។ ជម្រើសមួយទៀតគឺត្រូវធ្វើការជាមួយក្រុមហ៊ុនដែលមានឯកទេសក្នុងការបង្កើតជាលំហាក្នុងការបណ្ដុះអាជីវកម្ម។

មួយវិញទៀត ក្នុងការជ្រើសរើសគម្រោងពីស្ថាប័នឯកជន ដែលទាក់ទងក្នុងការអភិវឌ្ឍទីក្រុងឆ្លាតវៃ និងការលើកកម្ពស់ផែនទីបង្ហាញផ្លូវ រដ្ឋបាលខេត្ត គួរតែធ្វើការវាយតម្លៃគម្រោងដូចខាងក្រោម៖

- ដំណោះស្រាយ៖ តើគម្រោង មានការចូលរួមចំណែកក្នុងការដោះស្រាយបញ្ហាក្នុងទីក្រុង និងផ្ដល់ផលប្រយោជន៍ដល់ប្រជាពលរដ្ឋមូលដ្ឋាន និងភ្ញៀវទេសចរដែរឬទេ?
- ចីរភាព៖ តើគម្រោង មានលក្ខណៈយូរអង្វែងដែរឬទេ?
- លទ្ធភាព៖ តើស្ថាប័នរដ្ឋ និងស្ថាប័នឯកជនមានធនធានគ្រប់គ្រាន់ក្នុងការអនុវត្តគម្រោងដែរឬទេ?
- យុទ្ធសាស្រ្ត៖ តើគម្រោងនេះ ត្រូវការការអនុវត្តពីវិស័យឯកជន ដែរឬទេ ដើម្បីធ្វើការដោះស្រាយបញ្ហាទីក្រុងដោយយោងតាមផែនទីបង្ហាញផ្លូវ។

## ៧.៩ ការកំណត់តំបន់អាទិភាព

ដើម្បីអនុវត្តគម្រោងអាទិភាពឱ្យមានប្រសិទ្ធភាព ការកំណត់តំបន់ដែលការវិនិយោគជាលក្ខណៈប្រមូលផ្ដុំនៃគម្រោងនេះ និងផ្សព្វផ្សាយគម្រោងនានាដែលពាក់ព័ន្ធនឹងទីក្រុងឆ្លាតវៃ ដល់ប្រជាពលរដ្ឋ និងភ្ញៀវទេសចរ និងធ្វើឱ្យមើលឃើញនូវប្រសិទ្ធភាពនោះ។ ដូច្នេះយើងកំណត់តំបន់កណ្តាលទីក្រុងដែលមានបញ្ហាច្រើនថាជាតំបន់គោលដៅ ហើយផ្ដល់អាទិភាពលើគម្រោងអាទិភាពនានាជាកញ្ចប់។




រូបភាព ៧.៧៖ រូបភាពនៃការណែនាំអំពីកញ្ចប់គម្រោងនៅក្នុងតំបន់កណ្ដាលទីក្រុង

# ជំពូកទី ៨: ទម្រង់នៃគម្រោងអាទិភាព (បង្កើតឡើងនៅក្នុងឆ្នាំ២០២១)

គ្រោងការនៃគម្រោងអាទិភាពគោលដៅឆ្នាំ ២០៣៥ និងផែនការប្រតិបត្តិដែលមានសកម្មភាពរយៈពេលខ្លីកំណត់គោលដៅឆ្នាំ ២០២៥ ត្រូវបានសង្ខេបដូចខាងក្រោម។ គ្រោងការនេះត្រូវបានធ្វើការសង្ខេបនៅក្នុងឆ្នាំ២០២១។ ស្ថានភាពបច្ចុប្បន្នត្រូវបានសរសេររៀបរាប់នៅក្នុងឧបសម្ព័ន្ធ។

## ៨.១ ការគ្រប់គ្រងទិន្នន័យ -DATA MANAGEMENT

### *៨.១.១ គម្រោង D-01៖ ការប្រមូល និងវិភាគទិន្នន័យរួមបញ្ចូលគ្នា*

<table>
<tr><th>គម្រោង D-01</th><th colspan="2">ការប្រមូល និងវិភាគទិន្នន័យរួមបញ្ចូលគ្នា</th></tr>
<tr><td colspan="3">ខ្លឹមសារនៃគម្រោង (គោលដៅឆ្នាំ ២០៣៥)</td></tr>
<tr><td>បញ្ហាឆ្លើយតប</td><td colspan="2">៦. ការមិនទាន់បានអភិវឌ្ឍនូវផ្នែករឹងសម្រាប់គ្រប់គ្រងទិន្នន័យ និងហេដ្ឋារចនាសម្ព័ន្ធទំនាក់ទំនង<br>៧. តម្រូវឲ្យមានការចែកចាយ និងប្រើប្រាស់ទិន្នន័យជាលក្ខណៈពហុវិស័យ</td></tr>
<tr><td>គោលបំណង</td><td colspan="2">បង្កើតប្រព័ន្ធប្រមូល និងវិភាគទិន្នន័យរួមគ្នាអំពីបរិស្ថានទីក្រុង។</td></tr>
<tr><td>គោលដៅគម្រោង</td><td colspan="2">ទាំងរដ្ឋ និងឯកជនអាចធ្វើការសម្រេចចិត្តនានា តាមរយៈការត្រួតពិនិត្យ និងវិភាគបរិស្ថានទីក្រុង។ (ឆ្ពោះទៅការកសាងប្រព័ន្ធប្រតិបត្តិការទីក្រុង)</td></tr>
<tr><td>តំបន់គោលដៅសំខាន់</td><td colspan="2">តំបន់ទាំងមូល</td></tr>
<tr><td>បញ្ហាក្នុងការអនុវត្ត</td><td colspan="2">-កិច្ចសហប្រតិបត្តិការអន្តរកម្មរបស់អង្គភាពរដ្ឋបាលមិនគ្រប់គ្រាន់<br>-ការធ្វើឌីជីថលនីយកម្មពុំទាន់មានគ្រប់គ្រាន់<br>-ឧបករណ៍គ្រប់គ្រងទិន្នន័យមិនគ្រប់គ្រាន់ (រួមទាំងមជ្ឈមណ្ឌលទិន្នន័យ)</td></tr>
<tr><td>សូចនាករ (KPI)</td><td colspan="2">បរិមាណ /ភាពចម្រុះនៃទិន្នន័យដែលបញ្ចូល</td></tr>
<tr><td colspan="3">សកម្មភាពរយៈពេលខ្លី (គម្រោងអាទិភាពសម្រាប់គោលដៅប្រចាំឆ្នាំ ២០២៥)</td></tr>
<tr><td rowspan="3">អង្គភាពអនុវត្ត</td><td>ចម្បង</td><td>រដ្ឋបាលខេត្ត និងមន្ទីរ ប្រៃសណីយ៍ និងទូរគមនាគមន៍</td></tr>
<tr><td>បន្ទាប់បន្សំ</td><td>អាជីវករឯកជន (អ្នកបង្កើតប្រព័ន្ធ) មន្ទីរអង្គភាពជំនាញពាក់ព័ន្ធ ស្នងការនគរបាលខេត្ត</td></tr>
<tr><td>អង្គភាពពាក់ព័ន្ធ</td><td>-</td></tr>
<tr><td>សកម្មភាពចម្បង<br>[ការបែងចែកតួនាទី]</td><td colspan="2">១. ការសម្របសម្រួលនៃអង្គភាពពាក់ព័ន្ធសម្រាប់ការអភិវឌ្ឍថ្នាលទិន្នន័យអន្តរវិស័យ [រដ្ឋបាលខេត្ត ]<br>២. ការរចនា និងការអភិវឌ្ឍថ្នាលទិន្នន័យ (កិច្ចសន្យាសេវាកម្ម Cloud ឬការដំឡើងប្រព័ន្ធថ្មីក្នុងបរិវេណ) [រដ្ឋបាលខេត្ត  មន្ទីរ ប្រៃសណីយ៍ និងទូរគមនាគមន៍ប្រតិបត្តិករឯកជន]<br>៣. ការបញ្ចូលទិន្នន័យស្ថិតិដែលមានស្រាប់ទៅក្នុងថ្នាលទិន្នន័យ [រដ្ឋបាលខេត្ត មន្ទីរអង្គភាពជំនាញពាក់ព័ន្ធ ស្នងការនគរបាលខេត្ត]<br>៤. ការបញ្ចូលទិន្នន័យដែលទទួលបានពីគម្រោងផ្សេងៗទៅក្នុងថ្នាលទិន្នន័យរួមបញ្ចូលគ្នា [រដ្ឋបាលខេត្ត មន្ទីរអង្គភាពជំនាញពាក់ព័ន្ធ ស្នងការនគរបាលខេត្ត]<br>៥. ការថែទាំ និងការត្រួតពិនិត្យប្រព័ន្ធទាំងមូល [ប្រតិបត្តិករឯកជន មន្ទីរ ប្រៃសណីយ៍ និងទូរគមនាគមន៍]</td></tr>
<tr><td rowspan="2">ប្រភពមូលនិធិ / គំរូអាជីវកម្ម</td><td colspan="2">នៅពេលធ្វើលទ្ធកម្មថ្នាលទិន្នន័យជាមួយនឹងកិច្ចសន្យាសេវាកម្មក្លោដ តម្លៃលទ្ធកម្មនឹងមានតម្លៃទាប ដូច្នេះការវិនិយោគដំបូងគឺជាហិរញ្ញប្បទានរបស់រដ្ឋបាលខេត្ត។ ចំពោះថ្លៃប្រតិបត្តិការ និងការថែទាំ គឺជាបន្ទុកចំណាយរបស់រដ្ឋបាលខេត្ត។</td></tr>
<tr><td>ថ្លៃដើមចាប់ផ្តើមដំបូង</td><td>ក្នុងករណីប្រើសេវាកម្មក្លោដ៖ ជាបន្ទុកចំណាយនៃរដ្ឋបាលខេត្ត (ហិរញ្ញប្បទានដោយដៃគូអភិវឌ្ឍន៍ក៏អាចជាចំណែកមួយផងដែរ)</td></tr>
</table>

| | | |
|---|---|---|
| | | ក្នុងករណីដំឡើងនៅទីតាំងផ្ទាល់ ៖ ជាការផ្តល់មូលនិធិគាំទ្រដោយដៃគូអភិវឌ្ឍន៍ (តម្លៃសម្រាប់ជាឯកសារយោង៖ ៣០០ ០០០ ដុល្លារអាមេរិក (សម្រាប់ការអភិវឌ្ឍ software) ៤០០ ០០០ដុល្លារអាមេរិក (សម្រាប់ដំឡើងឧបករណ៍នានា) និង ៥០ ០០០ ដុល្លារអាមេរិក (សម្រាប់ការចំនាយលើការបញ្ចូលទិន្នន័យ)) |
| | ចំណាយលើ ប្រតិបត្តិការ និង ថែទាំ | មូលនិធិរបស់រដ្ឋបាលខេត្ត |

## ៨.១.២ គម្រោង D-០២៖ ការបង្ហាញទិន្នន័យដល់ភាគីពាក់ព័ន្ធ

<table>
<tr><th>គម្រោង D-០២</th><th colspan="2">ការបង្ហាញទិន្នន័យទៅកាន់ភាគីពាក់ព័ន្ធ</th></tr>
<tr><td colspan="3">ខ្លឹមសារនៃគម្រោង (គោលដៅឆ្នាំ ២០៣៥)</td></tr>
<tr><td>បញ្ហាឆ្លើយតប</td><td colspan="2">៨. តម្រូវការប្រព័ន្ធទិន្នន័យចំហ សុវត្ថិភាពទិន្នន័យ និងបទប្បញ្ញត្តិ</td></tr>
<tr><td>គោលបំណង</td><td colspan="2">បង្កើតប្រព័ន្ធបង្ហាញទិន្នន័យដើម្បីឱ្យភាគីពាក់ព័ន្ធអាចប្រើប្រាស់ និងទទួលបានអត្ថប្រយោជន៍ពីប្រព័ន្ធនោះ។</td></tr>
<tr><td>គោលដៅគម្រោង</td><td colspan="2">ទិន្នន័យទាក់ទងនឹងទីក្រុងឆ្លាតវៃ គួរតែត្រូវបានចែករំលែកជាមួយអ្នកពាក់ព័ន្ធតាមការសមស្រប លើកលែងតែទិន្នន័យពាក់ព័ន្ធនឹងឯកជនភាពជាដើម។</td></tr>
<tr><td>តំបន់គោលដៅសំខាន់</td><td colspan="2">តំបន់ទាំងមូល</td></tr>
<tr><td>បញ្ហាក្នុងការអនុវត្ត</td><td colspan="2">-ដំណើរការបង្ហាញទិន្នន័យ និងការប្រើប្រាស់មិនត្រូវបានបង្កើតឡើង។<br>-ប្រព័ន្ធគ្រប់គ្រងសុវត្ថិភាពទិន្នន័យមិនត្រូវបានបង្កើតឡើង។</td></tr>
<tr><td>សូចនាករ (KPI)</td><td colspan="2">-ចំនួនទិន្នន័យដែលត្រូវបើកចំហ និងចំនួននៃការចូលប្រើប្រាស់</td></tr>
<tr><td colspan="3">សកម្មភាពរយៈពេលខ្លី (គម្រោងអាទិភាពសម្រាប់គោលដៅប្រចាំឆ្នាំ ២០២៥)</td></tr>
<tr><td rowspan="3">អង្គភាពអនុវត្ត</td><td>ចម្បង</td><td>រដ្ឋបាលខេត្ត មន្ទីរប្រៃសណីយ៍ និងទូរគមនាគមន៍</td></tr>
<tr><td>បន្ទាប់បន្សំ</td><td>ប្រតិបត្តិករឯកជន (អ្នកផ្តល់វេទិកា) មន្ទីរអង្គភាពជំនាញពាក់ព័ន្ធ ស្នងការនគរបាលខេត្ត</td></tr>
<tr><td>អង្គភាពពាក់ព័ន្ធ</td><td>ប្រតិបត្តិករអាជីវកម្មឯកជន (អ្នកទទួលផលទិន្នន័យ)</td></tr>
<tr><td>សកម្មភាពចម្បង<br>[ការបែងចែកតួនាទី]</td><td colspan="2">១.ការពិនិត្យមើលច្បាប់ និងបទប្បញ្ញត្តិគ្រប់គ្រងទិន្នន័យ [រដ្ឋបាលខេត្ត មន្ទីរប្រៃសណីយ៍ និងទូរគមនាគមន៍]<br>២.ដំណើរការទិន្នន័យសម្រាប់ការពិចារណាឯកជនភាពសម្រាប់ការបង្ហាញទិន្នន័យ [មន្ទីរប្រៃសណីយ៍ និងទូរគមនាគមន៍]<br>៣. ព័ត៌មាននីមួយៗដែលរក្សាទុកក្នុងគម្រោង D-០១ នឹងត្រូវបង្ហាញជាសាធារណៈតាមរយៈ API ដោយគិតគូរពីការការពារព័ត៌មានផ្ទាល់ខ្លួន។ [រដ្ឋបាលខេត្ត មន្ទីរ ប្រៃសណីយ៍ និងទូរគមនាគមន៍]</td></tr>
<tr><td rowspan="3">ប្រភពមូលនិធិ /<br>គំរូអាជីវកម្ម</td><td colspan="2">ការវិនិយោគដំបូងនឹងត្រូវបានអនុវត្តនៅក្នុងគម្រោង D-០១ ដូច្នេះវាមិនត្រូវបានសន្មតទេ។ ការចំណាយលើប្រតិបត្តិការ និងការថែទាំក៏នឹងត្រូវបានដាក់បញ្ចូលជាមួយគម្រោង D-០១ ផងដែរ ប៉ុន្តែសកម្មភាពសាជីវកម្មនឹងកាន់តែសកម្មដោយផ្អែកលើព័ត៌មានដែលបានបង្ហាញ ហើយចំនួនប្រាក់ចំណេញជាក់លាក់នឹងចូលក្នុងរដ្ឋបាលខេត្ត ពីចំណូលពន្ធទាក់ទងនឹងសកម្មភាពសាជីវកម្ម ហើយសន្មតថាវានឹងត្រូវយកបំពេញដល់ចំណាយប្រតិបត្តិការនិងថែទាំនៃគម្រោង D-០១។</td></tr>
<tr><td>ថ្លៃដើមចាប់ផ្តើមដំបូង</td><td>-</td></tr>
<tr><td>ចំណាយលើប្រតិបត្តិការ និងថែទាំ</td><td>មូលនិធិរបស់រដ្ឋបាលខេត្ត</td></tr>
</table>

## ៨.២ ទេសចរណ៍ឆ្លាតវៃ

### *៨.២.១ គម្រោង T-០១៖ ការអភិវឌ្ឍវេទិកាផ្សព្វផ្សាយទេសចរណ៍*

| គម្រោង T-០១ | ការអភិវឌ្ឍវេទិកាផ្សព្វផ្សាយទេសចរណ៍ | |
|---|---|---|
| ខ្លឹមសារនៃគម្រោង (គោលដៅឆ្នាំ ២០៣៥) | | |
| បញ្ហាកំពុងមាន | ៩. កង្វះការផ្សព្វផ្សាយជាទីក្រុងទេសចរណ៍ | |
| គោលបំណង | ដើម្បីទាក់ទាញភ្ញៀវទេសចរ មកខេត្តសៀមរាបកាន់តែច្រើនឡើង។ | |
| គោលដៅគម្រោង | ផ្សព្វផ្សាយសេវាកម្មទេសចរណ៍ផ្សេងៗនៅលើទម្រង់តែមួយ។ | |
| តំបន់គោលដៅ | តំបន់ទាំងមូល | |
| ការគ្រប់គ្រងទិន្នន័យ | -ស្ថានភាពប្រជាសាស្ត្រនៃភ្ញៀវទេសចរណ៍<br>-ចំណង់ចំណូលចិត្តនៃភ្ញៀវទេសចរណ៍<br>-អាកប្បកិរិយានៃភ្ញៀវទេសចរណ៍<br>-មតិយោបល់រិះគន់របស់ភ្ញៀវទេសចរណ៍ | |
| បញ្ហាដែលត្រូវដោះស្រាយ | -បន្ទុកនៃការចំណាយលើការអភិវឌ្ឍវេទិកា<br>-វិធានការធានាចំនួននៃអ្នកប្រើប្រាស់<br>-យន្តការដែលអនុញ្ញាតឱ្យមានការធ្វើបច្ចុប្បន្នភាពជាបន្តបន្ទាប់ | |
| សូចនាករ (KPI) | ចំនួននៃអ្នកមើល | |
| សកម្មភាពរយៈពេលខ្លី (គម្រោងអាទិភាពសម្រាប់គោលដៅប្រចាំឆ្នាំ ២០២៥) | | |
| អង្គភាពអនុវត្ត | ចម្បង | មន្ទីរទេសចរណ៍ប្រតិបត្តិករទេសចរណ៍ (អ្នកបង្កើតប្រព័ន្ធ) |
| | បន្ទាប់បន្សំ | ក្រុមហ៊ុនឯកជន (អ្នកផ្តល់សេវាទេសចរណ៍)មន្ទីរប្រៃសណីយ៍ និងទូរគមនាគមន៍ |
| | អង្គភាពពាក់ព័ន្ធ | - |
| សកម្មភាពចម្បង [ការបែងចែកតួនាទី] | ១. ការយល់ដឹងពីតម្រូវការរបស់ភ្ញៀវទេសចរសម្រាប់ការទៅលេងខេត្តសៀមរាប (ទេសចរណ៍ MICE ។ល។) និងផែនការទាក់ទងនឹងការផ្សព្វផ្សាយ [មន្ទីរទេសចរណ៍]<br>២.ការអភិវឌ្ឍទម្រង់សម្រាប់ការផ្សព្វផ្សាយ [ប្រតិបត្តិករអាជីវកម្មឯកជន (អ្នកបង្កើតប្រព័ន្ធ)]<br>៣. ការអភិវឌ្ឍខ្លឹមសារផ្សព្វផ្សាយ និងការបង្ហោះនៅលើវេទិកា (VR ។ល។) [អាជីវករឯកជន (អ្នកផ្តល់សេវាទេសចរណ៍នីមួយៗ)]<br>៤. ប្រតិបត្តិការនៃទម្រង់ផ្សព្វផ្សាយ [ក្រុមហ៊ុនឯកជន (អ្នកបង្កើតប្រព័ន្ធ)]<br>៥. ការផ្ទុកទិន្នន័យ និងការបង្ហាញទៅកាន់ថ្នាលទិន្នន័យ [មន្ទីរប្រៃសណីយ៍ និងទូរគមនាគមន៍] | |
| ប្រភពមូលនិធិ / គំរូអាជីវកម្ម | ដោយសារវាជាគម្រោងសាធារណៈកម្រិតខ្ពស់ដែលរួមចំណែកយ៉ាងទូលំទូលាយដល់ការលើកកម្ពស់ឧស្សាហកម្មទេសចរណ៍ក្នុងខេត្តសៀមរាប ហើយចំនួនទុនវិនិយោគមានតិចតួច ដូច្នេះការវិនិយោគដំបូងរំពឹងថានឹងធ្វើឡើងតាមរយៈមូលនិធិរបស់មន្ទីរទេសចរណ៍។<br>ជាការសន្មតមន្ទីរទេសចរណ៍ខេត្តនឹងធ្វើការប្រមូលថ្លៃផ្សព្វផ្សាយពីប្រតិបត្តិករទេសចរណ៍ដែលបានធ្វើការផ្សព្វផ្សាយអាជីវកម្មរបស់ខ្លួននៅនៅលើមាតិកាផ្សព្វផ្សាយទេសចរណ៍ ដែលថវិកាទាំងនេះនឹងត្រូវបានប្រើប្រាស់សម្រាប់ប្រតិបត្តិការ និងការថែទាំ។ | |
| | ថ្លៃដើមចាប់ផ្តើមដំបូង | មូលនិធិ មន្ទីរទេសចរណ៍ (ហិរញ្ញប្បទានដោយដៃគូអភិវឌ្ឍន៍ក៏ត្រូវបានសន្មតថាជាចំណែកមួយផងដែរ) |
| | ចំណាយលើប្រតិបត្តិការ និងថែទាំ | ការប្រមូលថ្លៃផ្សព្វផ្សាយពីអាជីវករឯកជន (អ្នកផ្តល់សេវាទេសចរណ៍) |

## ៨.២.២ គម្រោង T-0២៖ ការផ្តោតទៅលើប្រព័ន្ធនៃការកក់ និងការទូទាត់

| គម្រោងT-0២ | ការផ្តោតទៅលើប្រព័ន្ធនៃការកក់ និងការទូទាត់ | |
|---|---|---|
| ខ្លឹមសារនៃគម្រោង (គោលដៅឆ្នាំ ២០៣៥) | | |
| បញ្ហាឆ្លើយតប | -៩. កង្វះការផ្សព្វផ្សាយជាទីក្រុងទេសចរណ៍<br>-១០. កង្វះភាពងាយស្រួលសម្រាប់សកម្មភាពទេសចរណ៍ | |
| គោលបំណង | ដើម្បីបង្កភាពងាយស្រួលដល់អ្នកដំណើរម្នាក់ៗ ក្នុងការបង្កើតផែនការទេសចរណ៍ផ្ទាល់ខ្លួន។ | |
| គោលដៅគម្រោង | ដំណើរការវេទិកាដែលអនុញ្ញាតឱ្យមានការកក់ទុក និងការទូទាត់សម្រាប់មាតិកាទេសចរណ៍ផ្សេងៗ ។ | |
| តំបន់គោលដៅសំខាន់ | តំបន់ទាំងមូល | |
| ការគ្រប់គ្រងទិន្នន័យ | -កន្លែងទស្សនាកម្សាន្តដែលបានកក់ទុកដោយបុគ្គលម្នាក់ៗ | |
| សូចនាករ (KPI) | -ការចូលរួមរបស់ក្រុមហ៊ុនទេសចរណ៍នីមួយៗ<br>-សម្របសម្រួលផលប្រយោជន៍ជាមួយភ្នាក់ងារទេសចរណ៍ដែលមានស្រាប់ | |
| បញ្ហាឆ្លើយតប | ចំនួនអ្នកប្រើប្រាស់ (ចំនួននៃការកក់ទុក) | |
| សកម្មភាពរយៈពេលខ្លី (គម្រោងអាទិភាពសម្រាប់គោលដៅប្រចាំឆ្នាំ ២០២៥) | | |
| អង្គភាពអនុវត្ត | ចម្បង | មន្ទីរទេសចរណ៍ ប្រតិបត្តិករទេសចរណ៍ (អ្នកបង្កើតប្រព័ន្ធ) |
| | បន្ទាប់បន្សំ | អាជីវករឯកជន (អ្នកផ្តល់មាតិកាទេសចរណ៍នីមួយៗ)មន្ទីរប្រៃសណីយ៍ និងទូរគមនាគមន៍ |
| | អង្គភាពពាក់ព័ន្ធ | - |
| សកម្មភាពចម្បង [ការបែងចែកតួនាទី] | ១. ការសិក្សារៀបចំផែនការលើការកក់និងការទូទាត់នៅកន្លែងតែមួយ សម្រាប់សេវាកម្មទេសចរណ៍ [មន្ទីរទេសចរណ៍]<br>២. ការបង្កើតវេទិកាតែមួយសម្រាប់ការកក់ និងការទូទាត់ប្រាក់សម្រាប់សេវាកម្មទេសចរណ៍ [ប្រតិបត្តិករទេសចរណ៍ (អ្នកបង្កើតប្រព័ន្ធ)]<br>៣. ទាក់ទាញការបោះពុម្ពផ្សាយសេវាកម្មទេសចរណ៍ផ្សេងៗ [មន្ទីរទេសចរណ៍]<br>៤. ប្រតិបត្តិការនៃវេទិកាការកក់ / ទូទាត់ [ប្រតិបត្តិករអាជីវកម្មឯកជន (អ្នកបង្កើតប្រព័ន្ធ)]<br>៥. ការផ្ទុកទិន្នន័យ និងការបង្ហាញទៅកាន់ថ្នាលទិន្នន័យ [មន្ទីរ ប្រៃសណីយ៍ និងទូរគមនាគមន៍] | |
| ប្រភពមូលនិធិ / គំរូអាជីវកម្ម | វាត្រូវបានសន្មតថាថ្លៃផ្សព្វផ្សាយនឹងត្រូវបានប្រមូលពីក្រុមហ៊ុនទេសចរណ៍ដែលផ្សព្វផ្សាយសេវាកម្ម ហើយនឹងត្រូវប្រើប្រាស់សម្រាប់ប្រតិបត្តិការ និងថ្លៃថែទាំ។ | |
| | ថ្លៃដើមចាប់ផ្តើមដំបូង | មូលនិធិ មន្ទីរទេសចរណ៍ (ហិរញ្ញប្បទានដោយដៃគូអភិវឌ្ឍន៍ក៏ត្រូវបានសន្មតថាជាចំណែកមួយផងដែរ) |
| | ចំណាយលើប្រតិបត្តិការ និងថែទាំ | ការប្រមូលថ្លៃផ្សព្វផ្សាយពីអាជីវកម្មឯកជន (អ្នកផ្តល់សេវាទេសចរណ៍) |

## ៨.២.៣ គម្រោង T-០៣៖ ការអភិវឌ្ឍការចែករំលែកនូវសេវាចល័តរួម

| គម្រោង T-០៣ | ការអភិវឌ្ឍការចែករំលែកនូវសេវាចល័តរួម | |
|---|---|---|
| ខ្លឹមសារនៃគម្រោង (គោលដៅឆ្នាំ ២០៣៥) | | |
| បញ្ហាឆ្លើយតប | ១០. កង្វះភាពងាយស្រួលសម្រាប់សកម្មភាពទេសចរណ៍ | |
| គោលបំណង | ការធ្វើឱ្យប្រសើរឡើងការធ្វើដំណើរសម្រាប់ភ្ញៀវទេសចរ | |
| គោលដៅគម្រោង | ធ្វើការផ្សព្វផ្សាយសេវាចល័តតូចៗ និងធ្វើការផ្សព្វផ្សាយទៅដល់ភ្ញៀវទេសចរ | |
| តំបន់គោលដៅសំខាន់ | តំបន់ទាំងមូល | |
| ការគ្រប់គ្រងទិន្នន័យ | -ស្ថានភាពប្រើប្រាស់ (ព័ត៌មាន ទីតាំង ។ល។) | |
| បញ្ហាក្នុងការអនុវត្ត | -សម្របសម្រួលផលប្រយោជន៍ជាមួយនឹងសេវាចល័តដែលមានស្រាប់ | |
| សូចនាករ (KPI) | ចំនួនអ្នកប្រើប្រាស់ | |
| សកម្មភាពរយៈពេលខ្លី (គម្រោងអាទិភាពសម្រាប់គោលដៅប្រចាំឆ្នាំ ២០២៥) | | |
| អង្គភាពអនុវត្ត | ចម្បង | រដ្ឋបាលខេត្ត អាជីវកម្មឯកជន (ប្រតិបត្តិករអាជីវកម្ម) |
| | បន្ទាប់បន្សំ | មន្ទីរទេសចរណ៍ មន្ទីរប្រៃសណីយ៍ និងទូរគមនាគមន៍ |
| | អង្គភាពពាក់ព័ន្ធ | - |
| សកម្មភាពចម្បង [ការបែងចែកតួនាទី] | ១. ការពិនិត្យទម្រង់នៃសេវាចល័ត ដែលអាចធ្វើទៅបាន (ការពិនិត្យពីទិដ្ឋភាពបទប្បញ្ញត្តិ និងតម្រូវការ) [រដ្ឋបាលខេត្ត]<br>២. ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធផ្នែករឹង និងផ្នែកទន់ ដែលនឹងក្លាយជាមូលដ្ឋានសម្រាប់ការណែនាំសេវាចល័តរួមគ្នា [រដ្ឋបាលខេត្ត  អាជីវកម្មឯកជន (អាជីវកម្ម)]<br>៣. ប្រតិបត្តិការនៃការបង់ប្រាក់សេវាចល័តរួមគ្នា [អាជីវកម្មឯកជន (អាជីវកម្ម)]<br>៤. ការត្រួតពិនិត្យស្ថានភាពប្រតិបត្តិការ [រដ្ឋបាលខេត្ត ]<br>៥. ការប្រមូលទិន្នន័យ និងការបង្ហាញទម្រង់នៃទិន្នន័យ [មន្ទីរប្រៃសណីយ៍ និងទូរគមនាគមន៍] | |
| ប្រភពមូលនិធិ/ គំរូអាជីវកម្ម | ដោយសារវាជាគម្រោងសាធារណៈកម្រិតខ្ពស់ដែលបានរួមចំណែកយ៉ាងទូលំទូលាយដល់ការលើកកម្ពស់ឧស្សាហកម្មទេសចរណ៍ក្នុងខេត្តសៀមរាប ហើយចំនួនទុនវិនិយោគមានតិចតួច ដូចនេះការវិនិយោគដំបូងនឹងធ្វើឡើងដោយមូលនិធិផ្ទាល់របស់មន្ទីរទេសចរណ៍។<br>វាត្រូវបានសន្មតថាថ្លៃប្រើប្រាស់នឹងត្រូវបានប្រមូលពីអ្នកទេសចរដែលប្រើប្រាស់សេវាកម្ម ហើយវានឹងត្រូវប្រើប្រាស់សម្រាប់ប្រតិបត្តិការ និងថ្លៃថែទាំ។ | |
| | ថ្លៃដើមចាប់ផ្តើមដំបូង | ថវិការដ្ឋបាលខេត្ត (ហិរញ្ញប្បទានដោយដៃគូអភិវឌ្ឍន៍ក៏ត្រូវបានសន្មតថាជាចំណែកមួយផងដែរ) |
| | ចំណាយលើប្រតិបត្តិការ និងថែទាំ | ថ្លៃប្រើប្រាស់ពីអ្នកទេសចរដែលប្រើប្រាស់សេវាកម្ម |

## ៨.២.៤ គម្រោង T-04៖ សេវាកម្មធ្វើដំណើរទេសចរណ៍ (MaaS)

<table>
<tr><th>គម្រោង T-04</th><th colspan="2">សេវាកម្មធ្វើដំណើរទេសចរណ៍</th></tr>
<tr><td colspan="3">ខ្លឹមសារនៃគម្រោង (គោលដៅឆ្នាំ ២០៣៥)</td></tr>
<tr><td>បញ្ហាឆ្លើយតប</td><td colspan="2">១០. កង្វះភាពងាយស្រួលសម្រាប់សកម្មភាពទេសចរណ៍</td></tr>
<tr><td>គោលបំណង</td><td colspan="2">ការធ្វើឱ្យប្រសើរឡើងនូវមធ្យោបាយធ្វើដំណើរសម្រាប់ភ្ញៀវទេសចរ</td></tr>
<tr><td>គោលដៅគម្រោង</td><td colspan="2">តាមរយៈ MaaS នឹងអនុញ្ញាតឱ្យអ្នកទេសចរជ្រើសរើសពីមធ្យោបាយដឹកជញ្ជូនជាច្រើន និងធ្វើការបង់ប្រាក់នៅលើទម្រង់តែមួយ។</td></tr>
<tr><td>តំបន់គោលដៅសំខាន់</td><td colspan="2">តំបន់ទាំងមូល</td></tr>
<tr><td>ការគ្រប់គ្រងទិន្នន័យ</td><td colspan="2">-ស្ថានភាពប្រើប្រាស់ (លក្ខណៈផ្ទាល់ខ្លួន ចំនួននៃការកក់ទុក ព័ត៌មានទីតាំង។ល។)</td></tr>
<tr><td>បញ្ហាក្នុងការអនុវត្ត</td><td colspan="2">-សម្របសម្រួលផលប្រយោជន៍ជាមួយនឹងសេវាចល័តដែលមានស្រាប់</td></tr>
<tr><td>សូចនាករ (KPI)</td><td colspan="2">ចំនួនអ្នកប្រើប្រាស់</td></tr>
<tr><td colspan="3">សកម្មភាពរយៈពេលខ្លី (គម្រោងអាទិភាពសម្រាប់គោលដៅប្រចាំឆ្នាំ ២០២៥)</td></tr>
<tr><td rowspan="3">អង្គភាពអនុវត្ត</td><td>ចម្បង</td><td>រដ្ឋបាលខេត្ត អាជីវកម្មឯកជន (អ្នកបង្កើតប្រព័ន្ធ)</td></tr>
<tr><td>បន្ទាប់បន្សំ</td><td>អាជីវកម្មឯកជន (ប្រតិបត្តិករមធ្យោបាយចរាចរណ៍នីមួយៗ ភ្នាក់ងារទេសចរណ៍) មន្ទីរប្រៃសណីយ៍ និងទូរគមនាគមន៍</td></tr>
<tr><td>អង្គភាពពាក់ព័ន្ធ</td><td>-</td></tr>
<tr><td>សកម្មភាពចម្បង [ការបែងចែកតួនាទី]</td><td colspan="2">១. ការធ្វើផែនការ និងការសិក្សាពីការអភិវឌ្ឍសេវាកម្មធ្វើដំណើរទេសចរណ៍ MaaS [រដ្ឋបាលខេត្ត ]<br>២. ការសម្របសម្រួលជាមួយភាគីពាក់ព័ន្ធ [រដ្ឋបាលខេត្ត ]<br>៣. ការអភិវឌ្ឍប្រព័ន្ធធ្វើដំណើរទេសចរណ៍ MaaS [ប្រតិបត្តិករអាជីវកម្មឯកជន (អ្នកបង្កើតប្រព័ន្ធ)]<br>៤. ការរៀបចំប្រភេទនៃមធ្យោបាយដឹកជញ្ជូនដែលត្រូវធ្វើការចុះបញ្ជី [វិស័យឯកជន (ប្រតិបត្តិករនៃមធ្យោបាយដឹកជញ្ជូននីមួយៗ)]<br>៥. ការផ្សព្វផ្សាយដល់អ្នកប្រើប្រាស់ [រដ្ឋបាលខេត្ត អាជីវកម្មឯកជន (អ្នកបង្កើតប្រព័ន្ធ)]<br>៦. ប្រតិបត្តិការប្រព័ន្ធ [ប្រតិបត្តិករអាជីវកម្មឯកជន (អ្នកបង្កើតប្រព័ន្ធ)]<br>៧. ការផ្ទុកទិន្នន័យ និងការបង្ហាញទៅកាន់ទម្រង់នៃទិន្នន័យ [មន្ទីរប្រៃសណីយ៍ និងទូរគមនាគមន៍]</td></tr>
<tr><td rowspan="3">ប្រភពមូលនិធិ / គំរូអាជីវកម្ម</td><td colspan="2">វាត្រូវបានសន្មតថាវិស័យឯកជនដែលជាស្ថាប័នអនុវត្តនឹងរួមចំណែកក្នុងការវិនិយោគដំបូង និងប្រតិបត្តិការ និងថ្លៃថែទាំជាមួយនឹងមូលនិធិផ្ទាល់ខ្លួនរបស់ពួកគេ។</td></tr>
<tr><td>ថ្លៃដើមចាប់ផ្តើមដំបូង</td><td>មូលនិធិផ្ទាល់ខ្លួនរបស់វិស័យឯកជន</td></tr>
<tr><td>ចំណាយលើប្រតិបត្តិការ និងថែទាំ</td><td>មូលនិធិផ្ទាល់ខ្លួនរបស់វិស័យឯកជន (ការប្រមូលថ្លៃប្រើប្រាស់ពីអ្នកប្រើប្រាស់សេវា)</td></tr>
</table>







***បច្ចុប្បន្ន***

- ភ្ញៀវទេសចរភាគច្រើនជ្រើសរើសទស្សនាវង់តូច/ធំ
- ភ្ញៀវទេសចរមួយចំនួនប្រើប្រាស់មធ្យោបាយធ្វើដំណើរតាមរយៈ APP ( ឧ. PassApp ) សម្រាប់ការធ្វើដំណើរ ប៉ុន្តែការប្រាស្រ័យទាក់ទងផ្ទាល់មាត់រវាងភ្ញៀវទេសចរ និងអ្នកបើកបរហាក់ដូចជាមានការលំបាក។

***ពេលអនាគត***

- MaaS ជាកម្មវិធីដែលមានលទ្ធភាពក្នុងការប្រើប្រាស់ដោយសុវត្ថិភាព ងាយស្រួល ភាពទន់ភ្លន់ តម្លាភាព ព្រមទាំងគ្រប់ពេល និងគ្រប់ទីកន្លែង។
- ភ្ញៀវទេសចរមិនគ្រាន់តែទស្សនាតែទីតាំងទេសចរណ៍ប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងបានរីករាយជាមួយនឹងសកម្មភាពផ្សេងទៀតផងដែរ ឧ. ការទទួលទានអាហារ ឬការទទួលបានបទពិសោធន៍ផ្សេងៗ។

រូបភាព ៨.១៖ រូបភាពនៃការប្រើប្រាស់ MaaS

### ៨.២.៥ គម្រោង T-០៥៖ ការដាក់ឱ្យប្រើប្រាស់ប្រព័ន្ធទូទាត់អេឡិចត្រូនិកក្នុងស្រុក ដោយប្រើលេខកូដ QR

<table>
<tr><th>គម្រោង T-០៥</th><th colspan="2">ការដាក់ឱ្យប្រើប្រាស់ប្រព័ន្ធទូទាត់អេឡិចត្រូនិកក្នុងស្រុក ដោយប្រើកូដ QR</th></tr>
<tr><td colspan="3">ខ្លឹមសារនៃគម្រោង (គោលដៅឆ្នាំ ២០៣៥)</td></tr>
<tr><td>បញ្ហាឆ្លើយតប</td><td colspan="2">១០. កង្វះភាពងាយស្រួលសម្រាប់សកម្មភាពទេសចរណ៍</td></tr>
<tr><td>គោលបំណង</td><td colspan="2">ធ្វើឱ្យនីតិវិធីនៃការទូទាត់ប្រាក់នៅទីតាំងនោះមានភាពរលូនជាងមុន និងធ្វើឱ្យអាកប្បកិរិយាការទិញកាន់តែច្រើនដោយគ្មានភាពតានតឹង។</td></tr>
<tr><td>គោលដៅគម្រោង</td><td colspan="2">ណែនាំប្រព័ន្ធទូទាត់អេឡិចត្រូនិកក្នុងស្រុកដោយប្រើប្រាស់លេខកូដ QR និងធ្វើឱ្យការទូទាត់តាមអេឡិចត្រូនិកកាន់តែពេញនិយមក្នុងទីក្រុង</td></tr>
<tr><td>តំបន់គោលដៅសំខាន់</td><td colspan="2">តំបន់ទាំងមូល</td></tr>
<tr><td>ការគ្រប់គ្រងទិន្នន័យ</td><td colspan="2">-ព័ត៌មានអំពីការទិញ</td></tr>
<tr><td>បញ្ហាក្នុងការអនុវត្ត</td><td colspan="2">-</td></tr>
<tr><td>សូចនាករ (KPI)</td><td colspan="2">ចំនួនដងនៃការប្រើប្រាស់</td></tr>
<tr><td colspan="3">សកម្មភាពរយៈពេលខ្លី (គម្រោងអាទិភាពសម្រាប់គោលដៅប្រចាំឆ្នាំ ២០២៥)</td></tr>
<tr><td rowspan="3">អង្គភាពអនុវត្ត</td><td>ចម្បង</td><td>រដ្ឋបាលខេត្ត វិស័យឯកជន (អ្នកបង្កើតប្រព័ន្ធ)</td></tr>
<tr><td>បន្ទាប់បន្សំ</td><td>វិស័យឯកជន (ម្ចាស់ហាងនីមួយៗ)</td></tr>
<tr><td>អង្គភាពពាក់ព័ន្ធ</td><td>-</td></tr>
<tr><td>សកម្មភាពចម្បង [ការបែងចែកតួនាទី]</td><td colspan="2">១. ការធ្វើផែនការ និងការសិក្សានៃប្រព័ន្ធទូទាត់អេឡិចត្រូនិកក្នុងស្រុកដោយប្រើប្រាស់លេខកូដ QR [រដ្ឋបាល ខេត្ត]<br>២. ការអភិវឌ្ឍប្រព័ន្ធ [វិស័យឯកជន (អ្នកបង្កើតប្រព័ន្ធ)]<br>៣. ពន្យល់ពីការប្រើប្រាស់ប្រព័ន្ធទៅវិស័យឯកជន [រដ្ឋបាលខេត្ត]<br>៤. ប្រតិបត្តិការប្រព័ន្ធ [វិស័យឯកជន (អ្នកបង្កើតប្រព័ន្ធ)]</td></tr>
<tr><td rowspan="3">ប្រភពមូលនិធិ / គំរូអាជីវកម្ម</td><td colspan="2">វាត្រូវបានសន្មតថាការចំណាយលើការវិនិយោគដំបូងនឹងត្រូវបានគ្របដណ្តប់ដោយមូលនិធិផ្ទាល់ខ្លួនរបស់វិស័យឯកជន (អ្នកបង្កើតប្រព័ន្ធ)។ វាត្រូវបានសន្មតថាថ្លៃសេវាដែលកើតឡើងនៅពេលធ្វើការទូទាត់នឹងត្រូវប្រើប្រាស់សម្រាប់ប្រតិបត្តិការ និងថ្លៃថែទាំ។</td></tr>
<tr><td>ថ្លៃដើមចាប់ផ្តើមដំបូង</td><td>មូលនិធិផ្ទាល់ខ្លួនរបស់ម្ចាស់អាជីវកម្មឯកជន</td></tr>
<tr><td>ចំណាយលើប្រតិបត្តិការ និងថែទាំ</td><td>វិស័យឯកជន</td></tr>
</table>

## ៨.២.៦ គម្រោង T-0៦៖ លើកកម្ពស់បទពិសោធន៍ទេសចរណ៍ក្នុងស្រុកដោយប្រើប្រាស់បច្ចេកវិទ្យា AR

| គម្រោង T-0៦ | ការលើកកម្ពស់នៃបទពិសោធន៍ទេសចរណ៍ក្នុងស្រុកដោយប្រើប្រាស់ AR | |
|---|---|---|
| ខ្លឹមសារនៃគម្រោង (គោលដៅឆ្នាំ ២០៣៥) | | |
| បញ្ហាឆ្លើយតប | ១១. ភាពទាក់ទាញនៃបទពិសោធន៍ក្នុងស្រុកនៅកន្លែងទេសចរណ៍ | |
| គោលបំណង | ការកែលម្អការយល់ដឹង និងការពេញចិត្តរបស់ភ្ញៀវទេសចរអំពីតំបន់ទេសចរណ៍នៅតាមគោលដៅទេសចរណ៍ | |
| គោលដៅគម្រោង | មាតិកា AR ដែលធ្វើឱ្យបទពិសោធន៍ក្នុងតំបន់កាន់តែទាក់ទាញ នឹងត្រូវបានផ្ដល់ជូននៅតាមកន្លែងទេសចរណ៍នីមួយៗ | |
| តំបន់គោលដៅសំខាន់ | តំបន់ទាំងមូល | |
| ការគ្រប់គ្រងទិន្នន័យ | - គម្រូ 3D<br>- ទិន្នន័យទីតាំង<br>- ទិន្នន័យអ្នកប្រើ | |
| បញ្ហាក្នុងការអនុវត្ត | -សម្របសម្រួលផលប្រយោជន៍ជាមួយមគ្គុទ្ទេសក៍ទេសចរណ៍ដែលមានស្រាប់ ។ល។ | |
| សូចនាករ (KPI) | ចំនួននៃការមើល | |
| សកម្មភាពរយៈពេលខ្លី (គម្រោងអាទិភាពសម្រាប់គោលដៅប្រចាំឆ្នាំ ២០២៥) | | |
| អង្គភាពអនុវត្ត | ចម្បង | មន្ទីរទេសចរណ៍ អាជ្ញាធរជាតិអប្សរា ប្រតិបត្តិករអាជីវកម្មឯកជន (ប្រតិបត្តិករនៃកន្លែងទេសចរណ៍នីមួយៗ) |
| | បន្ទាប់បន្សំ | ប្រតិបត្តិករអាជីវកម្មឯកជន (អ្នកបង្កើតមាតិកានិម្មិត) |
| | អង្គភាពពាក់ព័ន្ធ | - |
| សកម្មភាពចម្បង [ការបែងចែកតួនាទី] | ១. ការរៀបចំផែនការមាតិកានិម្មិត (រួមទាំង AR) [មន្ទីរទេសចរណ៍ អាជ្ញាធរជាតិអប្សរា វិស័យឯកជន (ម្ចាស់អាជីវកម្មទេសចរណ៍នីមួយៗ)]<br>២. ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរឹង (ស្លាកសញ្ញាព័ត៌មានលេខកូដ QR ។ល។) សម្រាប់ចូលប្រើប្រាស់ មាតិកានិម្មិត (AR) [មន្ទីរទេសចរណ៍ អាជ្ញាធរជាតិអប្សរា វិស័យឯកជន (ម្ចាស់អាជីវកម្មទេសចរណ៍នីមួយៗ)]<br>៣. ការបង្កើត ការផ្សព្វផ្សាយ និងអភិវឌ្ឍច្បាប់សម្រាប់ប្រើប្រាស់មាតិកានិម្មិត [មន្ទីរទេសចរណ៍ អាជ្ញាធរជាតិអប្សរា] | |
| ប្រភពមូលនិធិ / គំរូអាជីវកម្ម | វាត្រូវបានសន្មតថាចំនួនវិនិយោគនឹងត្រូវបានទាញយកមកវិញដោយការលក់មាតិកានិម្មិត AR ដល់ភ្ញៀវទេសចរនៅក្នុងស្រុក។ | |
| | ថ្លៃដើមចាប់ផ្ដើមដំបូង | អាជ្ញាធរជាតិអប្សរា ប្រតិបត្តិករអាជីវកម្មឯកជន (ម្ចាស់អាជីវកម្មទេសចរណ៍នីមួយៗ) (ប្រាក់ចំណូលពីភ្ញៀវទេសចរ) |
| | ចំណាយលើប្រតិបត្តិការ និងថែទាំ | ត្រូវចំណាយដោយសហការរវាងរដ្ឋ និងឯកជន |

## ៨.៣. ការចល័តឆ្លាតវៃ

### *៨.៣.១ គម្រោង M-០១៖ ការណែនាំប្រព័ន្ធចំណតយានយន្តជាផ្លូវការ*

| គម្រោង M-០១ | ការណែនាំប្រព័ន្ធចំណតយានយន្តជាផ្លូវការ | |
|---|---|---|
| ខ្លឹមសារនៃគម្រោង (គោលដៅឆ្នាំ ២០៣៥) | | |
| បញ្ហាឆ្លើយតប | ១២. បញ្ហាចរាចរណ៍ដូចជាការកកស្ទះ គ្រោះថ្នាក់ចរាចរណ៍ និងការចតរថយន្តនៅតាមដងផ្លូវ | |
| គោលបំណង | ដើម្បីកែលម្អបរិយាកាសដើរ កែលម្អភាពទាក់ទាញនៃគោលដៅទេសចរណ៍ និងធ្វើឱ្យបរិយាកាសរស់នៅកាន់តែប្រសើរឡើង។ | |
| គោលដៅគម្រោង | ការដំឡើងប្រព័ន្ធចំណតរថយន្តនៅតំបន់ដែលមានយានយន្តចតតាមដងផ្លូវជាច្រើនក្នុងក្រុងសៀមរាប រួមទាំងផ្លូវជុំវិញផាប់ស្ទ្រីត | |
| តំបន់គោលដៅសំខាន់ | តំបន់ទីប្រជុំជន | |
| ការគ្រប់គ្រងទិន្នន័យ | ការធ្វើរួមបញ្ចូលគ្នានៃនីតិវិធីពីការកក់កន្លែងចតរថយន្តរហូតដល់ការទូទាត់ថ្លៃចតរថយន្ត ដោយការត្រួតពិនិត្យការចតតាមផ្លូវខុសច្បាប់ និងការណែនាំប្រព័ន្ធទូទាត់តាមអ៊ីនធឺណិត | |
| បញ្ហាក្នុងការអនុវត្ត | -ការសម្រេចចិត្តលើគោលនយោបាយ និងការបង្កើតប្រព័ន្ធចេញវិក្កយបត្រសម្រាប់គិតថ្លៃចំណត រថយន្តតាមដងផ្លូវ<br>-ការជ្រើសរើសប្រតិបត្តិករប្រព័ន្ធចតរថយន្ត<br>-ការជ្រើសរើសចំណុចកំណត់សម្រាប់ចំណតរថយន្តនៅតាមផ្លូវ<br>-លទ្ធកម្មដីសម្រាប់សាងសង់ចំណតរថយន្តក្រៅផ្លូវ (ចំណតរថយន្តច្រើនជាន់) | |
| សូចនាករ (KPI) | ចំនួនយានយន្តចតខុសច្បាប់ ការពេញចិត្តអ្នកថ្មើរជើង ការពេញចិត្តរបស់អ្នកបើកបរ | |
| សកម្មភាពរយៈពេលខ្លី (គម្រោងអាទិភាពសម្រាប់គោលដៅប្រចាំឆ្នាំ ២០២៥) | | |
| អង្គភាពអនុវត្ត | ចម្បង | រដ្ឋបាលខេត្ត មន្ទីរសាធារណការ និងដឹកជញ្ជូន |
| | បន្ទាប់បន្សំ | ប្រតិបត្តិករចំណតរថយន្ត |
| | អង្គភាពពាក់ព័ន្ធ | ស្នងការនគរបាលខេត្ត រដ្ឋបាលក្រុងសៀមរាប |
| សកម្មភាពចម្បង [ការបែងចែកតួនាទី] | ១. ការបង្កើត និងការអនុវត្តប្រព័ន្ធថ្លៃចតរថយន្តតាមដងផ្លូវ ការបង្កើត និងដំណើរការប្រព័ន្ធថ្លៃសេវា (ការកំណត់តំបន់ពិសេសសម្រាប់ផ្លូវជុំវិញផាប់ស្ទ្រីត ។ល។) [រដ្ឋបាលខេត្ត ]<br>២. ការកំណត់ និងកំណត់ទីតាំងចំណតផ្លូវគិតថ្លៃ [អ្នកគ្រប់គ្រងផ្លូវ (មន្ទីរសាធារណការ និងដឹកជញ្ជូន រដ្ឋបាលក្រុងសៀមរាប)]<br>៣. ប្រភេទកិច្ចសន្យានៃប្រតិបត្តិករចំណតរថយន្តតាមផ្លូវ និងការជ្រើសរើសប្រតិបត្តិករ [រដ្ឋបាលខេត្ត]<br>៤. ការដំឡើងឧបករណ៍ចាប់សញ្ញាចតរថយន្តនៅលើផ្លូវ (តំបន់ពិសេសដែលបានកំណត់) ជុំវិញផាប់ស្ទ្រីត [ប្រតិបត្តិករចំណតរថយន្ត]<br>៥. អាជីវកម្មប្រមូលថ្លៃចំណតតាមដងផ្លូវ និងការផ្តល់ព័ត៌មានអំពីកន្លែងចតរថយន្ត [ប្រតិបត្តិករចំណតរថយន្ត] | |
| ប្រភពមូលនិធិ / គំរូអាជីវកម្ម | ប្រើប្រាស់តំបន់អតិរេកនៃផ្លូវថ្នល់ប្រកបដោយប្រសិទ្ធភាព លុបបំបាត់ការចតរថយន្តខុសច្បាប់ដែលរារាំងចរាចរណ៍ផ្លូវគោក និងការប្រើប្រាស់ផ្លូវថ្នល់ គ្រប់គ្រងពេលវេលាដែលអាចប្រើប្រាស់បាន និងគ្រប់គ្រងពេលវេលាចតរថយន្ត ក្នុងគោលបំណងប្រើប្រាស់ចំណតរថយន្តតាមដងផ្លូវប្រកបដោយ សណ្តាប់ធ្នាប់ ដោយដាក់ឱ្យប្រើប្រាស់ប្រព័ន្ធទូទាត់ប្រាក់ដែលគ្របដណ្តប់លើការចំណាយលើការគ្រប់គ្រង។ គំរូអាជីវកម្មគឺជាអាជីវកម្មដែលគ្របដណ្តប់លើការចំណាយលើការគ្រប់គ្រង រួមទាំងការដាក់ឱ្យប្រើប្រាស់ឧបករណ៍ផ្សេងៗ ការស្តារឡើងវិញនូវការចំណាយលើការវិនិយោគដំបូងសម្រាប់ការអភិវឌ្ឍប្រព័ន្ធ ការថែទាំ និងជួសជុលឧបករណ៍ដែលរួមចំណែកដល់ការគ្រប់គ្រង និងធនធានមនុស្សដែលរួមចំណែកដល់ការគ្រប់គ្រង។ ទាក់ទងនឹងការកំណត់ថ្លៃចំណត ចាំបាច់ត្រូវកំណត់ថ្លៃចំណតដោយគិតគូរពីទំនាក់ទំនងជាមួយនឹងការ | |

| គម្រោង M-០១ | ការណែនាំប្រព័ន្ធចំណតយានយន្តជាផ្លូវការ | |
|---|---|---|
| | គិតថ្លៃចំណតដែលដំណើរការដោយក្រុមហ៊ុនឯកជនជុំវិញ និងលទ្ធភាពអាជីវកម្មដោយគិតពីរយៈពេលសងត្រលប់នៃការវិនិយោគ។ | |
| | ថ្លៃដើមចាប់ផ្តើមដំបូង | បន្ទុករបស់ប្រតិបត្តិករចំណតរថយន្ត (ការប្រមូលមូលនិធិជាមួយនឹងមួយផ្នែកនៃប្រាក់ចំណូលថ្លៃចំណត) |
| | ចំណាយលើប្រតិបត្តិការ និងថែទាំ | ប្រាក់ចំណូលថ្លៃចំណត បំពេញបន្ថែមពីមូលនិធិជំរុញទេសចរណ៍ (បើចាំបាច់) |




ប្រភព៖ ក្រុមសិក្សា JICA

### រូបភាព ៨.២៖ រូបភាពនៃចំណតយានយន្តក្នុងក្រុងដំណាក់កាលដំបូង

## ៨.៣.២ គម្រោង M-០២៖ ការត្រួតពិនិត្យស្ថានភាពផ្ទៃផ្លូវ

| គម្រោង M-០២ | ការត្រួតពិនិត្យស្ថានភាពផ្ទៃផ្លូវ | |
|---|---|---|
| ខ្លឹមសារនៃគម្រោង (គោលដៅឆ្នាំ ២០៣៥) | | |
| បញ្ហាឆ្លើយតប | ១៣. ការថែទាំផ្លូវមិនមានប្រសិទ្ធភាព<br>១៤. ហានិភ័យបទល្មើស / គ្រោះថ្នាក់ចរាចរណ៍ | |
| គោលបំណង | ធានាគុណភាពនៃស្ថានភាពផ្លូវថ្នល់ និងការកសាងផែនការថែទាំ និងជួសជុលផ្លូវជាប្រព័ន្ធ និងមានប្រសិទ្ធភាព | |
| គោលដៅគម្រោង | ធានាបាននូវ គុណភាពផ្ទៃផ្លូវដែលត្រូវការក្នុងតម្លៃទាបបំផុតដោយប្រើកម្មវិធីទូរស័ព្ទដៃឈ្មោះ Road Care ដែលអភិវឌ្ឍដោយក្រសួងសាធារណការ និងដឹកជញ្ជូន | |
| តំបន់គោលដៅសំខាន់ | តំបន់ទីប្រជុំជន (ចម្បង) តំបន់បេតិកភណ្ឌ (ចម្បង) តំបន់បឹងទន្លេសាប (បន្ទាប់បន្សំ) | |
| ការគ្រប់គ្រងទិន្នន័យ | -ប្រមូល និងរក្សាទុកទិន្នន័យរូបភាពផ្ទៃផ្លូវដោយស្វ័យប្រវត្តិ<br>-ការរកឃើញ និងការវាយតម្លៃនៃការខូចខាតផ្ទៃផ្លូវដោយប្រើបញ្ញាសិប្បនិម្មិត (AI)<br>-ប្រើសម្រាប់ការរៀបចំផែនការថែទាំ និងជួសជុលជាកំណត់ត្រាជាក់ស្តែង | |
| បញ្ហាក្នុងការអនុវត្ត | -ស្វែងរកអ្នកសហការសម្រាប់ការប្រមូលទិន្នន័យ<br>-ធ្វើឱ្យប្រសើរឡើងនូវការគ្របដណ្តប់នៃផ្លូវប្រមូលទិន្នន័យ<br>-ធានាការចំណាយលើដំណើរការទិន្នន័យ | |
| សូចនាករ (KPI) | តុល្យភាពរវាងគុណភាពផ្ទៃផ្លូវ និងថ្លៃជួសជុល (ប្រសិទ្ធភាព) ចំនួននៃការរាយការណ៍ដោយប្រើកម្មវិធី Roadcare | |
| សកម្មភាពរយៈពេលខ្លី (គម្រោងអាទិភាពសម្រាប់គោលដៅប្រចាំឆ្នាំ ២០២៥) | | |
| អង្គភាពអនុវត្ត | ចម្បង | រដ្ឋបាលខេត្ត មន្ទីរសាធារណការ និងដឹកជញ្ជូន អាជ្ញាធរជាតិអប្សរា |
| | បន្ទាប់បន្សំ | អ្នកផ្តល់សេវាកម្មវិធី រដ្ឋបាលក្រុងសៀមរាប |
| | អង្គភាពពាក់ព័ន្ធ | - |
| សកម្មភាពចម្បង<br>[ការបែងចែកតួនាទី] | ១. កំណត់គោលដៅរបស់អ្នកប្រើប្រាស់។ កំណត់ថាតើកម្មវិធីនោះគឺសម្រាប់នរណា ហើយនរណានឹងទទួលបានអត្ថប្រយោជន៍ច្រើនបំផុត។ នេះអាចរួមបញ្ចូលអ្នកបើកបរ ក្រុមហ៊ុនដឹកជញ្ជូន ភ្នាក់ងាររាជរដ្ឋាភិបាល ឬអ្នកពាក់ព័ន្ធផ្សេងទៀត។[រដ្ឋបាលខេត្ត]<br>២. ផ្សព្វផ្សាយអំពីកម្មវិធី។ ប្រើប្រាស់បណ្តាញផ្សព្វផ្សាយផ្សេងៗដើម្បីផ្សព្វផ្សាយកម្មវិធី និងបង្កើនការយល់ដឹងក្នុងចំណោមអតិថិជនគោលដៅ។ នេះអាចរួមបញ្ចូលប្រព័ន្ធផ្សព្វផ្សាយសង្គម ការផ្សាយពាណិជ្ជកម្មតាមគេហទំព័រ យុទ្ធនាការអ៊ីមែល និងយុទ្ធសាស្ត្រទីផ្សារផ្សេងទៀត។ [មន្ទីរសាធារណការ និងដឹកជញ្ជូន]<br>៣. ផ្តល់ការបណ្តុះបណ្តាល និងការគាំទ្រ។ ផ្តល់ការបណ្តុះបណ្តាល និងការគាំទ្រដើម្បីជួយអ្នកប្រើប្រាស់យល់ពីរបៀបប្រើប្រាស់កម្មវិធីប្រកបដោយប្រសិទ្ធភាព។ [រដ្ឋបាលខេត្ត]<br>៤. សម្របសម្រួលមតិកែលម្អ។ លើកទឹកចិត្តអ្នកប្រើប្រាស់ឱ្យផ្តល់មតិកែលម្អលើបញ្ហា និងការកែលម្អជាមួយកម្មវិធី។ [រដ្ឋបាលខេត្ត]<br>៥. តាមដានការប្រើប្រាស់ និងលទ្ធផល។ តាមដានការប្រើប្រាស់កម្មវិធី និងលទ្ធផលដើម្បីវាយតម្លៃប្រសិទ្ធភាពរបស់វា និងកំណត់តំបន់សម្រាប់ការកែលម្អ។ [មន្ទីរសាធារណការ និងដឹកជញ្ជូន]<br>៦. សហការជាមួយស្ថាប័នពាក់ព័ន្ធ។ សហការជាមួយអង្គភាពពាក់ព័ន្ធ។ [មន្ទីរសាធារណការ និងដឹកជញ្ជូន] | |
| ប្រភពមូលនិធិ /<br>គំរូអាជីវកម្ម | | |
| | ថ្លៃដើមចាប់ផ្តើមដំបូង | ថវិកាសាធារណៈ (មួយផ្នែកនៃថវិកាជួសជុលផ្លូវប្រចាំឆ្នាំត្រូវបានប្រើប្រាស់ (តម្លៃកំណត់ដំបូង ចំនួនតិចតួចសម្រាប់ការរៀនម៉ាស៊ីននៃដំណើរការរូបភាពដែលតម្រូវតាមគេហទំព័រ)) |
| | ចំណាយលើប្រតិបត្តិការ និងថែទាំ | ថវិកាសាធារណៈ (ប្រើប្រាស់មួយផ្នែកនៃថវិកាជួសជុលផ្លូវប្រចាំឆ្នាំ) |

## ៨.៣.៣ គម្រោង M-០៣៖ ការកែលម្អភ្លើងបំភ្លឺផ្លូវ

<table>
<tr><th>គម្រោង M-០៣</th><th colspan="2">ការកែលម្អភ្លើងបំភ្លឺផ្លូវ</th></tr>
<tr><td colspan="3">ខ្លឹមសារនៃគម្រោង (គោលដៅឆ្នាំ ២០៣៥)</td></tr>
<tr><td>បញ្ហាឆ្លើយតប</td><td colspan="2">១៥. ត្រូវការសុវត្ថិភាពបន្ថែមដោយជៀសផុតហានិភ័យនៃគ្រោះថ្នាក់ចរាចរណ៍ និង បទល្មើស</td></tr>
<tr><td>គោលបំណង</td><td colspan="2">ដើម្បីទប់ស្កាត់ការកើតឡើងនៃបទល្មើសតាមដងផ្លូវ និងផ្តល់បរិយាកាសដើរប្រកបដោយសុវត្ថិភាព សម្រាប់អ្នកថ្មើរជើង រួមទាំងភ្ញៀវទេសចរបរទេសផងដែរ។</td></tr>
<tr><td>គោលដៅគម្រោង</td><td colspan="2">ភ្លើងបំភ្លឺផ្លូវពហុមុខងារតាមរយៈប្រតិបត្តិការរួមបញ្ចូលគ្នាជាមួយកាមេរ៉ាឃ្លាំមើល ឧបករណ៍ចាប់សញ្ញាបរិស្ថាន ឧបករណ៍ចាប់សញ្ញាកន្លែងចតរថយន្ត ។ល។</td></tr>
<tr><td>តំបន់គោលដៅសំខាន់</td><td colspan="2">តំបន់ទីប្រជុំជន (ចម្បង) តំបន់បេតិកភណ្ឌ (បន្ទាប់បន្សំ)</td></tr>
<tr><td>ការគ្រប់គ្រងទិន្នន័យ</td><td colspan="2">តាមដានការជន់លិចលើផ្ទៃផ្លូវ កម្រិតទឹកទន្លេ ព័ត៌មានអាកាសធាតុ ស្ថានភាពចរាចរណ៍ ។ល។</td></tr>
<tr><td>បញ្ហាក្នុងការអនុវត្ត</td><td colspan="2">- ការជ្រើសរើសអ្នកផ្តល់ឧបករណ៍ទំនាក់ទំនង និងប្រព័ន្ធទំនាក់ទំនង<br>- ការធានានូវសមត្ថភាពទំនាក់ទំនង</td></tr>
<tr><td>សូចនាករ (KPI)</td><td colspan="2">ការពេញចិត្តរបស់ភ្ញៀវទេសចរ និងប្រជាជន ចំពោះចំនួនបទល្មើសតាមដងផ្លូវប្រចាំឆ្នាំ និងសុវត្ថិភាពនៃបរិយាកាសដើរ</td></tr>
<tr><td colspan="3">សកម្មភាពរយៈពេលខ្លី (គម្រោងអាទិភាពសម្រាប់គោលដៅប្រចាំឆ្នាំ ២០២៥)</td></tr>
<tr><td rowspan="3">អង្គភាពអនុវត្ត</td><td>ចម្បង</td><td>រដ្ឋបាលខេត្ត មន្ទីរសាធារណការ និងដឹកជញ្ជូន</td></tr>
<tr><td>បន្ទាប់បន្សំ</td><td>មន្ទីរប្រៃសណីយ៍ និងទូរគមនាគមន៍ ប្រតិបត្តិករពន្លឺផ្លូវ ក្រុមហ៊ុនទូរគមនាគមន៍</td></tr>
<tr><td>អង្គភាពពាក់ព័ន្ធ</td><td>ស្នងការនគរបាលខេត្ត, រដ្ឋបាលខេត្ត</td></tr>
<tr><td>សកម្មភាពចម្បង<br>[ការបែងចែកតួនាទី]</td><td colspan="2">១. ផ្នែកដំឡើងភ្លើងតាមដងផ្លូវ (ផ្លូវជុំវិញផាប់ស្ទ្រីត និងនៅលើផ្លូវជាតិ) ប្រភេទឧបករណ៍ចាប់សញ្ញាដែលភ្ជាប់ទៅនឹងភ្លើងតាមដងផ្លូវ ទីតាំងដំឡើង ផែនការគ្រប់គ្រងទិន្នន័យ [មន្ទីរសាធារណការ និងដឹកជញ្ជូន]<br>២. ការដំឡើងឧបករណ៍ចាប់សញ្ញាផ្សេងៗសម្រាប់ភ្លើងតាមដងផ្លូវ [ក្រុមហ៊ុនបំភ្លឺផ្លូវ ក្រុមហ៊ុនផលិតឧបករណ៍ចាប់សញ្ញាផ្សេងៗ]<br>៣. ការតភ្ជាប់ជាមួយឧបករណ៍ទំនាក់ទំនង [ក្រុមហ៊ុនដឹកជញ្ជូនទូរគមនាគមន៍]<br>៤. ការផ្ទុកទិន្នន័យ និងការបង្ហាញទៅកាន់ថ្នាលទិន្នន័យ [មន្ទីរប្រៃសណីយ៍ និងទូរគមនាគមន៍]</td></tr>
<tr><td rowspan="3">ប្រភពមូលនិធិ<br>/ គំរូអាជីវកម្ម</td><td colspan="2">វាគឺជាអាជីវកម្មដែលអនុញ្ញាតឱ្យមានការត្រួតពិនិត្យតាមពេលវេលាជាក់ស្តែងដោយការផ្គត់ផ្គង់ថាមពល និងការទំនាក់ទំនងដោយបំពាក់ភ្លើងតាមចិញ្ចើមផ្លូវជាមួយនឹងឧបករណ៍ចាប់សញ្ញាផ្សេងៗដែលមានមុខងារភ្ជាប់ជាមួយឧបករណ៍ទំនាក់ទំនង។ ភ្លើងតាមដងផ្លូវ គឺជាគំរូអាជីវកម្មដែលឆ្លើយតបទៅនឹងតម្រូវការត្រួតពិនិត្យផ្សេងៗ ដោយប្រើអំពូល LED ដែលល្អសម្រាប់បរិស្ថាន និងការដំឡើងមុខងារមួយដើម្បីទទួលបានទិន្នន័យជាប្រចាំ។ ដោយសារការផ្គត់ផ្គង់ថាមពលដូចជាឧបករណ៍ចាប់សញ្ញាមិនត្រូវបានទាមទារសម្រាប់មុខងារនីមួយៗ និងអាចត្រូវបានចែករំលែកបាន ដូច្នេះថវិកាប្រតិបត្តិអាចត្រូវបានកាត់បន្ថយបាន។</td></tr>
<tr><td>ថ្លៃដើមចាប់ផ្តើមដំបូង</td><td>ថវិកាសាធារណៈ (មន្ទីរសាធារណការ និងដឹកជញ្ជូន និងថវិកាគ្រប់គ្រងសុវត្ថិភាពចរាចរណ៍ក្រុង ថវិកាជាតិ (គម្រោងសាងសង់ផ្លូវ ៣៨ ដែលកំពុងដំណើរការ))</td></tr>
<tr><td>ចំណាយលើប្រតិបត្តិការ និងថែទាំ</td><td>ថវិកាសាធារណៈ (មន្ទីរសាធារណការ និងដឹកជញ្ជូន ថវិកានៃអង្គភាពពាក់ព័ន្ធ ការប្រើប្រាស់ទិន្នន័យ)</td></tr>
</table>




ប្រភព៖ ក្រុមហ៊ុន Minebea Mitsumi

រូបភាព ៨.៣៖ រូបភាពនៃសកម្មភាពរយៈពេលខ្លីសម្រាប់ការកែលម្អភ្លើងបំភ្លឺផ្លូវ

### ៨.៣.៤ គម្រោង M-04៖ ការកែលម្អប្រព័ន្ធសញ្ញាចរាចរណ៍

| គម្រោង M-04 | ការកែលម្អប្រព័ន្ធសញ្ញាចរាចរណ៍ | |
|---|---|---|
| ខ្លឹមសារនៃគម្រោង (គោលដៅឆ្នាំ ២០៣៥) | | |
| បញ្ហាឆ្លើយតប | ១២. បញ្ហាចរាចរណ៍ដូចជាការកកស្ទះ គ្រោះថ្នាក់ចរាចរណ៍ និងការចតរថយន្តនៅតាមដងផ្លូវ | |
| គោលបំណង | ការកែលម្អលំហូរចរាចរណ៍ដើម្បីបង្កើនតម្លៃនៃគោលដៅទេសចរណ៍ និងគាំទ្រដល់កំណើនសេដ្ឋកិច្ច | |
| គោលដៅគម្រោង | លំហូរចរាចរណ៍ប្រសើរឡើងតាមតម្រូវការចរាចរណ៍ | |
| តំបន់គោលដៅសំខាន់ | តំបន់ទីប្រជុំជន | |
| ការគ្រប់គ្រងទិន្នន័យ | តាមដានលំហូរចរាចរណ៍ តម្រូវការចរាចរណ៍ និងការបង្ហាញសញ្ញា | |
| បញ្ហាក្នុងការអនុវត្ត | ការណែនាំអំពីភ្លើងចរាចរណ៍ថ្មីជាមួយនឹងមុខងារកែតម្រូវការបង្ហាញសញ្ញាដោយស្វ័យប្រវត្តិដែលភ្ជាប់ជាមួយនឹងមុខងារវាស់បរិមាណចរាចរណ៍ | |
| សូចនាករ (KPI) | ការកកស្ទះចរាចរណ៍ សមត្ថភាពចរាចរណ៍ | |
| សកម្មភាពរយៈពេលខ្លី (គម្រោងអាទិភាពសម្រាប់គោលដៅប្រចាំឆ្នាំ ២០២៥) | | |
| អង្គភាពអនុវត្ត | ចម្បង | មន្ទីរសាធារណការ និងដឹកជញ្ជូន |
| | បន្ទាប់បន្សំ | រដ្ឋបាលក្រុងសៀមរាប អាជីវកម្ម ឯកជន(ការអភិវឌ្ឍប្រព័ន្ធ) |
| | អង្គភាពពាក់ព័ន្ធ | ស្នងការនគរបាលខេត្ត |
| សកម្មភាពចម្បង [ការបែងចែកតួនាទី] | ១. ការកំណត់សញ្ញាចរាចរណ៍ភ្ជាប់សញ្ញាទិសដៅ [មន្ទីរសាធារណការ និងដឹកជញ្ជូន]<br>២. លទ្ធកម្មឧបករណ៍ភ្ជាប់សញ្ញាចរាចរណ៍ ការត្រួតពិនិត្យសញ្ញា ការត្រួតពិនិត្យចរាចរណ៍ ។ល។ [មន្ទីរសាធារណការ និងដឹកជញ្ជូន]<br>៣. ការដំឡើងឧបករណ៍ភ្ជាប់សញ្ញាចរាចរណ៍ ការត្រួតពិនិត្យសញ្ញា ការត្រួតពិនិត្យចរាចរណ៍ ។ល។ [ក្រុមហ៊ុនអភិវឌ្ឍន៍ប្រព័ន្ធគ្រប់គ្រងភ្លើង និងសញ្ញាចរាចរណ៍]<br>៤. ប្រតិបត្តិការឧបករណ៍ភ្ជាប់សញ្ញាចរាចរណ៍ ការត្រួតពិនិត្យសញ្ញា ការត្រួតពិនិត្យចរាចរណ៍ ។ល។ [មន្ទីរសាធារណការ និងដឹកជញ្ជូន] | |
| ប្រភពមូលនិធិ / គំរូអាជីវកម្ម | តម្លៃនៃដើមទុនប្រែប្រួលអាស្រ័យលើទំហំភ្លើងចរាចរណ៍ និងប្រព័ន្ធ។ ទោះបីជាយ៉ាងណាក៏ដោយ ដោយសារតែលក្ខណៈនៃបរិក្ខារ និងមុខងារ វាជាការវិនិយោគសាធារណៈ ហើយវាពិបាកក្នុងការទទួលបានប្រាក់ចំណេញពីប្រព័ន្ធដំណើរការចរាចរណ៍ទាំងនេះដោយខ្លួនឯង ដូច្នេះគំរូមួយជាទូទៅត្រូវបានអនុវត្តជាការវិនិយោគសាធារណៈសុទ្ធសាធ។ | |
| | ថ្លៃដើមចាប់ផ្តើមដំបូង | ថវិកាសាធារណៈ ((មន្ទីរសាធារណការ និងដឹកជញ្ជូន រដ្ឋបាលខេត្ត រដ្ឋបាលក្រុងសៀមរាប អាជ្ញាធរជាតិអប្សរា) ជំនួយអភិវឌ្ឍន៍ផ្លូវការ (តម្លៃសម្រាប់ជាឯកសារយោង៖ ១៥,000,000 ដុល្លារអាមេរិក (ចំនួនជំនួយឥតសំណងរបស់ដៃគូអភិវឌ្ឍន៍សម្រាប់ការអភិវឌ្ឍប្រព័ន្ធគ្រប់គ្រងចរាចរណ៍ក្នុងរាជធានីភ្នំពេញ ដែលមានភ្លើងសញ្ញាចរាចរណ៍នៅតាមផ្លូវបំបែកចំនួន ១១៥ទីតាំង)) |
| | ចំណាយលើប្រតិបត្តិ-ការ និងថែទាំ | ថវិកាសាធារណៈ (មន្ទីរសាធារណការ និងដឹកជញ្ជូន រដ្ឋបាលខេត្ត រដ្ឋបាលក្រុងសៀមរាប អាជ្ញាធរជាតិអប្សរា) |




ប្រភព៖ គេហទំព័រ Sumitomo Electric System Solutions Co., Ltd. និងក្រុមសិក្សា JICA

## រូបភាព ៨.៤៖ រូបភាពនៃសកម្មភាពរយៈពេលខ្លីសម្រាប់ការកែលម្អប្រព័ន្ធសញ្ញាចរាចរណ៍

## ៨.៣.៥ គម្រោង M-05៖ ការកែលម្អការគ្រប់គ្រងសុវត្ថិភាពចរាចរណ៍

| គម្រោង M-0៥ | ការកែលម្អការគ្រប់គ្រងសុវត្ថិភាពចរាចរណ៍ | |
|---|---|---|
| ខ្លឹមសារនៃគម្រោង (គោលដៅឆ្នាំ ២០៣៥) | | |
| បញ្ហាឆ្លើយតប | ១៥. ត្រូវការសុវត្ថិភាពបន្ថែមដោយជៀសផុតហានិភ័យនៃគ្រោះថ្នាក់ចរាចរណ៍ និង បទល្មើស | |
| គោលបំណង | ការកែលម្អការគ្រប់គ្រងសុវត្ថិភាពចរាចរណ៍ និងការបើកបរប្រកបដោយសុវត្ថិភាពសម្រាប់កន្លែងរស់នៅប្រកបដោយសុវត្ថិភាព និងតំបន់ទេសចរណ៍ | |
| គោលដៅគម្រោង | កន្លែងរស់នៅប្រកបដោយសុវត្ថិភាព និងជាកន្លែងទេសចរណ៍ដែលអ្នកអាចដើរដោយសុវត្ថិភាព | |
| តំបន់គោលដៅសំខាន់ | តំបន់ទីប្រជុំជន (ចម្បង) តំបន់បេតិកភណ្ឌ (ចម្បង) តំបន់បឹងទន្លេសាប (បន្ទាប់បន្សំ) | |
| ការគ្រប់គ្រងទិន្នន័យ | -កំណត់តំបន់គ្រោះថ្នាក់នៃគ្រោះថ្នាក់ចរាចរណ៍ និងការចែករំលែកព័ត៌មាន<br>-ការវិភាគអំពីមូលហេតុនៃគ្រោះថ្នាក់ចរាចរណ៍<br>-ការវាយតម្លៃ និងការកែលម្អការគាំទ្រនៃអាកប្បកិរិយាបើកបររបស់អ្នកបើកបរម្នាក់ៗ | |
| បញ្ហាក្នុងការអនុវត្ត | -ស្វែងរកអ្នកសហការប្រមូលទិន្នន័យ (តែជាមួយស្មាតហ្វូន ឬឧបករណ៍ថត ដែលអាចវាស់ស្ទង់ការបង្កើនល្បឿនជាលក្ខណៈ 3D)<br>-ធ្វើឱ្យប្រសើរឡើងនូវការគ្របដណ្តប់នៃផ្លូវប្រមូលទិន្នន័យ<br>-ធានាការចំណាយលើដំណើរការទិន្នន័យ | |
| សូចនាករ (KPI) | ចំនួននៃគ្រោះថ្នាក់ចរាចរណ៍ ចំនួននៃការធ្វើឱ្យប្រសើរឡើងនៃគ្រោះថ្នាក់ចរាចរណ៍ | |
| សកម្មភាពរយៈពេលខ្លី (គម្រោងអាទិភាពសម្រាប់គោលដៅប្រចាំឆ្នាំ ២០២៥) | | |
| អង្គភាពអនុវត្ត | ចម្បង | ស្នងការនគរបាលខេត្ត |
| | បន្ទាប់បន្សំ | ប្រតិបត្តិករអាជីវកម្ម (ការប្រមូលទិន្នន័យ ការវិភាគ) |
| | អង្គភាពពាក់ព័ន្ធ | មន្ទីរសាធារណការ និងដឹកជញ្ជូន ក្រុងសៀមរាប អាជ្ញាធរជាតិអប្សរា មន្ទីរប្រៃសណីយ៍ និងទូរគមនាគមន៍ |
| សកម្មភាពចម្បង [ការបែងចែកតួនាទី] | ១. ជាតុជាក់លាក់នៃព្រឹត្តិការណ៍ដែលមិនមានសុវត្ថិភាពចរាចរណ៍ ផែនការទទួលបានទិន្នន័យ និងផែនការសម្រាប់ការឆ្លុះបញ្ចាំងនៅក្នុងគម្រោងការប្រឆាំង [ស្នងការនគរបាលខេត្ត មន្ទីរសាធារណការ និងដឹកជញ្ជូន]<br>២. ការសម្របសម្រួល និងធានាសុវត្ថិភាពដៃគូសហការ / អង្គការនានា (រថយន្តល្បាតផ្លូវថ្នល់ យានជំនិះរបស់ខេត្ត រ៉ឺម៉ក ឡានក្រុង ។ល។) បំពាក់ដោយស្មាតហ្វូនដែលមានភ្ជាប់កម្មវិធី និងឧបករណ៍ថត [រដ្ឋបាលខេត្តសៀមរាប]<br>៣. ការណែនាំអំពីសេវាកម្មកម្មវិធីសម្រាប់ចាប់យកឥរិយាបថបើកបរ [អ្នកផ្តល់សេវា]<br>៤. ការប្រមូលទិន្នន័យ ការប្រមូលផ្តុំលទ្ធផលសិក្សាស្ថានភាព និងការផ្តល់ទិន្នន័យ [អ្នកផ្តល់សេវា]<br>៥. ការផ្ទុកទិន្នន័យ និងការបង្ហាញទៅកាន់ថ្នាលទិន្នន័យ [មន្ទីរប្រៃសណីយ៍ និងទូរគមនាគមន៍]<br>៦. ការអនុវត្តការបណ្តុះបណ្តាលសុវត្ថិភាពសម្រាប់អ្នកបើកបរដោយផ្អែកលើទិន្នន័យ [ស្នងការនគរបាលខេត្ត] | |
| ប្រភពមូលនិធិ / គំរូអាជីវកម្ម | អ្នកគ្រប់គ្រងចរាចរណ៍ដំឡើងស្មាតហ្វូន / ឧបករណ៍ថតដែលបំពាក់ដោយកម្មវិធីនៅលើយានជំនិះដែលពួកគេបើកបរជារៀងរាល់ថ្ងៃ ដើម្បីកំណត់តំបន់គ្រោះថ្នាក់ចរាចរណ៍ដែលអាចកើតមាន និងវិធានការបង្ការ ព្រមទាំងប្រមូលទិន្នន័យអាកប្បកិរិយានៃការបើកបរជាប្រចាំ។ តាមរយៈការធ្វើដូច្នេះ ព័ត៌មានស្តីពីចំណុចគ្រោះថ្នាក់ចរាចរណ៍ត្រូវបានទទួល វិធានការត្រូវបានជ្រើសរើស ហើយព័ត៌មាននេះត្រូវបានបង្ហាញដល់សាធារណជនទូទៅ ដើម្បីលើកទឹកចិត្តដល់សកម្មភាពសុវត្ថិភាពចរាចរណ៍។ គំរូអាជីវកម្មគឺទិញឧបករណ៍ក្នុងរថយន្តការវិភាគទិន្នន័យ និងប្រព័ន្ធបង្ហាញពីអ្នកផ្តល់កម្មវិធីជាថ្លៃដើម ហើយបង់ថ្លៃប្រើប្រាស់ប្រព័ន្ធប្រចាំឆ្នាំដោយចំណាយរដ្ឋបាល។ ទាក់ទងនឹងយានយន្តដែលត្រូវវាស់វែង ជាពិសេសក្រុមហ៊ុនដឹកអ្នកដំណើរ យើងនឹងដំណើរការដោយយន្តការស្នើសុំកិច្ចសហប្រតិបត្តិការពីយានយន្តដែលបានចុះបញ្ជីក្នុងអត្រាជាក់លាក់មួយ។ | |
| | ថ្លៃដើមចាប់ផ្តើមដំបូង | ថវិកាសាធារណៈ (ជាផ្នែកមួយនៃថវិកាគ្រប់គ្រងសុវត្ថិភាពចរាចរណ៍) |

| | | |
|---|---|---|
| | ចំណាយលើប្រតិបត្តិការ និងថែទាំ | ថវិកាសាធារណៈ (ជាផ្នែកមួយនៃថវិកាគ្រប់គ្រងសុវត្ថិភាពចរាចរណ៍) |




ប្រភព៖ គេហទំព័រ Honda Motor Co., Ltd

## រូបភាព ៨.៥៖ រូបភាពនៃសកម្មភាពរយៈពេលខ្លីសម្រាប់ការកែលម្អនូវសុវត្ថិភាពតាមដងផ្លូវ

## ៤.៣.៦ គម្រោង M-០៦៖ ការណែនាំអំពីយានយន្តអគ្គិសនី

| គម្រោង M-០៦ | ការណែនាំអំពីយានយន្តអគ្គិសនី | |
|---|---|---|
| ខ្លឹមសារនៃគម្រោង (គោលដៅឆ្នាំ ២០៣៥) | | |
| បញ្ហាឆ្លើយតប | ១៤. ការបំពុលបរិយាកាស និងបន្ទុកបរិស្ថានដែលបណ្តាលមកពីចល័តភាព | |
| គោលបំណង | ការកែលម្អកម្រិតបរិស្ថាន និងការលើកកម្ពស់គោលដៅទេសចរណ៍ប្រកបដោយនិរន្តរភាព | |
| គោលដៅគម្រោង | ធ្វើបច្ចុប្បន្នភាពទៅរថយន្តអគ្គិសនី | |
| តំបន់គោលដៅសំខាន់ | តំបន់បេតិកភណ្ឌ (ចម្បង) តំបន់ទីប្រជុំជន (បន្ទាប់បន្សំ) តំបន់បឹងទន្លេសាប (បន្ទាប់បន្សំ) | |
| ការគ្រប់គ្រងទិន្នន័យ | -តាមដានស្ថានភាពប្រតិបត្តិការរបស់រថយន្តអគ្គិសនី<br>-ការត្រួតពិនិត្យទិន្នន័យប្រតិបត្តិការ (ផ្លូវ ចម្ងាយ ល្បឿន) និងទិន្នន័យការប្រើប្រាស់ថាមពល<br>-ការដាក់កន្លែងសាកថ្មប្រកបដោយប្រសិទ្ធភាព និងការរៀបចំកាលវិភាគសាកថ្ម | |
| បញ្ហាក្នុងការអនុវត្ត | -ធ្វើឱ្យមានស្ថេរភាពនៃការផ្គត់ផ្គង់ថាមពលអគ្គិសនីដល់កន្លែងសាកថ្ម<br>-ការបង្កើតគោលនយោបាយកាត់បន្ថយការបំភាយឧស្ម័នកាបូនិកទៅក្នុងបរិយាកាស និងយុទ្ធសាស្រ្តរួមសម្រាប់ការប្រើប្រាស់ប្រភេទយានយន្តអគ្គិសនីផ្សេងៗ (ឡានក្រុងអគ្គិសនី ម៉ូតូកង់បីអគ្គិសនី ម៉ូតូអគ្គិសនី កង់អគ្គិសនី ។ល។)<br>-ការលើកកម្ពស់ការរៀបចំកន្លែងសាកថ្មដោយឧបត្ថម្ភធន<br>-ការដាក់ឱ្យប្រើនូវផែនការកំណត់តម្លៃចំពោះរ៉ឺម៉កកង់បីអគ្គិសនី និងរថយន្តឈ្នួលអគ្គិសនី<br>-អភិវឌ្ឍរ៉ឺម៉កកង់បីអគ្គិសនីដែលមានតម្លៃសមរម្យសម្រាប់អ្នកបើកបរ និងដាក់ឱ្យប្រើនូវកម្ចី ឬការឧបត្ថម្ភធនក្នុងការទិញ<br>-ការធានាបាននូវប្រាក់ចំណេញដល់រថយន្តក្រុងអគ្គិសនី<br>-ការកែលម្អដោយផ្អែកលើមតិយោបល់នៃភាគីពាក់ព័ន្ធ (សមាគមដឹកជញ្ជូនភ្ញៀវទេសចរ Grab និង PassApp ជាដើម) | |
| សូចនាករ (KPI) | អត្រាប្រើប្រាស់រថយន្តអគ្គិសនី អត្រាប្រើប្រាស់រថយន្តអគ្គិសនីរបស់ភ្ញៀវទេសចរ(ក្នុងមួយចម្ងាយធ្វើដំណើរសរុប) | |
| សកម្មភាពរយៈពេលខ្លី (គម្រោងអាទិភាពសម្រាប់គោលដៅប្រចាំឆ្នាំ ២០២៥) | | |
| អង្គភាពអនុវត្ត | ចម្បង | រដ្ឋបាលខេត្ត និង MPWT |
| | បន្ទាប់បន្សំ | អជ្ញាធរជាតិអប្សរា សមាគមដឹកជញ្ជូនភ្ញៀវទេសចរ ក្រុមហ៊ុនឯកជន (ក្រុមហ៊ុនផ្តល់ថាមពលអគ្គិសនី ក្រុមហ៊ុនផលិតយានយន្តអគ្គិសនី និងស្ថាប័នហិរញ្ញវត្ថុ) |
| | អង្គភាពពាក់ព័ន្ធ | ក្រសួងបរិស្ថានកម្ពុជា និង អង្គការ UNESCO |
| សកម្មភាពចម្បង [ការបែងចែកតួនាទី] | ១. ការបង្កើតគោលនយោបាយលើកកម្ពស់ការដាក់ឱ្យប្រើប្រាស់យានយន្តអគ្គិសនី [រដ្ឋបាលខេត្ត]<br>២.ការដំឡើងស្ថានីយបញ្ចូលអាគុយយានយន្តអគ្គិសនី គម្រោងសាកល្បងនៃយានយន្តអគ្គិសនី [រដ្ឋបាលខេត្ត]<br>៣. ការវាយតម្លៃគម្រោងដាក់ឱ្យប្រើរ៉ឺម៉កកង់បីអគ្គិសនី ដោយវិនិច្ឆ័យទៅលើ ការឧបត្ថម្ភធន ការវាយតម្លៃភាពងាយស្រួលនៃការប្រើប្រាស់ ការស្ទង់មតិអំពីឆន្ទៈក្នុងការបង់ថ្លៃរបស់ភ្ញៀវជាតិ និងអន្តរជាតិ។ [រដ្ឋបាលខេត្ត]<br>៤. ការចាប់ផ្តើមអាជីវកម្មយានយន្តអគ្គិសនី [ក្រុមហ៊ុនដែលផ្គត់ផ្គង់យានយន្តអគ្គិសនី] | |
| ប្រភពមូលនិធិ / គំរូអាជីវកម្ម | គម្រោងនេះ នឹងប្រើយានយន្តអគ្គិសនី ជំនួសឱ្យយានយន្តដែលប្រើឥន្ធនៈហ្វូស៊ីល។ ប្រសិនបើយានយន្តអគ្គិសនីមានតម្លៃខ្ពស់ពេក នោះតម្រូវឱ្យមានការឧបត្ថម្ភធន ឬកម្ចីពីរដ្ឋ។ នេះជាការលើកទឹកចិត្តដល់ក្រុមហ៊ុនដឹកជញ្ជូនក្នុងការប្តូរទៅប្រើយានយន្តអគ្គិសនី។ ចំពោះបរិក្ខារសាកថ្មឬបរិក្ខារផ្លាស់ប្តូរថ្មផ្ទុក ការថែទាំបឋមត្រូវរៀបចំដោយមូលនិធិ សាធារណៈពីរដ្ឋ។ល។ ប៉ុន្តែការថែទាំជាបន្តបន្ទាប់នឹងត្រូវបានចំណាយដោយទឹកប្រាក់ដែលប្រមូលបានពីអ្នកប្រើប្រាស់ចុងក្រោយដែលប្រើប្រាស់យានយន្តអគ្គិសនី។ | |
| | ថ្លៃដើមចាប់ផ្តើមដំបូង | បន្ទុករបស់ប្រតិបត្តិករដឹកជញ្ជូន ការឧបត្ថម្ភធន និងរដ្ឋបាលខេត្ត |

| | | |
|---|---|---|
| | ចំណាយលើប្រតិបត្តិការ និងថែទាំ | បន្ទុករបស់អ្នកប្រើប្រាស់ |

## ៨.៤ សន្តិសុខ និងសុវត្ថិភាពឆ្លាតវៃ

### *៨.៤.១ គម្រោង S-០១៖ ការណែនាំប្រព័ន្ធ CCTV*

<table>
<tr><th>គម្រោង S-០១</th><th colspan="2">ការណែនាំប្រព័ន្ធ CCTV</th></tr>
<tr><td colspan="3">ខ្លឹមសារនៃគម្រោង (គោលដៅឆ្នាំ ២០៣៥)</td></tr>
<tr><td>បញ្ហាឆ្លើយតប</td><td colspan="2">១៥. ត្រូវការសុវត្ថិភាពបន្ថែមដោយជៀសផុតហានិភ័យនៃគ្រោះថ្នាក់ចរាចរណ៍ និងបទល្មើស<br>៦. តម្រូវការការកែលម្អផ្នែករឹង និងបរិក្ខារ ICT<br>៧. តម្រូវការការចែករំលែក និងប្រើប្រាស់ទិន្នន័យជាពហុវិស័យ<br>៨. តម្រូវការឱ្យមានប្រព័ន្ធទិន្នន័យចំហ សុវត្ថិភាពទិន្នន័យ និងបទប្បញ្ញត្តិ</td></tr>
<tr><td>គោលបំណង</td><td colspan="2">ធានាសុវត្ថិភាពពីបទល្មើសសម្រាប់ភ្ញៀវទេសចរ និងប្រជាពលរដ្ឋ</td></tr>
<tr><td>គោលដៅគម្រោង</td><td colspan="2">រូបភាពវីដេអូបន្តបន្ទាប់តាមពេលវេលានៃផ្នែកសំខាន់នៃក្រុងសៀមរាប នឹងត្រូវបានចេញផ្សាយជាមួយនឹងព័ត៌មានចាំបាច់ដែលនឹងនាំទៅដល់សន្តិសុខភ្ញៀវទេសចរ និងការត្រួតពិនិត្យបទល្មើស។</td></tr>
<tr><td>តំបន់គោលដៅសំខាន់</td><td colspan="2">តំបន់ទីប្រជុំជន</td></tr>
<tr><td>ការគ្រប់គ្រងទិន្នន័យ</td><td colspan="2">មជ្ឈមណ្ឌលកណ្តាល វិភាគ និងផ្សព្វផ្សាយទិន្នន័យពីកាមេរ៉ា CCTV សាធារណៈទាំងអស់ ក្រោមប្រព័ន្ធរួមបញ្ចូលគ្នា (ដោយគិតគូរពីឯកជនភាព)</td></tr>
<tr><td>បញ្ហាក្នុងការអនុវត្ត</td><td colspan="2">ការរួមបញ្ចូល និងការភ្ជាប់ប្រព័ន្ធកាមេរ៉ាសុវត្ថិភាព CCTV ដែលណែនាំដោយអ្នកពាក់ព័ន្ធនានា</td></tr>
<tr><td>សូចនាករ (KPI)</td><td colspan="2">ចំនួនកាមេរ៉ា CCTV ដែលប្រតិបត្តិការ និងទិន្នន័យបង្ហាញជាសាធារណៈ</td></tr>
<tr><td colspan="3">សកម្មភាពរយៈពេលខ្លី (គម្រោងអាទិភាពសម្រាប់គោលដៅប្រចាំឆ្នាំ ២០២៥)</td></tr>
<tr><td rowspan="3">អង្គភាពអនុវត្ត</td><td>ចម្បង</td><td>រដ្ឋបាលខេត្ត</td></tr>
<tr><td>បន្ទាប់បន្សំ</td><td>ស្នងការនគរបាលខេត្ត មន្ទីរប្រៃសណីយ៍ និងទូរគមនាគមន៍ អាជីវកម្មឯកជន (អ្នកផ្តល់ប្រព័ន្ធ)</td></tr>
<tr><td>អង្គភាពពាក់ព័ន្ធ</td><td>មន្ទីរសាធារណការ និងដឹកជញ្ជូន</td></tr>
<tr><td>សកម្មភាពចម្បង<br>[ការបែងចែកតួនាទី]</td><td colspan="2">១. ការដំឡើងកាមេរ៉ា CCTV [រដ្ឋបាលខេត្ត]<br>២. ការអភិវឌ្ឍប្រព័ន្ធត្រួតពិនិត្យទិន្នន័យសម្រាប់កាមេរ៉ា CCTVs ដែលមានស្រាប់ [អាជីវកម្មឯកជន]<br>៣. ការអភិវឌ្ឍរចនាសម្ព័ន្ធប្រតិបត្តិការ និងត្រួតពិនិត្យ និងប្រព័ន្ធថែរក្សាសន្តិសុខ [ស្នងការនគរបាលខេត្ត]<br>៤. ប្រតិបត្តិការ និងការថែទាំប្រព័ន្ធ [អាជីវកម្មឯកជន]<br>៥. ការអភិវឌ្ឍប្រព័ន្ធដំណើរការទិន្នន័យសម្រាប់ការពារឯកជនភាព [អាជីវកម្មឯកជន]<br>៦. ការប្រមូលផ្តុំ និងការបង្ហាញទិន្នន័យដែលបានវិភាគរួចទៅកាន់ថ្នាលទិន្នន័យ [មន្ទីរប្រៃសណីយ៍ និងទូរគមនាគមន៍]</td></tr>
<tr><td rowspan="3">ប្រភពមូលនិធិ /<br>គំរូអាជីវកម្ម</td><td colspan="2">ដោយសារការចំណាយដំបូងមានចំនួនតិចតួច ដូចនេះការចំណាយត្រូវបានសន្មតថាជាបន្ទុករបស់រដ្ឋបាលខេត្ត ថ្វីបើអាចមានមូលនិធិពីដៃគូអភិវឌ្ឍន៍ផងដែរ។ ការប្រមូលថ្លៃដើមដំបូង និងថ្លៃប្រតិបត្តិការ និងការថែទាំត្រូវបានសន្មតថាសម្រេចបានតាមរយៈមូលនិធិលើកកម្ពស់ទេសចរណ៍។</td></tr>
<tr><td>ថ្លៃដើមចាប់ផ្តើមដំបូង</td><td>មូលនិធិរបស់រដ្ឋបាលខេត្ត (សន្មតថាការផ្តល់មូលនិធិពីដៃគូអភិវឌ្ឍន៍ក៏ត្រូវបានគិតគូរផងដែរ)(ថ្លៃចំណាយសម្រាប់ជាឯកសារយោង៖ ៣ ០០០ ដុល្លារអាមេរិក (សម្រាប់ការដំឡើងកាមេរ៉ា ១ គ្រឿង))</td></tr>
<tr><td>ចំណាយលើប្រតិបត្តិការ និងថែទាំ</td><td>ចំណូលនៃមូលនិធិជំរុញទេសចរណ៍</td></tr>
</table>




ប្រភព៖ ក្រុមសិក្សា JICA

រូបភាព ៨.៦៖ ដ្យាក្រាមគំនិតនៃសកម្មភាពរយៈពេលខ្លីសម្រាប់ការណែនាំប្រព័ន្ធ CCTV

## ៨.៤.២ គម្រោង S-0២៖ ការអភិវឌ្ឍប្រព័ន្ធប្រកាសអាសន្នទឹកជំនន់

| គម្រោង S-0២ | ការអភិវឌ្ឍប្រព័ន្ធប្រកាសអាសន្នទឹកជំនន់ | |
|---|---|---|
| ខ្លឹមសារនៃគម្រោង (គោលដៅឆ្នាំ ២០៣៥) | | |
| បញ្ហាឆ្លើយតប | ១៦. តម្រូវការសុវត្ថិភាពបន្ថែមទប់ស្កាត់ហានិភ័យគ្រោះមហន្តរាយ (អគ្គិភ័យ ទឹកជំនន់ ជាដើម)<br>៨. តម្រូវការឱ្យមានប្រព័ន្ធទិន្នន័យចំហ សុវត្ថិភាពទិន្នន័យ និងបទបញ្ញត្តិ | |
| គោលបំណង | ការជូនដំណឹងអំពីគ្រោះមហន្តរាយដល់ភ្ញៀវទេសចរ និងប្រជាពលរដ្ឋ | |
| គោលដៅគម្រោង | ការព្រមានជាមុនអំពីគ្រោះធម្មជាតិដែលត្រូវបានដឹងយ៉ាងទូលំទូលាយដល់ប្រជាពលរដ្ឋ និងភ្ញៀវទេសចរអន្តរជាតិ | |
| តំបន់គោលដៅសំខាន់ | តំបន់ទីប្រជុំជន តំបន់បឹងទន្លេសាប | |
| ការគ្រប់គ្រងទិន្នន័យ | ការប្រមូលផ្តុំ និងការផ្សព្វផ្សាយភ្លាមៗនៃព័ត៌មានទាក់ទងនឹងគ្រោះមហន្តរាយធម្មជាតិដែលទទួលបានពីប្រភពទិន្នន័យផ្សេងៗ | |
| បញ្ហាក្នុងការអនុវត្ត | -ថ្នាលទិន្នន័យមិនទាន់បានអភិវឌ្ឍសម្រាប់ការប្រមូលផ្តុំព័ត៌មានព្រមានពីគ្រោះមហន្តរាយធម្មជាតិ<br>-កង្វះប្រភពទិន្នន័យដែលមានប្រសិទ្ធភាពសម្រាប់ព័ត៌មានព្រមានពីគ្រោះមហន្តរាយធម្មជាតិ | |
| សូចនាករ (KPI) | -ចំនួននៃការព្រមានអំពីគ្រោះធម្មជាតិដែលបានចេញ<br>-ចំនួនអ្នកទទួលការព្រមានពីគ្រោះធម្មជាតិ | |
| សកម្មភាពរយៈពេលខ្លី (គម្រោងអាទិភាពសម្រាប់គោលដៅប្រចាំឆ្នាំ ២០២៥) | | |
| អង្គភាពអនុវត្ត | ចម្បង | រដ្ឋបាលខេត្ត |
| | បន្ទាប់បន្សំ | ស្នងការនគរបាលខេត្ត |
| | អង្គភាពពាក់ព័ន្ធ | អង្គភាពអនុវត្តនៃកម្មវិធីទេសចរណ៍ |
| សកម្មភាពចម្បង [ការបែងចែកតួនាទី] | ១. បង្កើតផែនការដំឡើងឧបករណ៍ចាប់សញ្ញាទឹកជំនន់ [រដ្ឋបាលខេត្ត ស្នងការនគរបាលខេត្ត និង សង្គមស៊ីវិល]<br>២. ផ្សព្វផ្សាយនិងជូនដំណឹងដល់អ្នកពាក់ព័ន្ធ និងប្រជាពលរដ្ឋ [រដ្ឋបាលខេត្ត]<br>៣. ដំឡើងឧបករណ៍ចាប់សញ្ញាទឹកជំនន់នៅទីប្រជុំជន (ផ្សារចាស់ ជាដើម) [ក្រុមហ៊ុនឯកជន]<br>៤. ធ្វើចក្ខុនិម្មិតទិន្នន័យ និងចែករំលែកទិន្នន័យ [រដ្ឋបាលខេត្ត] | |
| ប្រភពមូលនិធិ / គំរូអាជីវកម្ម | ដោយសារការចំណាយដំបូងជាការចំណាយក្នុងទំហំទឹកប្រាក់តិចតួច នោះគេអាចសន្មតថាជាបន្ទុកចំណាយរបស់រដ្ឋបាលខេត្ត តែក៏អាចពិចារណាអំពីការសុំមូលនិធិពីដៃគូអភិវឌ្ឍន៍ផងដែរ។ ការប្រមូលប្រាក់សម្រាប់ការចំណាយដំបូង និងសម្រាប់ការចំណាយលើប្រតិបត្តិការ និងការថែទាំ អាចសម្រេចទៅបានតាមរយៈមូលនិធិអភិវឌ្ឍន៍ទេសចរណ៍។ | |
| | ថ្លៃដើមចាប់ផ្តើមដំបូង | មូលនិធិរបស់រដ្ឋបាលខេត្ត (អាចជាការផ្តល់មូលនិធិដោយដៃគូអភិវឌ្ឍន៍ផងដែរ) |
| | ចំណាយលើប្រតិបត្តិការ និងថែទាំ | ចំណូលពីកម្មវិធីទេសចរណ៍ (គម្រោង T-0១, T-0២, T-0៤) |

# ៨.៤.៣ គម្រោង S-០៣៖ ការដំឡើងប្រព័ន្ធប្រកាសអាសន្នអគ្គិភ័យ

<table>
<tr><th>គម្រោង S-០៣</th><th colspan="2">ការដំឡើងប្រព័ន្ធប្រកាសអាសន្នអគ្គិភ័យ</th></tr>
<tr><td colspan="3">ខ្លឹមសារនៃគម្រោង (គោលដៅឆ្នាំ ២០៣៥)</td></tr>
<tr><td>បញ្ហាឆ្លើយតប</td><td colspan="2">១៦.តម្រូវការសុវត្ថិភាពបន្ថែមទប់ស្កាត់ហានិភ័យគ្រោះមហន្តរាយ (អគ្គិភ័យ ទឹកជំនន់ ជាដើម)<br>៦.តម្រូវការការកែលម្អផ្នែករឹង និងបរិក្ខារ ICT</td></tr>
<tr><td>គោលបំណង</td><td colspan="2">ដើម្បីជូនដំណឹងដល់អ្នកដែលអាចរងគ្រោះពីអគ្គិភ័យ។ សហគមន៍គួរតែអាចពន្លត់ភ្លើងបានក្នុងដំណាក់កាលដំបូងនៃអគ្គិភ័យនោះ។</td></tr>
<tr><td>គោលដៅគម្រោង</td><td colspan="2">ការជូនដំណឹងអំពីអគ្គិភ័យឆាប់ សម្រេចបាននូវការជម្លៀសចេញយ៉ាងឆាប់រហ័ស និងការពន្លត់ភ្លើងដំបូង</td></tr>
<tr><td>តំបន់គោលដៅសំខាន់</td><td colspan="2">តំបន់ទីប្រជុំជន</td></tr>
<tr><td>ការគ្រប់គ្រងទិន្នន័យ</td><td colspan="2">ប្រមូល និងផ្សព្វផ្សាយព័ត៌មានអំពីអគ្គិភ័យយ៉ាងឆាប់រហ័សពីឧបករណ៍ប្រកាសអាសន្នអគ្គិភ័យជាច្រើន។</td></tr>
<tr><td>បញ្ហាក្នុងការអនុវត្ត</td><td colspan="2">-កង្វះឧបករណ៍ប្រកាសអាសន្នអគ្គិភ័យនៅក្នុងទីក្រុង<br>-បណ្ដាញព័ត៌មានមិនទាន់បានអភិវឌ្ឍរវាងឧបករណ៍ប្រកាសអាសន្នអគ្គិភ័យជាច្រើន</td></tr>
<tr><td>សូចនាករ (KPI)</td><td colspan="2">-ចំនួនឧបករណ៍ប្រកាសអាសន្នអគ្គិភ័យដែលបានដំឡើង<br>-ចំនួនដងនៃការជូនដំណឹងអំពីអគ្គិភ័យ</td></tr>
<tr><td colspan="3">សកម្មភាពរយៈពេលខ្លី (គម្រោងអាទិភាពសម្រាប់គោលដៅប្រចាំឆ្នាំ ២០២៥)</td></tr>
<tr><td rowspan="3">អង្គភាពអនុវត្ត</td><td>ចម្បង</td><td>រដ្ឋបាលខេត្ត ស្នងការនគរបាលខេត្ត</td></tr>
<tr><td>បន្ទាប់បន្សំ</td><td>ម្ចាស់អចលនទ្រព្យនីមួយៗ អាជីវកម្មឯកជន (ក្រុមហ៊ុនផលិតឧបករណ៍ប្រកាសអាសន្នអគ្គិភ័យ)</td></tr>
<tr><td>អង្គភាពពាក់ព័ន្ធ</td><td>-</td></tr>
<tr><td>សកម្មភាពចម្បង [ការបែងចែកតួនាទី]</td><td colspan="2">១. ការបង្កើតផែនការដំឡើងឧបករណ៍ប្រកាសអាសន្នអគ្គិភ័យ [រដ្ឋបាលខេត្ត ស្នងការនគរបាលខេត្ត និងសមាគមនានា]<br>២. ការពន្យល់ដល់ភាគីពាក់ព័ន្ធ (ប្រជាពលរដ្ឋ ។ល។) [រដ្ឋបាលខេត្ត ]<br>៣. ណែនាំអំពីឧបករណ៍ប្រកាសអាសន្នអគ្គិភ័យនៅក្នុងតំបន់ដែលមានភាពងាយរងគ្រោះភ្លើងឆេះខ្ពស់នៅកណ្ដាលទីក្រុង (តំបន់ផ្សារចាស់ តំបន់ផាប់ស្ទ្រីត ជាដើម) [ប្រតិបត្តិករអាជីវកម្មឯកជន (ក្រុមហ៊ុនផលិតឧបករណ៍ ប្រកាសអាសន្នអគ្គិភ័យ)]<br>៤. ការបណ្ដុះបណ្ដាល និងសកម្មភាពអប់រំទាក់ទងនឹងការជម្លៀសភ្លាមៗ និងការពន្លត់អគ្គិភ័យដំបូងដោយប្រើព័ត៌មានពីការជូនដំណឹងអំពីអគ្គិភ័យ [រដ្ឋបាលខេត្ត ស្នងការនគរបាលខេត្ត]</td></tr>
<tr><td rowspan="3">ប្រភពមូលនិធិ / គំរូអាជីវកម្ម</td><td colspan="2">ដោយសារចំនួនទឹកប្រាក់ដែលត្រូវវិនិយោគដំបូងមានទំហំតូច នោះរដ្ឋបាលខេត្តជាអ្នកទទួលបន្ទុកចំណាយ ប៉ុន្តែប្រសិនបើចាំបាច់ ក៏ត្រូវពិចារណាលើមូលនិធិពីដៃគូអភិវឌ្ឍន៍ផងដែរ។</td></tr>
<tr><td>ថ្លៃដើមចាប់ផ្ដើមដំបូង</td><td>មូលនិធិរបស់រដ្ឋបាលខេត្ត (ក៏អាចពិចារណាទៅលើមូលនិធិពីដៃគូអភិវឌ្ឍន៍ផងដែរ)(ថ្លៃចំណាយសម្រាប់ជាឯកសារយោង៖ ៣ ០០០ ដុល្លារអាមេរិក (តម្លៃលើទីផ្សារសម្រាប់ការដំឡើងប្រព័ន្ធប្រកាសអាសន្នអគ្គិភ័យមួយ)</td></tr>
<tr><td>ចំណាយលើប្រតិបត្តិការ និងថែទាំ</td><td>មូលនិធិអភិវឌ្ឍទេសចរណ៍</td></tr>
</table>

## ៨.៤.៤ គម្រោង S-04៖ ការកែលម្អទំនាក់ទំនងសាធារណៈ ដើម្បីសុវត្ថិភាព

| គម្រោង S-04 | ការកែលម្អទំនាក់ទំនងសាធារណៈ ដើម្បីសុវត្ថិភាព | |
|---|---|---|
| ខ្លឹមសារនៃគម្រោង (គោលដៅឆ្នាំ ២០៣៥) | | |
| បញ្ហាឆ្លើយតប | ១៥.ត្រូវការសុវត្ថិភាពបន្ថែមដោយជៀសផុតហានិភ័យនៃគ្រោះថ្នាក់ចរាចរណ៍ និង បទល្មើស<br>១៦.តម្រូវការសុវត្ថិភាពបន្ថែមទប់ស្កាត់ហានិភ័យគ្រោះមហន្តរាយ (អគ្គិភ័យ ទឹកជំនន់ ជាដើម)<br>៨.តម្រូវការឱ្យមានប្រព័ន្ធទិន្នន័យចំហ សុវត្ថិភាពទិន្នន័យ និងបទប្បញ្ញត្តិ | |
| គោលបំណង | ដើម្បីកែលម្អទំនាក់ទំនងសាធារណៈ នៃមន្ត្រីនគរបាល និងជូនដំណឹងអំពីបទល្មើស ឬគ្រោះថ្នាក់ចរាចរណ៍ | |
| គោលដៅគម្រោង | ព័ត៌មានស្តីពីបទល្មើសប្រចាំថ្ងៃ និងគ្រោះថ្នាក់ចរាចរណ៍ត្រូវបានចែករំលែកជាមួយប្រជាពលរដ្ឋ | |
| តំបន់គោលដៅសំខាន់ | តំបន់ទាំងមូល | |
| ការគ្រប់គ្រងទិន្នន័យ | ប្រមូល និងចែករំលែកទិន្នន័យអំពីអគ្គិភ័យ ដែលទិន្នន័យទាំងនោះបានមកពីឧបករណ៍ប្រកាសអាសន្នអគ្គិភ័យ | |
| បញ្ហាក្នុងការអនុវត្ត | -ខ្វះប្រព័ន្ធចែករំលែកព័ត៌មានទាន់ពេលវេលាសម្រាប់មន្ត្រីនគរបាល<br>-ខ្វះវេទិកាផ្តល់ព័ត៌មានសម្រាប់ប្រជាជន | |
| សូចនាករ (KPI) | ចំនួននៃការចូលប្រើព័ត៌មាន | |
| សកម្មភាពរយៈពេលខ្លី (គម្រោងអាទិភាពសម្រាប់គោលដៅប្រចាំឆ្នាំ ២០២៥) | | |
| អង្គភាពអនុវត្ត | ចម្បង | ស្នងការនគរបាលខេត្ត |
| | បន្ទាប់បន្សំ | អាជីវករឯកជន (អ្នកផ្តល់ប្រព័ន្ធ) |
| | អង្គភាពពាក់ព័ន្ធ | - |
| សកម្មភាពចម្បង [ការបែងចែកតួនាទី] | ១. កសាងប្រព័ន្ធកណ្តាលមួយនៅក្នុងស្នងការដ្ឋាននគរបាលខេត្តដើម្បីប្រមូល និងគ្រប់គ្រងព័ត៌មានពីបទល្មើសប្រចាំថ្ងៃ និង ព័ត៌មានពីគ្រោះថ្នាក់ចរាចរណ៍ [ស្នងការនគរបាលខេត្ត]<br>២. ការអភិវឌ្ឍឧបករណ៍ និងប្រព័ន្ធសម្រាប់ផ្សព្វផ្សាយព័ត៌មានទាក់ទងនឹងបទល្មើស និងគ្រោះថ្នាក់ចរាចរណ៍ [ប្រតិបត្តិករអាជីវកម្មឯកជន (អ្នកផ្តល់ប្រព័ន្ធ)]<br>៣. ផ្សព្វផ្សាយព័ត៌មានទាក់ទងនឹងបទល្មើស និង គ្រោះថ្នាក់ចរាចរណ៍ខាងលើនៅលើគេហទំព័រស្នងការនគរបាលខេត្ត និងរដ្ឋបាលខេត្ត និងកម្មវិធីទេសចរណ៍ [ស្នងការនគរបាលខេត្ត] | |
| ប្រភពមូលនិធិ / គំរូអាជីវកម្ម | ដោយសារចំនួនទឹកប្រាក់នៃការវិនិយោគមានទំហំតូច គេសន្មតថាស្នងការនគរបាលខេត្តនឹងធ្វើការបណ្តាក់ទុនដំបូងជាមួយនឹងមូលនិធិផ្ទាល់ខ្លួន ប៉ុន្តែប្រសិនបើចាំបាច់ ការរួមចំណែកនៃមូលនិធិពីដៃគូអភិវឌ្ឍន៍ក៏នឹងត្រូវពិចារណា។ ដោយសារការចំណាយលើប្រតិបត្តិការ និងការថែទាំមានតិចតួចបំផុត វាត្រូវបានសន្មតថានគរបាលខេត្តនឹងចូលរួមចំណែកជាមួយមូលនិធិផ្ទាល់ខ្លួន។ | |
| | ថ្លៃដើមចាប់ផ្តើមដំបូង | មូលនិធិរបស់ស្នងការនគរបាលខេត្ត (អាចពិចារណាលើមូលនិធិនៃដៃគូអភិវឌ្ឍន៍ ផងដែរ) |
| | ចំណាយលើប្រតិបត្តិការ និងថែទាំ | មូលនិធិរបស់ស្នងការនគរបាលខេត្ត |

## ៨.៥ ការគ្រប់គ្រងកាកសំណល់ឆ្លាតវៃ

### *៨.៥.១ គម្រោង W-០១៖ ពង្រឹងប្រព័ន្ធគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន និងការអប់រំអំពីបរិស្ថាន*

<table>
<tr><th>គម្រោង W-០១</th><th colspan="2">ពង្រឹងប្រព័ន្ធគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន និងការអប់រំអំពីបរិស្ថាន</th></tr>
<tr><td colspan="3">ខ្លឹមសារនៃគម្រោង (គោលដៅឆ្នាំ ២០៣៥)</td></tr>
<tr><td>បញ្ហាប្រឈម</td><td colspan="2">១៧. ត្រូវការការអប់រំដែលឈានទៅរកសកម្មភាពដែលប្រកបដោយភាតរបរិស្ថាន<br>១៨. តម្រូវការសម្រាប់ការជំរុញគំនិតផ្តួចផ្តើមសាធារណៈ</td></tr>
<tr><td>គោលបំណង</td><td colspan="2">លើកកម្ពស់ការយល់ដឹងអំពីបរិស្ថានដល់ប្រជាពលរដ្ឋ ដោយផ្តោតលើការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន</td></tr>
<tr><td>គោលដៅគម្រោង</td><td colspan="2">កាត់បន្ថយបរិមាណសំរាម សំណល់រឹងតាមទីផ្សារ សណ្ឋាគា និងគ្រួសារ ព្រមទាំងធ្វើការញែកសំរាមតាមប្រភេទ</td></tr>
<tr><td>តំបន់គោលដៅសំខាន់</td><td colspan="2">តំបន់ទីប្រជុំជន</td></tr>
<tr><td>ការគ្រប់គ្រងទិន្នន័យ</td><td colspan="2">មានទិន្នន័យបរិមាណសំរាម សំណល់រឹងពីលំនៅឋាន និងតំបន់ទេសចរណ៍តាមរយៈប្រព័ន្ធប្រមូលសំរាមដែលមានប្រសិទ្ធភាព</td></tr>
<tr><td>ដំណោះស្រាយបញ្ហាប្រឈម</td><td colspan="2">• កិច្ចសហប្រតិបត្តិការជាមួយក្រុមហ៊ុនឯកជន ដែលផ្តល់សេវាគ្រប់គ្រងសំរាម<br>• លើកទឹកចិត្តដល់អាជីវកម្មកែច្នៃសំរាម<br>• លើកទឹកចិត្តគ្រួសារក្រីក្រក្នុងការបង់ថ្លៃសេវា</td></tr>
<tr><td>សូចនាករ (KPI)</td><td colspan="2">• បរិមាណសំណល់<br>• ភាគរយនៃការកែច្នៃសំរាម<br>• ចំនួនដងនៃយុទ្ធនាការផ្សព្វផ្សាយ</td></tr>
<tr><td colspan="3">សកម្មភាពរយៈពេលខ្លី (គម្រោងអាទិភាពសម្រាប់គោលដៅប្រចាំឆ្នាំ ២០២៥)</td></tr>
<tr><td rowspan="3">អង្គភាពអនុវត្ត</td><td>ចម្បង</td><td>រដ្ឋបាលខេត្ត មន្ទីរបរិស្ថានខេត្ត មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងរដ្ឋបាលក្រុង/ស្រុក</td></tr>
<tr><td>បន្ទាប់បន្សំ</td><td>រដ្ឋបាលសង្កាត់/ឃុំគំរូ និងក្រុមហ៊ុនផ្តល់សេវា</td></tr>
<tr><td>អង្គភាពពាក់ព័ន្ធ</td><td>ក្រសួងមហាផ្ទៃ ក្រសួងបរិស្ថាន ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ប្រជាពលរដ្ឋ និងអាជីវករប្រមូលទិញ/កែច្នៃអេតចាយ</td></tr>
<tr><td>សកម្មភាពចម្បង [ការបែងចែកតួនាទី]</td><td colspan="2">១. ពិភាក្សាជ្រើសរើសសង្កាត់គំរូសម្រាប់អនុវត្តប្រព័ន្ធគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន (ការប្រមូល ការបោះចោលសំរាម និងការប្រមូលថ្លៃសេវា) [រដ្ឋបាលខេត្ត មន្ទីរបរិស្ថានខេត្ត មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋបាលក្រុង/ស្រុក និងរដ្ឋបាលសង្កាត់/ឃុំគំរូ]<br>២. ការរៀបចំផែនការវិធីសាស្ត្រអនុវត្ត ប្រព័ន្ធគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន និងពន្យល់ណែនាំដល់ប្រជាពលរដ្ឋឱ្យមានការឯកភាពគ្នា [រដ្ឋបាលខេត្ត មន្ទីរបរិស្ថានខេត្ត មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋបាលក្រុង/ស្រុក រដ្ឋបាលសង្កាត់/ឃុំគំរូ និងប្រជាពលរដ្ឋ]<br>៣. អនុវត្តន៍វិធីសាស្ត្រអប់រំស្តីពីបរិស្ថាន ដោយប្រើប្រាស់បច្ចេកវិទ្យា [ឃុំសង្កាត់គំរូ]<br>៤. ការអនុវត្តប្រព័ន្ធគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន (ការប្រមូល ការបោះចោលសំរាម និងការប្រមូលថ្លៃសេវា) [រដ្ឋបាលក្រុង/ស្រុក និងរដ្ឋបាលសង្កាត់គំរូ]<br>៥. អប់រំការងារបរិស្ថាន ដោយណែនាំឱ្យប្រជាពលរដ្ឋធ្វើការញែកសំរាមកែច្នៃ និងកាត់បន្ថយបរិមាណសំរាម [សង្កាត់គំរូ]</td></tr>
<tr><td rowspan="2">ប្រភពមូលនិធិ / គំរូអាជីវកម្ម</td><td colspan="2">ទទួលគាំទ្រពីដៃគូអភិវឌ្ឍន៍ផ្សេងៗ សម្រាប់បំពាក់មធ្យោបាយ និងសម្ភារផ្សេងៗ បន្ថែមលើថវិកាពីថ្លៃប្រមូលសេវា និងថវិការបស់រដ្ឋបាលខេត្ត</td></tr>
<tr><td>ថ្លៃដើមចាប់ផ្តើមដំបូង</td><td>ថវិការដ្ឋបាលខេត្ត (ការផ្តល់មូលនិធិដោយដៃគូអភិវឌ្ឍន៍ក៏ត្រូវបានគិតគូរផងដែរ)(តម្លៃជាឯកសារយោង៖ 500 000ដុល្លា (ប្រាំរយពាន់ដុល្លាអាមេរិច)</td></tr>
</table>

| គម្រោង W-០១ | ពង្រឹងប្រព័ន្ធគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន និងការអប់រំអំពីបរិស្ថាន | |
|---|---|---|
| | ចំណាយលើប្រតិបត្តិការ និងថែទាំ | ថ្លៃសេវាប្រមូលពីអ្នកប្រើប្រាស់ |




ប្រភព ៖ ក្រុមសិក្សា JICA

**រូបភាព ៨.៧៖ ប្រព័ន្ធគ្រប់គ្រងកាកសំណល់**

## ៨.៥.២ គម្រោង W-០២៖ ការដំឡើងប្រព័ន្ធ IoT សម្រាប់គ្រប់គ្រងការប្រមូលសំរាម

<table>
<tr><th>គម្រោង W-០២</th><th colspan="2">ការដំឡើងប្រព័ន្ធ IoT សម្រាប់គ្រប់គ្រងការប្រមូលសំរាម</th></tr>
<tr><td colspan="3">ខ្លឹមសារនៃគម្រោង (គោលដៅឆ្នាំ ២០៣៥)</td></tr>
<tr><td>បញ្ហាឆ្លើយតប</td><td colspan="2">១៨. តម្រូវការសម្រាប់ការជំរុញគំនិតផ្តួចផ្តើមសាធារណៈ</td></tr>
<tr><td>គោលបំណង</td><td colspan="2">បង្កើនអត្រាប្រមូលសំរាមពីតំបន់សាធារណៈ និងគ្រួសារដល់ ១០០ ភាគរយ។</td></tr>
<tr><td>គោលដៅគម្រោង</td><td colspan="2">ធុងសំរាមដែលមានឧបករណ៍ចាប់សញ្ញាបង្ហាញបរិមាណកាកសំណល់នឹងត្រូវដំឡើងនៅទីប្រជុំជន និងនៅកន្លែងសាធារណៈ ហើយនៅពេលជាមួយគ្នានោះការបែងចែកសំរាមក៏នឹងត្រូវបានអនុវត្តផងដែរ។</td></tr>
<tr><td>តំបន់គោលដៅសំខាន់</td><td colspan="2">តំបន់ទីប្រជុំជន តំបន់បេតិកភណ្ឌ</td></tr>
<tr><td>ការគ្រប់គ្រងទិន្នន័យ</td><td colspan="2">• វាស់ស្ទង់បរិមាណកាកសំណល់តាមដងផ្លូវ និងសួនច្បារតាមដងស្ទឹងសៀមរាប<br>• ត្រួតពិនិត្យមើលខ្សែផ្លូវរថយន្តប្រមូលសំរាម</td></tr>
<tr><td>បញ្ហាក្នុងការអនុវត្ត</td><td colspan="2">• ការយល់ដឹងអំពីបរិស្ថានរបស់ប្រជាពលរដ្ឋ និងភ្ញៀវទេសចរ<br>• ការបែងចែកតួនាទីរវាងក្រុមហ៊ុនប្រមូលសំរាម និងរដ្ឋបាលខេត្ត</td></tr>
<tr><td>សូចនាករ (KPI)</td><td colspan="2">• អនាម័យកន្លែងសាធារណៈ<br>• កាត់បន្ថយការចោលសំរាមខុសច្បាប់ ខ្សែផ្លូវឡានដឹកសំរាម</td></tr>
<tr><td colspan="3">សកម្មភាពរយៈពេលខ្លី (គម្រោងអាទិភាពសម្រាប់គោលដៅប្រចាំឆ្នាំ ២០២៥)</td></tr>
<tr><td rowspan="3">អង្គភាពអនុវត្ត</td><td>ចម្បង</td><td>រដ្ឋបាលក្រុង និងអាជ្ញាធរជាតិអប្សរា</td></tr>
<tr><td>បន្ទាប់បន្សំ</td><td>ប្រតិបត្តិករសម្បទាន (ឧ. GAEA) រដ្ឋបាលខេត្ត មន្ទីរបរិស្ថាន និងឃុំ សង្កាត់</td></tr>
<tr><td>អង្គភាពពាក់ព័ន្ធ</td><td>ក្រសួងមហាផ្ទៃក្រសួងបរិស្ថាន</td></tr>
<tr><td>សកម្មភាពចម្បង [ការបែងចែកតួនាទី]</td><td colspan="2">១. ដំឡើងឧបករណ៍ចាប់សញ្ញានៅតាមឡានដឹកសំរាម<br>២. រៀបចំផែនការគ្រប់គ្រងសំរាម [រដ្ឋបាលខេត្ត និងអាជ្ញាធរជាតិអប្សរា]<br>៣. ការពន្យល់អំពីវិធីសាស្ត្រនៃការអនុវត្ត និងផែនការគ្រប់គ្រងកាកសំណល់ទៅសាលាឃុំ សង្កាត់ ដើម្បីអោយមានការអនុវត្តជាឯកច្ឆ័ន [រដ្ឋបាលខេត្ត សាលាឃុំ សង្កាត់ និងប្រតិបត្តិករសម្បទាន]<br>៤. ដំឡើងធុងសំរាមជាមួយនឹងឧបករណ៍ចាប់សញ្ញាដែលបង្ហាញពីបរិមាណសំរាម សំណល់រឹងទីប្រជុំជន [រដ្ឋបាលក្រុង ប្រតិបត្តិករសម្បទាន]<br>៥.ការប្រមូលទិន្នន័យដែលពាក់ព័ន្ធ (បរិមាណនៃសំរាម) [រដ្ឋបាលក្រុង]<br>៦.ការប្រើប្រាស់ប្រព័ន្ធ IoTដើម្បីធ្វើឱ្យការប្រមូលសំរាមកាន់តែមានប្រសិទ្ធភាព</td></tr>
<tr><td rowspan="3">ប្រភពមូលនិធិ / គំរូអាជីវកម្ម</td><td colspan="2">ចំពោះការគ្រប់គ្រងការចោលសំរាម (ដូចជាការបែងចែកកាកសំណល់ទៅតាមប្រភេទ ជាដើម) គឺពុំត្រូវការថវិកាក្នុងចំនួនច្រើននោះឡើយ ហើយវាជាកិច្ចការដែលអាចសម្រេចទៅបានតាមរយៈការអប់រំអំពីបរិស្ថានដល់ភាគីពាក់ព័ន្ធ និងការអនុវត្ត។ ការដំឡើងឧបករណ៍ចាប់សញ្ញានឹងត្រូវចំណាយថវិកាដោយរដ្ឋបាលខេត្ត ហើយថវិកាថែទាំ និងប្រតិបត្តិការនឹងត្រូវចំណាយដោយយកថវិកាដែលប្រមូលបានមកពីការប្រមូលថ្លៃសេវា។ រដ្ឋបាលខេត្តត្រូវខិតខំប្រឹងប្រែងពន្យល់អំពីគោលបំណង ដើម្បីឱ្យប្រតិបត្តិករសម្បទាន និងអាជ្ញាធរជាតិអប្សរាអាចសហការចូលរួមផ្នែកហិរញ្ញវត្ថុផងដែរ។ ហើយក៏ចាំបាច់ត្រូវកែសម្រួលដើម្បីទទួលបានការគាំទ្រពីដៃគូអភិវឌ្ឍន៍ផងដែរ។</td></tr>
<tr><td>ថ្លៃដើមចាប់ផ្តើមដំបូង</td><td>រដ្ឋបាលខេត្ត (ថ្លៃចំណាយ សម្រាប់ជាឯកសារយោង៖ ២០០ ដុល្លារក្នុងការដំឡើងឧបករណ៍ចាប់សញ្ញាសម្រាប់ឡានដឹកសំរាមមួយគ្រឿង និង ១០០,០០០ ដុល្លារសម្រាប់តម្លៃអភិវឌ្ឍន៍កម្មវិធី)</td></tr>
<tr><td>ចំណាយលើប្រតិបត្តិ-ការ និងថែទាំ</td><td>ការប្រមូលថ្លៃសេវាពីប្រជាជន</td></tr>
</table>



ប្រភព៖ ក្រុមសិក្សា JICA

រូបភាព ៨.៨៖ រូបភាពនៃគម្រោងការដំឡើងប្រព័ន្ធ IoTសម្រាប់ការប្រមូលសំរាម

## ៨.៥.៣ គម្រោង W-0៣៖ ការគ្រប់គ្រងទីលានទុកដាក់សំរាមប្រកបដោយអនាម័យ

| គម្រោង W-0៣ | ការគ្រប់គ្រងទីលានទុកដាក់សំរាមប្រកបដោយអនាម័យ | |
|---|---|---|
| ខ្លឹមសារនៃគម្រោង (គោលដៅឆ្នាំ ២០៣៥) | | |
| បញ្ហាឆ្លើយតប | ១៩. មានតម្រូវការបន្ថែមលើការកសាងហេដ្ឋារចនាសម្ព័ន្ធ | |
| គោលបំណង | បង្កើតកន្លែងចាក់សំរាម ជាមួយនឹងការគ្រប់គ្រងបរិស្ថានល្អ | |
| គោលដៅគម្រោង | បង្កើតកន្លែងចាក់សំរាមប្រកបដោយអនាម័យ មិនមែនជាកន្លែងចោលចុងក្រោយដូចសព្វថ្ងៃនោះទេ | |
| តំបន់គោលដៅសំខាន់ | តំបន់ទីប្រជុំជន | |
| ការគ្រប់គ្រងទិន្នន័យ | -ការអនុវត្តការវាយតម្លៃការញែក និងការកែច្នៃឡើងវិញ<br>-ការគណនាតម្លៃស្តង់ដារបរិស្ថាន<br>-ចំនួនទឹកប្រាក់ថ្លៃប្រមូល | |
| បញ្ហាក្នុងការអនុវត្ត | -ទីតាំងចាក់សំរាម<br>-ស្តង់ដារបរិស្ថានសម្រាប់ការចាក់សំរាម | |
| សូចនាករ (KPI) | -បរិមាណកាកសំណល់<br>-អត្រានៃការកែច្នៃ<br>-តម្លៃស្តង់ដារបរិស្ថាន | |
| សកម្មភាពរយៈពេលខ្លី (គម្រោងអាទិភាពសម្រាប់គោលដៅឆ្នាំ ២០២៥) | | |
| អង្គភាពអនុវត្ត | ចម្បង | រដ្ឋបាលខេត្ត |
| | បន្ទាប់បន្សំ | មន្ទីរបរិស្ថាន ក្រសួងបរិស្ថាន CDC |
| | អង្គភាពពាក់ព័ន្ធ | ក្រសួងមហាផ្ទៃ ប្រតិបត្តិករសម្បទាន (GAEA) ដៃគូអភិវឌ្ឍន៍ និង សហគ្រាសឯកជន |
| សកម្មភាពចម្បង [ការបែងចែកតួនាទី] | ១. ធ្វើការពិភាក្សាអំពី ទីលានចាក់សំរាម [រដ្ឋបាលខេត្ត ប្រតិបត្តិករសម្បទាន និងអាជ្ញាធរជាតិអប្សរា]<br>២. ការរៀបចំផែនការអនុវត្ត និង ទម្រង់សំណើនៃទីលានចាក់សំរាមប្រកបដោយអនាម័យ [រដ្ឋបាលខេត្ត ប្រតិបត្តិករសម្បទាន អាជ្ញាធរជាតិអប្សរា]<br>៣. ការរចនា និងការសាងសង់ទីលានចាក់សំរាមប្រកបដោយអនាម័យ ដែលបំពេញតាមស្តង់ដារបរិស្ថាន [រដ្ឋបាលខេត្ត និងដៃគូអភិវឌ្ឍន៍]<br>៤. ប្រតិបត្តិការសមស្រប និងការគ្រប់គ្រងទីលានចាក់សំរាមប្រកបដោយអនាម័យ [ក្រុមហ៊ុនឯកជន] | |
| ប្រភពមូលនិធិ / គំរូអាជីវកម្ម | សាងសង់ហេដ្ឋារចនាសម្ព័ន្ធដែលរួមបញ្ចូលគ្នានូវកន្លែងចាក់សំរាម និងបរិក្ខារបន្ថែមដែលពាក់ព័ន្ធដែលអាចរក្សាទុកកាកសំណល់បានត្រឹមត្រូវ និងធ្វើឱ្យវាមានស្ថេរភាពជីវសាស្ត្រ រូបសាស្ត្រ និងគីមីស្របតាមស្តង់ដារបរិស្ថានដែលមិនរារាំងដល់ការអភិរក្សបរិស្ថានរស់នៅ ហើយប្រតិបត្តិការដោយ ដៃគូអភិវឌ្ឍន៍របស់ខេត្ត ឬក្រុមហ៊ុនឯកជន។ ផ្តោតលើការទទួលយកកាកសំណល់មិនទូទៅ ដូចជាផលិតផលសំណង់ កាកសំណល់រោងចក្រ/កសិកម្ម នោះប្រតិបត្តិករអាចប្រមូលថ្លៃក្នុងការប្រតិបត្តិការពីបុគ្គលដែលបោះចោលកាកសំណល់។ រដ្ឋបាលខេត្ត នឹងដាក់ចេញនូវគោលនយោបាយអនុគ្រោះសម្រាប់ការកែច្នៃ និងលើកកម្ពស់គម្រោងកែច្នៃឡើងវិញ។ | |
| | ថ្លៃដើមចាប់ផ្តើមដំបូង | ថវិកាសាធារណៈ (រដ្ឋបាលខេត្ត និងមូលនិធិដៃគូអភិវឌ្ឍន៍)<br>(ថ្លៃចំណាយ សម្រាប់ជាឯកសារយោង៖ ២០,០០០,០០០ ដុល្លារ (ឧ. ការសាងសង់លើផ្ទៃដី ៨ ហិកតា ដោយ ADB)) |
| | ចំណាយលើប្រតិបត្តិការ និងថែទាំ | ថវិកាសាធារណៈ (ថវិកាប្រចាំឆ្នាំរបស់រដ្ឋបាលខេត្ត ឬកិច្ចសន្យាសម្បទាន ឬមូលនិធិក្រុមហ៊ុនឯកជន) |




ប្រភព៖ ក្រុមសិក្សា JICA

រូបភាព ៨.៩៖ ទីលានចាក់សំរាមប្រកបដោយអនាម័យ

## *៨.៥.៤ គម្រោង W-0៤៖ ការកែលម្អគុណភាពស្ទឹង និងការប្រើប្រាស់ស្ទឹង*

| គម្រោង W-0៤ | ការកែលម្អគុណភាពស្ទឹង និងការប្រើប្រាស់ស្ទឹង | |
|---|---|---|
| ខ្លឹមសារនៃគម្រោង (គោលដៅឆ្នាំ ២០៣៥) | | |
| បញ្ហាឆ្លើយតប | ១៨. តម្រូវការសម្រាប់ការជំរុញគំនិតផ្តួចផ្តើមសាធារណៈ | |
| គោលបំណង | ដើម្បីកែលម្អគុណភាពទឹកក្នុងតំបន់ទីសាធារណៈស្របតាមស្តង់ដារបរិស្ថាន | |
| គោលដៅគម្រោង | បង្កើតប្រព័ន្ធត្រួតពិនិត្យ | |
| តំបន់គោលដៅសំខាន់ | តំបន់ទីប្រជុំជន | |
| ការគ្រប់គ្រងទិន្នន័យ | ការវាស់កម្រិតតម្រូវការអុកស៊ីសែនគីមី (COD) និង អុកស៊ីសែនជីវៈគីមី (BOD) និងវាស់កម្រិតបំភាយក្លិន | |
| បញ្ហាក្នុងការអនុវត្ត | ទឹកដែលមិនបានបន្សុទ្ធ កំពុងហូរចូលក្នុងតំបន់ទីសាធារណៈ | |
| សូចនាករ (KPI) | តួលេខនៃកម្រិត COD និង BOD | |
| សកម្មភាពរយៈពេលខ្លី (គម្រោងអាទិភាពសម្រាប់គោលដៅប្រចាំឆ្នាំ ២០២៥) | | |
| អង្គភាពអនុវត្ត | ចម្បង | សហគ្រាសឯកជន និងរដ្ឋបាលខេត្ត |
| | បន្ទាប់បន្សំ | មន្ទីរសាធារណការ និងដឹកជញ្ជូន |
| | អង្គភាពពាក់ព័ន្ធ | មន្ទីរទេសចរណ៍ |
| សកម្មភាពចម្បង [ការបែងចែកតួនាទី] | ១. ការត្រួតពិនិត្យគុណភាពទឹក និងការបំភាយក្លិននៃស្ទឹងសៀមរាប (ការដំឡើងឧបករណ៍ចាប់សញ្ញា) [មន្ទីរសាធារណការ និងដឹកជញ្ជូន]<br>២. ការកែលម្អគុណភាពទឹកស្ទឹងសៀមរាប និងផែនការប្រើប្រាស់ដី [រដ្ឋបាលខេត្ត និងមន្ទីរសាធារណការ និងដឹកជញ្ជូន និងសហគ្រាសឯកជន]<br>៣. ការអនុវត្តការកែលម្អគុណភាពទឹកស្ទឹងសៀមរាប [មន្ទីរសាធារណការ និងដឹកជញ្ជូន និងក្រុមហ៊ុនឯកជន]<br>៤. ការអនុវត្តផែនការប្រើប្រាស់ដី [រដ្ឋបាលខេត្ត មន្ទីរទេសចរណ៍ និងសហគ្រាសឯកជន]<br>៥. ការផ្ទុកទិន្នន័យ និងការផ្សព្វផ្សាយនៅលើថ្នាលទិន្នន័យ [មន្ទីរប្រៃសណីយ៍ និងទូរគមនាគមន៍] | |
| ប្រភពមូលនិធិ / គំរូអាជីវកម្ម | ការត្រួតពិនិត្យគុណភាពទឹក នៅក្នុងផែនការគ្រប់គ្រងនិងថែទាំដែលបន្ទាប់ពីគម្រោងកែលម្អស្ទឹងសៀមរាប ដែលកំពុងត្រូវបានអនុវត្តនាពេលបច្ចុប្បន្ន មានសារៈសំខាន់ណាស់សម្រាប់ទីក្រុងទេសចរណ៍។ ដើម្បីធ្វើឱ្យមាត់ស្ទឹងក្លាយជាកន្លែងទាក់ទាញភ្ញៀវទេសចរ និងការជួសជុលស្តារឡើងវិញ រដ្ឋបាលខេត្តនឹងខិតខំថែរក្សាគុណភាពទឹកដោយបង្កើតលំហូរសិប្បនិម្មិតនៅក្នុងស្ទឹងសៀមរាប។ ចំពោះគ្រឿងបរិក្ខារ ក្រសួងទេសចរណ៍ និងរដ្ឋបាលខេត្ត នឹងពិភាក្សាអំពីថវិកាជាតិ ឬការប្រើប្រាស់មូលនិធិនៃដៃគូអភិវឌ្ឍន៍។ ប្រសិនបើអាច រដ្ឋបាលខេត្តគួរបង្កើតមូលនិធិអភិវឌ្ឍវិស័យទេសចរណ៍ សម្រាប់ការងារថែទាំ។ | |
| | ថ្លៃដើមចាប់ផ្តើមដំបូង | ថវិកាសាធារណៈ (រដ្ឋបាលខេត្ត ក្រសួងទេសចរណ៍ ជំនួយឧបត្ថម្ភពីដៃគូអភិវឌ្ឍន៍)(ថ្លៃចំណាយ សម្រាប់ជាឯកសារយោង៖ ២,000 ដុល្លារ/គ.ម (សាងសង់តាមដងស្ទឹង) ១00,000 ដុល្លារ/គ.ម (សម្រាប់បការដំឡើងប្រព័ន្ធបន្សុទ្ធទឹក) ៥0 ដុល្លារ /ម$^{៣}$ (សម្ភារៈបន្សុទ្ធទឹក) និង ១00,000 ដុល្លារ (ថ្លៃចំណាយបង្កើតកម្មវិធី) |
| | ចំណាយលើប្រតិបត្តិការ និងថែទាំ | ថវិកាសាធារណៈ (រដ្ឋបាលខេត្ត ឬការប្រើប្រាស់មូលនិធិ ។ល។) |



ប្រភព៖ ក្រសួងដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី



ប្រភព៖ Photock

រូបភាព ៨.១០៖ រូបភាពនៃការប្រើប្រាស់ដងស្ទឹង

## ៨.៥.៥ គម្រោង W-០៥៖ ការកែលម្អប្រព័ន្ធគ្រប់គ្រងឧបករណ៍បរិក្ខារទឹកកខ្វក់

| គម្រោង W-០៥ | ការកែលម្អប្រព័ន្ធគ្រប់គ្រងឧបករណ៍បរិក្ខារទឹកកខ្វក់ | |
|---|---|---|
| ខ្លឹមសារនៃគម្រោង (គោលដៅឆ្នាំ ២០៣៥) | | |
| បញ្ហាឆ្លើយតប | ១៩. មានតម្រូវការបន្ថែមលើការកសាងហេដ្ឋារចនាសម្ព័ន្ធ | |
| គោលបំណង | បណ្តាញប្រព័ន្ធលូទឹកកខ្វក់ និងកន្លែងបន្សុទ្ធនឹងត្រូវបានពង្រឹង ហើយប្រព័ន្ធថែទាំនឹងត្រូវបានបង្កើតឡើង | |
| គោលដៅគម្រោង | ការបង្កើតប្រព័ន្ធគ្រប់គ្រងថែទាំបណ្តាញលូទឹកកខ្វក់ដែលទាក់ទងនឹងផែនការរយៈពេលវែង និងការគាំទ្រវិធានការគ្រប់គ្រងវិបត្តិ (បង្កើតមូលដ្ឋានទិន្នន័យនៃព័ត៌មានអំពីបណ្តាញលូ) | |
| តំបន់គោលដៅសំខាន់ | តំបន់ទីប្រជុំជន | |
| ការគ្រប់គ្រងទិន្នន័យ | -ធ្វើបច្ចុប្បន្នភាពសៀវភៅបញ្ជីសារពើភ័ណ្ឌខ្សែបណ្តាញទឹកកខ្វក់<br>-ព័ត៌មានតាមដានចរន្តលំហូរទឹកឡើង និងចុះ | |
| បញ្ហាក្នុងការអនុវត្ត | -បច្ចេកទេសក្នុងការធ្វើបច្ចុប្បន្នភាពសៀវភៅបញ្ជីសារពើភ័ណ្ឌខ្សែបណ្តាញទឹកខ្វក់<br>-ការចូលរួមក្នុងការបង់ថ្លៃឈ្នួលបញ្ចេញទឹកកខ្វក់ | |
| សូចនាករ (KPI) | -អត្រានៃការបង់ថ្លៃបញ្ចេញចោលទឹកកខ្វក់ពីសំណាក់ក្រុមគ្រួសារ និងក្រុមហ៊ុន<br>-ផែនការថែទាំប្រចាំឆ្នាំ | |
| សកម្មភាពរយៈពេលខ្លី (គម្រោងអាទិភាពសម្រាប់គោលដៅប្រចាំឆ្នាំ ២០២៥) | | |
| អង្គភាពអនុវត្ត | ចម្បង | រដ្ឋបាលខេត្ត និង MPWT |
| | បន្ទាប់បន្សំ | មន្ទីរសាធារណការ និងដឹកជញ្ជូន |
| | អង្គភាពពាក់ព័ន្ធ | ដៃគូអភិវឌ្ឍន៍ |
| សកម្មភាពចម្បង [ការបែងចែកតួនាទី] | ១) បង្កើតប្រព័ន្ធអនុវត្តការថែទាំបំពង់បង្ហូរទឹក [មន្ទីរសាធារណការ និងដឹកជញ្ជូន រដ្ឋបាលខេត្ត]<br>២) ការប្រមូលទិន្នន័យអំពីបណ្តាញលូដែលមានស្រាប់ និងការត្រួតពិនិត្យសមត្ថភាពបណ្តាញលូទឹកកខ្វក់ [មន្ទីរសាធារណការ និងដឹកជញ្ជូន]<br>៣) ផែនការ និងហិរញ្ញប្បទានសម្រាប់រោងចក្រប្រព្រឹត្តិកម្មទឹកស្អុយថ្មី [រដ្ឋបាលខេត្ត និងក្រសួងសាធារណការ និងដឹកជញ្ជូន]<br>៤) ការសាងសង់រោងចក្រប្រព្រឹត្តិកម្មទឹកស្អុយថ្មី [ក្រសួងសាធារណការ និងដឹកជញ្ជូន] | |
| ប្រភពមូលនិធិ / គំរូអាជីវកម្ម | កង្វះសមត្ថភាពសម្រាប់ប្រព្រឹត្តិកម្មទឹកស្អុយត្រូវបានបញ្ជាក់នៅក្នុងទិន្នន័យរួចហើយ ហើយការពង្រីក និងការសាងសង់ថ្មីគឺជាបញ្ហាបន្ទាន់។ ដើម្បីសាងសង់កន្លែងធំជាងទំហំបច្ចុប្បន្ន ចាំបាច់ត្រូវស្នើសុំថវិកាពីដៃគូអភិវឌ្ឍន៍។ ទោះបីជាយ៉ាងណាក៏ដោយ នៅពេលពិចារណាលើជំនួយហិរញ្ញវត្ថុសម្រាប់ការសាងសង់ ដៃគូអភិវឌ្ឍន៍នឹងត្រូវទាមទារឱ្យមានប្រព័ន្ធប្រតិបត្តិការថែទាំ និងប្រតិបត្តិការនូវប្រព្រឹត្តកម្មនៅនឹងកន្លែង ហើយការបណ្តុះបណ្តាលសមត្ថភាពគ្រប់គ្រង និងប្រព័ន្ធប្រមូលប្រាក់ពី MPWT ទៅ មន្ទីរសាធារណការ និងដឹកជញ្ជូន នឹងប្រព័ន្ធប្រមូលថ្លៃសេវាគឺជាការចាំបាច់។ | |
| | ថ្លៃដើមចាប់ផ្តើមដំបូង | ថវិកាសាធារណៈ (មូលនិធិដៃគូអភិវឌ្ឍន៍ ។ល។)<br>(ថ្លៃចំណាយ សម្រាប់ជាឯកសារយោង៖ ៤៨,000,000 ដុល្លារ (រោងចក្រប្រព្រឹត្តកម្មទឹកកខ្វក់ដែលមានសមត្ថភាពស្មើនឹងរោងចក្របច្ចុប្បន្ន) ១៣,000,000 ដុល្លារ (សម្រាប់បណ្តាញលូទឹកកខ្វក់ដែលមានសមត្ថភាពស្មើនឹងបណ្តាញលូបច្ចុប្បន្ន) |
| | ចំណាយលើប្រតិបត្តិការ និងថែទាំ | ថវិកាសាធារណៈ (មន្ទីរសាធារណការ និងដឹកជញ្ជូន) |

## ៨.៥.៦ គម្រោង W-0៦៖ យន្តការបង់ថ្លៃសេវាសាធារណៈរួមគ្នា

| គម្រោង W-0៦ | យន្តការបង់ថ្លៃសេវាសាធារណៈរួមគ្នា (ថ្លៃទឹកភ្លើង សំរាម ជាដើម) | |
|---|---|---|
| ខ្លឹមសារនៃគម្រោង (គោលដៅឆ្នាំ ២០៣៥) | | |
| បញ្ហាឆ្លើយតប | ១៧. ត្រូវការការអប់រំដែលឈានទៅរកសកម្មភាពដែលប្រកបដោយភាតរបរិស្ថាន<br>១៨. តម្រូវការសម្រាប់ការជំរុញគំនិតផ្តួចផ្តើមសាធារណៈ | |
| គោលបំណង | បង្កើតប្រព័ន្ធមួយដើម្បីបង្រួបបង្រួមការគិតថ្លៃសេវាសាធារណៈ ដើម្បីកែលម្អភាពងាយស្រួលរបស់ប្រជាពលរដ្ឋ និងបង្កើនប្រសិទ្ធភាពរដ្ឋបាល | |
| គោលដៅគម្រោង | បង្កើតប្រព័ន្ធមួយដើម្បីបង្រួបបង្រួមការគិតថ្លៃសេវាសាធារណៈ | |
| តំបន់គោលដៅសំខាន់ | តំបន់ទីប្រជុំជន (ចម្បង) តំបន់បឹងទន្លេសាប (បន្ទាប់បន្សំ) | |
| ការគ្រប់គ្រងទិន្នន័យ | -អត្រាប្រមូលថ្លៃសេវា<br>-របាយការណ៍សមតុល្យ | |
| បញ្ហាក្នុងការអនុវត្ត | -ការប្រមូលថ្លៃសេវាសមស្របនឹងថវិកាថែទាំ<br>-ការចូលរួមក្នុងការបង់ថ្លៃសេវារបស់ប្រជាពលរដ្ឋ | |
| សូចនាករ (KPI) | -តារាងគណនាចំណូលចំណាយ និងតារាងតុល្យការ<br>-អត្រាប្រមូលថ្លៃសេវា | |
| សកម្មភាពរយៈពេលខ្លី (គម្រោងអាទិភាពសម្រាប់គោលដៅប្រចាំឆ្នាំ ២០២៥) | | |
| អង្គភាពអនុវត្ត | ចម្បង | រដ្ឋបាលខេត្ត ក្រុមហ៊ុនគោលបំណងពិសេស (បង្កើតឡើងដោយសាជីវកម្មសាធារណៈ អាជីវកម្មឯកជន ។ល។) |
| | បន្ទាប់បន្សំ | - |
| | អង្គភាពពាក់ព័ន្ធ | ក្រសួងសាធារណការ និងដឹកជញ្ជូន មន្ទីរប្រៃសណីយ៍ និងទូរគមនាគមន៍ |
| សកម្មភាពចម្បង [ការបែងចែកតួនាទី] | ១. ការបង្កើតអនុគណៈកម្មាធិការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន<br>២. ការប្រមូលទិន្នន័យ និងវាយតម្លៃពីស្ថានភាពបច្ចុប្បន្ន និងការពិចារណាទៅលើប្រព័ន្ធថ្មី [រដ្ឋបាលក្រុង រដ្ឋបាលខេត្ត រដ្ឋាករទឹកស្អាត ក្រុមហ៊ុនប្រមូលសំរាម និងក្រសួងសាធារណការ និងដឹកជញ្ជូន]<br>៣. ការបង្កើតក្រុមហ៊ុនគោលបំណងពិសេស (SPC) [រដ្ឋាករទឹកស្អាត និងក្រុមហ៊ុនប្រមូលសំរាម]<br>៤. ការអភិវឌ្ឍប្រព័ន្ធការប្រមូល និងត្រួតពិនិត្យ [SPC និងរដ្ឋបាលក្រុង]<br>៥. ការប្រមូលថ្លៃសេវាសាធារណៈ ការត្រួតពិនិត្យស្ថានភាព [SPC និងរដ្ឋបាលក្រុង]<br>៦. ការផ្ទុកទិន្នន័យ និងការផ្សព្វផ្សាយនៅលើថ្នាលទិន្នន័យ [SPC និងរដ្ឋបាលក្រុង] | |
| ប្រភពមូលនិធិ / គំរូអាជីវកម្ម | ការកសាង និងដំណើរការប្រព័ន្ធគិតថ្លៃដែលរួមបញ្ចូលទាំងទឹកស្អាត និងប្រព័ន្ធលូទឹកកខ្វក់ និងកាកសំណល់ ។ល។ ចាប់ផ្តើមជាមួយនឹងការវិនិយោគដំបូង (ការអភិវឌ្ឍកម្មវិធី) មូលនិធិប្រតិបត្តិការនឹងត្រូវបានចេញដោយក្រុមហ៊ុនឯកជន ឬ SPC ដែលបង្កើតឡើងដោយរដ្ឋបាលខេត្ត និងអាជ្ញាធរសាធារណៈ និងក្រុមហ៊ុនឯកជន។ នៅពេលអនាគត យើងក៏នឹងសម្លឹងមើលការពង្រីកទៅដល់ការរួមបញ្ចូលការចំណាយលើថាមពលអគ្គិសនី និងការដឹកជញ្ជូនសាធារណៈទៅជាកញ្ចប់ចំណាយរួមគ្នាផងដែរ។ | |
| | ថ្លៃដើមចាប់ផ្តើមដំបូង | ក្រុមហ៊ុនគោលបំណងពិសេស(SPC) |
| | ចំណាយលើប្រតិបត្តិការ និងថែទាំ | ក្រុមហ៊ុនគោលបំណងពិសេស(SPC និង រដ្ឋបាលក្រុង) |




ប្រភព៖ ក្រុមសិក្សា JICA

រូបភាព ៨.១១៖ ប្រព័ន្ធបង់ថ្លៃប្រើប្រាស់រួម

# ឧបសម្ព័ន្ធ ១៖ វិធីសាស្ត្រក្នុងការធ្វើបច្ចុប្បន្នភាពផែនទីបង្ហាញផ្លូវ

- **សាវតា**

ផែនទីបង្ហាញផ្លូវទីក្រុងឆ្លាតវៃ នៃសៀមរាប ត្រូវបានធ្វើសេចក្តីព្រាងដោយផ្អែកលើលទ្ធផលនៃ"ការស្ទង់មតិប្រមូលទិន្នន័យលើការកែលម្អទីក្រុងក្នុងក្រុងសៀមរាបនៃព្រះរាជាណាចក្រកម្ពុជា(២០២០-២០២១)ដែលគាំទ្រដោយទីភ្នាក់ងារ JICA"។ គ្រោងការនេះត្រូវបានអនុម័តដោយឯកឧត្តមអភិបាលខេត្ត នៅក្នុងគណៈកម្មាធិការសម្របសម្រួលរួមនៃការស្ទង់មតិក្នុងខែធ្នូ ឆ្នាំ២០២១។ នៅខែឧសភា ឆ្នាំ២០២២ គម្រោងទីក្រុងឆ្លាតវៃ4ត្រូវបានចាប់ផ្តើម ហើយក្រុមការងាររបស់គម្រោងត្រូវបានបង្កើតឡើងដោយមានការចូលរួមពីមន្ត្រីរដ្ឋបាលខេត្ត និងទីភ្នាក់ងារ JICA។ ផែនការសម្មភាពដើម្បីបញ្ចប់ផែនទីបង្ហាញផ្លូវមួយ ត្រូវបានស្នើឡើងដោយក្រុមការងារគម្រោងទីក្រុងឆ្លាតវៃ និងត្រូវបានអនុម័តដោយឯកឧត្តមអភិបាលខេត្ត។

- **គោលបំណង**

គោលបំណងនៃការធ្វើបច្ចុប្បន្នភាព គឺដើម្បីកែលម្អផែនទីបង្ហាញផ្លូវទៅជាទម្រង់មួយដែលកាន់តែងាយស្រួលក្នុងការប្រើប្រាស់សម្រាប់ខេត្តសៀមរាប។ តម្រូវការឱ្យមានការធ្វើបច្ចុប្បន្នភាពនេះគឺដោយសារតែកត្តាជាច្រើនតួយ៉ាងដូចជាការផ្លាស់ប្តូរយ៉ាងខ្លាំងនៃស្ថានភាពសង្គមសេដ្ឋកិច្ចដែលបណ្តាលមកពីជំងឺរាតត្បាតកូវីដ១៩។ មានព្រឹត្តិការណ៍សំខាន់ៗជាច្រើនក្នុងឆ្នាំ២០២១ រួមទាំងគម្រោងកែលម្អផ្លូវចំនួន ៣៨ខ្សែ និងការកើនឡើងនៃការប្រើប្រាស់កូដ QR ក្នុងការសម្រេចចិត្ត។ លើសពីនោះទៅទៀតមានផែនការសំខាន់ៗជាច្រើនត្រូវបានបង្កើតឡើងហើយផែនការទាំងនោះពុំទាន់ចេញជារូបរាងនៅឡើយ នាពេលដែលកំពុងតែរៀបចំធ្វើផែនទីបង្ហាញផ្លូវនេះនៅពេលដំបូង។ ហេតុដូចនេះទើបតម្រូវឱ្យបញ្ចូលនូវកត្តាទាំងនេះ ទៅក្នុងផែនទីបង្ហាញផ្លូវ។

- **ថេរវេលា**

ចាប់ពី ខែឧសភា ឆ្នាំ២០២២ ដល់ ខែកុម្ភៈ ឆ្នាំ២០២៣

- **វិធីសាស្ត្រ**

ដំណើរការក្នុងការធ្វើបច្ចុប្បន្នភាពត្រូវបានអនុវត្តដូចខាងក្រោម៖

4 គម្រោងទីក្រុងឆ្លាតវៃ៖ គម្រោងនេះមានគោលបំណងដោះស្រាយបញ្ហានីមួយៗដោយប្រើបច្ចេកវិទ្យាឆ្លាតវៃនៅក្នុងតំបន់ទីប្រជុំជនក្រុងហើយក្នុងពេលជាមួយគ្នានេះក៏បង្កើតប្រព័ន្ធមួយសម្រាប់ផ្នែករដ្ឋបាល ព្រមទាំងបង្កើតទំនាក់ទំនងជាមួយក្រុមហ៊ុនឯកជនដើម្បីប្រមូលយកបទពិសោធន៍ និងសម្រេចឲ្យបាននូវទីក្រុងឆ្លាតវៃ។

- ការកំណត់អត្តសញ្ញាណតម្រូវការនៃការធ្វើបច្ចុប្បន្នភាព៖ តម្រូវការធ្វើបច្ចុប្បន្នភាពផែនទីបង្ហាញផ្លូវទីក្រុងឆ្លាតវៃខេត្តសៀមរាបត្រូវបានពិនិត្យដោយក្រុមការងារគម្រោង និងបានស្នើឡើងក្នុងកិច្ចប្រជុំJCC លើកដំបូង។
- កិច្ចប្រជុំរវាងភាគីពាក់ព័ន្ធ៖ការពិភាក្សាលើខ្លឹមសារនៃផែនទីបង្ហាញផ្លូវ ត្រូវបានធ្វើឡើងរវាងក្រុមការងារគម្រោង ក្រសួងពាក់ព័ន្ធ និងភាគីពាក់ព័ន្ធ។
- ពិនិត្យ និងកែសម្រួលឯកសារដែលបានធ្វើបច្ចុប្បន្នភាព៖ឯកសារព្រាងត្រូវបានពិនិត្យ និងកែសម្រួលដោយ ក្រុមការងារបច្ចេកទេស (TWG) គណៈកម្មាធិការសម្របសម្រួលរួម (JCC) និងគណៈកម្មាធិការទីក្រុងឆ្លាតវៃខេត្តសៀមរាប។
- ការអនុម័ត និងសម្រេច៖ ឯកសារនេះត្រូវបានអនុម័តដោយគណៈកម្មាធិការទីក្រុងឆ្លាតវៃ និងគណៈកម្មាធិការសម្របសម្រួលរួមនៃគម្រោងទីក្រុងឆ្លាតវៃ។

- **កិច្ចពិភាក្សា**

ការពិភាក្សាត្រូវបានធ្វើឡើងនៅក្នុងការពិគ្រោះយោបល់ជាលក្ខណៈបុគ្គលមួយចំនួន កិច្ចប្រជុំក្រុមការងារបច្ចេកទេសគម្រោងទីក្រុងឆ្លាតវៃ (TWG) ប្រចាំខែ និងកិច្ចប្រជុំគណៈកម្មាធិការសម្របសម្រួលរួមជាទៀងទាត់។ កិច្ចប្រជុំសំខាន់ៗត្រូវបានធ្វើឡើងដូចខាងក្រោម៖

- កិច្ចប្រជុំ JCC លើកទី១ នៅថ្ងៃទី ២៤ ខែឧសភា ឆ្នាំ២០២២៖ ការចាប់ផ្តើមសម្រាប់គម្រោងទីក្រុងឆ្លាតវៃខេត្តសៀមរាប
- កិច្ចប្រជុំ TWG លើកទី១ នៅថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០២២៖ ការធ្វើផែនការនៃផែនទីបង្ហាញផ្លូវ
- កិច្ចប្រជុំ TWG លើកទី២ នៅថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០២២៖ ការធ្វើផែនការនៃគម្រោងសាកល្បង
- កិច្ចប្រជុំ TWG លើកទី៣ នៅថ្ងៃទី២៣ ខែសីហា ឆ្នាំ២០២២៖ ការធ្វើបច្ចុប្បន្នភាពផែនទីបង្ហាញផ្លូវ និងវឌ្ឍនភាពនៃគម្រោងសាកល្បង
- សិក្ខាសាលា នៅថ្ងៃទី១២ ខែតុលា ឆ្នាំ២០២២៖ ការផ្លាស់ប្តូរមតិយោបល់អំពីផែនទីបង្ហាញផ្លូវ
- កិច្ចប្រជុំ TWG លើកទី៤ នៅថ្ងៃទី២១ ខែតុលា ឆ្នាំ២០២២៖ ការធ្វើបច្ចុប្បន្នភាពផែនទីបង្ហាញផ្លូវ និងការអនុម័តលើគម្រោងសាកល្បង
- កិច្ចប្រជុំ JCC លើកទី២ និងកិច្ចប្រជុំគណៈកម្មាធិការទីក្រុងឆ្លាតវៃ នៃខេត្តសៀមរាប នៅថ្ងៃទី៣១ ខែតុលា ឆ្នាំ២០២២៖ របាយការណ៍អំពីវឌ្ឍនភាពនៃគម្រោងសាកល្បង

- បញ្ជីឈ្មោះសមាជិកដែលចូលរួមក្នុងការធ្វើបច្ចុប្បន្នភាពផែនទីបង្ហាញផ្លូវ

| សមាជិកនៃគណៈកម្មាធិការសម្របសម្រួលរួម (JCC) |
|---|
| ឯកឧត្តម ទៀ សីហា អភិបាល នៃគណៈអភិបាលខេត្តសៀមរាប |
| លោក លី សំរិទ្ធ អភិបាលរង នៃគណៈអភិបាលខេត្តសៀមរាប |
| លោក យុន លីនណេ អភិបាលរង នៃគណៈអភិបាលខេត្តសៀមរាប |
| លោក សុខ ថុល អភិបាលរង នៃគណៈអភិបាលខេត្តសៀមរាប |
| លោក លី វណ្ណៈ នាយករដ្ឋបាល សាលាខេត្តសៀមរាប |
| លោក អភិបាល នៃគណៈអភិបាលក្រុងសៀមរាប |
| លោក ប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តសៀមរាប |
| លោក ប្រធានមន្ទីរសាធារណការ និងដឹកជញ្ជូនខេត្តសៀមរាប |
| លោក ប្រធានមន្ទីរផែនការខេត្តសៀមរាប |
| លោក ប្រធានមន្ទីរទេសចរណ៍ខេត្តសៀមរាប |
| លោក ប្រធានមន្ទីរបរិស្ថានខេត្តសៀមរាប |
| លោក ប្រធានមន្ទីរប្រៃសណីយ៍ និងទូរគមនាគមន៍ខេត្តសៀមរាប |
| លោក ប្រធានមន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្តសៀមរាប |
| លោក នាយករងរដ្ឋបាល សាលាខេត្តសៀមរាប |
| លោក អនុប្រធាននាយកដ្ឋានទ្រទ្រង់បច្ចេកទេស និងគម្រោងអន្តរវិស័យ នៃអាជ្ញាធរជាតិអប្សរា |
| លោកស្រី អភិបាលរងក្រុងសៀមរាប |
| លោក ស្នងការរងទទួលផែនសន្តិសុខ នៃស្នងការដ្ឋាននគរបាលខេត្តសៀមរាប |
| លោក មេបញ្ជាការរងកងរាជអាវុធហត្ថខេត្តសៀមាប |
| លោក នាយកទីចាត់ការគ្រប់គ្រងធនធានមនុស្ស សាលាខេត្តសៀមរាប |
| លោក នាយកទីចាត់ការហិរញ្ញវត្ថុ សាលាខេត្តសៀមរាប |
| លោក ទិព្វ ពិសិទ្ធ នាយកទីចាត់ការផែនការ និងវិនិយោគ សាលាខេត្តសៀមរាប |
| លោកនាយក ទីចាត់ការអន្តរវិស័យ សាលាខេត្តសៀមរាប |
| លោក នាយកទីចាត់ការទំនាក់ទំនងសាធារណៈ និងកិច្ចសហប្រតិបត្តិការអន្តរជាតិ សាលាខេត្តសៀមរាប |
| លោក ប្រធានការិយាល័យវិនិយោគ សាលាខេត្តសៀមរាប |
| លោក ប្រធាននាយកដ្ឋាន ផ្នែកគាំទ្រព័ត៌មានវិទ្យា នៃគ្រឹះស្ថានអង្គរ |
| **សមាជិកផ្សេងៗទៀតនៅក្នុងរដ្ឋបាលខេត្តសៀមរាប** |
| លោក ប្រធានការិយាល័យផែនការ |
| លោក ប្រធានការិយាល័យសេដ្ឋកិច្ច និងសង្គមកិច្ច |
| លោក ប្រធានការិយាល័យសរុប និងព័ត៌មាន |
| លោក អនុប្រធានការិយាល័យ ទំនាក់ទំនងអន្តរជាតិ |
| លោក អនុប្រធានការិយាល័យវិនិយោគ |

| |
|---|
| មន្ត្រីនៃការិយាល័យហិរញ្ញវត្ថុ |
| មន្ត្រីកិច្ចសន្យានៃការិយាល័យវិនិយោគ |
| **JICA និងក្រុមអ្នកជំនាញរបស់ JICA** |
| អគ្គនាយករង ក្រុមអភិវឌ្ឍទីក្រុង និងតំបន់ នៃនាយកដ្ឋាន គ្រប់គ្រងហេដ្ឋារចនាសម្ព័ន្ធ របស់ស្នាក់ការកណ្តាល JICA |
| ប្រធាន ក្រុមអភិវឌ្ឍទីក្រុង និងតំបន់ នៃនាយកដ្ឋាន គ្រប់គ្រងហេដ្ឋារចនាសម្ព័ន្ធ របស់ស្នាក់ការកណ្តាល JICA |
| មន្ត្រីទទួលបន្ទុកកិច្ចការនៃគម្រោង ស្នាក់ការកណ្តាល |
| ជំនួយការ អ្នកជំនាញទទួលបន្ទុកកិច្ចការនៃគម្រោង ស្នាក់ការកណ្តាល JICA |
| អ្នកតំណាង JICA ការិយាល័យប្រចាំប្រទេសកម្ពុជា |
| ទីប្រឹក្សាផ្នែករៀបចំគម្រោង នៃការិយាល័យ JICAប្រចាំប្រទេសកម្ពុជា |
| មន្ត្រីកម្មវិធីគម្រោង នៃការិយាល័យ JICAប្រចាំប្រទេសកម្ពុជា |
| អ្នកជំនាញ JICA៖ ប្រធានទីប្រឹក្សា អ្នកគ្រប់គ្រងគម្រោង |
| អ្នកជំនាញ JICA៖ អ្នកជំនាញផ្នែកទីក្រុងឆ្លាតវៃ អ្នកសម្របសម្រួលគម្រោង |
| ប្រធានក្រុមទីប្រឹក្សា JICA៖ អ្នកជំនាញផ្នែក បច្ចេកវិទ្យាឆ្លាតវៃ និងភាពជាដៃគូរវាងរដ្ឋ និងឯកជន |
| អនុប្រធានក្រុមទីប្រឹក្សា JICA៖ អ្នកជំនាញផ្នែកហិរញ្ញវត្ថុ និងរៀបចំផែនការ |
| សមាជិកក្រុមទីប្រឹក្សា JICA៖ អ្នកជំនាញផ្នែករៀបចំ និងអនុវត្តគម្រោងសាកល្បង និងផ្សព្វផ្សាយ (Branding) |
| សមាជិកក្រុមទីប្រឹក្សា JICA៖ អ្នកជំនាញផ្នែកគ្រប់គ្រងទិន្នន័យ |
| សមាជិកក្រុមទីប្រឹក្សា JICA៖ អ្នកជំនាញផ្នែកគ្រប់គ្រងកាកសំណល់ |
| លោក ថាច់ សុខសុវិជ្ជា អ្នកសម្របសម្រួល និងបកប្រែ |
| លោក កាំង ឈីវលី អ្នកសម្របសម្រួល និងបកប្រែ |
| លោក តក់ តី អ្នកសម្របសម្រួល |

# ឧបសម្ព័ន្ធ ២៖ ផែនការថវិកា

ផែនការថវិកាត្រូវបានបង្ហាញខាងក្រោម។ នេះគឺជាការប៉ាន់ប្រមាណត្រួសៗនៃថ្លៃចំណាយដំបូង និងការចំណាយប្រចាំឆ្នាំដែលត្រូវការសម្រាប់ការអនុវត្តវិធានការអនុវត្តនីមួយៗ និងគម្រោងអាទិភាព ហើយនេះសម្រាប់តែជាឯកសារយោងប៉ុណ្ណោះ។ ជាមួយនឹងករណីលើកលែងមួយចំនួន វិធានការថវិកាបច្ចុប្បន្នមិនត្រូវបានអនុវត្តទេ ហើយនឹងត្រូវពិនិត្យឡើងវិញតាមភាពសមស្រប។

| ល.រ | គម្រោងអាទិភាព | ថ្លៃចំណាយដំបូង (ជាដុល្លារអាមេរិក) | ផែនការថវិកាសម្រាប់ប្រតិបត្តិការ (ជាដុល្លារក្នុង១ឆ្នាំ) | អង្គភាពទទួលបន្ទុកក្នុងការប្រតិបត្តិការ |
|---|---|---|---|---|
| D-០១ | ការប្រមូល និងវិភាគទិន្នន័យរួមបញ្ចូលគ្នា | ១,០០០,០០០ (មជ្ឈមណ្ឌលទិន្នន័យ) ៣០០,០០០ (ការអភិវឌ្ឍផ្នែកទន់ (software)), ៤០០,០០០ (ការរៀបចំបរិស្ថាន) ៥០,០០០ (ការបញ្ចូលទិន្នន័យ) | ២៥០,០០០ (ការថែទាំ) | រដ្ឋបាលខេត្តសៀមរាប |
| D-០២ | ការបង្ហាញទិន្នន័យដល់ភាគីពាក់ព័ន្ធ | ត្រូវបានបញ្ចូលនៅក្នុងគម្រោងD-០១ | ត្រូវបានបញ្ចូលនៅក្នុងគម្រោង D-០១ | រដ្ឋបាលខេត្តសៀមរាប |
| T-០១ | ការអភិវឌ្ឍទម្រង់ផ្សព្វផ្សាយទេសចរណ៍ | អាស្រ័យទៅតាមអាជីវកម្ម | អាស្រ័យទៅតាមអាជីវកម្ម | វិស័យឯកជន |
| T-០២ | ការផ្តោតទៅលើប្រព័ន្ធនៃការកក់ និងការទូទាត់ | អាស្រ័យទៅតាមអាជីវកម្ម | អាស្រ័យទៅតាមអាជីវកម្ម | វិស័យឯកជន |
| T-០៣ | ការអភិវឌ្ឍការចែករំលែកនូវសេវាចល័តរួម | អាស្រ័យទៅតាមអាជីវកម្ម | អាស្រ័យទៅតាមអាជីវកម្ម | វិស័យឯកជន |
| T-០៤ | សេវាកម្មធ្វើដំណើរទេសចរណ៍ Maas | អាស្រ័យទៅតាមអាជីវកម្ម | អាស្រ័យទៅតាមអាជីវកម្ម | វិស័យឯកជន |
| T-០៥ | ការដាក់ឱ្យប្រើប្រាស់ប្រព័ន្ធទូទាត់អេឡិចត្រូនិកក្នុងស្រុកដោយប្រើលេខកូដ QR | អាស្រ័យទៅតាមអាជីវកម្ម | អាស្រ័យទៅតាមអាជីវកម្ម | វិស័យឯកជន |
| T-០៦ | លើកកម្ពស់បទពិសោធន៍ទេសចរណ៍ក្នុងស្រុកដោយប្រើប្រាស់បច្ចេកវិទ្យា AR | អាស្រ័យទៅតាមអាជីវកម្ម | អាស្រ័យទៅតាមអាជីវកម្ម | វិស័យឯកជន |
| M-០១ | ការណែនាំប្រព័ន្ធចំណតយានយន្តជាផ្លូវការ | ១,០០០,០០០ | រ៉ាប់រងដោយថវិកានៃដែលទទួលបានពីការប្រើប្រាស់ចំណត (អាចមានការផ្លាស់ប្តូរអាស្រ័យទៅលើថ្លៃឈ្នួលនៃការចតយានយន្ត) | មន្ទីរសាធារណការ និងដឹកជញ្ជូនខេត្ត/ វិស័យឯកជន |
| M-០២ | ការត្រួតពិនិត្យស្ថានភាពផ្ទៃផ្លូវ | ២០០,០០០ | ប្រើប្រាស់ការចំណាយទូទៅលើការថែទាំ | មន្ទីរសាធារណការ និងដឹកជញ្ជូនខេត្ត |
| M-០៣ | ការកែលម្អភ្លើងបំភ្លឺផ្លូវ | (រ៉ាប់រងដោយគម្រោងសាងសង់ផ្លូវ៣៨ខ្សែ) | | មន្ទីរសាធារណការ និងដឹកជញ្ជូនខេត្ត |
| M-០៤ | ការកែលម្អប្រព័ន្ធសញ្ញាចរាចរណ៍ | ១៥,០០០,០០០ | ២,៥០០៖ ថ្លៃថែទាំប្រព័ន្ធគ្រប់គ្រងចរាចរណ៍នៅរាជធានី | មន្ទីរសាធារណការ និងដឹកជញ្ជូនខេត្ត |

| ល.រ | គម្រោងអាទិភាព | ថ្លៃចំណាយដំបូង (ជាដុល្លារអាមេរិក) | ផែនការថវិកាសម្រាប់ប្រតិបត្តិការ (ជាដុល្លារក្នុង១ឆ្នាំ) | អង្គភាពទទួលបន្ទុកក្នុងការប្រតិបត្តិការ |
|---|---|---|---|---|
| | | | ភ្នំពេញ មានតម្លៃប្រមាណ ១១៩,០០០ ដុល្លារ/ឆ្នាំ ដែលតម្លៃនេះសំរាប់ ១០០ទីតាំង | |
| M-០៥ | ការកែលម្អការគ្រប់គ្រងសុវត្ថិភាពចរាចរណ៍ | ៥០០,០០០ | ១០,០០០ | មន្ទីរសាធារណការ និងដឹកជញ្ជូនខេត្ត |
| M-០៦ | ការណែនាំអំពីយានយន្តអគ្គិសនី | | កំពុងស្ថិតនៅក្នុងការស្ទង់មតិ | មន្ទីរសាធារណការ និងដឹកជញ្ជូនខេត្ត |
| S-០១ | ការណែនាំប្រព័ន្ធ CCTV | ផ្នែករឹង(Hardware)៖ រ៉ាប់រងដោយគម្រោងសាងសង់ផ្លូវ៣៨ខ្សែ) | ៣៦,០០០(បណ្តាញ CCTV) | រដ្ឋបាលខេត្ត សៀមរាប |
| S-០២ | ការអភិវឌ្ឍប្រព័ន្ធប្រកាសអាសន្នទឹកជំនន់ | ១០០,០០០ | ១៥,០០០ | រដ្ឋបាលខេត្ត សៀមរាប |
| S-០៣ | ការដំឡើងប្រព័ន្ធប្រកាសអាសន្នអគ្គិភ័យ | ៣០០,០០០ | ៤,០០០ | ស្នងការដ្ឋាននគរបាលខេត្ត សៀមរាប |
| S-០៤ | ការកែលម្អទំនាក់ទំនងសាធារណៈ ដើម្បីសុវត្ថិភាព | ៣០,០០០ | ត្រូវបានបញ្ចូលនៅក្នុងចំណាយនៃការប្រតិបត្តិការប្រចាំថ្ងៃ | ស្នងការដ្ឋាននគរបាលខេត្ត សៀមរាប |
| W-០១ | ពង្រឹងប្រព័ន្ធគ្រប់គ្រងសំរាមសំណល់រឹងទីប្រជុំជន និងការអប់រំអំពីបរិស្ថាន | ៥០០,០០០ | ត្រូវបានបញ្ចូលនៅក្នុងចំណាយនៃការប្រតិបត្តិការប្រចាំថ្ងៃ | មន្ទីរបរិស្ថានខេត្ត |
| W-០២ | ការដំឡើងប្រព័ន្ធ IoT សម្រាប់គ្រប់គ្រងការប្រមូលសំរាម | (ក្រសួងបរិស្ថានបានដំឡើងប្រព័ន្ធតាមដានការប្រមូលសំរាមរួចហើយ) | | |
| W-០៣ | ការគ្រប់គ្រងទីលានទុកដាក់សំរាមប្រកបដោយអនាម័យ | ២០,០០០,០០០ | កំពុងធ្វើការស្ទង់មតិ | ក្រសួងបរិស្ថាន មន្ទីរបរិស្ថានខេត្ត |
| W-០៤ | ការកែលម្អគុណភាពស្ទឹង និងការប្រើប្រាស់ស្ទឹង | ១,០០០,០០០ | ៣០០,០០០/១ឆ្នាំ | រដ្ឋបាលខេត្ត សៀមរាប |
| W-០៥ | ការកែលម្អប្រព័ន្ធគ្រប់គ្រងឧបករណ៍បរិក្ខាទឹកកខ្វក់ | (តម្លៃសម្រាប់ជាឯកសារយោង៖ ៤៨,០០០,០០០ដុល្លារ (រោងចក្រប្រព្រឹត្តកម្មទឹកដែលមានសមត្ថភាពធ្វើការដូចគ្នាទៅនឹងរោងចក្រដែលមានស្រាប់ ),១៣,០០០,០០០ ដុល្លារ(ប្រព័ន្ធបង្ហូរទឹកកខ្វក់ដែលមានសមត្ថភាពធ្វើការដូចទៅនឹងប្រព័ន្ធលូដែលមានស្រាប់)) | ពុំទាន់ដាក់លាក់ | ក្រសួងសាធារណការ និងដឹកជញ្ជូន រដ្ឋបាលខេត្តសៀមរាប អាជ្ញាធរជាតិអប្សរា |
| W-០៦ | យន្តការបង់ថ្លៃសេវាសាធារណៈរួមគ្នា | ៣០០,០០០ | ១៥០,០០០/១ឆ្នាំ | ក្រុមហ៊ុនគោលបំណងពិសេស |

# ឧបសម្ព័ន្ធ ៣៖ វឌ្ឍនភាពនៃ ផែនការសកម្មភាព

វឌ្ឍនភាពនៃវិធានការអនុវត្ត និងគម្រោងអាទិភាពចាប់ពីឆ្នាំ ២០២១ ដល់ឆ្នាំ ២០២៣ (នៅពេលដែលផែនទីបង្ហាញផ្លូវត្រូវបានបង្កើតឡើង) ត្រូវបានបង្ហាញដូចខាងក្រោម៖

## 1. ការលើកកម្ពស់ និងប្រតិបត្តិការរបស់គណៈកម្មាធិការទីក្រុងឆ្លាតវៃ

គណៈកម្មាធិការទីក្រុងឆ្លាតវៃត្រូវបានពង្រឹងដូចដែលបានគូសបញ្ជាក់នៅក្នុងផែនទីបង្ហាញផ្លូវក្នុងខែមិថុនា ឆ្នាំ២០២២។ គណៈកម្មាធិការទីក្រុងឆ្លាតវៃបច្ចុប្បន្នមានសមាជិកសមាជិកាដូចខាងក្រោម៖

- ប្រធាន:
  - ឯកឧត្តមអភិបាល នៃគណៈអភិបាលខេត្តសៀមរាប
- **សមាជិក សមាជិកា**
  - ឯកឧត្តម អភិបាលរង នៃគណៈអភិបាលខេត្តសៀមរាប
  - លោក នាយករដ្ឋបាល សាលាខេត្តសៀមរាប
  - លោក ប្រធានមន្ទីរសាធារណការ និងដឹកជញ្ជូនខេត្តសៀមរាប
  - លោក ប្រធានមន្ទីរបរិស្ថានខេត្តសៀមរាប
  - លោក ប្រធានមន្ទីរប្រៃសណីយ៍ និងទូរគមនាគមន៍ខេត្តសៀមរាប
  - លោក ប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តសៀមរាប
  - លោក ប្រធានមន្ទីរទេសចរណ៍ខេត្តសៀមរាប
  - លោក ប្រធានមន្ទីរផែនការខេត្តសៀមរាប
  - លោក ប្រធានមន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្តសៀមរាប
  - លោក អនុប្រធាននាយកដ្ឋានទ្រទ្រង់បច្ចេកទេស និងគម្រោងអន្តរវិស័យ នៃអាជ្ញាធរជាតិអប្សរា
  - លោក ប្រធាននាយកដ្ឋាន ផ្នែកគាំទ្រព័ត៌មានវិទ្យា នៃគ្រឹះស្ថានអង្គរ
  - លោក ស្នងការរងទទួលផែនសន្តិសុខ នៃស្នងការដ្ឋាននគរបាលខេត្តសៀមរាប
  - លោក មេបញ្ជាការរងកងរាជអាវុធហត្ថខេត្តសៀមាប
  - លោក អភិបាល នៃគណៈអភិបាលក្រុងសៀមរាប
  - លោកស្រី អភិបាលរងក្រុងសៀមរាប
  - លោក នាយកទីចាត់ការផែនការ និងវិនិយោគ សាលាខេត្តសៀមរាប

- លោក នាយកទីចាត់ការទំនាក់ទំនងសាធារណៈ និងសហប្រតិបត្តិការអន្តរជាតិ សាលាខេត្តសៀមរាប
- លោក នាយកទីចាត់ការគ្រប់គ្រងធនធានមនុស្ស សាលាខេត្តសៀមរាប
- លោក នាយកទីចាត់ការហិរញ្ញវត្ថុ សាលាខេត្តសៀមរាប
- លោក នាយកទីចាត់ការអន្តរវិស័យ សាលាខេត្តសៀមរាប
- លោក ប្រធានការិយាល័យសេដ្ឋកិច្ច និងសង្គមកិច្ច នៃទីចាត់ការអន្តរវិស័យ
- លោក ប្រធានការិយាល័យផែនការ នៃទីចាត់ការផែនការ និងវិនិយោគ
- លោក ប្រធានការិយាល័យព័ត៌មាន និងស្ថិតិ នៃទីចាត់ការរដ្ឋបាល
- លោក ប្រធានការិយាល័យវិនិយោគ នៃទីចាត់ការផែនការ និងវិនិយោគ
- លោក អនុប្រធានការិយាល័យវិនិយោគ នៃទីចាត់ការផែនការ និងវិនិយោគ
- លោក អនុប្រធានការិយាល័យទំនាក់ទំនងសាធារណៈ និងសហប្រតិបត្តិការអន្តរជាតិ
- មន្ត្រី នៃទីចាត់ការហិរញ្ញវត្ថុ

គណៈកម្មាធិការទីក្រុងឆ្លាតវៃ ត្រូវបានគេរំពឹងថា នឹងបន្តដំណើរការដូចខាងក្រោម៖

- បង្កើតក្រុមការងារសម្រាប់ការងារជាក់លាក់ ៖ ការបង្កើតក្រុមការងារគួរត្រូវពិចារណាក្នុងការអនុវត្តគម្រោងសាកល្បងជាដើម។
- វិធានការថវិកា៖ ដើម្បីធ្វើឱ្យគណៈកម្មាធិការទីក្រុងឆ្លាតវៃមានកិច្ចប្រជុំទៀងទាត់ វិធានការថវិកាគួរតែត្រូវបានយកមកពិចារណា។

## 2. ការបង្កើតថ្មីនូវទីចាត់ការទីក្រុងឆ្លាតវៃ

រដ្ឋបាលខេត្តសៀមរាបកំពុងដំណើរការសម្របសម្រួលជាមួយថ្នាក់ក្រសួង។ គោលដៅគឺដើម្បីបង្កើតទីចាត់ការថ្មី និងពិចារណាលើការបែងចែកថវិកាដើម្បីធ្វើឱ្យក្រុងសៀមរាបឆ្លាតវៃមាននិរន្តរភាព។

## 3. វេទិកាវិស័យឯកជន-វិស័យសាធារណៈ-ស្ថាប័នសិក្សាធិការ-សហគមន៍ (វេទិកាទីក្រុងឆ្លាតវៃ)

ដើម្បីសម្រេចបាននូវវេទិកាទីក្រុងឆ្លាតវៃ កិច្ចប្រជុំខាងក្រោមត្រូវបានរៀបចំឡើងដែលពាក់ព័ន្ធនឹងកិច្ចការនេះ។

- ថ្ងៃទី ១២ ខែតុលា ឆ្នាំ២០២២៖ សិក្ខាសាលាស្តីអំពីផែនទីបង្ហាញផ្លូវទីក្រុងឆ្លាតវៃ នៃខេត្តសៀមរាប (អ្នកចូលរួម៖ តំណាងប្រជាពលរដ្ឋ អ្នកជំនួញ សាកលវិទ្យាល័យ និងដៃគូអភិវឌ្ឍន៍)

- ថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០២២៖ សិក្ខាសាលានៃវិស័យសិក្សា-រដ្ឋបាលខេត្ត៖ អ្នកចូលរួម៖ សាកលវិទ្យាល័យចំនួន ៣

## 4. ប្រព័ន្ធត្រួតពិនិត្យ និងវាយតម្លៃ

ប្រព័ន្ធត្រួតពិនិត្យ និងវាយតម្លៃសម្រាប់ទីក្រុងឆ្លាតវៃនឹងត្រូវបានសង្ខេបនៅក្នុងរបាយការណ៍ដាច់ដោយឡែកមួយ ដែលបច្ចុប្បន្នកំពុងត្រូវបានសិក្សាដោយក្រុមការងារគម្រោងដែលមានគោលបំណងចេញផ្សាយនៅឆ្នាំ ២០២៤។

## 5. វិធានការទំនាក់ទំនងសាធារណៈ និងការផ្សព្វផ្សាយ

សកម្មភាពទំនាក់ទំនងសាធារណៈត្រូវបានអនុវត្តដូចខាងក្រោម៖

- ប្រើប្រាស់បណ្តាញសង្គម៖ យើងកំពុងប្រើប្រាស់ហ្វេសប៊ុកជាការសាកល្បង
- ប្រារព្ធនូវសិក្ខាសាលាអំពីផែនទីបង្ហាញផ្លូវ៖ សិក្ខាសាលាប្រព្រឹត្តទៅនៅថ្ងៃទី១២ ខែតុលា ឆ្នាំ២០២២
- ការចូលរួមនៅក្នុងសន្និសីទអន្តរជាតិ៖ ស្តង់មួយត្រូវបានដាក់តាំងបង្ហាញនៅក្នុងកិច្ចប្រជុំជាន់ខ្ពស់ទីក្រុងឆ្លាតវៃជប៉ុន-អាស៊ាន






- កិច្ចសហប្រតិបត្តិការជាមួយទីក្រុងផ្សេងៗទៀត៖ ការពិភាក្សាកំពុងដំណើរការនៅកម្រិតបុគ្គលិកជាមួយនឹងទីក្រុងនៃប្រទេសជប៉ុនដែលអនុវត្តទីក្រុងឆ្លាតវៃ។

## 6. ការអភិវឌ្ឍនូវថ្នាលទិន្នន័យ និងការផ្សព្វផ្សាយទិន្នន័យបើកចំហ

រចនាសម្ព័ន្ធសម្រាប់ថ្នាលទិន្នន័យកំពុងត្រូវបានពិចារណានៅក្នុងគម្រោងទីក្រុងឆ្លាតវៃ។ ជាការចាំបាច់ត្រូវមានការសហការជាមួយអ្នកឯកទេសមកពីវិស័យផ្សេងៗ រួមទាំងការពិចារណាលើការបង្កើតវេទិកាទីក្រុងឆ្លាតវៃផងដែរ។

## 7. ការកែលម្អបរិយាកាសអាជីវកម្ម

ច្បាប់វិនិយោគត្រូវបានកែសម្រួល។ នេះនឹងត្រូវបានអនុវត្តដោយភ្ជាប់ជាមួយនឹងសកម្មភាពរបស់ទីចាត់ការទីក្រុងឆ្លាតវៃដែលបានរៀបរាប់ខាងលើ។ ដូចគ្នានេះដែរ ចាំបាច់ត្រូវបង្កើតប្រព័ន្ធមួយដើម្បី

បញ្ចូលគំនិតផ្តួចផ្តើមរបស់រាជរដ្ឋាភិបាលទៅក្នុងខេត្តសៀមរាប ស្របពេលនឹងការអនុម័តគំនិតផ្តួចផ្តើមរបស់រាជរដ្ឋាភិបាល។

## 8. ការកែលម្អមុខងារគាំទ្រ

នៅខែកុម្ភៈ ឆ្នាំ២០២១ ការប្រកួតប្រជែងអាជីវកម្មទីក្រុងឆ្លាតវៃត្រូវបានប្រកាស និងរៀបចំដោយរដ្ឋបាលខេត្ត និង JICA។ ចាប់ពីខែឧសភា ឆ្នាំ២០២២ មក គម្រោងទីក្រុងឆ្លាតវៃបច្ចុប្បន្នកំពុងដំណើរការដើម្បីផ្តល់ការអភិវឌ្ឍសមត្ថភាពដល់វិស័យសាធារណៈ រួមទាំងការបណ្តុះបណ្តាលលើការងារផ្ទាល់ផងដែរ។

## 9. ការគ្រប់គ្រងតំបន់

គំនិតផ្តួចផ្តើមនៃការគ្រប់គ្រងតំបន់កំពុងត្រូវបានផ្តើមអនុវត្តជាមួយនឹងការគ្រប់គ្រងកាកសំណល់ដែលជាបញ្ហាគន្លឹះរបស់កិច្ចការនេះ។ អនុគណៈកម្មាធិការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន កំពុងស្ថិតក្នុងដំណើរការរៀបចំ។ សង្កាត់អាទិភាពមួយនឹងត្រូវបានអភិវឌ្ឍ ហើយតំបន់ដែលត្រូវអនុវត្តគម្រោងសាកល្បងនឹងត្រូវបានកំណត់។

(គម្រោងអាទិភាព)

10. D-0១ ការប្រមូល និងវិភាគទិន្នន័យរួមបញ្ចូលគ្នា

| សកម្មភាពកំពុងដំណើរការ / បានបញ្ចប់ | ១. ការសម្របសម្រួលនៃអង្គភាពពាក់ព័ន្ធសម្រាប់ការអភិវឌ្ឍថ្នាលទិន្នន័យអន្តរវិស័យ [រដ្ឋបាលខេត្ត ] |
|---|---|
| សកម្មភាពដែលត្រូវបញ្ចប់ | ២. ការរចនា និងការអភិវឌ្ឍថ្នាលទិន្នន័យ (កិច្ចសន្យាសេវាកម្ម Cloud ឬការដំឡើងប្រព័ន្ធថ្មីក្នុងបរិវេណ) [រដ្ឋបាលខេត្ត មន្ទីរប្រៃសណីយ៍ និងទូរគមនាគមន៍ ប្រតិបត្តិករឯកជន]<br>៣. ការបញ្ចូលទិន្នន័យស្ថិតិដែលមានស្រាប់ទៅក្នុងថ្នាលទិន្នន័យ [រដ្ឋបាលខេត្ត ទីចាត់ការទទួលបន្ទុកផ្នែកនីមួយៗ ស្នងការនគរបាលខេត្ត]<br>៤. ការបញ្ចូលទិន្នន័យដែលទទួលបានពីគម្រោងផ្សេងៗទៅក្នុងថ្នាលទិន្នន័យរួមបញ្ចូលគ្នា [រដ្ឋបាលខេត្ត ទីចាត់ការទទួលបន្ទុកផ្នែកនីមួយៗ ស្នងការនគរបាលខេត្ត]<br>៥. ការថែទាំ និងការត្រួតពិនិត្យប្រព័ន្ធទាំងមូល [ប្រតិបត្តិករឯកជន មន្ទីរប្រៃសណីយ៍ និងទូរគមនាគមន៍] |

បច្ចុប្បន្ននេះ គម្រោងទីក្រុងឆ្លាតវៃកំពុងប្រមូលព័ត៌មានអំពីស្ថានភាពទិន្នន័យ និងការកសាងទំនាក់ទំនងជាមួយអ្នកជំនាញក្នុងវិស័យផ្សេងៗ។ ដូចដែលបានបញ្ជាក់នៅក្នុងវិធានការអនុវត្តខាងលើ ទិសដៅនៃការគ្រប់គ្រងទិន្នន័យ នឹងត្រូវបានពិភាក្សាជាមួយភាគីពាក់ព័ន្ធផ្សេងៗ។

11. D-0២ ការបង្ហាញទិន្នន័យដល់ភាគីពាក់ព័ន្ធ

| | |
|---|---|
| សកម្មភាពដែលត្រូវបញ្ចប់ | ១. ការពិនិត្យមើលច្បាប់ និងបទប្បញ្ញត្តិគ្រប់គ្រងទិន្នន័យ [រដ្ឋបាលខេត្ត មន្ទីរប្រៃសណីយ៍ និងទូរគមនាគមន៍]<br>២. ដំណើរការទិន្នន័យសម្រាប់ការពិចារណាឯកជនភាពសម្រាប់ការបង្ហាញទិន្នន័យ [មន្ទីរប្រៃសណីយ៍ និងទូរគមនាគមន៍] |

| | |
|---|---|
| | ៣. ព័ត៌មាននីមួយៗដែលរក្សាទុកក្នុងគម្រោង D-០១ នឹងត្រូវបង្ហាញជាសាធារណៈតាមរយៈ API ដោយគិតគូរពីការការពារព័ត៌មានផ្ទាល់ខ្លួន។ [រដ្ឋបាលខេត្ត មន្ទីរប្រៃសណីយ៍ និងទូរគមនាគមន៍] |

គម្រោងនេះកំពុងស្ថិតក្នុងដំណាក់កាលនៃការសិក្សា ព្រោះវាជាដំណាក់កាលបន្ទាប់ពីគម្រោង D-០១។ ទន្ទឹមនឹងនេះដែរ គម្រោងសាកល្បង និងសកម្មភាពផ្សេងៗទៀតកំពុងត្រូវបានប្រើប្រាស់ដើម្បីរៀបចំជាបទប្បញ្ញត្តិ សម្រាប់ការគ្រប់គ្រងទិន្នន័យ និងដើម្បីបង្កើនសមត្ថភាពសម្រាប់ការបង្ហាញទិន្នន័យផងដែរ។

## 12. T-០១ ការអភិវឌ្ឍវេទិកាផ្សព្វផ្សាយទេសចរណ៍

| | |
|---|---|
| សកម្មភាពដែលកំពុងដំណើរការ/បានបញ្ចប់ | ១. ស្វែងយល់ពីតម្រូវការរបស់អ្នកទស្សនាខេត្តសៀមរាប (ទេសចរណ៍ MICE ។ល។) និងផែនការទាក់ទងនឹងការផ្សព្វផ្សាយ ។ល។ [មន្ទីរទេសចរណ៍]<br>២. ការអភិវឌ្ឍវេទិកាដើម្បីផ្សព្វផ្សាយ [វិស័យឯកជន (អ្នកអភិវឌ្ឍប្រព័ន្ធ)]<br>៣. ការអភិវឌ្ឍមាតិកាផ្សព្វផ្សាយ និងបង្ហោះនៅលើវេទិកា (VR ។ល។) [វិស័យឯកជន (អ្នកផ្តល់សេវាទេសចរណ៍)] |
| សកម្មភាពដែលត្រូវបញ្ចប់ | ៤. ប្រតិបត្តិការនៃវេទិកាផ្សព្វផ្សាយ [វិស័យឯកជន (អ្នកអភិវឌ្ឍប្រព័ន្ធ)]<br>៥. ប្រមូលនិងផ្សព្វផ្សាយទិន្នន័យនៅលើថ្នាលទិន្នន័យ [មន្ទីរប្រៃសណីយ៍និងទូរគមនាគមន៍] |

ចាប់ពីឆ្នាំ២០២២ តទៅ ក្លឹបទេសចរណ៍ខេត្តសៀមរាប (STC) នឹងចូលរួមជាទីប្រឹក្សានៅក្នុងគម្រោងទីក្រុងសៀមរាបឆ្លាតវៃ។ ទោះបីនេះជាគំនិតផ្តួចផ្តើមនៃវិស័យឯកជនក៏ដោយ ការអភិវឌ្ឍនៃវេទិកាទេសចរណ៍ កំពុងស្ថិតក្នុងដំណើរការរៀបចំ។

## 13. T-០២ ប្រព័ន្ធនៃការកក់ និងការទូទាត់រួមគ្នាតែមួយ

| | |
|---|---|
| សកម្មភាពដែលកំពុងដំណើរការ/បានបញ្ចប់ | ១. ការធ្វើផែនការ និងការសិក្សាអំពីការកក់ និងការទូទាត់ថ្លៃសេវានៅមួយកន្លែងសម្រាប់សេវាកម្មទេសចរណ៍ [វិស័យឯកជន] |
| សកម្មភាពដែលត្រូវបញ្ចប់ | ២. ការបង្កើតថ្នាលតែមួយសម្រាប់ការកក់ និងការទូទាត់សេវាកម្មទេសចរណ៍ [វិស័យឯកជន (អ្នកអភិវឌ្ឍប្រព័ន្ធ)]<br>៣. ការទាក់ទាញការចុះបញ្ជីសេវាកម្មទេសចរណ៍ផ្សេងៗ [មន្ទីរទេសចរណ៍]<br>៤. ប្រតិបត្តិការនៃការកក់ និងការទូទាត់ [វិស័យឯកជន (អ្នកអភិវឌ្ឍប្រព័ន្ធ)]<br>៥. ប្រមូលផ្តុំ និងផ្សព្វផ្សាយទិន្នន័យនៅក្នុងថ្នាលទិន្នន័យ [មន្ទីរប្រៃសណីយ៍ និងទូរគមនាគមន៍] |

ដូចគ្នានេះដែរ ការអនុវត្តត្រូវបានរំពឹងថានឹងធ្វើឡើងដោយសហការជាមួយវិស័យឯកជន។ អង្គភាពឯកជនកំពុងធ្វើការអភិវឌ្ឍគម្រោងនេះ។

## 14. T-០៣ ការអភិវឌ្ឍការចែករំលែកនូវសេវាចល័តរួម

| | |
|---|---|
| សកម្មភាពដែលកំពុងដំណើរការ/បានបញ្ចប់ | ១. ការពិនិត្យទម្រង់នៃសេវាចល័ត ដែលអាចធ្វើទៅបាន (ការពិនិត្យពីទិដ្ឋភាពបទប្បញ្ញត្តិ និងតម្រូវការ) [រដ្ឋបាលខេត្ត]<br>២. ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធផ្នែករឹង និងផ្នែកទន់ ដែលនឹងក្លាយជាមូលដ្ឋានសម្រាប់ការដាក់ឱ្យប្រើនូវសេវាចល័តរួមគ្នា [រដ្ឋបាលខេត្ត អាជីវកម្មឯកជន (អាជីវកម្ម)]<br>៣. ប្រតិបត្តិការនៃការបង់ប្រាក់សេវាចល័តរួមគ្នា [អាជីវកម្មឯកជន (អាជីវកម្ម)]<br>៤. ការត្រួតពិនិត្យស្ថានភាពប្រតិបត្តិការ [រដ្ឋបាលខេត្ត]<br>៥ .ការប្រមូលទិន្នន័យ និងការបង្ហាញទិន្នន័យនៅលើថ្នាលទិន្នន័យ [មន្ទីរប្រៃសណីយ៍ និងទូរគមនាគមន៍] |

| | |
|---|---|
| សកម្មភាពដែលត្រូវបញ្ចប់ | ៦. ការត្រួតពិនិត្យប្រតិបត្តិការ [រដ្ឋបាលខេត្ត]<br>៧. ការប្រមូលទិន្នន័យ និងការបង្ហាញនៅក្នុងថ្នាលទិន្នន័យ [មន្ទីរប្រៃសណីយ៍ និងទូរគមនាគមន៍] |

នៅឆ្នាំ២០២១ ក្រុមចែករំលែកមធ្យោបាយធ្វើដំណើរមួយត្រូវបានបង្កើតឡើង និងដំណើរការនៅក្នុងក្រុងសៀមរាបដោយក្រុមហ៊ុនឯកជនមួយ។

ផ្ទុយទៅវិញ បញ្ហាប្រឈមចំពោះកិច្ចការនេះ គឺការទទួលបានទិន្នន័យ និងការត្រួតពិនិត្យដោយរដ្ឋបាលខេត្ត។ តើទិន្នន័យនឹងត្រូវបានទទួលដោយរបៀបណា និងដោយអ្នកណា នឹងក្លាយជាបញ្ហាសម្រាប់ពិចារណាបន្ថែមទៀតនៅពេលខាងមុខ។

15. T-០៤ សេវាកម្មធ្វើដំណើរទេសចរណ៍

| | |
|---|---|
| សកម្មភាពដែលកំពុងដំណើរការ/បានបញ្ចប់ | ១. ការធ្វើផែនការ និងការសិក្សាពីការអភិវឌ្ឍទេសចរណ៍ MaaS [រដ្ឋបាលខេត្ត ]<br>២. ការសម្របសម្រួលជាមួយភាគីពាក់ព័ន្ធ [រដ្ឋបាលខេត្ត ]<br>៣. ការអភិវឌ្ឍប្រព័ន្ធទេសចរណ៍ MaaS [ប្រតិបត្តិករអាជីវកម្មឯកជន (អ្នកបង្កើតប្រព័ន្ធ)] |
| សកម្មភាពដែលត្រូវបញ្ចប់ | ៤. ការរៀបចំប្រភេទនៃមធ្យោបាយដឹកជញ្ជូនដែលត្រូវធ្វើការចុះបញ្ជី [វិស័យឯកជន (ប្រតិបត្តិករនៃមធ្យោបាយដឹកជញ្ជូននីមួយៗ)]<br>៥. ការផ្សព្វផ្សាយដល់អ្នកប្រើប្រាស់ [រដ្ឋបាលខេត្ត អាជីវកម្មឯកជន (អ្នកបង្កើតប្រព័ន្ធ)]<br>៦. ប្រតិបត្តិការប្រព័ន្ធ [ប្រតិបត្តិករអាជីវកម្មឯកជន (អ្នកបង្កើតប្រព័ន្ធ)]<br>៧. ការប្រមូលទិន្នន័យ និងការបង្ហាញទិន្នន័យនៅលើថ្នាលទិន្នន័យ [មន្ទីរប្រៃសណីយ៍ និងទូរគមនាគមន៍] |

សេវាកម្មធ្វើដំណើរទេសចរណ៍ ក៏កំពុងត្រូវបានអនុវត្តដោយសហការជាមួយវិស័យឯកជន និងរដ្ឋបាលខេត្ត ហើយបច្ចុប្បន្នកំពុងស្ថិតក្នុងដំណាក់កាលសាកល្បង។ការអនុវត្តអាជីវកម្មប្រកបដោយនិរន្តរភាព និងការទទួលបានទិន្នន័យនឹងត្រូវយកមកពិចារណានាពេលអនាគត។

16. T-០៥ ការដាក់ឱ្យប្រើប្រាស់ប្រព័ន្ធទូទាត់អេឡិចត្រូនិកក្នុងស្រុក ដោយប្រើលេខកូដ QR

| | |
|---|---|
| សកម្មភាពដែលកំពុងដំណើរការ/បានបញ្ចប់ | ១. ការធ្វើផែនការ និងការសិក្សាអំពីប្រព័ន្ធទូទាត់អេឡិចត្រូនិកក្នុងស្រុកដោយប្រើប្រាស់លេខកូដ QR [រដ្ឋបាលខេត្ត]<br>២. ការអភិវឌ្ឍប្រព័ន្ធ [វិស័យឯកជន (អ្នកបង្កើតប្រព័ន្ធ)]<br>៣. ពន្យល់ពីការប្រើប្រាស់ប្រព័ន្ធទៅវិស័យឯកជន [រដ្ឋបាលខេត្ត]<br>៤. ប្រតិបត្តិការប្រព័ន្ធ [វិស័យឯកជន (អ្នកបង្កើតប្រព័ន្ធ)] |

ការរាតត្បាតនៃជំងឺកូវីដ-១៩ បានឈានទៅដល់ការលូតលាស់នៃការទូទាត់ប្រាក់តាមរយៈកូដ KHQRទូទាំងប្រទេសកម្ពុជា។ KHQR គឺជាប្រព័ន្ធលេខកូដឆ្លើយតបរហ័ស (QR) ទូលំទូលាយដែលបង្កើតឡើងសម្រាប់ការទូទាត់ប្រាក់សម្រាប់ការលក់រាយនៅក្នុងប្រទេសកម្ពុជា ដែលទាមទារតែលេខកូដ QR ដើម្បីទទួលយកការទូទាត់ពីកម្មវិធីទូរស័ព្ទណាមួយ។ នៅពេលចាប់ផ្តើមសេវាកម្ម (ឆ្នាំ២០២២) ធនាគារ និងគ្រឹះស្ថានហិរញ្ញវត្ថុចំនួន ៣៧ កំពុងចូលរួមក្នុងសេវាកម្មទូទាត់កូដ KHQR ដែលក្នុងនោះ ធនាគារ និងស្ថាប័នហិរញ្ញវត្ថុចំនួន២៩ បានដំណើរការដោយជោគជ័យនៅក្នុងហាងប្រមាណ ២៣០,០០០ នៅទូទាំងប្រទេស។

បញ្ហាប្រឈម គឺថាការទូទាត់តាមកូដ QR ដែលមានស្រាប់គឺមិនត្រូវគ្នាជាមួយនឹងការទូទាត់របស់ភ្ញៀវទេសចរ (ដែលនៅមានកម្រិតត្រឹមតែចំពោះប្រព័ន្ធធនាគារដៃគូរបស់កម្ពុជា)។ ឧបករណ៍ដែលមានប្រើកូដ QR មួយចំនួនត្រូវបានភ្ជាប់ទៅការទូទាត់តាមកាតឥណទាន ហើយការប្រើប្រាស់បែបនេះត្រូវតែមានភាពទូលំទូលាយជាងនេះ។

17. T-0៦ លើកកម្ពស់បទពិសោធន៍ទេសចរណ៍ក្នុងស្រុកដោយប្រើប្រាស់បច្ចេកវិទ្យា AR

| | |
|---|---|
| សកម្មភាពកំពុងដំណើរការ / បានបញ្ចប់ | ១. ការរៀបចំផែនការមាតិកានិម្មិត (រួមទាំង AR) [មន្ទីរទេសចរណ៍ អាជ្ញាធរជាតិអប្សរា វិស័យឯកជន (ម្ចាស់អាជីវកម្មទេសចរណ៍នីមួយៗ)] |
| សកម្មភាពដែលត្រូវបញ្ចប់ | ២. ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរឹង (ស្លាកសញ្ញាព័ត៌មានលេខកូដ QR ។ល។) សម្រាប់ចូលប្រើប្រាស់មាតិកានិម្មិត (AR) [មន្ទីរទេសចរណ៍ អាជ្ញាធរជាតិអប្សរា វិស័យឯកជន (ម្ចាស់អាជីវកម្មទេសចរណ៍នីមួយៗ)]<br>៣. ការបង្កើតច្បាប់ ការផ្សព្វផ្សាយ និងការកែលម្អរបៀបប្រើប្រាស់មាតិកានិម្មិត [មន្ទីរទេសចរណ៍ អាជ្ញាធរជាតិអប្សរា] |

ដោយមានការគាំទ្រពីក្រសួងដែនដី ហេដ្ឋារចនាសម្ព័ន្ធ ដឹកជញ្ជូន និងទេសចរណ៍របស់ប្រទេសជប៉ុន ARកំពុងត្រូវបានសិក្សា ហើយការស្ទង់មតិកំពុងដំណើរការដើម្បីធ្វើផែនការ និងអភិវឌ្ឍទិដ្ឋភាពនិម្មិតនោះ។ ការស្ទង់មតិនឹងត្រូវបានចងក្រងនៅខែមីនា ឆ្នាំ២០២៣។

18. M-0១ ការណែនាំប្រព័ន្ធចំណតយានយន្តជាផ្លូវការ

| | |
|---|---|
| សកម្មភាពដែលត្រូវបញ្ចប់ | ១. ការបង្កើត និងការអនុវត្តប្រព័ន្ធថ្លៃចតរថយន្តតាមដងផ្លូវ ការបង្កើត និងដំណើរការប្រព័ន្ធថ្លៃសេវា (ការកំណត់តំបន់ពិសេសសម្រាប់ផ្លូវជុំវិញផាប់ស្ទ្រីត ។ល។) [រដ្ឋបាលខេត្ត ]<br>២. ការកំណត់ និងកំណត់ទីតាំងចំណតផ្លូវគិតថ្លៃ [អ្នកគ្រប់គ្រងផ្លូវ (មន្ទីរសាធារណការ និងដឹកជញ្ជូន រដ្ឋបាលក្រុងសៀមរាប)]<br>៣. ប្រភេទកិច្ចសន្យានៃប្រតិបត្តិករចំណតរថយន្តតាមផ្លូវ និងការជ្រើសរើសប្រតិបត្តិករ [រដ្ឋបាលខេត្ត]<br>៤. ការដំឡើងឧបករណ៍ចាប់សញ្ញាចតរថយន្តនៅលើផ្លូវ (តំបន់ពិសេសដែលបានកំណត់) ជុំវិញផាប់ស្ទ្រីត [ប្រតិបត្តិករចំណតរថយន្ត]<br>៥. អាជីវកម្មប្រមូលថ្លៃចំណតតាមដងផ្លូវ និងការផ្តល់ព័ត៌មានអំពីកន្លែងចតរថយន្ត [ប្រតិបត្តិករចំណតរថយន្ត] |

ការសាកល្បងអំពីចំណតរថយន្តឆ្លាតវៃមួយ ត្រូវបានធ្វើឡើងនៅក្នុងក្រុងសៀមរាបក្នុងខែធ្នូ ឆ្នាំ២០២១។ សម្រាប់ការអនុវត្តជាក់ស្តែង តម្រូវឱ្យមានការពិភាក្សាអំពីការកែទម្រង់ និងគ្រោងទុកនូវប្រព័ន្ធបង់ថ្លៃសេវា។

19. M-0២ ការត្រួតពិនិត្យស្ថានភាពផ្ទៃផ្លូវ

| | |
|---|---|
| សកម្មភាពដែលត្រូវបញ្ចប់ | ១. កំណត់គោលដៅរបស់អ្នកប្រើប្រាស់។ កំណត់ថាតើកម្មវិធីនឹងដាក់គោលដៅចំពោះនរណា ហើយនរណានឹងទទួលបានអត្ថប្រយោជន៍ច្រើនបំផុត។ នេះអាចរួមបញ្ចូលអ្នកបើកបរ ក្រុមហ៊ុនដឹកជញ្ជូន ភ្នាក់ងាររាជរដ្ឋាភិបាល ឬភាគីពាក់ព័ន្ធផ្សេងទៀត។[រដ្ឋបាលខេត្ត]<br>២. ផ្សព្វផ្សាយកម្មវិធី។ ប្រើប្រាស់បណ្តាញផ្សេងៗដើម្បីផ្សព្វផ្សាយកម្មវិធី និងបង្កើនការយល់ដឹងក្នុងចំណោមអ្នកប្រើប្រាស់គោលដៅ។ នេះអាចរួមបញ្ចូលប្រព័ន្ធផ្សព្វផ្សាយសង្គម ការផ្សាយពាណិជ្ជកម្មតាមគេហទំព័រ យុទ្ធនាការអ៊ីមែល និងយុទ្ធសាស្ត្រទីផ្សារផ្សេងទៀត។[មន្ទីរសាធារណការ និងដឹកជញ្ជូន] |

| | |
|---|---|
| | ៣. ផ្តល់ការបណ្តុះបណ្តាល និងការគាំទ្រ។ ផ្តល់ការបណ្តុះបណ្តាល និងការគាំទ្រដើម្បីជួយអ្នកប្រើប្រាស់យល់ពីរបៀបប្រើប្រាស់កម្មវិធីប្រកបដោយប្រសិទ្ធភាព។ [រដ្ឋបាលខេត្ត]<br>៤. សម្របសម្រួលមតិកែលម្អ។ លើកទឹកចិត្តអ្នកប្រើប្រាស់ឱ្យផ្តល់មតិកែលម្អលើបញ្ហា និងការកែលម្អជាមួយកម្មវិធី។ [រដ្ឋបាលខេត្ត]<br>៥. តាមដានការប្រើប្រាស់ និងលទ្ធផល។ តាមដានការប្រើប្រាស់កម្មវិធី និងលទ្ធផលដើម្បីវាយតម្លៃប្រសិទ្ធភាពរបស់វា និងកំណត់តំបន់សម្រាប់ការកែលម្អ។[មន្ទីរសាធារណការ និងដឹកជញ្ជូន]<br>៦. សហការជាមួយអង្គភាពពាក់ព័ន្ធ។ [មន្ទីរសាធារណការ និងដឹកជញ្ជូន] |

ការសិក្សាពីលទ្ធភាពដើម្បីប្រើបច្ចេកវិទ្យាចាប់សញ្ញាពីចម្ងាយដោយប្រើដ្រូនសម្រាប់ការវាស់វែងហេដ្ឋារចនាសម្ព័ន្ធត្រូវបានធ្វើឡើងក្នុងឆ្នាំ២០២២។ ការគ្រប់គ្រងហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់នឹងត្រូវបានសិក្សាតាមទស្សនៈពហុជំនាញ។

កម្មវិធី Road Care ដែលបង្កើតឡើងដោយក្រសួងសាធារណការ និងដឹកជញ្ជូន គឺជាការអនុវត្តដ៏ល្អសម្រាប់គំនិតផ្តួចផ្តើមនេះ។ ក្រសួងសាធារណការ និងដឹកជញ្ជូន បានទទួលរបាយការណ៍ប្រហែល 6,000 អំពីរណ្តៅ និងការខូចខាតផ្លូវផ្សេងទៀតតាមរយៈកម្មវិធី Road Care Mobile App ចាប់តាំងពីការបើកដំណើរការរបស់ខ្លួនក្នុងខែធ្នូ ឆ្នាំ ២០១៨។ អ្នកប្រើប្រាស់កម្មវិធីថតរូបការខូចខាត ដាក់ស្លាកទីតាំង ហើយផ្ញើវាតាមរយៈកម្មវិធីនេះ។ ក្រសួងកំពុងធ្វើការជាមួយសាលាក្រុងដើម្បីដោះស្រាយរបាយការណ៍ភាគច្រើនឱ្យបានលឿនតាមដែលអាចធ្វើទៅបាន (ខ្លះត្រូវបានបញ្ចូលទៅក្នុងផែនការអភិវឌ្ឍន៍រយៈពេលវែង)។ កម្មវិធីនេះជួយឱ្យក្រសួងកំណត់អាទិភាពការងាររបស់ខ្លួនដោយផ្អែកលើបញ្ហាដែលប៉ះពាល់ដល់មនុស្សច្រើនបំផុត។

ទោះជាយ៉ាងណាក៏ដោយ ការប្រើប្រាស់កម្មវិធីនេះនៅក្នុងខេត្តសៀមរាបនៅមានកម្រិត ហើយគេរំពឹងថាកម្មវិធីនេះនឹងត្រូវបានប្រើប្រាស់។

20. M-0៣ ការកែលម្អភ្លើងបំភ្លឺផ្លូវ

| | |
|---|---|
| សកម្មភាពកំពុងដំណើរការ / បានបញ្ចប់ | ១.ផ្អែកដំឡើងភ្លើងតាមដងផ្លូវ (ផ្លូវជុំវិញផាប់ស្រ្ទីត និងនៅលើផ្លូវជាតិ) ប្រភេទឧបករណ៍ចាប់សញ្ញាដែលភ្ជាប់ទៅនឹងភ្លើងតាមដងផ្លូវ ទីតាំងដំឡើង ផែនការគ្រប់គ្រងទិន្នន័យ [មន្ទីរសាធារណការ និងដឹកជញ្ជូន]<br>២. ការដំឡើងឧបករណ៍ចាប់សញ្ញាផ្សេងៗសម្រាប់ភ្លើងតាមដងផ្លូវ [ក្រុមហ៊ុនផ្គត់ផ្គង់អំពូលភ្លើង ក្រុមហ៊ុនផលិតឧបករណ៍ចាប់សញ្ញាផ្សេងៗ] |
| សកម្មភាពដែលត្រូវបញ្ចប់ | ៣. ការតភ្ជាប់ជាមួយឧបករណ៍ទំនាក់ទំនង [ក្រុមហ៊ុនផ្គត់ផ្គង់សេវាទូរគមនាគមន៍]<br>៤. ការផ្ទុកទិន្នន័យ និងការបង្ហាញទៅកាន់ថ្នាលទិន្នន័យ [មន្ទីរប្រៃសណីយ៍ និងទូរគមនាគមន៍] |

ការកែលម្អភ្លើងបំភ្លឺផ្លូវត្រូវបានធ្វើឡើងតាមរយៈគម្រោងសាងសង់ផ្លូវ៣៨ខ្សែ ដែលបានដំឡើងអំពូលភ្លើងឆ្លាតវៃតាមដងផ្លូវ ចំនួន ៥,៣០០គ្រឿង។ អំពូលភ្លើងតាមដងផ្លូវទាំងនេះមានសមត្ថភាពប្តូរភាពភ្លឺរបស់អំពូលដោយផ្អែកលើពន្លឺជាក់ស្តែងនៃបរិស្ថានជុំវិញ ដែលជាហេតុអោយយើងរំពឹងបានថានឹងនាំឱ្យការប្រើប្រាស់អគ្គិសនីកាន់តែមានប្រសិទ្ធភាពប្រសើរជាងមុន។ ទោះជាយ៉ាងនេះក្តីក៏ការតភ្ជាប់ និងការផ្ទុកទិន្នន័យនៅមិនទាន់ត្រូវបានធ្វើឡើងនៅឡើយ ប៉ុន្តែដោយសារតែលទ្ធភាពដែលអាចពង្រីកបន្ថែមបាននៃបរិក្ខារមានស្រាប់ នោះការអនុវត្តនឹងត្រូវយកមកពិចារណា។

## 21. M-0៤ ការកែលម្អប្រព័ន្ធសញ្ញាចរាចរណ៍

| | |
|---|---|
| សកម្មភាពដែលត្រូវបញ្ចប់ | ១. ការកំណត់សញ្ញាចរាចរណ៍គោលដៅភ្ជាប់ទៅនឹងបណ្តាញសញ្ញាចរចរណ៍ [មន្ទីរសាធារណការ និងដឹកជញ្ជូន]<br>២. លទ្ធកម្មឧបករណ៍ភ្ជាប់សញ្ញាចរាចរណ៍ ការត្រួតពិនិត្យសញ្ញាចរាចរណ៍ ការត្រួតពិនិត្យចរាចរណ៍ ។ល។ [មន្ទីរសាធារណការ និងដឹកជញ្ជូន]<br>៣. ការដំឡើងឧបករណ៍ភ្ជាប់សញ្ញាចរាចរណ៍ ការត្រួតពិនិត្យសញ្ញាចរាចរណ៍ ការត្រួតពិនិត្យចរាចរណ៍ ។ល។ [ក្រុមហ៊ុនអភិវឌ្ឍប្រព័ន្ធគ្រប់គ្រងភ្លើង និងសញ្ញាចរាចរណ៍]<br>៤. ប្រតិបត្តិការឧបករណ៍ភ្ជាប់សញ្ញាចរាចរណ៍ ការត្រួតពិនិត្យសញ្ញាចរាចរណ៍ ការត្រួតពិនិត្យចរាចរណ៍ ។ល។ [មន្ទីរសាធារណការ និងដឹកជញ្ជូន] |

ការកែលម្អប្រព័ន្ធសញ្ញាចរាចរណ៍ក៏ត្រូវបានធ្វើឡើងក្នុងគម្រោងសាងសង់ផ្លូវ៣៨ខ្សែផងដែរ ភ្លើងសញ្ញាចរាចរណ៍ចំនួន២០ទីតាំងត្រូវបានកែលម្អអោយមានភាពល្អប្រសើរជាងមុន។ ភ្លើងសញ្ញាចរាចរណ៍ទាំងនេះជាប្រភេទដាច់ដោយឡែកៗពីគ្នាហើយមិនបានភ្ជាប់ទៅកាន់ប្រព័ន្ធគ្រប់គ្រងភ្លើងសញ្ញាចរាចរណ៍នោះទេ។

## 22. M-0៥ ការកែលម្អការគ្រប់គ្រងសុវត្ថិភាពចរាចរណ៍

| | |
|---|---|
| សកម្មភាពដែលត្រូវបញ្ចប់ | ១. ជាតុជាក់លាក់នៃព្រឹត្តិការណ៍ដែលមិនមានសុវត្ថិភាពចរាចរណ៍ ផែនការទទួលបានទិន្នន័យ និងផែនការសម្រាប់ការឆ្លុះបញ្ចាំងនៅក្នុងគម្រោងការក្នុងការដោះស្រាយបញ្ហានេះ [ស្នងការនគរបាលខេត្ត មន្ទីរសាធារណការ និងដឹកជញ្ជូន]<br>២. ការសម្របសម្រួល និងធានាសុវត្ថិភាពដៃគូសហប្រតិបត្តិការ (រថយន្តល្បាតផ្លូវថ្នល់ យានជំនិះរបស់ខេត្ត រ៉ឺម៉កឡានក្រុង ។ល។) បំពាក់ដោយស្មាតហ្វូនដែលមានភ្ជាប់កម្មវិធី និងឧបករណ៍ថត [រដ្ឋបាលខេត្តសៀមរាប]<br>៣. ការណែនាំអំពីសេវាកម្មកម្មវិធីសម្រាប់ចាប់យកឥរិយាបថបើកបរ [អ្នកផ្តល់សេវា]<br>៤. ការប្រមូលទិន្នន័យ ការប្រមូលផ្តុំលទ្ធផលសិក្សាស្ថានភាព និងការផ្តល់ទិន្នន័យ [អ្នកផ្តល់សេវា]<br>៥. ការផ្ទុកទិន្នន័យ និងការបង្ហាញទៅកាន់ថ្នាលទិន្នន័យ [មន្ទីរប្រៃសណីយ៍ និងទូរគមនាគមន៍]<br>៦. ការអនុវត្តការបណ្តុះបណ្តាលសុវត្ថិភាពសម្រាប់អ្នកបើកបរដោយផ្អែកលើទិន្នន័យ [ស្នងការនគរបាលខេត្ត] |

ក្នុងពេលបច្ចុប្បន្ននេះ មិនទាន់មានវិធានការជាក់លាក់ណាមួយត្រូវបានរៀបចំនៅឡើយនោះទេ ដោយសារតែមិនទាន់មានដៃគូសហការសម្រាប់ការប្រមូលទិន្នន័យ។ គម្រោងនេះមានផែនការស្វែងរកដៃគូសហការដោយរាប់បញ្ចូលទាំងក្រុមហ៊ុនឯកជនផងដែរ។

## 23. M-0៦ ការណែនាំអំពីយានយន្តអគ្គិសនី

| | |
|---|---|
| សកម្មភាពដែលត្រូវបញ្ចប់ | ១. ការបង្កើតគោលនយោបាយលើកកម្ពស់ការដាក់ឱ្យប្រើប្រាស់យានយន្តអគ្គិសនី [រដ្ឋបាលខេត្ត ]<br>២. ការដំឡើងស្ថានីយបញ្ចូលអាគុយរថយន្តអគ្គិសនី គម្រោងសាកល្បងនៃយានយន្តអគ្គិសនី [រដ្ឋបាលខេត្ត ]<br>៣. តាមដានរ៉ឺម៉កកង់បីដែលប្រើប្រាស់ការឧបត្ថម្ភធន ការវាយតម្លៃភាពងាយស្រួល ការសិក្សាអំពីឆន្ទៈក្នុងការទូទាត់ដោយភ្ញៀវទេសចរក្នុងស្រុក និងបរទេសនៃរ៉ឺម៉កកង់បីអគ្គិសនី [រដ្ឋបាលខេត្ត ]<br>៤. ការចាប់ផ្តើមអនុវត្តយានយន្តអគ្គិសនីជាលក្ខណៈអាជីវកម្ម [អាជីវករឯកជន] |

ស្ថានីយ៍សាកអាគុយយានយន្តអគ្គិសនី ត្រូវបានដំឡើងនៅក្នុងក្រុងសៀមរាប។ បច្ចុប្បន្ននេះ Cities Development Initiative for Asia (CDIA) បានគ្រោងផ្តល់មូលនិធិសម្រាប់ការសិក្សាបឋមពី

លទ្ធភាពនៃការដាក់ឱ្យប្រើប្រាស់យានយន្តក្រុងអគ្គិសនី។ រ៉ឺម៉កកង់បីអគ្គិសនីកំពុងត្រូវបានក្រុមហ៊ុនឯកជនធ្វើគម្រោងសាកល្បង ដែលវាជាផ្នែកមួយនៃការអនុវត្តសេវាចល័តរួម។

រដ្ឋបាលថ្នាក់ជាតិគួរតែគិតគូរផ្តល់ការលើកទឹកចិត្តពិសេសសម្រាប់យានយន្តអគ្គិសនី។




ប្រភព៖ ការសិក្សាបឋមពីការវាយតម្លៃទៅលើរថយន្តក្រុងអគ្គិសនីនៅក្នុងខេត្តសៀមរាប ប្រទេសកម្ពុជា

**ផែនទីនៃផ្លូវរថយន្តក្រុងអគ្គិសនីចំនួន៣ខ្សែដែលបានស្នើឡើង**

## 24. S-0១ ការចាប់ផ្តើមប្រព័ន្ធការមេរ៉ា (CCTV)

| | |
|---|---|
| សកម្មភាពកំពុងដំណើរការ / បានបញ្ចប់ | ១. ការដំឡើងកាមេរ៉ា CCTV [រដ្ឋបាលខេត្ត] |
| សកម្មភាពដែលត្រូវបញ្ចប់ | ២. ការអភិវឌ្ឍប្រព័ន្ធត្រួតពិនិត្យទិន្នន័យសម្រាប់កាមេរ៉ា CCTVs ដែលមានស្រាប់ (រួមបញ្ចូលទាំងកាមេរ៉ា៦គ្រឿងដែលប្រើសម្រាប់ត្រួតពិនិត្យចរាចរណ៍ និង២០គ្រឿងសម្រាប់ត្រួតពិនិត្យបរិស្ថានតាមដងផ្លូវនៅតំបន់ Pub Street [អាជីវកម្មឯកជន]<br>៣. ការអភិវឌ្ឍរចនាសម្ព័ន្ធប្រតិបត្តិការ និងត្រួតពិនិត្យ និងប្រព័ន្ធថែរក្សាសន្តិសុខ [ស្នងការនគរបាលខេត្ត]<br>៤. ប្រតិបត្តិការ និងការថែទាំប្រព័ន្ធ [អាជីវកម្មឯកជន]<br>៥. ការអភិវឌ្ឍប្រព័ន្ធដំណើរការទិន្នន័យសម្រាប់ការពារឯកជនភាព [អាជីវកម្មឯកជន]<br>៦. ការប្រមូលផ្តុំ និងការបង្ហាញទិន្នន័យដែលបានវិភាគរួចទៅកាន់ថ្នាលទិន្នន័យ [មន្ទីរប្រៃសណីយ៍ និងទូរគមនាគមន៍] |

កាមេរ៉ាសុវត្ថិភាព CCTV ចំនួន ២០០ គ្រឿង ត្រូវបានដំឡើងតាមរយៈគម្រោងស្ថាបនាហេដ្ឋារចនាសម្ព័ន្ធផ្លូវចំនួន៣៨ខ្សែនៅក្រុងសៀមរាបខេត្តសៀមរាប។ ការបង្កើនប្រសិទ្ធភាពនៃវិធីសាស្ត្រប្រតិបត្តិការរបស់កាមេរ៉ាទាំងនោះនឹងត្រូវបានយកមកសិក្សា។

25. S-០២ ការអភិវឌ្ឍប្រព័ន្ធប្រកាសអាសន្នទឹកជំនន់

| | |
|---|---|
| សកម្មភាពដែលត្រូវបញ្ចប់ | ១. ការរៀបចំផែនការដំឡើងឧបករណ៍ចាប់សញ្ញា [រដ្ឋបាលខេត្ត ស្នងការនគរបាលខេត្ត និងសមាគមនានា]<br>២. ការពន្យល់ដល់ភាគីពាក់ព័ន្ធ (ប្រជាពលរដ្ឋមូលដ្ឋាន។ល។) [រដ្ឋបាលខេត្ត]<br>៣. ការដំឡើងឧបករណ៍ចាប់សញ្ញានៅកណ្តាលទីក្រុង (ផ្សារចាស់ តំបន់ផាប់ស្ទ្រីត ។ល។) [អាជីវកម្មឯកជន (អ្នកផលិតឧបករណ៍ប្រកាសអាសន្ន)]<br>៤. ការធ្វើចក្ខុនិម្មិតចំពោះទិន្នន័យ និងការផ្សព្វផ្សាយ [រដ្ឋបាលខេត្ត] |

សកម្មភាពជាក់លាក់មិនទាន់ត្រូវបានធ្វើនៅឡើយទេ។ ម្យ៉ាងវិញទៀត ការអភិវឌ្ឍសមត្ថភាពចាំបាច់សម្រាប់ការប្រមូលទិន្នន័យដោយប្រើឧបករណ៍ចាប់សញ្ញាបរិស្ថាននៅក្នុងរដ្ឋបាលខេត្តកំពុងដំណើរការ។ ទីតាំងរបស់ឧបករណ៍ចាប់សញ្ញាជាក់លាក់នឹងត្រូវបានគិតគូរនាពេលអនាគត។

26. S-០៣ ការដំឡើងប្រព័ន្ធប្រកាសអាសន្នអគ្គិភ័យ

| | |
|---|---|
| សកម្មភាពដែលត្រូវបញ្ចប់ | ១. ការបង្កើតផែនការដំឡើងឧបករណ៍ប្រកាសអាសន្នអគ្គិភ័យ [រដ្ឋបាលខេត្ត ស្នងការនគរបាលខេត្ត និងសមាគមន៍នានា]<br>២. ការពន្យល់ដល់ភាគីពាក់ព័ន្ធ (ប្រជាពលរដ្ឋ ។ល។) [រដ្ឋបាលខេត្ត]<br>៣. ណែនាំអំពីឧបករណ៍ប្រកាសអាសន្នអគ្គិភ័យនៅក្នុងតំបន់ដែលមានភាពងាយរងគ្រោះភ្លើងឆេះខ្ពស់នៅកណ្តាលទីក្រុង (តំបន់ផ្សារចាស់ តំបន់ផាប់ស្ទ្រីត ជាដើម) [ប្រតិបត្តិករអាជីវកម្មឯកជន (ក្រុមហ៊ុនផលិតឧបករណ៍ ប្រកាសអាសន្នអគ្គិភ័យ)]<br>៤. ការបណ្តុះបណ្តាល និងសកម្មភាពអប់រំទាក់ទងនឹងការជម្លៀសភ្លាមៗ និងការពន្លត់អគ្គិភ័យដំបូងដោយប្រើព័ត៌មានពីការជូនដំណឹងអំពីអគ្គិភ័យ [រដ្ឋបាលខេត្ត ស្នងការនគរបាលខេត្ត] |

ដោយរួមសហការជាមួយសាកលវិទ្យាល័យជប៉ុន ការអភិវឌ្ឍសមត្ថភាពសម្រាប់កាត់បន្ថយគ្រោះមហន្តរាយ កំពុងត្រូវបានធ្វើឡើងនៅតំបន់ផ្សារចាស់នៃខេត្តសៀមរាប។ គេរំពឹងថា តំបន់នេះនឹងត្រូវបានប្រើប្រាស់ជាតំបន់គំរូដើម្បីអភិវឌ្ឍសហគមន៍ដែលធន់ទៅនឹងគ្រោះមហន្តរាយ។

27. S-០៤ ការកែលម្អទំនាក់ទំនងសាធារណៈ ដើម្បីសុវត្ថិភាព

| | |
|---|---|
| សកម្មភាពដែលត្រូវបញ្ចប់ | ១. កសាងប្រព័ន្ធកណ្តាលមួយដើម្បីប្រមូល និងគ្រប់គ្រងព័ត៌មានពីបទល្មើសប្រចាំថ្ងៃ/ គ្រោះថ្នាក់ចរាចរណ៍នៅក្នុងស្នងការនគរបាលខេត្ត [ស្នងការនគរបាលខេត្ត]<br>២. ការអភិវឌ្ឍឧបករណ៍ និងប្រព័ន្ធសម្រាប់ផ្សព្វផ្សាយព័ត៌មានទាក់ទងនឹងបទល្មើស និងគ្រោះថ្នាក់ចរាចរណ៍ [ប្រតិបត្តិករអាជីវកម្មឯកជន (អ្នកផ្តល់ប្រព័ន្ធ)]<br>៣. ផ្សព្វផ្សាយព័ត៌មានទាក់ទងនឹងបទល្មើស / គ្រោះថ្នាក់ចរាចរណ៍ខាងលើនៅលើគេហទំព័របណ្តាញស្នងការនគរបាលខេត្ត / រដ្ឋបាលខេត្ត ឬកម្មវិធីទេសចរណ៍ [ស្នងការនគរបាលខេត្ត] |

កាមេរ៉ាសុវត្ថិភាព CCTV និងបន្ទប់ត្រួតពិនិត្យសម្រាប់គោលបំណងនេះក៏ត្រូវបានបង្កើតឡើងនៅក្នុងគម្រោងស្ថាបនាហេដ្ឋារចនាសម្ព័ន្ធផ្លូវចំនួន៣៨ខ្សែ នៅក្រុងសៀមរាប ខេត្តសៀមរាប ផងដែរ។

នៅពេលអនាគត គឺជាការចាំបាច់ក្នុងការពង្រឹកសមត្ថភាពរបស់រដ្ឋបាលខេត្តសៀមរាប រួមទាំងទំនួលខុសត្រូវការងារ សម្រាប់ប្រតិបត្តិការប្រព័ន្ធនោះប្រកបដោយប្រសិទ្ធភាព។ ទន្ទឹមនឹងនោះ វាក៏ចាំបាច់ផងដែរក្នុងការបង្កើត និងផ្សព្វផ្សាយច្បាប់សម្រាប់ការគ្រប់គ្រងកាមេរ៉ាសុវត្ថិភាពCCTVទាំងនោះ។

28. W-០១ ពង្រឹងប្រព័ន្ធគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន និងការអប់រំអំពីបរិស្ថាន

| | |
|---|---|
| សកម្មភាពកំពុងដំណើរការ / បានបញ្ចប់ | ១. ពិភាក្សាជ្រើសរើសសង្កាត់គំរូសម្រាប់អនុវត្តប្រព័ន្ធគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន (ការប្រមូល ការបោះចោលសំរាម និងការប្រមូលថ្លៃសេវា) [រដ្ឋបាលខេត្ត មន្ទីរបរិស្ថានខេត្ត មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋបាលក្រុង/ស្រុក និងរដ្ឋបាលសង្កាត់/ឃុំគំរូ]<br>២. ការរៀបចំផែនការវិធីសាស្ត្រអនុវត្ត ប្រព័ន្ធគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន និងពន្យល់ណែនាំដល់ប្រជាពលរដ្ឋឱ្យមានការឯកភាពគ្នា [រដ្ឋបាលខេត្ត មន្ទីរបរិស្ថានខេត្ត មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋបាលក្រុង/ស្រុក រដ្ឋបាលសង្កាត់/ឃុំគំរូ និងប្រជាពលរដ្ឋ] |
| សកម្មភាពដែលត្រូវបញ្ចប់ | ៣. អនុវត្តន៍វិធីសាស្ត្រអប់រំស្តីពីបរិស្ថាន ដោយប្រើប្រាស់បច្ចេកវិទ្យា [រដ្ឋបាលខេត្ត]<br>៤. ការអនុវត្តប្រព័ន្ធគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន (ការប្រមូល ការបោះចោលសំរាម និងការប្រមូលថ្លៃសេវា) [រដ្ឋបាលក្រុង/ស្រុក និងរដ្ឋបាលសង្កាត់គំរូ]<br>៥. អប់រំការងារបរិស្ថាន ដោយណែនាំឱ្យប្រជាពលរដ្ឋធ្វើការញែកសំរាមកែច្នៃ និងកាត់បន្ថយបរិមាណសំរាម[រដ្ឋបាលខេត្ត មន្ទីរបរិស្ថានខេត្ត រដ្ឋបាលក្រុង/ស្រុក និងរដ្ឋបាលសង្កាត់គំរូ] |

- ការផ្លាស់ប្តូរៈ ចំណងជើងត្រូវបានធ្វើបច្ចុប្បន្នភាពសម្រាប់ភាពច្បាស់លាស់។ មាតិកាផ្សេងទៀតត្រូវបានពង្រីកបន្ថែម។ ដៃគូអភិវឌ្ឍន៍ (GIZ និង JICA) សហការជាមួយសាលាក្រុងសៀមរាប បានបង្កើតអនុគណៈកម្មាធិការគ្រប់គ្រងកាកសំណល់ស្របតាមអនុក្រឹត្យលេខ ១១៣។ នៅពេលអនាគត តំបន់អាទិភាពនឹងត្រូវបានបង្កើតឡើង ហើយគម្រោងសាកល្បងនឹងត្រូវបានអនុវត្តជាសង្កាត់គំរូ។ លើសពីនេះ ការអប់រំបរិស្ថានដោយប្រើម៉ាស៊ីនបញ្ចាំង (Projectors) ក៏កំពុងត្រូវបានពិចារណាផងដែរ។

29. W-០២ ការដំឡើងប្រព័ន្ធ IoT សម្រាប់គ្រប់គ្រងការប្រមូលសំរាម

| | |
|---|---|
| សកម្មភាពកំពុងដំណើរការ/ បានបញ្ចប់ | ១. តម្លើងឧបករណ៍ចាប់សញ្ញានៅតាមឡានដឹកសំរាម |
| សកម្មភាពដែលត្រូវបញ្ចប់ | ២. រៀបចំផែនការគ្រប់គ្រងសំរាម [រដ្ឋបាលខេត្ត អាជ្ញាធរជាតិអប្សរា]<br>៣. ការពន្យល់អំពីវិធីសាស្ត្រនៃការអនុវត្ត និងផែនការគ្រប់គ្រងកាកសំណល់ទៅសាលាសង្កាត់ ដើម្បីឱ្យមានការអនុវត្តជាឯកច្ឆ័ន [រដ្ឋបាលក្រុង សាលាសង្កាត់ ប្រតិបត្តិករសម្បទាន]<br>៤. ដំឡើងធុងសំរាមជាមួយនឹងឧបករណ៍ចាប់សញ្ញាដែលបង្ហាញពីបរិមាណសំរាម សំណល់រឹងទីប្រជុំជន[រដ្ឋបាលក្រុង ប្រតិបត្តិករសម្បទាន]<br>៥. ការប្រមូលទិន្នន័យដែលពាក់ព័ន្ធ (បរិមាណនៃសំរាម) [រដ្ឋបាលក្រុង]<br>៦. ការប្រើប្រាស់ប្រព័ន្ធ IoTដើម្បីធ្វើឱ្យការប្រមូលសំរាមកាន់តែមានប្រសិទ្ធភាព |

រថយន្តដឹកសំរាមទាំងអស់ត្រូវបានបំពាក់ប្រព័ន្ធ GPS (អនុវត្តដោយក្រសួងបរិស្ថាន)។ នៅពេលអនាគត មន្ត្រីខេត្តសៀមរាបនឹងពិនិត្យពីវិធីប្រើប្រាស់ GPS នេះ រួមទាំងពិចារណាផងដែរទៅលើតារាងពេលវេលា និងខ្សែផ្លូវប្រមូលសំរាម អោយកាន់តែមានប្រសិទ្ធភាពជាងមុន។

## 30. W-០៣ ការគ្រប់គ្រងទីលានទុកដាក់សំរាមប្រកបដោយអនាម័យ

| | |
|---|---|
| សកម្មភាពដែលត្រូវបញ្ចប់ | ១. ធ្វើការពិភាក្សាអំពីទីលានចាក់សំរាម [រដ្ឋបាលខេត្ត ប្រតិបត្តិករសម្បទាន អាជ្ញាធរជាតិអប្សរា]<br>២. ការរៀបចំអនុវត្តផែនការអនុវត្ត និងទម្រង់សំណើនៃទីលានចាក់សំរាមប្រកបដោយអនាម័យ [រដ្ឋបាលខេត្ត ប្រតិបត្តិករសម្បទាន អាជ្ញាធរជាតិអប្សរា]<br>៣. ការរចនា និងការសាងសង់ទីលានចាក់សំរាមប្រកបដោយអនាម័យ ដែលបំពេញតាមស្តង់ដារបរិស្ថាន [រដ្ឋបាលខេត្ត ដៃគូអភិវឌ្ឍន៍]<br>៤. ប្រតិបត្តិការសមស្រប និងការគ្រប់គ្រងទីលានចាក់សំរាមប្រកបដោយអនាម័យ [ក្រុមហ៊ុនឯកជន] |

ធនាគារពិភពលោក បានធ្វើការសិក្សារួចហើយ។ ធនាគារពិភពលោក សហការជាមួយក្រសួងមួយចំនួន កំពុងរៀបចំគម្រោង ប្រាំមួយឆ្នាំ ៦០លានដុល្លារ ដើម្បីកែលម្អការគ្រប់គ្រងសំរាម សំណល់រឹង និងសំណល់ប្លាស្ទិក នៅក្នុងខេត្តចំនួន៥ ក្នុងនោះក៏មានខេត្តសៀមរាបផងដែរ។

## 31. W-០៤ ការកែលម្អគុណភាពស្ទឹង និងការប្រើប្រាស់ស្ទឹង

| | |
|---|---|
| សកម្មភាពកំពុងដំណើរការ / បានបញ្ចប់ | ១. ការកែលម្អគុណភាពទឹកស្ទឹងសៀមរាប និងការរៀបចំផែនការប្រើប្រាស់ដី [រដ្ឋបាលខេត្ត មន្ទីរសាធារណការ និងដឹកជញ្ជូន សហគ្រាសឯកជន]<br>២. ការអនុវត្តការកែលម្អគុណភាពទឹកស្ទឹងសៀមរាប [មន្ទីរសាធារណការ និងដឹកជញ្ជូន ក្រុមហ៊ុនឯកជន]<br>៣. ការអនុវត្តផែនការប្រើប្រាស់ដី [រដ្ឋបាលខេត្ត មន្ទីរទេសចរណ៍ សហគ្រាសឯកជន] |
| សកម្មភាពដែលត្រូវបញ្ចប់ | ៤. តាមដានគុណភាពទឹក និងក្លិនទឹកស្ទឹងសៀមរាបដោយប្រើប្រាស់ឧបករណ៍ចាប់សញ្ញា [មន្ទីរប្រៃសណីយ៍ និងទូរគមនាគមន៍]<br>៥. ការផ្ទុកទិន្នន័យ និងការបង្ហាញទៅកាន់ថ្នាលទិន្នន័យ [មន្ទីរប្រៃសណីយ៍ និងទូរគមនាគមន៍] |

ការអភិវឌ្ឍកែលម្អដងស្ទឹង ត្រូវបានធ្វើនៅក្នុងគម្រោងស្ថាបនាហេដ្ឋារចនាសម្ព័ន្ធផ្លូវចំនួន៣៨ខ្សែ នៅក្រុងសៀមរាប ខេត្តសៀមរាប។ ចិញ្ចើមផ្លូវ កៅអីអង្គុយ និងភ្លើងបំភ្លឺផ្លូវនៅតាមដងស្ទឹងត្រូវបានសាងសង់ ហើយប្រជាពលរដ្ឋគ្រប់គ្នាបានរីករាយក្នុងការប្រើប្រាស់សមិទ្ធផលទាំងនេះ។ ឧបករណ៍ចាប់សញ្ញាគុណភាពទឹក គួរតែត្រូវបានគិតគូរពិចារណាដំឡើងក្នុងពេលដំណាលគ្នាជាមួយនឹងការដំឡើងប្រព័ន្ធប្រកាសអាសន្នទឹកជំនន់ផងដែរ។

## 32. W-០៥ ការកែលម្អប្រព័ន្ធគ្រប់គ្រងឧបករណ៍បរិក្ខារទឹកកខ្វក់

| | |
|---|---|
| សកម្មភាពដែលត្រូវបញ្ចប់ | ១) បង្កើតប្រព័ន្ធអនុវត្តការថែទាំបំពង់បង្ហូរទឹក [មន្ទីរសាធារណការ និងដឹកជញ្ជូន រដ្ឋបាលខេត្ត ]<br>២) ការប្រមូលទិន្នន័យ និងការត្រួតពិនិត្យសមត្ថភាពប្រព័ន្ធលូទឹកកខ្វក់សម្រាប់បំពង់បង្ហូរទឹកដែលមានស្រាប់ [មន្ទីរសាធារណការ និងដឹកជញ្ជូន]<br>៣) ផែនការ និងហិរញ្ញប្បទានសម្រាប់រោងចក្រប្រព្រឹត្តិកម្មទឹកស្អុយថ្មី [រដ្ឋបាលខេត្ត, MPWT]<br>៤) ការសាងសង់រោងចក្រប្រព្រឹត្តិកម្មទឹកស្អុយថ្មី [MPWT] |

កំពុងធ្វើ ការស្ទង់មតិនៃការផ្ទៀងផ្ទាត់ធុរកិច្ច សម្រាប់ការធ្វើផែនទីប្រព័ន្ធលូទឹកកខ្វក់

## 33. W-០៦ យន្តការបង់ថ្លៃសេវាសាធារណៈរួមគ្នា

| | |
|---|---|
| សកម្មភាពកំពុងដំណើរការ / បានបញ្ចប់ | ១. ការបង្កើតអនុគណៈកម្មាធិការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន [សាលាក្រុងសៀមរាប] |
| សកម្មភាពដែលត្រូវបញ្ចប់ | ២. ការផ្ទុកទិន្នន័យ និងការបង្ហាញទៅកាន់ថ្នាលទិន្នន័យ [មន្ទីរប្រៃសណីយ៍ និងទូរគមនាគមន៍] |

| | |
|---|---|
| | ៣. ការត្រួតពិនិត្យប្រព័ន្ធប្រមូលថ្លៃសេវាបច្ចុប្បន្ន ការពិនិត្យមើលប្រព័ន្ធថ្មី [រដ្ឋបាលខេត្ត រដ្ឋាករទឹកស្អាត ក្រុមហ៊ុនប្រមូលសំរាម ក្រសួងសាធារណការ និងដឹកជញ្ជូន]<br>៤. ការបង្កើតក្រុមហ៊ុនគោលបំណងពិសេស (SPC) [រដ្ឋាករទឹកស្អាត ក្រុមហ៊ុនប្រមូលសំរាម]<br>៥. ការអភិវឌ្ឍប្រព័ន្ធការប្រមូល/ត្រួតពិនិត្យ [SPC]<br>៦. ការប្រមូលថ្លៃសេវាសាធារណៈ ការត្រួតពិនិត្យស្ថានភាព [SPC] |

ដោយមានគោលបំណងដើម្បីសម្រេចអោយបាននូវអនុក្រឹត្យលេខ ១១៣ ក្នុងការគ្រប់គ្រងសំរាម សំណល់រឹង ទីប្រជុំជន ដូចនេះវិធីសាស្ត្រនៃការទូទាត់ប្រាក់សម្រាប់កាកសំណល់នឹងត្រូវបានយកមកធ្វើការសិក្សា។ តម្រូវការសម្រាប់ការធ្វើសមាហរណកម្មរវាង ទឹកស្អាត និងទឹកសំណល់ គឺជាជំហានបន្ទាប់ដែលត្រូវធ្វើ ហើយវាមិនទាន់ត្រូវបានចាប់ផ្តើមនៅឡើយ។

**គាំទ្រដោយ**

**ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិ នៃប្រទេសជប៉ុន** (JICA)

SMART SIEM REAP

jica
Japan International Cooperation Agency